ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- [illegible]
- [illegible]

[illegible]

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា
លេខ៥៣ ខែឧសភា ឆ្នាំ២០០៤

## មាតិកា


- សំបុត្រៈ ការកាត់ទោសមេដឹកនាំខ្មែរក្រហម.......................... ១

**ផ្នែកឯកសារ**

- ចម្លើយសារភាពរបស់ សេក សាត ហៅ ប្រាក់.................... ៤
- បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរ ស-២១...........៨
- តារាងចាត់តាំងភូមិភាគឧត្តរ........................................ ១០

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

- រឿងរ៉ាវ ហ៊ឹម ម៉ាន.......................................................២០
- ក្លាយជាស្ត្រីមេម៉ាយនៅកោះខ្សាច់ទន្លា................................ ២៤
- គ្មានអ្វីអាចសងជីវិតបាន..................................................២៦

**ផ្នែកច្បាប់**

- តើសកម្មជនជំរុញឲ្យមានតុលាការព្រហ្មទណ្ឌអន្តរជាតិ..............២៩

**វេទិកាពិភាក្សាសាធារណៈ**

- ការលំបាកក្នុងការកសាងសន្តិភាពនៅកម្ពុជា.......................... ៣៦
- មេដឹកនាំខ្មែរក្រហមវាយបកទៅអ្នករិះគន់............................ ៤៧

**ទំព័រស្វែងរកគ្រួសារ**

- គ្រួសារខ្ញុំ.................................................................. ៤៨
- ស្រមោលបង.............................................................. ៥១




ក្រោយពីរបបខ្មែរក្រហមដួលរលំ ប្រជាជនវិលត្រឡប់ទៅលំនៅឋានវិញ ១៩៧៩



លោកស្រី ហេង សុខផាន់ណា អ្នកនិពន្ធប្រវត្តិជីវិតពិតៈ ស្រមោលបង


## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា



អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និង សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង



**ស្នេរលេខនេះៈ** យិន នាន, អ៊ីសា ឧស្មាន, ចំរើនស័ក្តិ ម៉ារឌី, ហេង សុខផាន់ណា, គី សុផល, ម៉ាលី កេ្លសៀស, ម៉ារី ឡាប៊ឹក, ភីធ័រ ម៉ាឃៀរ **អ្នកនិពន្ធនិងស្រាវជ្រាវៈ** លី សុផល, សូ ហ្វារីណា **ជំនួយការនិពន្ធនាយកៈ** សាន់ កល្យាណ **និពន្ធនាយករងៈ** ស្ហួ ប៊ុនស៊ូ **អ្នកបកប្រែៈ** អេង កុកថាយ **និពន្ធនាយកទូទៅៈ** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រៈ** ស៊ឹម សុភ័ក្ត្រ **គ្រប់គ្រងការចែកផ្សាយៈ** មាស ប៊ុនថាន

*សំបុត្រៈ*

# ការកាត់ទោសមេដឹកនាំខ្មែរក្រហមប្រកបដោយយុត្តិធម៌ និងអាចទុកចិត្តបាន មានសារសំខាន់ចំពោះកម្ពុជា

មានក្តីសង្ឃឹមមួយថាអ្នកដែលនៅរស់សេសសល់ពីរបបខ្មែរក្រហមអាចទទួលបានយុត្តិធម៌ ។ ពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ របបខ្មែរក្រហមដឹកនាំដោយ ប៉ុល ពត និងមេដឹកនាំខ្មែរក្រហមមួយចំនួនទៀតគឺជាអ្នកទទួលខុសត្រូវចំពោះការធ្វើឲ្យបាត់បង់ជីវិតប្រជាជនកម្ពុជាប្រមាណ២លាននាក់ ស្មើនឹងមួយភាគបួននៃប្រជាជនកម្ពុជាទាំងមូល ។ ប៉ុល ពត បានស្លាប់បាត់ទៅហើយ ប៉ុន្តែមេដឹកនាំធំៗ ផ្សេងទៀតនៃរបបខ្មែរក្រហមបន្តរស់នៅដោយមិនទាន់បានទទួលទោសចំពោះឧក្រិដ្ឋកម្មរបស់ខ្លួននៅឡើយទេ ។ ឥឡូវនេះមានក្តីសង្ឃឹមយ៉ាងពិតប្រាកដមួយថា ជនដៃដល់នៃ “វាលពិឃាត” របស់ខ្មែរក្រហមអាចត្រូវបាននាំខ្លួនឡើងមកកាន់តុលាការ ។

ក្រោយពីបានចរចាគ្នាអស់រយៈពេលជាច្រើនឆ្នាំមក នៅទីបំផុត រាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិបានឈានដល់ការចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយ ដើម្បីបង្កើតតុលាការកាត់ទោសអតីតមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ។

ជាដំបូង រដ្ឋសភាជាតិកម្ពុជាត្រូវផ្តល់សច្ចាប័នទៅលើកិច្ចព្រមព្រៀងតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមជាមុនសិន ។ តុលាការនេះទៀតសោតត្រូវការជំនួយថវិកាពីប្រទេសអ្នកផ្តល់ជំនួយក្នុងការអនុវត្តន៍បេសកកម្មរបស់ខ្លួន ។

អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាមិនទាន់បានព្រមព្រៀងគ្នាជាផ្លូវការអំពីថវិកាសម្រាប់ផ្គត់ផ្គង់តុលាការនេះនៅឡើយទេ ។ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ស្នើគម្រោងថវិកាដែលមានទឹកប្រាក់ចំនួន៤០លានដុល្លារអាមេរិកសម្រាប់តុលាការ ដែលបានសន្និដ្ឋានថានឹងត្រូវចំណាយពេលបីឆ្នាំ ។

ទោះបីជា៤០លានដុល្លារនេះជាចំនួនតិចជាងថវិកាដែលបានចំណាយទៅលើតុលាការនៅប្រទេសសេរ៉ាឡេអូនក៏ដោយ ក៏ចំនួននេះនៅតែជាតួលេខដ៏ខ្ពស់ដដែល ។ ការកាត់ទោសមេដឹកនាំខ្មែរក្រហមប្រកបដោយយុត្តិធម៌និងគួរឲ្យទុកចិត្តបាន មានសារប្រយោជន៍ចំពោះកម្ពុជា ប៉ុន្តែថវិកាដ៏ច្រើននេះនឹងមិនធានាបាននូវតុលាការបែបនេះទេ ។ ផ្ទុយទៅវិញ ទឹកប្រាក់នេះអាចក្លាយទៅជាផ្លាក់ទាក់ទាញអំពើពុករលួយបន្ថែមទៀតនៅប្រទេសកម្ពុជា ។ ទាំងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាគួរតែខំប្រឹងស្វែងរកមធ្យោបាយដើម្បីកាត់បន្ថយជាអប្បបរមានូវរាល់មុខចំណាយតាមដែលអាចធ្វើទៅបាន ហើយប្រើប្រាស់ធនធានក្នុងស្រុកតាមលទ្ធភាពដែលអាចធ្វើទៅកើត ។ លុះត្រាតែរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិសហការគ្នាក្នុងគោលបំណងតែមួយគត់ គឺជំរុញឲ្យមានការគោរពច្បាប់នៅក្នុងប្រទេសកម្ពុជា ទើបការកាត់ក្តីប្រកបដោយយុត្តិធម៌អាចក្លាយទៅជាការពិត ។

**ឆាំង យុ**



១៩៧៩



ប្រជាជនបានគាស់ឆ្អឹងសាកសពដែលបានស្លាប់ក្នុងរបបខ្មែរក្រហម



*(អត្ថបទសង្ខេបចេញពីចម្លើយសារភាព)*

# ចម្លើយសារភាពរបស់ សេក សាត ហៅ ប្រាក់

សេក សាត មានឈ្មោះបដិវត្តន៍ ប្រាក់ ជាអតីតលេខាតំបន់២៥ ។ ប្រាក់ មានស្រុកកំណើតនៅភូមិតាប៉ោ ឃុំសំឡី ស្រុកកំពង់រោទិ៍ ខេត្តស្វាយរៀង ក្នុងវណ្ណៈភាពកសិករកណ្តាលថ្នាក់ក្រោម ។ ប្រាក់ មានប្រពន្ធឈ្មោះ ចាន់ គីមស្រុន ព្រមទាំងមានកូន៣នាក់ ។ ប្រាក់ ត្រូវអង្គការចាប់ខ្លួននៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៧៨ និងបញ្ជូនមកគុកទួលស្លែង ពីបទក្បត់បដិវត្តន៍ បម្រើសេ.អ៊ី.អា ។ ប្រពន្ធនិងកូនទាំង៣នាក់របស់គាត់ក៏ត្រូវចាប់ខ្លួនបញ្ជូនមកគុកទួលស្លែងដែរ ។

ខាងក្រោមនេះគឺជាសេចក្តីសង្ខេបចម្លើយសារភាពរបស់ សេក សាត ហៅ ប្រាក់÷

ប្រាក់ ឈប់រៀនត្រឹមថ្នាក់ទី៧ដោយសារជីវភាពគ្រួសារក្រីក្រ ។ ៧ខែក្រោយមក គឺប្រហែលក្នុងឆ្នាំ១៩៦៤ អាចារ្យ ចាន់ សុខា ហៅ វ៉ា បាននាំ ប្រាក់ ទៅរៀននៅភ្នំពេញ ។ ប្រាក់ រៀននៅវិទ្យាល័យឯកជនតារាសាស្ត្រ និងស្នាក់នៅវត្តមហាមន្ត្រី ជាមួយអាចារ្យ ចាន់ សុខា ។ ប្រាក់បង់ថ្លៃសាលា ថ្លៃសម្លៀកបំពាក់ និងការចំណាយគ្រប់បែបយ៉ាង ជាបន្ទុករបស់អាចារ្យ ចាន់ សុខា ។ រយៈពេលដែលស្នាក់នៅកុដិ ប្រាក់ តែងតែអានកាសែតជារៀងរាល់ថ្ងៃ ។ នៅកុដិនេះទៀតសោត ច្រើនមានការប្រជុំពិភាក្សាគ្នារវាងព្រះសង្ឃមកពីវត្តអារាមផ្សេងៗ ដូចជា វត្តស្រះចក វត្តលង្កា វត្តកោះ និងវត្តកំសាន្ត ជាដើម ។ ការពិភាក្សាច្រើនតែផ្តោតទៅលើទំនាស់ក្នុងសង្គមកម្ពុជា អំពីលទ្ធិកុម្មុយនិស្តនិងសេរី ។ តាមរយៈការស្តាប់ព្រះសង្ឃជជែកគ្នាគួបផ្សំនឹងការអានកាសែតជារៀងរាល់ថ្ងៃ ធ្វើឲ្យ ប្រាក់ មានការយល់ដឹងខ្លះៗអំពីបញ្ហានយោបាយក្នុងស្រុក ។

នៅឆ្នាំ១៩៦៥ អាចារ្យ ម៉ែន ស៊ុន, អាចារ្យ ចាន់ សុខា និង អាចារ្យ សុខ ហេង បានបញ្ចុះបញ្ចូល ប្រាក់ ឲ្យធ្វើជាភ្នាក់ងារ សេ.អ៊ី.អា ដោយប្រគល់ភារកិច្ចដូចតទៅ÷ ១) ទៅរស់នៅទីណាត្រូវរកវិធីបំផ្លាញកុម្មុយនិស្តនៅទីនោះឲ្យអស់ ២) រស់នៅទីណាត្រូវកសាងកម្លាំងសេ.អ៊ី.អាឲ្យបានច្រើន ៣) ត្រូវចេះរស់នៅបង្កប់ខ្លួនក្នុងជួរកុម្មុយនិស្តឲ្យបានយូរអង្វែង ហើយធ្វើសកម្មភាពកម្ទេចនិងបំផ្លាញកុម្មុយនិស្តដោយស្ងៀមស្ងាត់ ៤) ត្រូវរក្សាការសម្ងាត់និងប្រុងប្រយ័ត្នជាប់ជានិច្ច ។

នៅឆ្នាំ១៩៦៦ ប្រាក់ ប្រឡងជាប់ឌីប្លូម ហើយផ្លាស់មករៀននៅវិទ្យាល័យចៅពញាយ៉ាត ។ រៀននៅសាលានេះ ប្រាក់ បានស្គាល់សិស្សថ្នាក់ទី៣ម្នាក់ឈ្មោះ ជា ហើយអ្នកទាំងពីរក៏ក្លាយជាមិត្តភក្តិ និងធ្វើការបម្រើសេ.អ៊ី.អាជាមួយគ្នាតាំងពីពេលនោះមក ។ រយៈពេលមួយខែក្រោយមក ជា បានណែនាំ ប្រាក់ ឲ្យអ្នកដឹកនាំរបស់ខ្លួនឈ្មោះ តាម៉ាប់ ហៅ ឆយ បានស្គាល់ ។ ឆយ ដាក់ផែនការឲ្យ ប្រាក់ និង ជា រកវិធីបំផ្លាញកម្លាំងបដិវត្តន៍ ឃោសនាវាយប្រហារចលនាតស៊ូបដិវត្តន៍របស់ខ្មែរក្រហម និងកសាងកម្លាំងបង្កប់ក្នុងជួរបដិវត្តន៍ឲ្យបានច្រើន ។ ធ្វើការបានតែ៥ខែ ជា ក៏សុំឈប់ ប៉ុន្តែ ប្រាក់ នៅធ្វើសកម្មភាពជាមួយកម្លាំងដែលខ្លួនបានកសាង ។ ប្រាក់ ឈប់រៀននៅចុងឆ្នាំ១៩៦៧ ហើយបបួលគ្នា៤នាក់មកស្នាក់នៅរួមគ្នាក្នុងផ្ទះមួយ ។

នៅខែ១ ឆ្នាំ១៩៦៨ ប្រាក់ ត្រូវអង្គការចាត់តាំងឲ្យទៅប្រចាំការនៅខាងកើតទន្លេបាសាក់ ។ ឆយ បានណែនាំឲ្យ ប្រាក់ សង់ផ្ទះមួយនៅកៀនស្វាយសម្រាប់ធ្វើជាមូលដ្ឋានបង្អែករបស់ សេ.អ៊ី.អា ។ បន្ថែមពីលើនេះ ឆយ បានណែនាំភារកិច្ចមួយចំនួនឲ្យអនុវត្តគឺ ១) ខិតខំស្រាវជ្រាវរកស្នូលបដិវត្តន៍ដែលបង្កប់នៅទីនេះ ២) ខិតខំឃោសនាអប់រំប្រជាជនកុំឲ្យមានជំនឿលើបដិវត្តន៍ ៣) ខិតខំកសាងកម្លាំងថែមទៀត ។ ជំហានដំបូង ប្រាក់ ចុះទៅជិតស្និទ្ធជាមួយប្រជាជននៅតំបន់នោះជាញឹកញាប់ដោយឃោសនាអប់រំប្រជាជនឲ្យស្អប់កុម្មុយនិស្ត ក្នុងគោលបំណងកុំឲ្យប្រជាជនចូលខាងបដិវត្តន៍ ។ ប្រាក់ បាននិយាយប្រាប់ប្រជាជនថា "ជនជាតិចិនរត់ពីស្រុកចិនមកដល់ស្រុកខ្មែរសុខចិត្តបៀមដើងក្តាមមួយតាំងពីស្រុកចិនរហូតដល់ស្រុកខ្មែរ ក៏ព្រោះតែខ្លាច

កុម្មុយនិស្ត មកពីកុម្មុយនិស្តលំបាក ។ បើកុម្មុយនិស្តស្រួលមិនមែនជនជាតិចិនរត់ចោលស្រុកទេ។" នៅចុងខែ៥ ឆ្នាំ១៩៦៩ ប្រាក់ បានធ្វើជីវិទស្សន៍ជូនអង្គការ ហើយយកឯកសារជីវិទស្សន៍នោះមកភ្នំពេញ។ មកដល់ភ្នំពេញ ប្រាក់ ត្រូវប៉ូលិស (រាជរដ្ឋាភិបាល) ចាប់ខ្លួនហើយឆែកឃើញឯកសារជីវិទស្សន៍។ ប៉ូលិសក៏យក ប្រាក់ មកដាក់មន្ទីរឃុំឃាំង ។ មួយខែក្រោយមក ប្រាក់ សារភាពរឿងសម្ងាត់របស់បដិវត្តន៍ប្រាប់ប៉ូលិសទាំងអស់ ។ បន្ទាប់ពីនៅក្នុងគុកអស់រយៈពេល៦ខែ ប្រាក់ ត្រូវមេប៉ូលិសឈ្មោះ សួង សិទ្ធិ លួងលោមឲ្យធ្វើជាកម្លាំងបង្កប់របស់ប៉ូលិស ។ ប្រាក់ បានយល់ព្រម ។ បន្ទាប់ពីនោះរយៈពេល១ខែ ប្រាក់ ត្រូវបញ្ជូនមកមន្ទីរឃុំឃាំងព្រៃស ។ នៅព្រៃសបាន៤ខែ ប្រាក់ ត្រូវបានដោះលែង ។

នៅខែ៥ ឆ្នាំ១៩៧០ ប្រាក់ ត្រូវចាត់តាំងឲ្យទៅព្រែកប្រា ។ ឆយ បានទៅព្រែកប្រាដើម្បីដាក់ផែនការថ្មី។ ប្រាក់ បានរាយការណ៍ឲ្យ សួង សិទ្ធិ អំពីបដិវត្តន៍ ហើយបានទទួលរង្វាន់ជាប្រាក់ចំនួន៦០០រៀល ។

នៅខែ៩ ឆ្នាំ១៩៧០ ដោយស្ថានការណ៍នៅព្រែកប្រាមិនអនុគ្រោះ ប្រាក់ បានទៅនៅតំបន់២៥ (តំបន់រំដោះ) វិញ ហើយជួប ឆយ នៅទីនោះ។ ប្រាក់ បានទទួលការចាត់តាំងជាសមាជិកនគរបាលតំបន់២៥ ។ ឆយ បានឲ្យដឹងថា សភាពការណ៍នៅតំបន់២៥មិនសូវល្អទេ។ ចំរើន, សុខ និង សេ ត្រូវរ៉ូវគ្នាជាមួយយួន ហើយមានទំនាស់ជាមួយ កែវ សំផន។ រយៈពេល៧ថ្ងៃបន្ទាប់មក កែវ សំផន ត្រូវយួនសម្លាប់ ចំណែក ឆយ ត្រូវចាប់ឃុំឃាំងនៅស្រុកកោះធំ។ ក្រោយមក ប្រាក់ ក៏ត្រូវចាប់ឃុំឃាំងទៀត។ ដោយសារអន្តរាគមន៍របស់ ឌុច (តំណាងបក្សនៅ ស-២១) និងដោយមានការតវ៉ារបស់មហាជន ទើប ប្រាក់ ត្រូវបានដោះលែង។ សុខ ក៏បញ្ជូន ប្រាក់ ឲ្យធ្វើការនៅរោងពុម្ព ។ កន្លះខែក្រោយមក ប្រាក់ បាននាំកម្លាំង១០០នាក់ទៅស្នាក់នៅព្រៃល្វា ភូមិភាគនិរតី (ខេត្តតាកែវ) ។

នៅឆ្នាំ១៩៧១ ប្រាក់ ត្រូវបានតែងតាំងជាអ្នកដឹកនាំកងនៅតំបន់៣៣ ។ ឆយ ក៏នៅទីនោះដែរ។ ប្រាក់ នាំកម្លាំងទាំង១០០នាក់មករាយការណ៍ឲ្យ អុន និង ឌុច នៅផ្លូវជាតិលេខ៣ ។ អុន បែងចែកកម្លាំងទាំងនោះជា៣ផ្នែកគឺ មួយផ្នែកទៅខាងកងទ័ព មួយផ្នែកទៅខាងមូលដ្ឋាន និងមួយផ្នែកទៀតទៅតាមមន្ទីរនានា ។

នៅខែ២ ឆ្នាំ១៩៧១ ប្រាក់ ត្រូវចាត់តាំងជាស្នងការអនុសេនាធំលេខ១៨ នៅតំបន់៣៣ ។ នៅក្នុងអនុសេនាធំនេះមានកម្លាំងសេ.អ៊ី.អា៤នាក់គឺ វរៈ, វុធធី, ប្រាក់ និង ស៊ុយ ព្រមទាំងមានកម្មាភិបាលម្នាក់មកពីហាណូយ ។ ប្រាក់ រកវិធីកម្ចាត់កម្មាភិបាលនោះដោយបង្កទំនាស់ជាប់ជានិច្ច រហូតដល់ អុន ដកកម្មាភិបាលនោះចេញ ។

ខែ៣ ឆ្នាំ១៩៧១ គឺរយៈពេលមួយខែក្រោយពីការចាត់តាំង ប្រាក់ ចូលរួមប្រជុំដាក់ផែនការ ។ ក្នុងការប្រជុំនេះមានសមាសភាព៣នាក់គឺ អុន, វរៈ និង ប្រាក់។ ខ្លឹមសារនៃអង្គប្រជុំនេះគឺប្រឆាំងបដិវត្តន៍ដោយបង្កហេតុអុកឡុកបំផុសឲ្យទ័ពរត់ចោលជួរទៅចូលខាងទាហានលន់ណុល បំផ្លាញគ្រប់ផែនការទាំងអស់ធ្វើយ៉ាងណាកុំឲ្យបដិវត្តន៍ទៅមុខរួច ។ នៅឆ្នាំ១៩៧២ ប្រាក់ ត្រូវអង្គការតែងតាំងជាស្នងការវរសេនាតូចលេខ១៩ តំបន់៣៣ ហើយទទួលបញ្ជាទៅវាយខ្មាំងនៅសមរភូមិស្រង់ ។ ប្រាក់ រកវិធីបំផ្លាញផែនការនោះចោលដោយណែនាំ វុទ្ធី និង ម៉ុន ឲ្យរាយការណ៍ថា ទីតាំងភ្នំស្រង់នេះចូលជិតមិនបានទេ វាយ៥យប់៥ថ្ងៃហើយនៅតែមិនបានជោគជ័យ ។ ផុតពីនោះអង្គការលើកទិសឲ្យរំដោះវត្តប្រាសាទនាងខ្មៅតាមផ្លូវជាតិលេខ២ម្តង ។ ប្រាក់ បំផ្លាញផែនការនេះដោយយកលេសថាអត់គ្រាប់កាំភ្លើង ។

ប្រាក់ ចាត់តាំងឲ្យ វុទ្ធី និង តាសៀង ធ្វើសកម្មភាពទាក់ទងជាមួយទាហានលន់ណុលនៅកងរបស់មេបញ្ជាការ អិត សួង ។ ទាហាននោះឈ្មោះ គាត់ ជុំ ។ រំលង២-៣ថ្ងៃ ទាហាននោះបាននាំគ្នីគ្នាពីរនាក់ទៀតនិងកាំភ្លើង១២ដើមមកចរចាអំពីកិច្ចសហការគ្នាក្នុងការផ្តួលរំលំបដិវត្តន៍។ ប្រាក់ ក៏រាយការណ៍អំពីរឿងនេះទៅ ឌុច ។ ដំណឹងនេះលេចឮដល់តាលេខានិរតី (តាម៉ុក?) ។ តាលេខានិរតីមិនទុកចិត្តទាហានទាំង៣នាក់នោះ ក៏បញ្ជាឲ្យសម្លាប់ចោល ។

នៅខែ១ឆ្នាំ១៩៧៣ អង្គការបានតែងតាំង ប្រាក់ ជាស្នងការ

កងវរសេនាតូចលេខ១៣៨ប្រចាំភូមិភាគនិរតី ។ ប្រាក់ នៅតែបន្តប្រឆាំងបដិវត្តន៍ដដែល ។ នៅឆ្នាំ១៩៧៣ មានការបង្កើនការទម្លាក់គ្រាប់បែកក្នុងគោលបំណងបង្ខំឲ្យបដិវត្តន៍ព្រមចរចា ។ ឆ្លៀតឱកាសនេះ ប្រាក់ ព្យាយាមបញ្ចុះបញ្ចូលឲ្យមានការចរចា ដោយលើកហេតុផលថា យើងធ្វើសង្គ្រាមស្លាប់ទាហានអស់ច្រើនហើយ បើច្បាំងតទៅទៀតពិតជាខូចខ្ទីមិនខាន ។ នៅខែ៦ ឆ្នាំ១៩៧៣ ប្រាក់ ចុះទៅសមរភូមិតាកែវ ដើម្បីរំដោះទីរួមខេត្តតាកែវ ។ អង្គភាពរបស់ ប្រាក់ បានបំផ្លាញគ្រាប់១២០ម.ម អស់រាប់រយគ្រាប់ ។ ក្នុងពេលប្រយុទ្ធ ប្រាក់ រាយការណ៍ជូនអង្គការថាខ្លួនផ្លោងចំកន្លែងខ្មាំងហើយ តែតាមការពិតគ្រាប់ដែលផ្លោងនោះធ្លាក់ខុសគោលដៅ ។

ខែ១១ ឆ្នាំ១៩៧៣ ប្រាក់ ទទួលតំណែងជាស្នងការវរសេនាធំលេខ១២ ។ កងនេះមាន៤វរសេនាតូច គឺវរសេនាតូចលេខ៣៨០, ៣៥០, ៤០១ និង៤០៤ ។ ដើមឆ្នាំ១៩៧៤ អង្គការមានគោលបំណងបើកសមរភូមិភ្នំពេញ ដោយរំដោះខេត្តកំពង់ស្ពឺជាមុនសិន ។ ប្រាក់ ដាក់ផែនការបំផ្លាញចោលដោយប្រើយុទ្ធសាស្ត្រដូចលើកមុនគឺបំផុសឲ្យយុទ្ធជនរត់ចោលខ្សែត្រៀមនៅពេលខ្មាំងកំពុងតែវាយសម្រុក ។ ចំណែកផ្លូវពីកំពង់ស្ពឺទៅភ្នំពេញដែលអង្គការបញ្ជាឲ្យកាត់ផ្តាច់ ក៏ ប្រាក់ មិនបានកាត់ផ្តាច់ដែរ ដើម្បីទុកឱកាសឲ្យកម្លាំងរបស់ ចន្ទ រង្សី ចល័តជួយភ្នំពេញបាន ។

ប្រាក់ បញ្ឈប់ការទាក់ទងជាមួយ អុន និង ឌុច ក្រោយពេលដែលខ្លួនរាយការណ៍ជូនអង្គការអំពីរឿង អុន ខូចសីលធម៌ជាមួយនារី ជឿន និងនារីជាច្រើនទៀតនៅក្នុងតំបន់សន្តិសុខ ។ នៅចុងខែ៧ ឆ្នាំ១៩៧៤ ប្រាក់ ត្រូវបញ្ជូនឲ្យមករៀននៅសាលាបក្សភូមិភាគនិរតី ។ នៅទីនោះ ប្រាក់ ជួប តាស៊ី ដែលជាខ្សែរយៈយូរហើយ និងប្រាប់អំពីការផ្តាច់ទំនាក់ទំនងជាមួយ អុន ។ តាស៊ី ប្រាប់ឲ្យទាក់ទងជាមួយគាត់ដោយផ្ទាល់ ប៉ុន្តែត្រូវប្រយ័ត្នប្រយែង ។ នៅខែ៨ ឆ្នាំ១៩៧៤ អង្គការចាត់តាំងឲ្យ ប្រាក់ ធ្វើជាអនុលេខាតំបន់៣៣ ទទួលភារកិច្ចខាងយោធា ។ កម្លាំងសេ.អ៊ី.អាទាំងអស់នៅតែបន្តសកម្មភាពដដែល ។ ប្រាក់ បានកោះហៅកម្លាំងសេ.អ៊ី.អាទាំងអស់ហើយខ្ទេសនាមឲ្យស្គាល់គ្នា ។ បន្ទាប់មក ប្រាក់ ដាក់ផែនការឲ្យ សុផៃ ទាក់ទងជាមួយទាហានសក្តិ៣ម្នាក់ឈ្មោះ អ៊ឹម ប៉ុន្តែមិនទាន់ទាំងអនុវត្តផង ប្រទេសកម្ពុជាត្រូវបដិវត្តន៍រំដោះបានទាំងស្រុងនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។

ពេលរំដោះភ្នំពេញបានភ្លាមៗ អង្គការចេញសេចក្តីណែនាំឲ្យរក្សាទុកជយភណ្ឌនៅភ្នំពេញទាំងអស់ ហើយហាមប៉ះពាល់ទុកឲ្យអង្គការជាអ្នកចាត់ចែង ។ ខែ៦ ឆ្នាំ១៩៧៥ ប្រាក់ ត្រូវចាត់តាំងជាអនុលេខាតំបន់២៥ដែលមាន ជា ជាលេខា ។ ក្រោយរំដោះកន្លះខែ អង្គការលើកគោលការណ៍បោសសម្អាតអ្នកមានបណ្តាសក្តិក្នុងរបបលន់ណុលឲ្យអស់ ។ ពេលនោះប្រជាជននៅតាមមូលដ្ឋានមួយចំនួនមានការភ្ញាក់ផ្អើលដោយសារតែការបោសសម្អាតមិនបានល្អ ។

នៅចុងខែ១១ ឆ្នាំ១៩៧៥ ប្រាក់ ចូលរួមមហាសន្និបាតសេដ្ឋកិច្ច ហើយបានជួប តាស៊ី ។ តាស៊ី បានចង្អុលមនុស្សម្នាក់ឲ្យ ប្រាក់ ស្គាល់គឺ សោភឹម លេខាភូមិភាគបូព៌ា ហើយប្រាប់ថាគាត់គឺជាលេខាបក្សពលករកម្ពុជា ។

នៅខែ៧ ឆ្នាំ១៩៧៦ ប្រាក់ ចេញដំណើរទៅតាខ្មៅដើម្បីប្រជុំដំណាច់ខែ ប៉ុន្តែមិនទាន់មកដល់តាខ្មៅផងឡានបែកកង់ក៏ចូលសម្រាកនៅស្រុកស្អាង គិតថាចាំព្រឹកស្អែកសឹមធ្វើដំណើរទៅជាមួយលេខាស្រុកស្អាងឈ្មោះ តាសៀន ។ ក្រោយពីប្រជុំដំណាច់ខែចប់ ប្រាក់ និង ជា បន្តស្នាក់នៅតាខ្មៅមួយរយៈ ។ ជា បានលើកអំពីខ្សែបក្សពលករដែលគេស្គាល់មាន តាភឹម, យ៉ា, ធុច, កែវ មាស, តាស៊ី, តូច ភឿន, តាចាន់, តាជ័យ និង ឈូក ។ ក្រៅពីនេះ ជា បានបញ្ជាឲ្យបំផ្លាញពោតចោលនោះអង្គការពិតជាខ្វះពោត ហើយសភាពអត់ឃ្លានពិតជាកើតឡើង ។ ធ្វើដូច្នោះប្រជាជននឹងអស់ជំនឿលើបដិវត្តន៍ ។ ទទួលបានផែនការនេះ ប្រាក់ យកទៅផ្សព្វផ្សាយនៅស្រុកកោះធំដើម្បីអនុវត្ត ព្រោះរដូវកាច់ពោតជិតមកដល់ហើយ ។ លើសពីនេះ ប្រាក់ ណែនាំឲ្យអ្នកក្រោមបង្គាប់អនុវត្តវិធីម្យ៉ាងទៀតគឺឲ្យមនុស្សមួយក្រុមដើរប្រមូលអីវ៉ាន់តាមផ្ទះប្រជាជន ទោះតិចក្តីច្រើនក្តី ប្រមូលដាក់ជាសមូហភាពទាំងអស់ ហើយឲ្យមនុស្សផ្សេងទៀតឃោសនាឲ្យប្រជាជនរក្សាទុកកម្មសិទ្ធិឯកជនដដែល ។

នៅខែ៩ ឆ្នាំ១៩៧៦ ប្រាក់ ទទួលបញ្ជាពី ជា ឲ្យរៀបចំធ្វើរដ្ឋប្រហារនៅថ្ងៃបុណ្យកំណើតបក្សនាពេលខាងមុខនេះ ។ ប្រាក់ ត្រៀមកម្លាំងប្រជាជនជិត១ម៉ឺននាក់ ហើយមានគម្រោងអូសទាញកម្លាំងប្រជាជននៅឃុំកោះធំ ព្រែកស្ដី និងព្រែកថ្មីបន្ថែមទៀត ។ កម្លាំងទាំងនេះនឹងត្រូវមកជួបជុំគ្នាមួយថ្ងៃមុនថ្ងៃបុណ្យកំណើតបក្ស ដើម្បីធ្វើមិទ្ទីង ។ នៅសល់តែបីថ្ងៃទៀតដល់កំណត់ពេលវេលាដែលត្រូវអនុវត្តផែនការ ប្រាក់ មកជួប ជា នៅតាខ្មៅ ដើម្បីទទួលផែនការលម្អិត ប៉ុន្តែ ជា ប្រាប់ថាមិនទាន់បានទទួលការណែនាំថ្មីទេ ។ ប្រាក់ ចាំបាត់ៗរហូតក្រោយថ្ងៃបុណ្យជិតមួយខែ ទើបទទួលដំណឹងថា ផែនការរដ្ឋប្រហារបែកការណ៍ ហើយកម្លាំងសេ.អ៊ី.អាមួយចំនួនត្រូវអង្គការចាប់ខ្លួន ។

នៅចុងខែ១១ ឆ្នាំ១៩៧៦ ប្រាក់ បានមករៀនសូត្រនៅវគ្គសិក្សារបស់បក្ស ហើយជួបជាមួយ ឆយ ។ ប្រាក់ ប្រាប់ពីសភាពការណ៍នៅតំបន់២៥ថា អង្គការបោសសម្អាតខ្សែ ចំរើន និង សុខ ជិតអស់ហើយ ។ ឆយ បានណែនាំ ប្រាក់ កុំអង្គុយជុំៗគ្នាក្រែងមានរឿងមិនស្រួល ខ្លាចអង្គការសង្ស័យ ។

នៅឆ្នាំ១៩៧៧ ប្រាក់ កសាងកម្លាំងសេ.អ៊ី.អាបានជាច្រើន ។ កម្លាំងទាំងនេះត្រូវបានប្រើឲ្យបំផ្លាញបដិវត្តន៍ជាហូរហែទៅតាមផ្នែក ដូចជាផ្នែកពេទ្យឲ្យបំផ្លាញថ្នាំពេទ្យ ចាក់ថ្នាំធ្វើឲ្យអាប់សែ ខាងតម្បាញឲ្យបំផ្លាញអំបោះ បំផ្លាញកី ធ្វើឲ្យឃីតយ៉ាវមិនគ្រប់ផែនការ ខាងកិនស្រូវបំផ្លាញស្រូវអង្ករនិងម៉ាស៊ីនស្រូវ ខាងការដ្ឋានឲ្យបំផ្លាញឧបករណ៍កសិកម្ម ខាងដាំបាយឲ្យខ្ជះខ្ជាយហើយបើមានលទ្ធភាពគឺដាក់ថ្នាំបំពុល ។

ឆ្នាំ១៩៧៧នេះ អង្គការលើកគោលការណ៍វាយសម្រុកបោសសម្អាតខ្មាំងខ្មាំងក្បាជាងឆ្នាំណាៗទាំងអស់ ជាពិសេសខ្មាំងបង្កប់ស៊ីរូងក្នុងផ្ទៃបក្សគ្រប់ថ្នាក់ ។ ក្រៅពីខ្សែ ចំរើន និង សុខ សូម្បីតែកម្លាំងថ្មីដែល ជា និង ជ័យ កសាងក្រោយទៀតក៏ត្រូវបក្សបោសសម្អាតដែរ ។ តាម៉ុក លេខាភូមិភាគនិរតីបញ្ជាឲ្យបោសសម្អាតកម្លាំងក្បត់ជាបន្តបន្ទាប់ ។ ទោះជានៅក្នុងស្ថានការណ៍បែបនេះក៏ដោយ ក៏ ប្រាក់ នៅតែបន្តសកម្មភាពតទៅទៀត ។ ដើមខែ៤ ឆ្នាំ១៩៧៧ ប្រាក់ ចូលរួមប្រជុំដាក់ផែនការធ្វើរដ្ឋប្រហារជាលើកទី២ ។ ប្រាក់ ទទួលបញ្ជាឲ្យរៀបចំកម្លាំងប្រជាជនដូចមុន ប៉ុន្តែ ផែនការទី២នេះត្រូវបែកការណ៍ទៀត ។ ជា ណែនាំ ប្រាក់ ឲ្យប្រុងប្រយ័ត្នខ្លាំងជាងមុន ។

នៅខែ៦ ឆ្នាំ១៩៧៧ ប្រាក់ ត្រូវចាត់តាំងឲ្យធ្វើជាលេខាតំបន់តាកែវ ។ នៅទីនោះ ប្រាក់ បន្តបំផ្លាញផែនការបក្សហើយយកលេសផ្សេងៗមកដោះស្រាយ ។ នៅខែ១១ ប្រាក់ រៀបចំដំណើរទៅរៀនសូត្រនៅសាលាបក្សដំណាច់ឆ្នាំ១៩៧៧ ។ ពេលចេញពីសាលាបក្សបាន៤-៥ថ្ងៃ ប្រាក់ ត្រូវអង្គការស្នើទៅបើកវគ្គលេខាឃុំនៅមន្ទីរភូមិភាគ ។ ពេលកំពុងបើកវគ្គនៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៧៧ យួនវាយបុកចូលតាកែវ ។

នៅខែ២ ឆ្នាំ១៩៧៨ ប្រាក់ ចូលរួមប្រជុំដំណាច់ខែនៅតាកែវ ។ ជា ណែនាំឲ្យបង្កើនសកម្មភាពអុកឡុកក្នុងជួរបដិវត្តន៍កាន់តែខ្លាំងឡើង ។ មិនយូរប៉ុន្មាន ជា ត្រូវអង្គការចាប់ខ្លួន ហើយ៤ថ្ងៃក្រោយមក តាស៊ី ក៏ត្រូវអង្គការចាប់ខ្លួនដែរ ។ ប្រាក់ ត្រូវដាច់ខ្សែរយៈធំៗអស់ ក៏បានពិគ្រោះគ្នាជាមួយតាសៀន គិតប្រមូលខ្សែនៅតំបន់២៥ដែលនៅសល់ទាំងប៉ុន្មានដើម្បីបន្តសកម្មភាពទៀត ។ ប្រាក់ បានព្យាយាមទាក់ទង តាចាន់នៅភូមិភាគបូព៌ាដើម្បីរកខ្សែធ្វើការបន្តទៀត ប៉ុន្តែមិនទាន់បានប្រមូលគ្នាផង ប្រាក់ ត្រូវអង្គការចាប់ខ្លួននៅថ្ងៃទី១៣ ខែ៥ ឆ្នាំ១៩៧៨ ។

ប្រាក់ ត្រូវសួរចម្លើយនៅថ្ងៃទី២៣ ខែ៦ ឆ្នាំ១៩៧៨ ដោយឈ្មោះ វ៉ុន ។ ប្រាក់ បានសារភាពអំពីសកម្មភាពរបស់ខ្លួនជាមួយនឹងបញ្ជីដ៏វែងមួយមានឈ្មោះមនុស្ស២៨១នាក់ដែល ប្រាក់ បញ្ជាក់ថាមានទំនាក់ទំនងក្នុងសកម្មភាពក្បត់ជាមួយខ្លួន ។ មនុស្សមួយចំនួនធំដែលមានឈ្មោះក្នុងបញ្ជីនោះមានបញ្ជាក់នៅខាងចុងថា “ចាប់” ។

**សូ ហ្វារីណា**

## ពាក្យស្លោកខ្មែរក្រហម

◆ **បក្សនេះហើយជាអ្នករំដោះប្រជាជនកម្ពុជាឲ្យរួចផុតពីការជិះជាន់នានា កសាងកម្ពុជាជាថ្មី។**

*(ដកស្រង់ពីកំណត់ហេតុលេខ ១១៥)*

# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរ ស-២១ (គុកទួលស្លែង)

**រៀបចំនិងចងក្រងដោយៈ យិន នាន**

**(តពីលេខមុន)**

| ល.រ | ឈ្មោះ | តួនាទី | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|
| ១៣៧១ | អឿន ហួយ | សក្តិ១ | តាខ្មៅ | ៣១-៨-៧៦ | ៦-១២-៧៦ |
| ១៣៧២ | តូច អឿន ហៅ ឈឿន | យុទ្ធជន | ពាណិជ្ជកម្មក្រុង | ១២-៩-៧៦ | ៦-១២-៧៦ |
| ១៣៧៣ | ហែម ភី | មេពួក | កងពល៥០២ | ១២-៩-៧៦ | ៦-១២-៧៦ |
| ១៣៧៤ | ដួង ដារុង | កម្មករចាស់ | អគ្គិសនីទី២ | ៤-៨-៧៦ | ៦-១២-៧៦ |
| ១៣៧៥ | ខូវ បូរសិច | កម្មករចាស់ | រោងចក្រក.ជ | ១២-៩-៧៦ | ៦-១២-៧៦ |
| ១៣៧៦ | ប៊ុន លាង ហៅ ភ័ណ | យុទ្ធជន | កងពលទី៣ | ??-៩-៧៦ | ៦-១២-៧៦ |
| ១៣៧៧ | តាំង ឆាំង | ប្រជាជន | តំបន់២៥ | ៣០-៨-៧៦ | ៦-១២-៧៦ |
| ១៣៧៨ | ហម ហង់ | យុទ្ធជន | កងពល៥០២ | ??-៩-៧៦ | ៦-១២-៧៦ |
| ១៣៧៩ | ខ្វត សុខុម | កម្មករថ្មី | រទេះភ្លើង | ១១-៩-៧៦ | ៦-១២-៧៦ |
| ១៣៨០ | នេត សុខា ហៅ ដេត | មេក្រុម | ប្រាំងចំរេះ | ២២-៩-៧៦ | ៦-១២-៧៦ |
| ១៣៨១ | ស្ងួន នៃឡេង ហៅ សមិត្ត | កងហា | កងពល៥០២ | ១៨-៩-៧៦ | ៦-១២-៧៦ |
| ១៣៨២ | ខៀវ សុត ហៅ ម៉ា | ប្រធានវរសេនាធំ | កងពល១៧០ | ១៧-៩-៧៦ | ៦-១២-៧៦ |
| ១៣៨៣ | ស៊ុម ខន ហៅ វឿន | អនុក្រុម | ផ្សារក្រុង | ១២-៩-៧៦ | ៦-១២-៧៦ |
| ១៣៨៤ | លី ប៊ុនឈេង | សក្តិ៤ | យួន | ១៧-៩-៧៦ | ៦-១២-៧៦ |
| ១៣៨៥ | ជុំ សាវ៉ុន ហៅ ចាន់ | វរសេនាតូច | កងពល២៩០ | ១៧-៩-៧៦ | ៦-១២-៧៦ |
| ១៣៨៦ | ហ៊ីង សុខុម | សាស្ត្រាចារ្យ | អាមេរិក | ២៣-៩-៧៦ | ៦-១២-៧៦ |
| ១៣៨៧ | បេង ស៊ីយ៉ុមប៊ិន | សក្តិ៥ | ព្រះវិហារ | ២១-៩-៧៦ | ៦-១២-៧៦ |
| ១៣៨៨ | ឡឹក ហៃ | វរសេនាតូច | កងពល១៧០ | ៣០-៨-៧៦ | ៦-១២-៧៦ |
| ១៣៨៩ | គង់ យ៉ុង | វរសេនាធំ | កងពល១៧០ | ១៧-៩-៧៦ | ៦-១២-៧៦ |
| ១៣៩០ | យស់ ជុំ ហៅ សុខន | វរសេនាតូច | កងពល២៩០ | ១៧-៩-៧៦ | ៦-១២-៧៦ |
| ១៣៩១ | ប៉ែន ភាព (ស្រី) | ប្រពន្ធ អោម សិត | រទេះភ្លើង | ២-១២-៧៦ | ៦-១២-៧៦ |
| ១៣៩២ | អ៊ីង ស្រ៊ា (ស្រី) | ប្រពន្ធ នុន ប៊ុនលីម | រទេះភ្លើង | ២-១២-៧៦ | ៦-១២-៧៦ |
| ១៣៩៣ | អិន អ៊ីម (ស្រី) | ពលកម្ម | រទេះភ្លើង | ២-១២-៧៦ | ៦-១២-៧៦ |
| ១៣៩៤ | ឆាយ សារិន (ស្រី) | ប្រពន្ធ គង់ សុក | រទេះភ្លើង | ២-១២-៧៦ | ៦-១២-៧៦ |
| ១៣៩៥ | ម៉ឹង សឿន (ស្រី) | ពលកម្ម | រទេះភ្លើង | ២-១២-៧៦ | ៦-១២-៧៦ |
| ១៣៩៦ | ម៉ឹង ពួយ | ជំនួយសាលា | កងពល៧០៣ | ១-១២-៧៦ | ៦-១២-៧៦ |
| ១៣៩៧ | ប៉ែន អ៊ូ ហៅ រិន | ជំនួយសាលា | កងពល៧០៣ | ១-១២-៧៦ | ៦-១២-៧៦ |
| ១៣៩៨ | ម៉ក ប៊ិន ហៅ ខ៊ុំ | ជំនួយសាលា | កងពល៧០៣ | ១-១២-៧៦ | ៦-១២-៧៦ |

| | | | | | |
|---|---|---|---|---|---|
| ១៣៩៩ | លី ទ្រី | គ្រួសារ ចៅ សន | រដ្ឋករទឹក | ៣០-១០-៧៦ | ៦-១២-៧៦ |
| ១៤០០ | ចាន់ យូរ៉ុន | ចៅក្រម | ស្រុកបារាំង | ២៨-១០-៧៦ | ៦-១២-៧៦ |
| ១៤០១ | មាស ប៊ិន | កងហា | កងពល៣១០ | ២១-១១-៧៦ | ៦-១២-៧៦ |
| ១៤០២ | នៃ សារិន | វរសេនាតូច | កងពល៣១០ | ១៧-៩-៧៦ | ៦-១២-៧៦ |
| ១៤០៣ | សួស មុត | បើកឡាន | ស្រែអំបិល | ១៧-១១-៧៦ | ៦-១២-៧៦ |
| ១៤០៤ | គីម ឈិត | កម្មករចាស់ | រោងចក្រ ដ-៤ | ២០-១០-៧៦ | ៦-១២-៧៦ |
| ១៤០៥ | ឃៀម សុកជា | គ្រូបង្រៀន | តាខ្មៅ | ១២-១០-៧៦ | ៦-១២-៧៦ |
| ១៤០៦ | លី សៀ | កម្មករចាស់ | រទេះភ្លើង | ៣០-១០-៧៦ | ៦-១២-៧៦ |
| ១៤០៧ | សោម សៀត | យុទ្ធជន | កងពល១៧០ | ១៤-១១-៧៦ | ៦-១២-៧៦ |
| ១៤០៨ | ពត សិទ្ធ ហៅ សុន | យុទ្ធជន | ពាណិជ្ជកម្ម | ១៣-៩-៧៦ | ៦-១២-៧៦ |
| ១៤០៩ | នួន កុង ហៅ ព្រឹក្សា | វរសេនាតូច | កងពល២៩០ | ១៩-១០-៧៦ | ៦-១២-៧៦ |
| ១៤១០ | រដ្ឋ វណ្ណៈ | យុទ្ធជន | រោងចក្រ | ២៩-៩-៧៦ | ៦-១២-៧៦ |
| ១៤១១ | អ៊ីស៊ុប គន្ធី | ទូត | ប្រាំងចំរេះ | ៩-៩-៧៦ | ៦-១២-៧៦ |
| ១៤១២ | រស់ គីមយាង | យុទ្ធជន | រោងចក្រ | ២១-៩-៧៦ | ៦-១២-៧៦ |
| ១៤១៣ | ជីម ងីហេង | កម្មករចាស់ | អគ្គិសនីទី២ | ២៨-១០-៧៦ | ៦-១២-៧៦ |
| ១៤១៤ | នៅ ហន | យុទ្ធជន | ស-២១ ឃ | ១៩-១២-៧៦ | ២១-១២-៧៦ |
| ១៤១៥ | ដៃ សុផុន | កម្មករ | ស-២១ ឃ | ១៩-១២-៧៦ | ២១-១២-៧៦ |
| ១៤១៦ | ទៀ ខេង | កម្មករ | ស-២១ ឃ | ១៩-១២-៧៦ | ២១-១២-៧៦ |
| ១៤១៧ | ឈូ ប៊ុនលាត | វរសេនាធំ | កងពល៧០៣ | ៧-៦-៧៦ | ២១-១២-៧៦ |
| ១៤១៨ | ប៉ុល ខាត់ | វរសេនាតូច | កងពល៧០៣ | ៣០-៩-៧៦ | ២១-១២-៧៦ |
| ១៤១៩ | សូ សាន ហៅ ផាត | ជំនួយវរសេនាធំ | កងពល១៧០ | ១៧-៩-៧៦ | ២១-១២-៧៦ |
| ១៤២០ | ស្ដើង គ្រឿន | វរសេនាតូច | កងពល១៧០ | ១៧-៩-៧៦ | ២១-១២-៧៦ |
| ១៤២១ | ខាត់ សាខន | ជំនួយវរសេនាធំ | កងពល១៧០ | ១៧-៩-៧៦ | ២១-១២-៧៦ |
| ១៤២២ | ទៀប ស៊ីផុន | វរសេនាតូច | កងពល១៧០ | ១៧-៩-៧៦ | ២១-១២-៧៦ |
| ១៤២៣ | ប៉ែន ពេញ ហៅ ថោង អ៊ូច | ជំនួយវរសេនាធំ | កងពល១៧០ | ១៧-៩-៧៦ | ២១-១២-៧៦ |
| ១៤២៤ | អ៊ុង សុន | វរសេនាតូច | កងពល១៧០ | ១៧-៩-៧៦ | ២១-១២-៧៦ |
| ១៤២៥ | ហ៊ឹម រ៉ាន់នី ហោ រ៉ាន់ថា | មេពួក | កងពល១៧០ | ២៨-១០-៧៦ | ២១-១២-៧៦ |
| ១៤២៦ | ប៊ុន សុផល | កងរយ | កងពល១៧០ | ២៨-៩-៧៦ | ២១-១២-៧៦ |
| ១៤២៧ | កែន ង៉ុន | វរសេនាតូច | កងពល១៧០ | ១៧-៩-៧៦ | ២១-១២-៧៦ |
| ១៤២៨ | ហម អៀម | នីរសា | កងពល១៧០ | ២៨-១១-៧៦ | ២១-១២-៧៦ |
| ១៤២៩ | ម៉ី ប៊ុន ហៅ ថេន | យុទ្ធជន | កងពល១៧០ | ២៨-១១-៧៦ | ២១-១២-៧៦ |
| ១៤៣០ | ស៊ិន សុន | វរសេនាតូច | កងពល១៧០ | ១៧-៩-៧៦ | ២១-១២-៧៦ |

**(នៅមានត)**

(ឯកសារសន្តិបាល)

# គារាងចាត់តាំងភូមិភាគឧត្តរ (៣០៤)

***ក) តារាងចាត់តាំងភូមិភាគឧត្តរ (៣០៤) ពីឆ្នាំ១៩៦៣ ដល់ខែ២ ឆ្នាំ១៩៧៧***

សមាជិកភូមិភាគដែលបានជ្រើសតាំងចាប់ពីឆ្នាំ១៩៦៣ ដល់ខែ២ ឆ្នាំ១៩៧៧ ។

I. រយៈកាលពីឆ្នាំ១៩៦៣ដល់១៩៧២

១) មិត្ត កុយ ធួន សាស្ត្រាចារ្យ ឈ្មោះសម្ងាត់ ក៏ម ឬ គុណ ជ្រើសតាំងជាលេខាភូមិភាគ

២) កែ វិន កសិករ ឈ្មោះសម្ងាត់ កង ឬ គីត ជ្រើសតាំងជាអនុលេខាភាគ

៣) ថោង សំអាត គ្រូបង្រៀន ឈ្មោះសម្ងាត់ កេត ឬ ភាំ ឬ លឿន, គង់ ជាសមាជិក

៤) ទីត ឈន គ្រូបង្រៀនក្រៅក្របខណ្ឌ ហៅ ទឹន ឬ ប្រាំង ជាសមាជិក

៥) ភាំ ស៊ី សិស្សថ្នាក់ទី១ ហៅ បាន ឬ រ័ត្ន ជ្រើសតាំងជាសមាជិក

៦) ជ័យ ឆាន សិស្សថ្នាក់ទី៣ ហៅ ទាវ ឬ សេង ជ្រើសតាំងជាសមាជិក

***សម្គាល់***

◆ មិត្ត ក៏ម និង កន បក្សកំណត់ជាសមាជិកពេញសិទ្ធិ (២រូប)

◆ មិត្ត កេត, ទឹន, បាន, និង ទាវ ជាសមាជិកភូមិភាគត្រៀម (៤រូប)

◆ មិត្ត កេត និង ទឹន ត្រូវពលិកម្មក្នុងសង្គ្រាមផ្ទៃក្នុង

II. រយៈកាលពីឆ្នាំ១៩៧២-១៩៧៣

១) មិត្តគុណ ហៅ ធុច បានត្រូវចាត់តាំងជាលេខាភាគ៣០៤

២) មិត្តគីត ហៅ ថេង បានត្រូវចាត់តាំងជាអនុលេខាភាគ

៣) មិត្តកាន់ ហៅ ឡឿន បានត្រូវចាត់តាំងជាសមាជិក

៤) មិត្តទាវ ហៅ សេង បានត្រូវចាត់តាំងជាសមាជិក

៥) មិត្តផល សិស្សថ្នាក់ទី៣ ហៅ សុទ្ធ បានត្រូវចាត់តាំងជាសមាជិកត្រៀម

***សម្គាល់***

◆ មិត្តធុច, គីត, និង ឡឿន បានជ្រើសតាំងជាសមាជិកអចិន្ត្រៃយ៍ភូមិភាគ

◆ មិត្តសុទ្ធ បានចូលជាសមាជិកត្រៀម

III. រយៈកាលពីឆ្នាំ១៩៧៣-១៩៧៥

១) មិត្តធុច ហៅ ឃួន ធ្វើជាលេខាភូមិភាគ៣០៤

២) មិត្តពក ហៅ ឃុន ធ្វើជាអនុលេខាភូមិភាគ៣០៤

៣) មិត្តកាន់ ហៅ ឡឿន ធ្វើជាសមាជិកភូមិភាគ៣០៤

៤) មិត្តស្រេង ហៅ ប៉ុក ធ្វើជាសមាជិកភូមិភាគ៣០៤

៥) មិត្តសុទ្ធ ធ្វើជាសមាជិកត្រៀមរបស់ភូមិភាគ

៦) មិត្តម៉ុន កសិករ ហៅ ខន ឬ គុល ចាត់តាំងជាសមាជិកត្រៀម

***សម្គាល់៖***

ក្នុងរយៈកាលនេះ ភាគបានយកចិត្តទុកដាក់កសាង មិត្តសុទ្ធ និង គុល ដើម្បីជាសមាជិកពេញសិទ្ធ តែចូលជាសមាជិកមិនបាន ដោយគោលជំហរនយោបាយនិងសតិអារម្មណ៍បក្សមិនរឹងប៉ឹង ។

IV. រយៈកាលពីខែ៦-១៩៧៥ ដល់ខែ២ ១៩៧៧

១) មិត្តពក ហៅ ឃុន ត្រូវបានជ្រើសតាំងជាលេខាភូមិភាគឧត្តរថ្មី មានលេខ៣០៣

២) មិត្តស្រេង ហៅ ប៉ក ត្រូវបានជ្រើសតាំងជាអនុលេខាភូមិភាគឧត្តរថ្មី

៣) មិត្តគុល ត្រូវបានជ្រើសតាំងជាសមាជិកពេញសិទ្ធិភូមិភាគឧត្តរថ្មី

៤) មិត្ត ពេជ ជាង សិស្សថ្នាក់ទី១ ហៅ កែវ ឬ ជូ សមាជិកត្រៀមភូមិភាគឧត្តរថ្មី

៥) មិត្តសី កសិករ ត្រូវបានជ្រើសតាំងជាសមាជិកត្រៀម

***សម្គាល់***

◆ ការជ្រើសតាំង មិត្តថូ និង សី ចូលជាសមាជិកដោយឈរលើលក្ខណៈសម្បត្តិដែលមានជាងគេ ។ គោលបំណងនៃការចាត់តាំងគឺដើម្បីបន្ថែមក្បាលម៉ាស៊ីនដឹកនាំរបស់ភូមិភាគឲ្យបានគ្រប់គ្រាន់ ។

◆ ក្នុងរយៈកាលនេះ បក្សបានដក មិត្តឃួន និងរូបខ្ញុំ (ឌឿន) ឲ្យចេញពីភាគ ហើយមកជួយធ្វើការងារនៅខាងភ្នំពេញក្រោយរំដោះប្រទេសទាំងស្រុងមក ។

◆ មិត្តស្រេង ត្រូវភាគដកពីលេខាតំបន់ឲ្យមកប្រចាំការនៅមន្ទីរភូមិភាគ ។

◆ មិត្តសុទ្ធ ត្រូវដកចេញពីភូមិភាគ៣០៣រវាងខែ៦-៧៥ ហើយទៅទទួលជាលេខាតំបន់១០៦សៀមរាប-ឧត្តរមានជ័យវិញ ។

◆ ចាប់ពីខែ៦-៧៥ទៅ ភូមិភាគឧត្តរ (៣០៤) ត្រូវអង្គការដកតំបន់១០៦ចេញ ហើយឲ្យដូរឈ្មោះភូមិភាគឧត្តរថ្មីលេខ ៣០៣ ។

◆ ក្នុងរយៈកាលនេះ ប្រទេសកម្ពុជាបានរំដោះទាំងស្រុងនិងស្ថាពរហើយ ។

### ១) ការរៀងចាត់តាំងតំបន់ក្នុងភូមិភាគឧត្តរពីឆ្នាំ១៩៦៣ ដល់ខែ២ ឆ្នាំ១៩៧៧

I. រយៈកាលពីឆ្នាំ១៩៦៣-១៩៧២

**១) តំបន់៣០**

តំបន់នេះមានស្រុកព្រៃឈរ ពាមជីកង ជើងព្រៃ (ស្គន់) ។ គណៈកម្មាធិការតំបន់មានសមាជិកដូចតទៅ÷

១) មិត្តស្រេង បានជ្រើសតាំងជាលេខាតំបន់ ទទួលស្រុកព្រៃឈរនិងជើងព្រៃ

២) មិត្តទឹន បានជ្រើសតាំងជាអនុលេខាតំបន់ ទទួលស្រុកព្រៃឈរ

៣) មិត្តផល គ្រូបង្រៀន ហៅ ស៊ូ ជាសមាជិក ទទួលស្រុកពាមជីកង

**សម្គាល់**

◆ មិត្តទឹន ធ្លាប់ចាត់តាំងធ្វើជាលេខាតំបន់៣០ផងដែរ នៅពេលដែលដកមកនៅសម្ងាត់ក្នុងតំបន់នេះ ។ គាត់ទទួលធ្វើលេខាជំនួស មិត្តស្រេង ។

◆ មិត្តគុណ ជាលេខាភាគ បានមកបង្កប់នៅសម្ងាត់ក្នុងតំបន់៣០ ដើម្បីងាយស្រួលទាក់ទងតំបន់ផ្សេងៗ ព្រោះតំបន់៣០នៅចំកណ្តាលភូមិភាគ ។

◆ មិត្តស៊ូ ជាសមាជិកតំបន់ ត្រូវពលិកម្មឆ្នាំ១៩៦៧ដោយខ្មាំងវាចាប់បាន ។ ពេលនោះភូមិភាគបានចាត់តាំងឲ្យមកបង្កប់កសាងមូលដ្ឋានបន្ថែកនៅស្ទឹងត្រង់ខាងលើ ក្នុងតំបន់៣១ ។

◆ ភូមិភាគបានចាត់តាំង មិត្តវ៉ា ធ្វើជាសមាជិកតំបន់៣០ថែមទៀត ដើម្បីបង្កើនក្បាលម៉ាស៊ីនដឹកនាំ ។ មិត្តវ៉ា ត្រូវខ្មាំងចាប់ពេលធ្វើកុប្បកម្មនៅសាលាស្រុកព្រៃឈរដើម្បីរំដោះមិត្តមួយចំនួនដែលខ្មាំងវាចាប់ ។ មិត្តវ៉ា ត្រូវខ្មាំងវាកម្ទេចក្នុងឆ្នាំ១៩៦៧ ។ បញ្ជាក់ៈ វ៉ា នេះមិនមែន វ៉ា ហៅ កេត ទេ ។

**២) តំបន់៣១**

តំបន់នេះមានស្រុកកំពង់សៀម ស្ទឹងត្រង់ ចំការលើ បារាយណ៍ តាំងគោក ។ គណៈកម្មាធិការតំបន់មានសមាជិកដូចតទៅ÷

១) មិត្តកន ហៅ គឹត ធ្វើលេខាតំបន់ ទទួលស្រុកចំការលើ ស្ទឹងត្រង់

២) កេត ហៅ លឿន ចាត់តាំងជាអនុលេខា ទទួលស្រុកបារាយណ៍ តាំងគោក

៣) ឈាង កសិករ ហៅ សាធ ជាសមាជិកតំបន់ ធ្វើលេខាស្រុកកំពង់សៀម

◆ មិត្តឈាង (សាធ) ឲ្យធ្វើជាលេខាស្រុកកំពង់សៀម ព្រោះជាមូលដ្ឋានចាស់របស់គាត់ជិតនាន់វាយបារាំង ។

◆ មិត្តពក ធ្វើលេខាតំបន់នេះក្នុងរយៈកាលតស៊ូនយោបាយ និងសង្គ្រាមផ្ទៃក្នុង ។

◆ រូបខ្ញុំ (ឌឿន) បានទទួលធ្វើលេខាតំបន់នេះនៅឆ្នាំ១៩៧០-១៩៧១ ក្នុងសង្គ្រាម៥ឆ្នាំ

**៣) តំបន់៣២**

តំបន់នេះមានខេត្តកំពង់ធំទាំងមូល ដកស្រុកបារាយណ៍និងតាំងគោកចេញ ។

**សម្គាល់**

◆ តំបន់ថ្មីនេះគ្មានមូលដ្ឋានបដិវត្តដូចតំបន់ផ្សេងៗទេ ។ ម្យ៉ាងទៀត នៅឆ្ងាយពីការដឹកនាំ ដោយមូលហេតុតំបន់នេះនៅឆ្ងាយពីកន្លែងមិត្តលេខាភាគរស់នៅ ។ ដូច្នេះការដឹកនាំមិនបានដិតដល់ដូចជាតំបន់ផ្សេងៗ ។ មិត្តគុណ លេខាភូមិភាគ ត្រូវក្តាប់តំបន់នេះផ្ទាល់ដើម្បីជំរុញការងារឲ្យបានរហ័ស ។ នេះក្នុងរយៈកាលតស៊ូនយោបាយ ។

### ៤) តំបន់៣៥

តំបន់នេះមានខេត្តសៀមរាប-ឧត្តរមានជ័យ ។

គណៈកម្មាធិការតំបន់នេះមានសមាជិក ÷

១) មិត្តថេង ហៅ ពក ធ្វើជាលេខាតំបន់

២) មិត្តសុទ្ធ ធ្វើជាអនុលេខា

៣) មិត្តសាយ ធ្វើជាសមាជិកតំបន់ (មិត្តសាយ ជាទាហានខ្មែរបង្កប់ខាងអង្គការក្រុង)

**សម្គាល់**

◆ កាលពីតស៊ូនយោបាយ ភាគមានទិសកសាងតំបន់នេះ តែដោយនៅឆ្ងាយក្តាប់សភាពការណ៍មិនបាន ការកសាងមិនសម្រេចតាមសំណូមពរ ។ ឆ្នាំ១៩៦៦-៦៧ ភូមិភាគបានបញ្ជូនដោយសម្ងាត់នូវកម្មាភិបាលម្នាក់ឈ្មោះ ថាច់ ញ៉ើង ទៅបង្កប់ធ្វើការបានមួយរយៈត្រូវបែក ខ្មាំងវាចាប់បានយកទៅសម្លាប់នៅក្រុងសៀមរាប ។ ពេលនោះខ្មាំងធ្វើការរាតត្បាតធ្វើឲ្យបាក់ស្មារតីមហាជនចំរើននិងអ្នកមានសមានចិត្តចំពោះបដិវត្ត ។ តាំងពីពេលនោះមក តំបន់នេះមិនបានជំរុញការកសាងទៀតទេ ព្រោះខ្វះកម្មាភិបាលទៅទទួលកន្លែងនេះ ។

◆ ចាប់ពីក្រោយរដ្ឋប្រហារមក នៅឆ្នាំ១៩៧១ ភូមិភាគបានចាត់តាំងគណៈកម្មាធិការមួយមាន មិត្តពក ជាលេខា និងមានកម្លាំងយោធាមួយអនុសេនាធំឡើងទៅ តំបន់នេះធ្វើការឃោសនាអប់រំមហាជន ហើយចាត់តាំងរដ្ឋអំណាចបានចាប់ពីពេលនោះមក ។ ក្នុងនេះមាន មិត្តស៊ាន មកពីនិរតីម្នាក់ដែរ ។

◆ ចំពោះ មិត្តសាយ គាត់ជាទាហានដែលបក្សចាត់តាំងបង្កប់ក្នុងជួរខ្មាំងពេលសង្គ្រាមផ្ទៃក្នុង គាត់ចេញទៅខាងនិរតីដើមឆ្នាំ១៩៧១ បក្សដកពីនិរតីយកមកឲ្យភាគ៣០៤ ព្រោះ ៣០៤ខ្វះកម្មាភិបាល ។ ដូច្នេះគាត់ជាកម្មាភិបាលខ្មែរទីក្រុងភ្នំពេញ ។

◆ ចំពោះ មិត្តស៊ាន ក៏អង្គការដកពីនិរតីបញ្ជូនមក៣០៤ ៣០៤ឲ្យទៅខាងសៀមរាបជាមួយ សមមិត្តពក ក្នុងឋានៈជាកម្មាភិបាលរបស់តំបន់ ឲ្យជួយទទួលខាងយោធា ។

### ៥) តំបន់២៩

តំបន់នេះមានទីក្រុងកំពង់ចាមនិងមូលដ្ឋានទៅជាយក្រុងនេះ ។

គណៈកម្មាធិការតំបន់នេះមានសមាជិក ÷

១) មិត្តបាន (ខៀន) ធ្វើជាលេខាតំបន់ ទទួលភារៈកសាងមូលដ្ឋានជាយក្រុង ។

២) មិត្តស៊ុំ (ឡេង ប៊ុនសុង) ជាសមាជិក ទទួលខាងចលនាយុវជន

៣) មិត្តទឹន ជាអនុលេខាតំបន់ ទទួលខាងការងារអនុធនទីក្រុង និងជួយកសាងមូលដ្ឋានជាយក្រុង

**សម្គាល់**

◆ ភូមិភាគចាត់តាំងឲ្យខ្ញុំធ្វើលេខាតំបន់ក្រុងនេះ ព្រោះរូបខ្ញុំមិនទាន់បែកខ្មាំងមិនដឹង ដូច្នេះងាយស្រួលធ្វើដំណើរទាក់ទងគ្នា ម្យ៉ាងទៀតខ្ញុំមានភារៈទាក់ទងជាមួយអង្គការខាងលើខ្មែរទីក្រុងភ្នំពេញ ។

◆ ចំពោះ មិត្តទឹន ជាសមាជិកភូមិភាគ គាត់នៅបង្រៀនក្រុងកំពង់ចាមដែរ ដូច្នេះភូមិភាគចាត់តាំងចូលមកក្នុងគណៈក្រុង ដោយគាត់មានភារកិច្ចសំខាន់ចលនាអនុធននៅក្នុងទីក្រុងកំពង់ចាម ។ ព្រមជាមួយនេះ ជួយកសាងមូលដ្ឋានជនបទជាយៗក្រុង ។ មួយរយៈក្រោយមក មិត្តទឹន ត្រូវបែក ខ្មាំងតាមដានខ្លាំង ។ បក្សសម្រេចដកឲ្យចូលសម្ងាត់ ហើយឲ្យទៅនៅតំបន់៣០ដោយទទួលជាលេខាតំបន់នេះជំនួស ស្រេង ខ្វះៗផង ។ ឯមិត្តស៊ុំ ត្រូវដកពីតំបន់៣០ឲ្យទៅខាង៣១វិញ ។ សូមបញ្ជាក់ថា នៅឆ្នាំ ១៩៦៧ មិត្តទឹន ធ្វើជាលេខាតំបន់៣០ បានដឹកនាំប្រជាជនតស៊ូទៅវាយរំដោះមិត្តយើងពីសាលាស្រុកព្រៃឈរ ជាហេតុធ្វើឲ្យខ្មាំងចាប់បានស្ទើរទាំងអស់ ។ មហាជនមានការតក់ស្លុតយ៉ាងខ្លាំងពេលនោះ ។ នៅឆ្នាំ១៩៦៩ ពេលសង្គ្រាមផ្ទៃក្នុង គាត់ត្រូវពលិកម្មក្នុងពេលប្រយុទ្ធជាមួយខ្មាំងដែលធ្វើការរាតត្បាត ។

◆ មិត្តស៊ុំ បានបំផុសចលនាយុវជនក្រុងកំពង់ចាម ពិសេស

នៅវិទ្យាល័យបានផុលផុសល្អ តាមរយៈនេះ បានកសាងស្នូលជាយុវជនស្ម័គ្រចិត្តលះបង់បានជាច្រើន។ ឆ្នាំ១៩៦៨ នៅថ្ងៃប្រកាសធ្វើកុប្បកម្មនៅភាគឧត្តរ គឺថ្ងៃទី ៣០-៤-៦៨ ដើម្បីវាយដណ្តើមអាវុធពីខ្មាំង ពេលនោះគាត់បានធ្វើសកម្មភាពនេះដោយផ្ទាល់ដៃ ត្រូវខ្មាំងវាចាប់បានហើយត្រូវពលិកម្មក្នុងគុក។

### ៦) តំបន់១៣០

តំបន់នេះចាត់តាំងជាពិសេសសំរាប់ធ្វើជាមូលដ្ឋានបផ្អែករបស់ភូមិភាគឧត្តរ។ តំបន់នេះតូច មនុស្សតិច ជាតំបន់ដាច់ស្រយាល សម្បូរដោយព្រៃ ប្រជាជនភាគច្រើនក្រីក្រ។ តំបន់នេះមានស្រុកសន្ទុកខាងលើ សង្កាត់បឹងល្វា សូដេត កាំបិត និងស្រុកស្ទឹងត្រង់ខាងលើ (តំបន់ជាប់ព្រៃ) មានសង្កាត់សំរោង។

១) មិត្តយ៉ន (គ្រូបង្រៀន) ហៅ លន់ ធ្វើជាលេខាតំបន់ ទទួលសំរោង

២) មិត្តវ៉ាន់ (កសិករ) ហៅ ងីន ធ្វើជាអនុលេខា ទទួលនៅសូដេត កាំបិត

៣) មិត្តឈុន នារី (ឈ្មោះដើមមិនដឹង) ធ្វើជាសមាជិក ទទួលសង្កាត់បឹងល្វា

៤) មិត្តសាន (ឈ្មោះដើមមិនចាំ) ធ្វើជាសមាជិក ទទួលសេដ្ឋកិច្ចនិងពាណិជ្ជកម្ម

**សម្គាល់**

◆ តំបន់នេះកសាងឡើងដើម្បីការពារមន្ទីរភាគ ព្រោះភាគសង់មន្ទីរក្នុងដីតំបន់នេះ។

◆ នៅដើមឆ្នាំ១៩៧១ លេខាតំបន់នេះត្រូវដកទៅធ្វើជាអនុលេខាតំបន់៣២។ មិត្តងីន ត្រូវចាត់តាំងជាលេខាតំបន់នេះជំនួសវិញ។

II. រយៈកាលពីឆ្នាំ១៩៧២-១៩៧៣

ក្នុងរយៈកាលនេះ ភូមិភាគ៣០៤បានកែប្រែភូមិសាស្ត្រតំបន់ និងបន្ថែមបន្ថយសមាជិកខ្លះតម្រូវតាមសេចក្តីត្រូវការរបស់ភូមិភាគនិងតំបន់។

### ១) តំបន់៣០

តំបន់នេះមានស្រុកព្រៃឈរ ជើងព្រៃ (ស្គន់) ពាមជីកង (កងមាស) កំពង់សៀម។

គណៈកម្មាធិការតំបន់នេះមានសមាជិក÷

១) មិត្តលាន (ឈ្មោះមែនទែនមិនចាំ) សិស្សថ្នាក់ទី៣ ជាលេខាតំបន់ ទទួលជាលេខាក្រុងកំពង់ចាម និងលេខាស្រុកកំពង់សៀម

២) មិត្តមាស (កសិករ) ឈ្មោះដើមមិនចាំ ធ្វើលេខាស្រុកព្រៃឈរ

៣) មិត្តតាំង (កសិករ) ឈ្មោះដើមមិនចាំ ធ្វើជាសមាជិកតំបន់ និងទទួលធ្វើលេខាស្រុកពាមជីកង

៤) មិត្តសោរ (កសិករ) ឈ្មោះដើមមិនចាំ ជាសមាជិក និងជាលេខាស្រុកជើងព្រៃ

**សម្គាល់**

◆ ក្នុងរយៈកាលនេះ មិត្តស្រេង មានធ្វើជាលេខាតំបន់នេះដែរ តែក្នុងរយៈកាលខ្លីទេ។ គាត់ត្រូវភូមិភាគដកឲ្យទៅធ្វើការខាងសេនាធិការភូមិភាគវិញ។

◆ មិត្តលាន ជាលេខាតំបន់នេះ មិនទាន់ចូលជាសមាជិកភាគទេ។

◆ ដោយស្រុកពាមជីកងសំបូរពួកស្រទាប់លើ ហើយមានមនុស្សច្រើន ភាគបានដក មិត្តសុទ្ធ (ភាគខាងជើង) ដែលជាលេខាស្រុកសណ្តាន់នៃតំបន់៣២ ឲ្យមកធ្វើជាលេខាស្រុកនេះវិញ ព្រោះ មិត្តតាំង ខ្វះខាតការពិសោធន៍ដឹកនាំការងារស្រុក ខ្វះពិសោធន៍ធ្វើការងារជាមួយពួកស្រទាប់លើ ដូច្នេះធ្វើឲ្យពួកនេះវាធ្វើសកម្មភាពអុកឡុករដ្ឋអំណាច នាំឲ្យប៉ះពាល់ឥទ្ធិពលដល់បដិវត្តមួយកម្រិត។ តាមរយៈនេះក៏ខ្មាំងធ្វើសកម្មភាពបំបាក់បំបែកបំផុសជាសង្គ្រាមចិត្តសាស្ត្រជាច្រើន។ ពេលមិត្តសុទ្ធ មកក្តាប់ស្រុកនេះទើបដោះស្រាយបញ្ហាទាំងនេះបានធូរស្រាល។ ពេលនោះ មិត្តតាំង ត្រូវដកមកជាកម្មាភិបាលរបស់តំបន់វិញ។

◆ ក្នុងរយៈកាលនេះ តំបន់៣០មានការស្មុគស្មាញជាងតំបន់ផ្សេងៗ ព្រោះតំបន់នេះនៅជាប់នឹងខ្មាំងទាំងអស់។ មានតែស្រុកពាមជីកងមួយដែលរំដោះទាំងស្រុង។ ដោយតំបន់នេះមានខ្មាំងនៅឡើយ សភាពការណ៍មិនសូវល្អឲ្យយើងទេ។ សង្គ្រាមចិត្តសាស្ត្រនិងសន្តិសម្ព័ន្ធលេចឮរាល់ថ្ងៃ នាំឲ្យប្រជាជនច្របូក

ច្របល់ជាច្រើន ។ នេះជាបញ្ហាពិបាកឲ្យយើងកន្លងមក ។

**២) តំបន់៣១**

តំបន់នេះមានស្រុកស្ទឹងត្រង់ ចំការលើ ព្រៃកប្រសប់ បារាយណ៍ តាំងគោក ។ គណៈកម្មាធិការតំបន់មានសមាជិក÷

១) មិត្ត គីក គឹមអុន (សិស្សថ្នាក់ទី១) ហៅ ហុន ជាលេខាតំបន់ ទទួលធ្វើជាលេខាស្រុកចំការលើ តាំងគោក

២) មិត្តសាធ ជាអនុលេខា ទទួលធ្វើជាលេខាស្រុកស្ទឹងត្រង់

៣) មិត្តសាយ ជាសមាជិក ទទួលជាលេខាស្រុកព្រែកប្រសប់

**សម្គាល់**

◆ មិត្តធុច ត្រូវក្តាប់តំបន់នេះផ្ទាល់ ព្រោះ មិត្តហុន ជាលេខា មិនទាន់មានលក្ខណៈសម្បត្តិគ្រប់គ្រាន់នឹងធ្វើជាលេខា ហើយម្យ៉ាងទៀត ហុន មិនទាន់បានចូលជាសមាជិកភូមិភាគផង ។

◆ ហុន បានប្រព្រឹត្តល្មើសនឹងសីលធម៌របស់បក្ស ដោយរំលោភនារីជាច្រើន ធ្វើឲ្យច្របូកច្របល់ផ្ទៃក្នុង ភាគបានសម្រេចដាក់វិន័យដោយបណ្តេញចេញពីបក្សឲ្យទៅជាមហាជនធម្មតា ។

◆ ស្រុកព្រែកប្រសប់ អង្គការសម្រេចកាត់ផ្តាច់មកខាងភាគ៣០៤ ព្រោះភូមិសាស្ត្រនិងការនិយមប្រាស្រ័យទាក់ទងគ្នារបស់ប្រជាជនច្រើនទាក់ទងខាងកំពង់ចាមជាងឡើងទៅខាងក្រចេះ តំបន់៥០៥ ។

◆ តំបន់៣១ជាតំបន់សំបូរជាងគេនៅក្នុងភាគ៣០៤ សំបូរទាំងស្រូវនិងបន្លែផ្លែឈើ ដំណាំឧស្សាហកម្ម ពិសេសតំបន់នេះមានចំការកៅស៊ូធំល្វឹងល្វើយ មានចំការចេកធំៗជាច្រើន ។ ដីក្រហមមានជីជាតិល្អណាស់ អនុគ្រោះឲ្យកសិកម្មយ៉ាងខ្លាំង ពិសេសខាងដំណាំឧស្សាហកម្ម ។

◆ ចំពោះ មិត្តតុល អង្គការឲ្យទទួលស្រុកបារាយណ៍ ព្រោះជាមូលដ្ឋានចាស់របស់គាត់តាំងពីសម័យតស៊ូនយោបាយមក ដូច្នេះគាត់ក្តាប់សភាពការណ៍បានងាយស្រួលក្នុងការដឹកនាំ ។

◆ តំបន់នេះភូមិភាគកំណត់ត្រូវកសាងឲ្យរឹងប៉ឹងល្អសម្រាប់ធ្វើជាបង្អែកដល់តំបន់ផ្សេងៗក្នុងភូមិភាគ ម្យ៉ាងទៀតត្រូវការពារដល់មូលដ្ឋានបង្អែករបស់ភាគ និងការពារមន្ទីរដឹកនាំរបស់ភាគផង ព្រោះតំបន់នេះជាមាត់ទ្វារចេញចូលទៅមន្ទីររបស់ភាគ ។ ឆ្នាំ១៩៧២-១៩៧៣ ភាគបានមកធ្វើមន្ទីរនៅតាមចំការ តាមភូមិប្រជាជនឈប់នៅក្នុងព្រៃហើយ ។

**៣) តំបន់៣២**

តំបន់នេះមានស្រុកបារាយណ៍ សន្ទុក សណ្តាន់ កំពង់ស្វាយ ស្ទោង ។ គណៈកម្មាធិការតំបន់មានសមាជិកទាំងអស់÷

១) មិត្តកាន់ ធ្វើជាលេខាតំបន់ មិនក្តាប់ស្រុកទេ

២) មិត្តលន់ ធ្វើជាអនុលេខា ទទួលស្រុកកំពង់ស្វាយ

៣) មិត្ត តាន់ ទ្រី សាស្ត្រាចារ្យ ហៅ ឈឿន ជាសមាជិកតំបន់ ទទួលក្តាប់ស្រុកស្ទោង

៤) មិត្តហេន គ្រូបង្រៀន ហៅ ហង់ ជាសមាជិក ធ្វើជាលេខាស្រុកសណ្តាន់

៥) មិត្តវ៉ា (ឈ្មោះដើមមិនស្គាល់) ជាសមាជិកតំបន់ ទទួលជាលេខាស្រុកសន្ទុក

៦) មិត្តសាន់ អាចារ្យបាលី ហៅ ងួន ជាសមាជិកតំបន់ ធ្វើជាលេខាស្រុកបារាយណ៍

**សម្គាល់**

◆ស្រុកបារាយណ៍ជាស្រុកនៅក្នុងខេត្តកំពង់ធំ តាមភូមិសាស្ត្រ ស្រុកនេះលយចូលមកខាងកំពង់ចាម ។ ដូច្នេះ ដើម្បីងាយស្រួលដឹកនាំ ភូមិភាគបានដកបញ្ចូលស្រុកនេះទៅក្នុងតំបន់៣១វិញ ។ ពេលនោះភូមិភាគបានយក មិត្តតុល មកធ្វើជាលេខាស្រុកនេះ ហើយដក មិត្តងួន ទៅធ្វើជាលេខានៅតំបន់១៣០វិញ ។

◆ ចំពោះខេត្តកំពង់ធំ និយាយរួមជាមូលដ្ឋានថ្មី គ្មានមូលដ្ឋានបដិវត្តន៍ចាស់ទេ មានតែស្រុកបារាយណ៍មួយដែលភូមិភាគកាត់មកខាងតំបន់៣១ ។ ពីសម័យនយោបាយក៏មិនបានកសាងមូលដ្ឋាននៅជនបទដែរ បានកសាងនៅតាមសាលារៀនខ្លះ តាមអនុវិទ្យាល័យខ្លះ ដូចជាអនុវិទ្យាល័យកំពង់ធំ ស្ទោង ជាដើម ។ ចាប់តាំងពីរដ្ឋប្រហារមក ឆ្នាំ១៩៧០-១៩៧១ ភាគបានបញ្ជូនកម្មាភិបាលនិងកងទ័ពមកក្តាប់តំបន់នេះ មាន មិត្តកែវ (ជូរ), មិត្តសារឿន មកពីភាគខាងជើង, មិត្តសុទ្ធ, មិត្តសាតុំ មកពីជើង, និង មិត្តឈឿន មិត្តស្រ៊ុន ទាំងអស់គ្នាបានមកកាន់តំបន់នេះ ហើយរៀបចំរដ្ឋអំណាចបន្តបន្ទាប់ ដោយមានការប្រយុទ្ធគ្នាជាមួយវៀតណាមនិងពួក អាសាមិត ផង ។ ដល់ដើមឆ្នាំ១៩៧១ សភាពការណ៍ក្នុងតំបន់បាននឹងនជាទូទៅ ។

◆ នៅស្រុកសណ្តាន់ដែលជាស្រុកឆ្ងាយដាច់ពីគេ ពួកអាយុត ឧត្តម បានទៅបោះទីតាំងនៅស្រុកនេះ ប្រកាសថាវាជារណសិរ្សរួបរួមជាតិ ឲ្យប្រជាជនឧបត្ថម្ភគាំទ្រវា វាបោកប្រាស់ប្រជាជនមួយរយៈខ្លី ។ ពេលនោះ ភូមិភាគបានបញ្ជូន មិត្តហង្ស និងយុទ្ធជនមួយក្រុម ទៅធ្វើការស្រុកនេះមុនកន្លែងផ្សេងៗ ។ ធ្វើបានមួយរយៈខ្លី ប្រជាជនទទួលស្គាល់ហើយឧបត្ថម្ភគ្រឹកគគ្រេង ពួក អាយុត ត្រូវឯកោរត់ចេញពីស្រុកសណ្តាន់ទៅនៅខាងស្ទោងនិងកំពង់ក្តីតំបន់៣៥វិញ ។

◆ ក្នុងរយៈកាល១៩៧១-៧៣ ខ្ញុំបានរៀបចំតំបន់ដោយមានការផ្លាស់ប្តូរលេខាស្រុកខ្លះ ពេលនោះបានដក មិត្តវ៉ា ចេញពីស្រុកសន្ទុក ព្រោះ មិត្តវ៉ា មិនចូលចិត្តការងារមូលដ្ឋាន ដោយខ្លួនគាត់ខ្វះការពិសោធន៍ធ្វើការមូលដ្ឋាន ។ វ៉ា ត្រូវឲ្យទៅធ្វើការខាងសេនាធិការភាគ ហើយដក មិត្តហង្ស ពីសណ្តាន់មកធ្វើជាលេខាស្រុកសន្ទុកវិញ ព្រោះ ហង់ មានជំហរដឹកនាំការងារមូលដ្ឋានល្អបង្គួរ យល់ការងារនេះច្រើន ។ ឯស្រុកសណ្តាន់ដែលជាស្រុកតូចហើយរៀបចំរដ្ឋអំណាចស្រួលបួលហើយ ក៏សម្រេចឲ្យ មិត្តសុទ្ធ មកពីភាគខាងជើង ធ្វើលេខាស្រុកនេះ ក្រោយមកដកសុទ្ធ ទៅពាមជីកង (តំបន់៣០) ។ ចាត់តាំងឲ្យ មិត្តសែ មកពីជើង ធ្វើលេខាបន្តទៀត ។ ក្រោយមក អង្គការបានណែនាំឲ្យបន្ថយពួកមកពីក្រៅកុំឲ្យកាន់កាប់ការងារមូលដ្ឋាន ពេលនោះដក មិត្តសែ ពីស្រុកសណ្តាន់ ដាក់ មិត្តអ៊ីន ជាអនុលេខា ធ្វើជាលេខាស្រុកជំនួសវិញ ។

## ៤) តំបន់៣៥

តំបន់នេះមានខេត្តសៀមរាបនិងឧត្តរមានជ័យ ។

គណៈកម្មាធិការតំបន់នេះមានសមាជិក÷

១) មិត្តផេង ហៅ ពក ធ្វើជាលេខាតំបន់

២) មិត្តសុទ្ធ ធ្វើជាអនុលេខា និងធ្វើលេខាស្រុកជីក្រែង

៣) មិត្តសាយ ធ្វើជាសមាជិក និងធ្វើលេខាស្រុកសូទ្រនិគម

៤) មិត្តសេង ធ្វើជាសមាជិក និងធ្វើលេខាស្រុកពួក

៥) មិត្តអឿន ធ្វើជាសមាជិក និងធ្វើលេខាស្រុកស្វាយលើ

៦) មិត្តឿង ធ្វើជាសមាជិក និងធ្វើលេខាស្រុកវ៉ារិន

៧) មិត្តវ៉ាន់ ធ្វើជាសមាជិក និងធ្វើលេខាស្រុកក្រឡាញ់

៨) មិត្តប៊ុន ធ្វើជាសមាជិក និងធ្វើលេខាស្រុកអន្លង់វែង

**សម្គាល់**

◆ មិត្តពួក ចេញពីតំបន់៣៥ នៅក្នុងឆ្នាំ១៩៧៣ មកទទួលធ្វើជាលេខាសេនាធិការភាគ ដល់រវាងពាក់កណ្តាលឆ្នាំ១៩៧៤ អង្គការខាងលើសម្រេចឲ្យ យួន ទៅទទួលសេនាធិការនិងគ្រប់គ្រងកងទ័ពភាគ ហើយដក មិត្តពក ឲ្យទៅធ្វើជាលេខាតំបន់៣៥វិញ ។ ពេល មិត្តពក ទៅធ្វើនៅសេនាធិការ មិត្តសុទ្ធ ត្រូវតែងតាំងជាលេខាតំបន់១០៦រហូតដល់ពាក់កណ្តាលឆ្នាំ១៩៧៤ ។

◆ ពេល មិត្តសុទ្ធ ឡើងជាលេខាតំបន់១០៦ មិត្តសេង ត្រូវចាត់តាំងជាអនុលេខាតំបន់ ។

◆ មិត្តសាយ ជាសមាជិកតំបន់ ត្រូវអង្គការភាគដកចេញពីតំបន់១០៦ ដោយហេតុអស់ឥទ្ធិពលដឹកនាំនៅក្នុងស្រុក ហើយគោលជំហរមិនរឹង បើទុកឲ្យនៅតទៅទៀតនាំឲ្យខូចដល់មូលដ្ឋាន ។

◆ មិត្តអឿន បានប៉ះពាល់សីលធម៌ជាមួយនារី ភាគសម្រេចដកឈប់ឲ្យធ្វើលេខាស្រុក ឈប់ឲ្យធ្វើការងារមូលដ្ឋាន ។

◆ នៅក្នុងរយៈកាលនេះ តំបន់១០៦មិនទាន់ក្តាប់ខេត្តឧត្តរមានជ័យបានទេ ។ គ្រាន់តែក្តាប់សភាពការណ៍បានរួមៗប៉ុណ្ណោះ ។

## ៥) តំបន់១៣០

តំបន់នេះមានសង្កាត់បឹងល្វា សូដេត កាំបិត និង សំរោង ។

គណៈកម្មាធិការតំបន់មានសមាជិក÷

១) មិត្តងួន លេខាតំបន់ ទទួលក្តាប់សង្កាត់បឹងល្វានិងសំរោង

២) នារី សំអាត គ្រូបង្រៀន ហៅ វ៉ែន ជាអនុលេខាទទួលក្តាប់សង្កាត់សូដេត កាំបិត

៣) សាន សមាជិក ទទួលការងារសេដ្ឋកិច្ចនិងពាណិជ្ជកម្ម

**សម្គាល់**

◆ ក្នុងរយៈកាលនេះ ភាគបានដកមន្ទីរចេញពីតំបន់១៣០ហើយ ។ ដូច្នេះតំបន់នេះស្ងប់ស្ងាត់ មិនអ៊ូអរដូចឆ្នាំមុនៗទេ ព្រោះពុំមានកម្មាភិបាលចុះឡើងឆ្លងកាត់ដូចពេលមុនៗ ។

◆ ការជំរុញបង្កបង្កើនផលដើម្បីកែប្រែមុខមាត់តំបន់នេះក៏មិនប្លែកអ្វីដែរ ។



◆ ង្វួន ភាគដកយកមកឲ្យធ្វើលេខានៅតំបន់នេះ ដោយគោលជំហរដឹកនាំរបស់គាត់មិនរឹង មានជំហរបក្សពួកនិយម គ្រួសារនិយម ដោយមានកម្មសិទ្ធិនេះក្រាស់ពេក ហើយសកម្មភាពមិនល្អបន្តបន្ទាប់ ភាគឈប់ឲ្យធ្វើលេខាស្រុកធំៗ ឲ្យមកកាន់កាប់តំបន់១៣០វិញ ព្រោះមូលដ្ឋាននេះងាយស្រួលតាមដាន ត្រួតពិនិត្យនិងកសាងផង ។

III. រយៈកាលពីឆ្នាំ១៩៧៣-៧៥

**១) តំបន់៣០**

តំបន់នេះមានស្រុកកំពង់សៀមក្រោម ពាមជីកង ព្រៃឈរ ជើងព្រៃ និងមូលដ្ឋានក្រុងកំពង់ចាម ។ គណៈកម្មាធិការតំបន់មានសមាជិក÷

១) មិត្តស្រេង ត្រូវជ្រើសតាំងជាលេខាតំបន់ និងទទួលមូលដ្ឋានក្រុងផង

២) មិត្តងឹន ជាអនុលេខា ទទួលធ្វើជាលេខាស្រុកពាមជីកង

៣) មិត្តមាស សមាជិក ទទួលធ្វើជាលេខាស្រុកព្រៃឈរ

៤) មិត្តសៀន ឈ្មោះដើម អយ កសិករ សមាជិក ទទួលធ្វើជាលេខាស្រុកកំពង់សៀម

៥) មិត្តង្វួន កសិករ ហៅ សោរ សមាជិក ទទួលធ្វើជាលេខាស្រុកជើងព្រៃ

៦) មិត្តសាន ឈ្មោះដើមមិនចាំ សមាជិក ទទួលខាងសេដ្ឋកិច្ច

**សម្គាល់**

◆ មិត្តស្រេង ត្រូវដកពីសេនាធិការមកទទួលតំបន់៣០វិញ ព្រោះខ្វះកម្មាភិបាលដឹកនាំ ដោយ មិត្តលាន ជាលេខាតំបន់ត្រូវពលិកម្ម ។ ការដករូប មិត្តស្រេង មកកាន់តំបន់៣០ ព្រោះគាត់ធ្លាប់ក្តាប់តំបន់នេះតាំងពីដើមមក ម្យ៉ាងទៀតក៏មិនចាំបាច់ទុកគាត់នៅខាងសេនាធិការដែរ ព្រោះ មិត្តពក គាត់ទទួលការងារនេះបានហើយ ។

◆ មិត្តសុទ្ធ ជាលេខាស្រុកពាមជីកង ត្រូវពលិកម្មដោយរោគប្រចាំកាយ ។ មិត្តងឹន ត្រូវធ្វើជាលេខាស្រុកនេះបន្តទៅទៀត ។

◆ សភាពការណ៍តំបន់៣០មិនដូចរយៈកាលមុនទេ ព្រោះអស់ខ្មាំងពីផ្លូវលេខ៧និងទីរួមស្រុកទីប្រជុំជនដូចជា ត្រើង ព្រៃទទឹង ស្គន់ ដូវ បាធាយ តាំងគោក ដូច្នេះខ្មាំងនៅតែទីក្រុងកំពង់ចាមប៉ុណ្ណោះ ។

**២) តំបន់៣១**

តំបន់នេះមានស្រុកបារាយណ៍ ចំការលើ តាំងគោក ស្ទឹងត្រង់ ព្រែកប្រសប់ ។ គណៈកម្មាធិការតំបន់មានសមាជិក÷

១) មិត្តគុល ជាលេខាតំបន់ ទទួលជាលេខាស្រុកស្ទឹងត្រង់

២) មិត្តគាម អនុលេខា ទទួលជាលេខាស្រុកចំការលើ តាំងគោក

៣) មិត្តទឹម សមាជិក ទទួលជាលេខា ស្រុកបារាយណ៍

៤) មិត្តវ៉ែន ហៅ មឿង ជាអាចារ្យ ធ្វើជាសមាជិក ទទួលលេខាស្រុក ព្រែកប្រសប់

**សម្គាល់**

◆ បងសាធ ភាគដកពីមូលដ្ឋានយកមកឲ្យទទួលចំការកៅស៊ូរបស់ភាគ ។

◆ ហុន លេខាតំបន់ចាស់ ប៉ះពាល់សីលធម៌ជាមួយនារី ត្រូវ

ភាគដាក់វិន័យដកសិទ្ធិពីបក្សជនឲ្យនៅជាមហាជនធម្មតា ។

◆ មិត្តវ៉ែន ខ្វះជំហរដឹកនាំទទួលខុសត្រូវ ខ្វះការពិសោធន៍ ធ្វើការងារមូលដ្ឋានដោយធ្វើការមិនកើត ភាគសម្រេចដកយកមកនៅមន្ទីរភាគវិញ ។ ភាគបានចាត់តាំង មិត្តឡឿ កសិករ ជាអនុលេខា ធ្វើជាលេខាស្រុកនេះតែម្តង ។

◆ ចំពោះស្រុកតាំងគោកឲ្យនៅជាមួយចំការលើសិន ដោយមាន គាម ជាអ្នកដឹកនាំរួម ។

◆ ឃួន ត្រូវក្តាប់តំបន់នេះផ្ទាល់ ។ កន្លងមក ឃួន បានយកចិត្តទុកដាក់កសាងគណៈតំបន់នេះ តែដោយសមាសភាពមិនល្អ កសាងមិនចំរើន ។

◆ គាម ជាមនុស្សមកពីភាគខាងជើង ប៉ុនប្រសប់អែបអបនឹង ឃួន ។ ឃួន ក៏ស្នើឲ្យធ្វើលេខាស្រុកចំការលើ និងជាអនុលេខាតំបន់៤២ ក្រោយមកបក្សបានឲ្យដកចេញហើយភាគដក រួចប្រគល់ឲ្យទៅធ្វើការខាងចំការកៅស៊ូវិញ ។

### ៣) តំបន់៣៧

តំបន់នេះមានស្រុកសន្ទុក កំពង់ស្វាយ សណ្តាន់ ស្ទោង ។

គណៈកម្មាធិការតំបន់មានសមាជិក ÷

១) មិត្តកាន់ ជាលេខាតំបន់

២) មិត្តលន់ ជាអនុលេខា ទទួលធ្វើជាលេខាស្រុកស្ទោង

៣) មិត្តសារុន សិស្ស ហៅ ស្រុន ទទួលធ្វើជាលេខាស្រុកកំពង់ស្វាយ

៤) មិត្តអ៊ុន កសិករ ឈ្មោះដើមមិនចាំ ទទួលធ្វើជាលេខាស្រុកសណ្តាន់

៥) មិត្តហង់ ជាសមាជិក ទទួលធ្វើជាលេខាស្រុកសន្ទុក

៦) មិត្តនារី យុន ជាសមាជិក ទទួលការងារនារី

**សម្គាល់**

◆ ភាគបានដកស្រុកបារាយណ៍បញ្ចូលទៅក្នុងតំបន់៣១វិញ ។

◆ នៅក្នុងខែ៦-៧៤ ភាគបានដករូបខ្ញុំចេញពីតំបន់ ហើយឲ្យមកទទួលការងារសេដ្ឋកិច្ចនិងពាណិជ្ជកម្មរបស់ភាគ៣០៤ ។

◆ ភាគបានដក មិត្តសេង ពីតំបន់៣៥ មកធ្វើជាលេខាតំបន់៣៧វិញ ។

◆ មិត្តលន់ ជាអនុលេខា ត្រូវដកឲ្យទៅជួយខាងតំបន់៣៥ (ខាងឧត្តរមានជ័យ) ពិសេសឲ្យធ្វើការឃោសនាកៀងគរប្រជាជននៅកន្លែងនេះឲ្យមកខាងបដិវត្ត ។

◆ មិត្តអ៊ុន លេខាស្រុកសណ្តាន់ ត្រូវឡើងជាអនុលេខាតំបន់ជំនួស មិត្តលន់ ។

### ៤) តំបន់៣៥

តំបន់នេះមានខេត្តសៀមរាបនិងឧត្តរមានជ័យ ។

គណៈកម្មាធិការតំបន់មានសមាជិក ÷

១) មិត្តសុទ្ធ ទទួលធ្វើជាលេខាតំបន់ មិនក្តាប់ស្រុកណាទេ

២) មិត្តកេង ធ្វើជាអនុលេខា និងទទួលធ្វើលេខាស្រុកជីក្រែង

៣) មិត្តសេង ធ្វើជាសមាជិក ទទួលធ្វើលេខាស្រុកពួក

៤) មិត្តរឿង ធ្វើជាសមាជិក ទទួលធ្វើលេខាស្រុកក្រឡាញ់

៥) មិត្តវ៉ាន់ ធ្វើជាសមាជិក ទទួលធ្វើលេខាស្រុកវ៉ារិន

៦) មិត្តនឿន ធ្វើជាសមាជិក ទទួលធ្វើលេខាស្រុកស្វាយលើ

៧) មិត្ត ញ៉ែម នឿន គ្រូបង្រៀន ហៅ យឿន ធ្វើជាសមាជិក ទទួលធ្វើលេខាស្រុកសូទ្រនិគម

៨) មិត្តស៊ុន ធ្វើជាសមាជិក ទទួលការងារធម្មការ

៩) មិត្តស៊ាន ធ្វើជាសមាជិក ទទួលសេដ្ឋកិច្ចពាណិជ្ជកម្ម

**សម្គាល់**

◆ ក្នុងរយៈកាលនេះ មិត្តពក មានទទួលធ្វើជាលេខាតំបន់៣៥ខ្លះដែរ ។

◆ មិត្តលន់ ដកពីអនុលេខាតំបន់៣៧មកធ្វើជាសមាជិកតំបន់៣៥ ហើយត្រូវប្រគល់ភារកិច្ចឲ្យទទួលខុសត្រូវនៅខាងឧត្តរមានជ័យ ។

◆ មិត្តសុទ្ធ ជាលេខាតំបន់នេះ ត្រូវភាគដកឲ្យឈប់ធ្វើលេខាតំបន់ ហើយចាត់តាំងមកទទួលការងារសេដ្ឋកិច្ចពាណិជ្ជកម្មរបស់ភាគចាប់ពីរវាងខែ១-១៩៧៤ ដល់ខែ៥-១៩៧៥ ។ ចាប់ពីខែ៥-១៩៧៥ទៅ មិត្តសុទ្ធ ទៅធ្វើលេខាតំបន់១០៦ ជំនួស មិត្តពក វិញ ដោយ មិត្តពក អង្គការសម្រេចឲ្យធ្វើជាលេខាភាគ៣០៣ ។

◆ មិត្តពក ភាគបានដកពីតំបន់៣៥ឲ្យមកទទួលសេនាធិការរបស់ភាគរហូតដល់ពាក់កណ្តាលឆ្នាំ១៩៧៤ ។ នៅចុងឆ្នាំ១៩៧៤ ភាគបានចាត់តាំងឲ្យមកទទួលធ្វើជាលេខាតំបន់១០៦វិញ ព្រោះ

ការងារយោធាបក្សប្រគល់ឲ្យលេខាភាគក្តាប់និងដឹកនាំការប្រយុទ្ធគឺ ឃួន ទទួលខុសត្រូវ ។

### ៤) តំបន់១៣០ត្រូវផ្លាស់ទៅជាតំបន់៣៣

តំបន់នេះមានស្រុក១៣០ (តំបន់១៣០ចាស់) ស្រុកព្រែកប្រសប់ និងស្រុក៦៥ (ព្រែកសង្កែ) ។

គណៈកម្មាធិការតំបន់មានសមាជិក÷

១) មិត្តឈឿន លេខាតំបន់ និងធ្វើជាលេខាស្រុក៦៥ផង

២) មិត្តអ៊ុន អនុលេខា និងធ្វើជាលេខាស្រុកព្រែកប្រសប់

៣) មិត្តវ៉ែន សមាជិក និងធ្វើជាលេខាស្រុក១៣០

៤) មិត្តសាន សមាជិក ទទួលខុសត្រូវសេដ្ឋកិច្ច

**សម្គាល់**

◆ភាគបានសម្រេចបញ្ចូលស្រុកព្រែកប្រសប់ជាមួយតំបន់១៣០និងស្រុក៦៥ដើម្បីបង្កើតតំបន់ថ្មីមួយទៀតមានឈ្មោះតំបន់«៣៣» ។ ការបញ្ចូលស្រុក៦៥ជាមួយស្រុកព្រែកប្រសប់និងស្រុក១៣០ជាមួយគ្នា ដើម្បីឲ្យជួយយោងដល់គ្នាទៅវិញទៅមក ពិសេសស្រុកព្រែកប្រសប់ត្រូវជួយដល់ស្រុក១៣០ ។

IV. *រយៈកាលពីខែ៤-៧៥ ដល់ខែ២-៧៧*

### ១) តំបន់៤១

តំបន់នេះមានស្រុកព្រៃឈរ កំពង់សៀម ពាមជីកង ជើងព្រៃ បាធាយ ។ គណៈកម្មាធិការតំបន់មានសមាជិក÷

១) មិត្តតាំង ធ្វើជាលេខាតំបន់ និងធ្វើលេខាស្រុកព្រៃឈរ

២) មិត្តសឿន ធ្វើជាអនុលេខា និងធ្វើលេខាស្រុកកំពង់សៀម

៣) មិត្តមាស ធ្វើជាសមាជិក និងធ្វើលេខាស្រុកពាមជីកង

៤) មិត្តសុប ធ្វើជាសមាជិក និងធ្វើលេខាស្រុកជើងព្រៃ

៥) មិត្តសោរ ធ្វើជាសមាជិក និងធ្វើលេខាស្រុកបាធាយ

៦) មិត្តសាន ធ្វើជាសមាជិក ទទួលបន្ទុកសេដ្ឋកិច្ច

៧) មិត្តខាន់ ធ្វើជាសមាជិក គណៈយោធា

**សម្គាល់**

◆ មិត្តស្រេង អតីតលេខាតំបន់៤១ ត្រូវអង្គការដកមកឲ្យប្រចាំការ នៅមន្ទីរភាគ ។

◆ មិត្តតាំង ជាលេខាស្រុកពាមជីកង ត្រូវជ្រើសតាំងជាលេខាតំបន់៤១ជំនួស ស្រេង ។ មិត្តតាំង ខ្វះខាតគោលជំហរដឹកនាំការពិសោធន៍ផ្សេងៗ ដូច្នេះបក្សត្រូវឲ្យ ស្រេង ជួយដឹកនាំជាប្រយោលមួយរយៈ ។

### ២) តំបន់៤២

តំបន់នេះមានស្រុកព្រែកប្រសប់ ស្ទឹងត្រង់ ចំការលើ បារាយណ៍ តាំងគោក ។ គណៈកម្មាធិការតំបន់មានសមាជិក÷

១) មិត្តគុល ជាលេខាតំបន់ (សមាជិកភាគពេញសិទ្ធិ) ទទួលស្រុកចំការលើ

២) មិត្តបួន អនុលេខា និងជាលេខាស្រុកចំការលើ

៣) មិត្តចន សមាជិក និងជាលេខាស្រុកបារាយណ៍

៤) មិត្តអឿន សមាជិក និងជាលេខាស្រុកស្ទឹងត្រង់

៥) មិត្តជីវ សមាជិក និងជាលេខាស្រុកតាំងគោក

៦) មិត្តអ៊ុន សមាជិក និងជាលេខាស្រុកព្រែកប្រសប់

**សម្គាល់**

◆ ក្រោយជ័យជំនះទាំងស្រុង ស្រុកព្រែកប្រសប់ត្រូវដកមកចូលតំបន់៤២វិញ ។

◆ មិត្តចន លេខាស្រុកបារាយណ៍ ត្រូវភាគចាត់តាំងឲ្យធ្វើលេខាតំបន់៤៣ជំនួស ងីន ។ ដោយ មិត្តងីន ភាគ៣០៣ សម្រេចដកពីលេខាតំបន់៤៣ឲ្យមកទទួលកសិកម្មភាគ ។

◆ បងបួន ជាលេខាតំបន់ និងជាលេខាស្រុកចំការលើ ត្រូវភាគដកឲ្យមកជាកម្មាភិបាលតំបន់វិញ ជួយការងារតំបន់ទូទៅ ។ ម្យ៉ាងគាត់ចាស់ហើយ សមត្ថភាពដឹកនាំការងារធំៗគាត់ពុំសូវមានការពិសោធន៍ ។

◆ មិត្តសួរ ភាគយកមកធ្វើលេខាស្រុកបារាយណ៍ជំនួសមិត្តចន ដែលត្រូវឡើងជាលេខាតំបន់៤៣ ។ មិត្តសួរ ជាមនុស្សឱកាសនិយម ភាគមានទិសដកចេញវិញ ។

◆ មិត្តអឿន លេខាស្រុកស្ទឹងត្រង់ សីលធម៌មិនល្អ ដូច្នេះពុំសូវមានឥទ្ធិពលក្នុងផ្ទៃក្នុងទេ ។

### ៣) តំបន់៤៣

តំបន់នេះមានស្រុកសន្ទុក កំពង់ស្វាយ សណ្តាន់ ស្ទោង ។

គណៈកម្មាធិការតំបន់មាន÷

១) មិត្តចន ជាលេខាតំបន់

២) មិត្តស៊ុន អនុលេខា ទទួលជាលេខាស្រុកស្ទោង

៣) មិត្តកេង សមាជិក ទទួលជាលេខាស្រុកកំពង់ស្វាយ

៤) មិត្តសោម សមាជិក ទទួលជាលេខាស្រុកសន្ទុក

៥) មិត្តប៉ាន សមាជិក ទទួលជាលេខាស្រុកសណ្តាន់

៦) មិត្តម៉ុម សមាជិកតំបន់ ទទួលជាលេខាគណៈកម្មាធិការសេដ្ឋកិច្ច

**សម្គាល់**

◆ ចាប់ពីចុងឆ្នាំ១៩៧៤ដល់ខែ៦-៧៥ មិត្តសេង ទទួលធ្វើជាលេខាតំបន់៤៣ ។

◆ ចាប់ពីខែ៦-៧៥ ដល់ដើមឆ្នាំ១៩៧៦ មិត្តងឹន បានទទួលការតែងតាំងពីភូមិភាគ៣០៣ ឲ្យទទួលជាលេខាតំបន់៤៣ជំនួស មិត្តសេង ដែលត្រូវភូមិភាគដកចេញ ។

◆ ចាប់ពីដើម១៩៧៦មក មិត្តចន បានត្រូវភូមិភាគ ៣០៣ចាត់តាំងជាលេខាតំបន់៤៣រហូតមកដល់សព្វថ្ងៃ ។ មិត្តងឹន ត្រូវភូមិភាគដកចេញឲ្យទៅទទួលខាងកសិកម្មរបស់ភាគវិញ ។

**សេចក្តីបញ្ជាក់ផ្សេងៗ**

◆ ចាប់តាំងពីក្រោយថ្ងៃ ១៧ មេសា ១៩៧៥ បក្សបានដកតំបន់សៀមរាប-ឧត្តរមានជ័យ ចេញពីភូមិភាគ ៣០៣ ។

◆ តំបន់សៀមរាប-ឧត្តរមានជ័យត្រូវឡើងមកអង្គការខាងលើ ។

◆ មិត្តសេង ជាអតីតលេខាតំបន់៤៣ ត្រូវ យួន ដកមកភ្នំពេញទុកនៅក្រសួងពាណិជ្ជកម្មរួចមកប្រគល់ជូនអង្គការ ។

**ក) តារាងចាត់តាំងក្រសួងនានារបស់ភូមិភាគឧត្តរ**

១) ក្រសួងកសិកម្មៈ មិត្តងឹន លេខាក្រសួង ។

២) ក្រសួងឧស្សាហកម្មៈ មិត្តវ៉ា លេខាក្រសួង, មិត្តកែវ អនុលេខាក្រសួង ។

៣) ក្រសួងសាធារណការៈ មិត្តវឹម លេខាក្រសួង ។

៤) ក្រសួងពាណិជ្ជកម្មៈ មិត្តពូល លេខាក្រសួង ។

៥) ក្រសួងសុខាភិបាលៈ មិត្តជិត លេខាក្រសួង ។

**ឯកសារ D១៥៧២៦**

## វេទិកាថែរក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

មជ្ឈមណ្ឌលឯកសារកម្ពុជានិងសមាគមអ្នកនិពន្ធខ្មែរនឹងរៀបចំកម្មវិធី "វេទិកាថែរក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ" លើកទី២ ចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៤ ដល់ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៥ ។ កម្មវិធីនេះសូមអំពាវនាវដល់សិស្ស និស្សិត ប្រជាជនកម្ពុជា និងអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ដែលកំពុងរស់នៅទាំងក្នុងនិងក្រៅប្រទេស ឲ្យសរសេរអត្ថបទស្តីអំពីរឿងរ៉ាវរបស់ខ្លួននៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ព័ត៌មានទាំងឡាយស្តីអំពីរបបកម្ពុជាប្រជាធិបតេយ្យដែលលោកអ្នកបានដឹងឮ និងទស្សនៈផ្ទាល់ខ្លួនចំពោះរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីរួមចំណែកចងក្រងប្រវត្តិសាស្ត្រនៃរបបនេះឲ្យកាន់តែពិស្តារ ។

វេទិកានេះមានគោលបំណងសំខាន់ៗដូចតទៅ÷

◆ រួមជាចំណែកថែរក្សាប្រវត្តិសាស្ត្រទុកសម្រាប់កូនចៅជំនាន់ក្រោយឲ្យបានដឹងនិងសិក្សារៀនសូត្រ ។

◆ ជាវិធីមួយដើម្បីរំងាប់អារម្មណ៍ដោយយកហេតុការណ៍សេចក្តីទុក្ខ ការវិងគុំកួន មកតម្កល់ជាឯកសារប្រវត្តិសាស្ត្រដើម្បីបម្រើដល់ការស្រាវជ្រាវតទៅអនាគត ។

◆ ការចងចាំគឺជាសន្តិវិធីមួយក្នុងការទប់ស្កាត់មិនឲ្យអំពើប្រល័យពូជសាសន៍កើតឡើងជាថ្មីម្តងទៀតនៅក្នុងសង្គមមនុស្ស ។

◆ ជួយដល់ការស្វែងរកយុត្តិធម៌ជូនដល់ប្រជាជនកម្ពុជាដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហម និងជួយលើកកម្ពស់ការគោរពសិទ្ធិមនុស្សនៅកម្ពុជា ។

ប្រធានបទខាងលើនេះតម្រូវឲ្យលោកអ្នកសរសេរបែបប្រវត្តិសាស្ត្រចាប់ពី១០ទំព័រឡើងទៅ ។ មជ្ឈមណ្ឌលឯកសារកម្ពុជានិងសមាគមអ្នកនិពន្ធខ្មែរនឹងមានកិត្តិយសចុះផ្សាយស្នាដៃរបស់លោកអ្នកនៅលើទំព័រទស្សនាវដ្តីស្វែងការរកការពិត ព្រមទាំងផ្តល់ថវិកាដល់ម្ចាស់អត្ថបទដែលនឹងត្រូវសរសេរបន្ថែមទៀតដើម្បីបោះពុម្ពជាសៀវភៅ ។ លោកអ្នកអាចផ្ញើអត្ថបទមកសមាគមអ្នកនិពន្ធខ្មែរ ដែលមានទីស្នាក់ការនៅវត្តបទុមវតី ឬប្រអប់សំបុត្រលេខ១១១០ ភ្នំពេញ ឬតាមរយៈអ៊ីម៉ែល dccam@online.com.kh ។

សូមទាក់ទងព័ត៌មានបន្ថែមតាមរយៈទូរស័ព្ទលេខៈ ០២៣ ២១១ ៨៧៥ ឬ ០១២ ៨៨៣ ០៧២ ។ សូមអរគុណ ។

# រឿងរ៉ាវ ហ៊ីម ម៉ាន ក្នុងរបបខ្មែរក្រហម

នៅខែកញ្ញា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានដាក់ការគាបសង្កត់យ៉ាងខ្លាំងក្លាទៅលើជនជាតិចាមក្នុងភូមិកោះផល ក្នុងគោលបំណងលុបបំបាត់សាសនាឥស្លាមតាមរយៈផែនការ“៥ ខ”គឺៈ ទី១) ស្ត្រីចាមត្រូវកាត់សក់ខ្លី និងឈប់ទទូរក្រមា ទី២) ប្រមូលគម្ពីរគីតាប-គួរអានទាំងអស់ដុតចោល ទី៣) បង្ខំឲ្យជនជាតិចាមចិញ្ចឹមជ្រូកនិងហូបសាច់ជ្រូក ទី៤) ហាមមិនឲ្យជនជាតិចាមសំយ៉ាងនិងបួស និងទី៥) បង្ខំឲ្យជនជាតិចាមរៀបការជាមួយជនជាតិខ្មែរ ។ អ្នកភូមិកោះផលមិនអាចទទួលយកផែនការទាំងនេះបានឡើយ ។ អ្នកភូមិបានប្រើប្រាស់កាំបិតនិងដាវជាអាវុធតបតយ៉ាងមោះមុតនឹងកងទ័ពខ្មែរក្រហមដែលមកបង្ក្រាបអ្នកភូមិ ។ ខ្មែរក្រហមបាញ់សម្លាប់អ្នកភូមិស្ទើរតែទាំងអស់ ។ មួយចំនួនដែលនៅសេសសល់ត្រូវបញ្ជូនឲ្យទៅស្លាប់ដោយជំងឺគ្រុនចាញ់នៅតាមតំបន់ព្រៃភ្នំ ។ បន្ទាប់មក ខ្មែរក្រហមបានដុតកម្ទេចភូមិទាំងមូល ហើយប្រែឈ្មោះពីភូមិកោះផលទៅជាភូមិកោះផេះវិញ ។

ចាប់តាំងពីពេលបះបោរនោះមក ខ្មែរក្រហមបានចាត់ទុកជនជាតិចាមជាជនមុខសញ្ញាខ្មាំងដែលត្រូវតែកម្ទាត់ចោល ។ មួយសប្តាហ៍ក្រោយពីបះបោរ ជនជាតិចាមទូទាំងប្រទេសត្រូវបានជម្លៀសដើម្បីបំបែកបំបាក់កម្លាំង ។ ទូរលេខ១៥ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៧៥ រាយការណ៍ដោយ “ឆុន” ផ្ញើជូនប៉ុល ពត បានបញ្ជាក់អំពីការអនុវត្តន៍បញ្ជាពីថ្នាក់មជ្ឈិមក្នុងការជម្លៀសប្រជាជនចាមចំនួន៥ម៉ឺននាក់ចេញពីភូមិភាគបូព៌ា ។ នៅក្នុងកំណត់ហេតុនៃការប្រជុំលេខាអនុលេខាកងពលនិងវរសេនាធំឯករាជ្យ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ១៩៧៦ សមមិត្ត “ពីន” ជាលេខាកងពល៧០៣ បានរាយការណ៍ជូនអង្គប្រជុំអំពីសកម្មភាពរបស់ជនជាតិចាមនៅភូមិស្រែចាម ខណ្ឌព្រៃនប់ (ក្រុងព្រះសីហនុ) ដែល “នាំគ្នាសំលៀងកាំបិតត្រៀមបះបោរ” ។ លើសពីនេះទៅទៀត នៅក្នុងសេចក្តីរាយការណ៍ប្រចាំសប្តាហ៍របស់គណៈកម្មាធិការតំបន់៥ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៧៧ ក៏បានរាយការណ៍អំពីការអនុវត្តន៍វិធានការពិសេសមួយនៅក្នុងការតាមរកម្ទេចចលនាជនជាតិចាមដែលតវ៉ាមិនព្រមហូបសាច់ជ្រូក គឺចាប់យកទៅសម្លាប់ចោល ។

នៅក្នុងកិច្ចប្រជុំមួយក្នុងឆ្នាំ១៩៧៨ សមមិត្ត កែ ពក លេខាភូមិភាគកណ្តាលបានប្រកាសឲ្យកម្មាភិបាលក្រោមបង្គាប់សម្លាប់ជនជាតិចាមឲ្យអស់ពីទឹកដីកម្ពុជានៅមុនឆ្នាំ១៩៨០ ។ ក្នុងការអនុវត្តគោលនយោបាយនេះឲ្យបានជោគជ័យ ខ្មែរក្រហមបានសម្លាប់ជនជាតិចាមគ្មានរើសមុខ ។ ទោះជាជនជាតិចាមខិតខំធ្វើការដើម្បីសម្របខ្លួនតាមបដិវត្តន៍យ៉ាងណាក៏ដោយ ក៏គ្រប់ជនជាតិចាមត្រូវបានចាត់ទុកជាខ្មាំងសត្រូវរបស់បដិវត្តន៍ដែលមិនអាចអត់ឱនឲ្យបាន ។ ក្នុងភូមិកំពង់ក្របី ស្រុកកំពង់សៀមដែលមុនឆ្នាំ១៩៧០មានប្រជាជនប្រហែល៦០០គ្រួសារ មកដល់ឆ្នាំ១៩៧៩នៅសល់តែ២០គ្រួសារប៉ុណ្ណោះ ហើយនៅភូមិចំនួនប្រាំមួយទៀតគឺ ភូមិកោះរកាមានប្រហែល៥០០គ្រួសារ ភូមិគគរមានច្រើនជាង៣០០គ្រួសារ ភូមិកោះប្រាក់មានច្រើនជាង១៥០គ្រួសារ ភូមិរអាងមានច្រើនជាង១០០គ្រួសារ ភូមិខ្វាវមានប្រហែល៤០គ្រួសារ និងភូមិចំការសាមសិបមានប្រហែល៣០គ្រួសារ ។ ខ្មែរក្រហមបានសម្លាប់ប្រជាជននៅក្នុងភូមិទាំងប្រាំមួយនេះស្ទើរតែទាំងអស់ ។ ក្នុងភូមិនីមួយៗនៅសេសសល់ប្រជាជនប្រមាណបួនប្រាំនាក់ប៉ុណ្ណោះ ហើយមិនអាចវិលត្រឡប់មករស់នៅក្នុងភូមិកំណើតវិញ ។ ភូមិទាំងអស់នេះបានបាត់បង់រហូតមកដល់សព្វថ្ងៃនេះ ។ ចំណែកស្រុកក្បែរគ្នា គឺស្រុកកងមាស ភូមិសាច់សូរ (តាស៊ូ) នៅមុនឆ្នាំ១៩៧០មានប្រជាជនចំនួន៤០០គ្រួសារ មកដល់ឆ្នាំ១៩៧៩នៅសល់៥០គ្រួសារ ភូមិពាម្រ (ស្វាយតាហែន) មានប្រជាជនប្រហែល២០០គ្រួសារ នៅសល់១៩គ្រួសារ ភូមិអន្ទុងសមានចំនួនច្រើនជាង៤០០គ្រួសារ នៅសល់ជិត១០០គ្រួសារ និងភូមិអង្គរបានមានចំនួន៥០០គ្រួសារ នៅសល់ជាង១០០គ្រួសារ ។

ប្រជាជនចាមដែលនៅសេសសល់បន្តិចបន្តួចនេះ គឺជាអ្នកដែលខ្មែរក្រហមបានជម្លៀសទៅខេត្តឆ្ងាយៗ ហើយបានលាក់

អត្តសញ្ញាណរបស់ខ្លួនតាមរយៈការផ្លាស់ប្តូរឈ្មោះ ឈប់និយាយភាសាចាម និងលះបង់ទំនៀមទម្លាប់ប្រពៃណីរបស់ខ្លួនទាំងស្រុង ។ ក្រុមគ្រួសារណាដែលខ្មែរក្រហមរកឃើញថាជាជនជាតិចាម ត្រូវប្រមូលយកទៅសម្លាប់ទាំងអស់តាំងពីមនុស្សចាស់ជរា អ្នកជំងឺ រហូតដល់ទារកទើបនឹងកើត ។ នៅក្នុងដំណើរស្រាវជ្រាវមួយនាពេលថ្មីៗនេះ យើងបានរកឃើញថា នៅក្នុងស្រុកកំពង់សៀមនិងកងមាសមានជនជាតិចាមតែប្រាំនាក់ប៉ុណ្ណោះ ដែលបានរួចជីវិតដោយការរត់គេចខ្លួន ។

ខាងក្រោមនេះគឺជារឿងរ៉ាវរបស់ជនជាតិចាមម្នាក់ឈ្មោះ ហ៊ឹម ម៉ាន ដែលបានរៀបរាប់អំពីរឿងរ៉ាវអ្នកភូមិនិងដំណើររឿងរបស់គាត់ដែលគេចខ្លួនពីការតាមសម្លាប់របស់ខ្មែរក្រហម÷


ហ៊ឹម ម៉ាន

ខ្ញុំកើតនិងរស់នៅក្នុងភូមិសាច់សូរនេះតាំងពីដើមមក ។ បងប្អូនចាមទម្លាប់ហៅភូមិនេះថាភូមិតាស៊ូ ។ ខ្ញុំមិនបានដឹងអំពីមូលហេតុនៃការហៅខុសគ្នានេះទេ ។ ភូមិចាមជាច្រើនទៀតក៏មានឈ្មោះពីរខុសគ្នាដែរ គឺឈ្មោះចាមមួយនិងឈ្មោះខ្មែរមួយ ។ កាលពីសម័យសង្គមរាស្ត្រនិយម ភូមិរបស់ខ្ញុំមានប្រជាជនប្រមាណ៤០០គ្រួសារ ប៉ុន្តែត្រូវខ្មែរក្រហមសម្លាប់ស្ទើរតែទាំងអស់ ។ នៅឆ្នាំ១៩៧៩ មានប្រជាជនតែប្រមាណ៥០គ្រួសារប៉ុណ្ណោះដែលនៅសេសសល់ពីការសម្លាប់ដោយរបបខ្មែរក្រហម ។ មកដល់សព្វថ្ងៃនេះ រាប់ទាំងគ្រួសារថ្មីចាស់ទាំងអស់មានប្រមាណ១០០គ្រួសារ គឺមិនទាន់ស្មើនឹងពាក់កណ្តាលនៃចំនួនចាស់នៅឡើយទេ ។

នៅឆ្នាំ១៩៧២ ខ្មែរក្រហមបានចូលមកគ្រប់គ្រងក្នុងភូមិរបស់ខ្ញុំ ។ នៅពេលនោះ ខ្មែរក្រហមបានលើកតម្កើងសាសនាឥស្លាមក៏ដូចជាសាសនាព្រះពុទ្ធដែរ ។ ខ្ញុំឮខ្មែរក្រហមប្រកាសថា សាសនាឥស្លាម សាសនាព្រះពុទ្ធ និងបដិវត្តន៍ មានមាគ៌ាដូចគ្នា ។ មកដល់ឆ្នាំ១៩៧៣ នៅពេលដែលប្រជាជនទាំងអស់ទុកចិត្តលើបដិវត្តន៍ខ្លាំងហើយ ខ្មែរក្រហមប្រែជាកាច់បំបាក់ជនជាតិចាមទៅវិញ ។ ខ្មែរក្រហមចាប់ផ្តើមប្រើល្បិចកលផ្សេងៗនៅក្នុងការផ្លាស់ប្តូរមាគ៌ារបស់ខ្លួន ។ កម្មាភិបាលជាន់ខ្ពស់របស់ខ្មែរក្រហមធ្វើល្បិចមកស្តីបន្ទោសប្រធានភូមិថា "ហេតុអ្វីបានជាមិនឲ្យប្រជាជនហូបឆ្អែត និងហើយហេតុអ្វីបានជារុះរើផ្ទះរបស់បងប្អូន ។ ប្រធានភូមិត្រូវទទួលខុសត្រូវក្នុងការលើកកម្ពស់ជីវភាពប្រជាជន និងសង់ផ្ទះថ្មីឲ្យបងប្អូនយើងវិញ" ។ ឮដូច្នោះ ប្រជាជននាំគ្នាត្រេកអរ ខ្លះបានចុះឈ្មោះនៅលើពាក្យបណ្តឹងមួយដើម្បីប្តឹងប្រធានភូមិ ។ បន្ទាប់មក អ្នកទាំងនោះត្រូវចាប់ខ្លួនយកទៅសម្លាប់ភ្លាមៗអំពីបទមិនពេញចិត្តនឹងបដិវត្តន៍ ។ នៅក្នុងឆ្នាំនេះដែរ ខ្មែរក្រហមបានជម្លៀសអ្នកភូមិខ្ញុំប្រហែល ២០គ្រួសារទៅខេត្តឆ្ងាយៗ ។ អ្នកទាំងនេះសុទ្ធតែជាអ្នកចេះដឹងនិងជាអ្នកដឹកនាំសាសនានៅក្នុងភូមិ ។

មកដល់ឆ្នាំ១៩៧៤ ខ្មែរក្រហមគាបសង្កត់យើងកាន់តែខ្លាំងឡើង ។ ខ្មែរក្រហមបានប្រកាសថា ចាមគឺជាខ្មាំងទី១ ខ្មែរគឺជាខ្មាំងទី២ ។ ខ្ញុំមិនដឹងថាតើជនជាតិចាមនិងខ្មែរបានធ្វើអ្វីខុសទើបត្រូវបានចាត់ទុកថាជាខ្មាំង ។ មនុស្សដែលត្រូវចាប់យកទៅសម្លាប់ចោលគឺសុទ្ធតែត្រូវចោទថាបានលួចនេះលួចនោះរបស់អង្គការ ។

នៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសអ្នកភូមិរបស់ខ្ញុំម្តងទៀត គឺជម្លៀសក្នុងបរិមាណដ៏ច្រើនសន្ធឹកសន្ធាប់ ។ មានតែប្រជាជន៣០គ្រួសារប៉ុណ្ណោះដែលមិនត្រូវជម្លៀស ។ ខ្មែរក្រហមមានបំណងបញ្ជូនជនជាតិចាមទៅឲ្យស្លាប់ដោយអត់បាយនិងជំងឺ រីឯអ្នកដែលនៅសេសសល់៣០គ្រួសារ មិនយូរមិនឆាប់ក៏គង់តែស្លាប់ឬត្រូវសម្លាប់ដូចតែគ្នា ។ ខ្មែរក្រហមធ្វើយ៉ាងនេះគឺចង់បំបែកកម្លាំងជនជាតិចាម ព្រោះថាបើទុកឲ្យនៅជុំគ្នាខ្លាចយើងតដៃដូចបងប្អូនចាមនៅភូមិកោះផល ។ ខ្ញុំឮថា ខ្មែរក្រហមបានយកម៉ារីនទៅព័ទ្ធភូមិកោះផល ហើយបាញ់កាំភ្លើងធំកម្ទេចភូមិ ប៉ុន្តែនៅតែមិនអាចបង្ក្រាបប្រជាជនចាមបាន ។ ចុងក្រោយខ្មែរក្រហមចាប់បានមេដឹកនាំសាសនាម្នាក់ ហើយធ្វើទារុណកម្មបង្ខំឲ្យគាត់ស្រែកបញ្ជាឲ្យអ្នកភូមិចុះចាញ់ ទើបអ្នកភូមិកោះផលទាំងអស់ព្រមទម្លាក់អាវុធចុះ ។ រួចហើយ ខ្មែរក្រហមបានដុតភូមិទាំងមូល រួចហៅថាភូមិកោះផេះវិញ ។

ក្រុមគ្រួសារខ្ញុំស្ថិតនៅក្នុងចំណោម៣០គ្រួសារ ។ បន្ទាប់មកខ្មែរក្រហមបានចាប់ផ្តើមបំបែកអ្នកទាំងអស់នេះជាបន្តទៀត យកទៅដាក់ពង្រាយស្ទើរគ្រប់ភូមិទូទាំងស្រុក ។ មានតែពីរគ្រួសារគត់ គឺគ្រួសារខ្ញុំនិងគ្រួសារអ្នកជិតខាងមួយទៀតដែលខ្មែរក្រហមអនុញ្ញាតឲ្យបន្តរស់នៅក្នុងភូមិដដែល ។ ក្នុងគ្រួសារខ្ញុំមានសមាជិកបីនាក់ គឺម្តាយខ្ញុំ ប្អូនប្រុសខ្ញុំ និងខ្ញុំ ។ ឪពុករបស់ខ្ញុំស្លាប់ដោយជំងឺតាំងពីឆ្នាំ១៩៧៣មកម៉្លេះ ។ ខ្មែរក្រហមបានឲ្យខ្ញុំរៀបការជាមួយនារីជនជាតិចាមម្នាក់ដែលជាប្រពន្ធរបស់ខ្ញុំសព្វថ្ងៃនេះ ។ ក្នុងថ្ងៃខ្ញុំការមាន៥០គូ ពីធីរៀបការគឺរៀបចំជាពិធីប្តេជ្ញាចិត្តតាមលក្ខណៈបដិវត្តន៍ ។

ខ្មែរក្រហមបានបំបិទសាសនា ។ សាសនាឥស្លាមគឺជាមុខព្រួញសំខាន់ក្នុងការកម្ចាត់ចោល ។ ខ្មែរក្រហមហាមដាច់ខាតមិនឲ្យជនជាតិចាមថ្វាយបង្គំព្រះ មិនឲ្យនិយាយភាសាចាម និងបង្ខំឲ្យហូបសាច់ជ្រូក ។ អ្នកដែលមិនព្រមអនុវត្តតាមត្រូវយកទៅសម្លាប់ចោល ។ ជារឿយៗ ខ្មែរក្រហមបានប្រកាសថា “នៅពេលនេះយើងគ្មានចាមគ្មានខ្មែរទៀតទេ យើងទាំងអស់គ្នាជាជាតិតែមួយ គឺជាតិខ្មែរ ដូច្នេះយើងត្រូវហូបចំណីតែមួយដូចគ្នា” ។ នៅពេលដែលមានម្ហូបធ្វើអំពីសាច់ជ្រូក ប្រធានក្រុមឬប្រធានសហករណ៍មិនបានឈរពិនិត្យមើលថាតើយើងហូបឬអត់នោះទេ ប៉ុន្តែស្ទើរតែទាំងអស់នៃប្រជាជនដែលនៅជុំវិញយើងក្នុងរោងបាយគឺជាខ្មែរក្រហម ។ ដោយហេតុថា អ្នកទាំងនោះចង់បានគុណសម្បត្តិខ្លួនឯងដើម្បីមានជីវិតរស់បន្តទៀត ដូច្នេះត្រូវតែរាយការណ៍អំពីកំហុសរបស់យើង ។ មិនយូរប៉ុន្មាន អ្នកទាំងនោះក៏ត្រូវយកទៅសម្លាប់ដូចគ្នា ។

ថ្ងៃមួយក្នុងឆ្នាំ១៩៧៨ ខ្មែរក្រហមបានប្រាប់ឲ្យបងប្អូនជនជាតិចាមទាំងអស់សម្រាកនៅផ្ទះរៀងៗខ្លួនមិនចាំបាច់ចេញទៅធ្វើការទេ ។ នៅលើផ្ទះដែលខ្ញុំនៅមានគ្នាបួននាក់គឺ ខ្ញុំ ប្រពន្ធខ្ញុំ ម្តាយ និងប្អូនប្រុសរបស់ខ្ញុំ ។ តាំងពីព្រឹកព្រលឹម បងប្អូនខ្មែរទាំងអស់ត្រូវប្រធានសហករណ៍ប្រាប់ឲ្យទៅធ្វើការឆ្ងាយៗពីភូមិ ។ ខ្ញុំចេះតែកើតការសង្ស័យអំពីរឿងនេះ ។ ម៉ោងប្រហែលបីរសៀល ខ្មែរក្រហមចាប់ផ្តើមប្រមូលយកជនជាតិចាមដែលនៅតាមផ្ទះនីមួយៗទូទាំងស្រុកកងមាស ។ ភាគច្រើននៃជនជាតិចាមទាំងនេះគឺជាអតីតអ្នកភូមិសាច់សូរ ភូមិអន្ទង់ស និងភូមិអង្គរបាន ដែលមានចំនួនរាប់រយនាក់ ។ អ្នកណាដែលខ្មែរក្រហមមើលទៅឃើញថាមានកម្លាំងកំហែងត្រូវចងស្លាបសេក ចំណែកស្ត្រី កូនក្មេង និងមនុស្សចាស់ ពួកវាមិនចងឡើយ ។ ខ្មែរក្រហមបណ្តើរប្រជាជនចាមទៅតាមផ្លូវថ្នល់ក្នុងភូមិ ដោយមានសន្តិសុខការពារសងខាងផ្លូវយ៉ាងប្រុងប្រយ័ត្ន ។ នៅពេលដែលក្បាលក្បួនមកដល់ផ្ទះរបស់ខ្ញុំ សន្តិសុខម្នាក់បានចូលមកហៅខ្ញុំចុះពីលើផ្ទះ ។ ខ្ញុំចុះទៅជាមួយប្រពន្ធ ម្តាយ និងប្អូនប្រុសរបស់ខ្ញុំ ។ សំណាងល្អដោយខ្មែរក្រហមមើលឃើញថាខ្ញុំហាក់ដូចជាគ្មានកម្លាំងនឹងរត់ ដូច្នេះខ្ញុំបានរួចខ្លួនពីការចង ។ ខ្ញុំឃើញអ្នកខ្លះដើរទាំងគ្មានពាក់អាវ ឬមានត្រឹមតែខោខ្លី ពីព្រោះខ្មែរក្រហមហៅចុះពីលើផ្ទះទាំងប្រញាប់ប្រញាល់ ។ ក្មេងតូចៗមួយចំនួនដែលបាត់ឪពុកម្តាយ បានរត់ប្រសាចឆ្អែឆ្អាពេញភូមិ ។ ខ្មែរក្រហមចាប់ជើងក្មេងៗទាំងនេះបោកនឹងគល់ឈើឬសសរផ្ទះសម្លាប់ចោល ។ ខ្មែរក្រហមបណ្តើរយើងសំដៅទៅវត្តអូរត្រកួនដែលជាកន្លែងសម្លាប់ ។

ខ្ញុំនិងប្រពន្ធរបស់ខ្ញុំដើរយ៉ាងលឿនសំដៅទៅខាងមុខក្បួន ។ ខ្ញុំគិតថា ខ្មែរក្រហមមុខតែសម្លាប់យើង ដូច្នេះមុននឹងស្លាប់ខ្ញុំត្រូវតែរត់ ។ នៅសល់ប្រហែល១០០ម៉ែត្រទៀតដល់វត្តអូរត្រកួន ខ្ញុំខ្សឹបប្រាប់ប្រពន្ធខ្ញុំឲ្យដឹងអំពីការសម្រេចចិត្តរបស់ខ្ញុំ ។ ប្រពន្ធខ្ញុំក៏យល់ព្រម ។ ឆ្លៀតពេលដែលសន្តិសុខធ្វេសប្រហែស ខ្ញុំនិងប្រពន្ធក៏រត់ចេញពីក្នុងក្បួន ។ សន្តិសុខមិនបានចាប់អារម្មណ៍នឹងយើងទាល់តែសោះ ។ យើងក៏ពួនសម្ងំនៅក្នុងគុម្ពោតព្រៃតូចមួយក្បែរនោះ ។ លុះដល់ពេលយប់ ខ្មែរក្រហមចាប់ផ្តើមសម្លាប់ប្រជាជនចាមទាំងអស់ដោយវាយនឹងដំបងឬសួរភូសៗ ។ ខ្ញុំមិនបានឃើញសកម្មភាពទាំងនេះដោយផ្ទាល់ភ្នែកទេ ប៉ុន្តែបានឮសម្រែក ហើយដឹងច្បាស់ថាពិតជាបងប្អូនចាម ពីព្រោះមុននឹងស្លាប់ ម្នាក់ៗស្រែកហៅព្រះអាឡាមកជួយស្រែករកម្តាយតាមភាសាចាម និងសម្រែកនៃការឈឺចាប់ផ្សេងៗទៀត ។ ក្នុងចំណោមនោះក៏មានម្តាយនិងប្អូនប្រុសរបស់ខ្ញុំដែរ ។ រហូតដល់ជិតភ្លឺទើបការសម្លាប់ចប់សព្វគ្រប់ ។ ខ្ញុំគិតថាខ្មែរក្រហមលែងយាមល្បាតហើយក្រោយពីបានបំពេញភារកិច្ច

របស់ខ្លួនចប់ ។ ខ្ញុំនិងប្រពន្ធក៏លួនចុះក្នុងទឹកបឹងមួយដែលនៅក្បែរនោះ ។

រយៈពេលបីខែនិងម្ភៃប្រាំបួនថ្ងៃគត់ដែលខ្ញុំពួននៅទីនោះ ។ នៅពេលថ្ងៃ យើងចុះក្នុងទឹក ហើយអើតក្បាលដកដង្ហើមតាមចន្លោះគុម្ពកំប្លោក ។ នៅពេលយប់ យើងឡើងមកដេកនៅលើមែកឈើតូចៗដែលដុះនៅមាត់បឹងនោះ ។ យប់ខ្លះភ្លៀងរលឹមទល់ភ្លឺ ។ រៀងរាល់យប់មានមនុស្សស្រមោកនៅលើខ្នងទំនប់ក្បែរកន្លែងដែលខ្ញុំពួន ។ ពេលដែលចង់កណ្តាស់ឬក្អក ខ្ញុំចុះមុជក្បាលចូលក្នុងទឹកយ៉ាងជ្រៅទើបហ៊ានកណ្តាស់ឬក្អក ។ បួនដប់ថ្ងៃដំបូង ខ្មែរក្រហមរាប់សិបនាក់ដើររកខ្ញុំជុំវិញបឹងនោះ ។ ពួកគេគិតថាខ្ញុំប្រាកដជាពួននៅទីកន្លែងនេះ ពីព្រោះបាត់ឈ្មោះពីក្នុងបញ្ជីសម្លាប់ ។ ពេលខ្លះពួកគេបាញ់កាំភ្លើងរះពេញក្នុងបឹង ។ គ្រាប់កាំភ្លើងរត់កាត់ក្បែរៗខ្ញុំ ។ ប្រពន្ធរបស់ខ្ញុំអស់សង្ឃឹម ហើយខ្សឹបប្រាប់ខ្ញុំថា «យើងគួរតែឡើងទៅសារភាព» ប៉ុន្តែខ្ញុំបដិសេធ ពីព្រោះបើសារភាពក៏គង់តែស្លាប់ ។ ខ្ញុំបានគេចពីកន្លែងមួយទៅកន្លែងមួយ ។ ពេលខ្លះឈ្លបខ្មែរក្រហមទៅកាប់ព្រៃនៅកន្លែងដែលខ្ញុំទើបតែចេញផុត ។

យើងគ្មានបាយមួយគ្រាប់ចូលពោះទាល់តែសោះ ។ រៀងរាល់ថ្ងៃ នៅពេលដែលខ្ញុំឮស្គរជួងហូបបាយ ខ្ញុំកាន់តែឃ្លានខ្លាំងឡើង ។ ទោះជារបបអាហារនៅក្នុងរោងសហករណ៍តិចតួចយ៉ាងណាក៏ដោយ ក៏គ្រាន់បើជាងរស់នៅក្នុងសភាពបែបនេះដែរ ។ នៅពេលដែលឃ្លានដល់កម្រិតមួយ ខ្ញុំស្រមៃឃើញបាយទាំងយប់ទាំងថ្ងៃ ។ ខ្ញុំគិតថា មុននឹងស្លាប់ឲ្យតែបានបាយមួយដុំប៉ុនកំភួនដៃខ្ញុំអស់ចិត្តហើយ ។ យូរៗម្តង ខ្ញុំចាប់បានកូនត្រីតូចៗ កង្កែប គីង្កក់ ក្តាម ពស់ កណ្តុរ និងរកបានខ្ចៅខ្យង យើងទំពាហូបទាំងឆៅ ។ មានថ្ងៃមួយ ខ្ញុំចាប់បានអន្ទង់ធំមួយ ហើយខាំហែកចែកគ្នាជាមួយប្រពន្ធទំពាហូប ប៉ុន្តែរសជាតិនៃអន្ទង់នោះឆ្អាបខ្លាំងណាស់ ។ ខ្ញុំក៏ក្អួតចេញមកវិញអស់ ។ ខ្ញុំយកចំណែកអន្ទង់ដែលនៅសល់ទៅដាក់ហាលថ្ងៃហាលសន្សើមពីរបីថ្ងៃរហូតទាល់តែស្អុយទើបខ្ញុំយកមកចែកគ្នាហូបម្តងទៀត ។ ខ្ញុំហូបត្រួយនិងផ្កាកំប្លោក និងក្រអៅឈូក ជាបន្លែ ។ ខ្ញុំមិនដែលនឹកខ្ពើមរអើមទាល់តែសោះ ។ បើថ្ងៃណាចាប់សត្វអ្វីហូបមិនបាន ខ្ញុំលួចមើលសត្វកណ្តុរ ។ នៅពេលដែលឃើញកណ្តុរស៊ីស្លឹកឬផ្លែរុក្ខជាតិណាមួយ ខ្ញុំក៏ហូបតាម ។

ចុងក្រោយ ខ្ញុំអត់ទ្រាំនឹងការស្រេកឃ្លានតទៅទៀតលែងបាន ខ្ញុំនិងប្រពន្ធក៏ដាច់ចិត្តចូលមកក្នុងភូមិនៅពេលយប់ដើម្បីលួចដំណាំរបស់សហករណ៍ ។ អ្នកភូមិឃើញខ្ញុំក៏ផ្អើលឆោឡោឡើង ។ គ្មានវិធីរត់គេចខ្លួនទៀតបានឡើយ ខ្មែរក្រហមចាប់បានខ្ញុំនិងប្រពន្ធរបស់ខ្ញុំ ។ ដោយសារតែខ្វះអ្នកបច្ចេកទេសស្លដែកធ្វើឧបករណ៍ប្រើប្រាស់ ខ្មែរក្រហមក៏ទុកខ្ញុំប្រើសិន ។ ប្រហែលពីរខែក្រោយមក មានបញ្ជាពីអង្គការថ្នាក់លើម្តងទៀតឲ្យបោសសម្អាតបំបាត់ពូជសាសន៍ចាមទាំងស្រុង ទោះបីអ្នកបច្ចេកទេសក៏ដោយ ។ ម្តងនេះខ្មែរក្រហមបានដឹកខ្ញុំនិងប្រពន្ធខ្ញុំរួមជាមួយអ្នកទោសបងប្អូនខ្មែរមួយចំនួនតាមកាណូតសំដៅយកទៅសម្លាប់នៅឯភូមិរាយប៉ាយ ។ ទើបតែចេញផុតពីមាត់ច្រាំងបានបន្តិច ម៉ាស៊ីនកាណូតរលត់លែងទៅមុខ ។ ភ្លាមៗនោះ កងទ័ពរណសិរ្ស និងវៀតណាមបានចូលមកដល់ ។ សន្តិសុខពីរបីនាក់ដែលនៅលើកាណូតបានលោតចុះទឹក ។ ខ្ញុំនិងប្រពន្ធខ្ញុំបានរួចផុតពីសេចក្តីស្លាប់តាំងពីពេលនោះរហូតមក ។

**អ៊ីសា ឧស្មាន**

## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាននិងកំពុងសរសេរអត្ថបទ ឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជា តាមអាសយដ្ឋានខាងក្រោមៈ

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

*Email: dccam@online.com.kh*

*Home page: www.dccam.org*

# ក្លាយជាស្ត្រីមេម៉ាយនៅកោះខ្សាច់ទន្លា



អ៊ុម ទូច

ខ្សាច់ទន្លាគឺជាឈ្មោះកោះមួយស្ថិតនៅក្នុងឃុំកោះខ្សាច់ទន្លា ស្រុកស្អាង ខេត្តកណ្ដាល ។ កោះនេះមានទំហំ៦គីឡូម៉ែត្រការ៉េ ។ នៅជុំវិញកោះសម្បូរទៅដោយដើមទន្លាដែលដុះនៅតាមមាត់ទឹក ។

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានប្រែឈ្មោះកោះនេះទៅជា «កោះស្ត្រីមេម៉ាយ» ពោលគឺសម្រាប់ដាក់ស្ត្រីមេម៉ាយដែលប្ដីត្រូវអង្គការយកទៅសម្លាប់ចោល ។ បន្ទាប់ពីរបបខ្មែរក្រហមត្រូវផ្ដួលរំលំ ស្ត្រីមេម៉ាយមួយចំនួននៅតែបន្តរស់នៅលើកោះនេះដដែល ។

អ៊ុម ទូច អាយុ៦២ឆ្នាំ រស់នៅលើកោះខ្សាច់ទន្លានេះ ។ ប្ដីរបស់គាត់ដែលជាអ្នករដ្ឋការនៅក្នុងរបបលន់ណុល ត្រូវអង្គការយកទៅសម្លាប់នៅឆ្នាំ១៩៧៥ ។

ទូច គឺជាកូនពៅក្នុងចំណោមបងប្អូនស្រីពីរនាក់ក្នុងត្រកូលក្រីក្រមួយនៅលើកោះ ។ ម្ដាយរបស់ ទូច បានស្លាប់ដោយជំងឺតាំងពី ទូច មានអាយុ១៤ឆ្នាំ ។ ទូច និងបងស្រី រស់នៅជាមួយឪពុកដែលដឹកស្រាស្រវឹងរាល់ថ្ងៃ ពុំរវីរវល់ចិញ្ចឹមកូនៗ ។ ទូច និងបងស្រី បានចាកចេញពីស្រុកកំណើតមកបម្រើការតាមផ្ទះនៅភ្នំពេញ ។ បងស្រីរបស់ ទូច បានទៅរស់នៅបម្រើគ្រួសារមួយក្បែរផ្សារច្បារអំពៅ ជាយក្រុងភ្នំពេញ ។ ចំណែក ទូច ត្រូវបងស្រីយកទៅឲ្យបម្រើនៅផ្ទះម្ដាយរបស់ចៅហ្វាយគាត់ដែលរស់នៅទីក្រុងភ្នំពេញ ។ ទូច បម្រើក្រុមគ្រួសារនេះមិនដែលឲ្យទាស់ចិត្តឡើយ ។ ដោយសារ ទូច មានរូបសម្បត្តិស្រស់ស្អាត កូនប្រុសរបស់ម្ចាស់ផ្ទះក៏បាក់ចិត្តស្រឡាញ់គាត់ ។

អ្នកទាំងពីរបានស្រឡាញ់គ្នាដោយលួចលាក់អស់រយៈពេលជិតមួយឆ្នាំទើបម្ដាយរបស់បុរសនោះដឹងរឿងនេះ ។ គាត់មិនទទួលស្គាល់ ទូច ជាកូនប្រសាទេ ប៉ុន្តែគាត់អនុញ្ញាតឲ្យ ទូច ធ្វើការនៅក្នុងផ្ទះរបស់គាត់ដដែល ។ ដោយខ្លាចមានទំនាស់រវាងម្ដាយនិងប្រពន្ធ ប្ដីរបស់ ទូច បានជួលផ្ទះមួយនៅដាច់ដោយឡែកពីម្ដាយ ។ ប្ដីរបស់ ទូច គឺជាស្មៀននៅសាលាក្រុង ។ អ្នកទាំងពីររួមរស់ជាមួយគ្នារហូតដល់បានកូនស្រីមួយអាយុ៣ខែ ។ ប្ដីរបស់ ទូច បានកុហកគាត់ថាទៅធ្វើការនៅតាមខេត្ត ប៉ុន្តែតាមពិតទៅរៀបការជាមួយនារីម្នាក់ទៀតនៅភូមិត្រើយស្លាតាមការផ្សំផ្គុំរបស់ម្ដាយ ។

ថ្ងៃមួយ ទូច បានទៅលេងបងស្រីនៅឯច្បារអំពៅ ហើយបានដឹងរឿងដែលប្ដីរបស់គាត់លួចទៅរៀបការ ។ ទូច បានសុំប្ដីលែងលះគ្នា ប៉ុន្តែប្ដីរបស់ ទូច មិនយល់ព្រម ហើយបានអង្វរករប្រពន្ធឲ្យជានាគ្នាវិញ ដោយសន្យាថាគាត់នឹងធានាចិញ្ចឹម ទូច អស់មួយជីវិត ។ ដោយសារប្ដីអង្វរករខ្លាំងពេក ទូច ក៏ព្រមព្រៀងជានាគ្នាវិញ ប៉ុន្តែសុំមករស់នៅកោះខ្សាច់ទន្លាជាមួយឪពុក ដើម្បីបានថែរក្សាគាត់ ។ ប្ដីរបស់ ទូច បានសង់ផ្ទះមួយខ្នងឲ្យប្រពន្ធកូននិងឪពុកក្មេក ហើយទិញម៉ាស៊ីនដេរនិងរបស់របរប្រើប្រាស់សព្វគ្រប់ដាក់ផ្ទះ ព្រមទាំងផ្ដល់ថវិកាដល់ប្រពន្ធជារៀងរាល់ខែ ។

នៅពេលដែលខ្មែរក្រហមបានបណ្ដេញប្រជាជនចេញពីទីក្រុងភ្នំពេញ ប្ដីរបស់ ទូច បានមករស់នៅជាមួយគាត់នៅលើកោះ ។ មិនបានប៉ុន្មានខែផង ខ្មែរក្រហមបានហៅប្ដីរបស់ ទូច ទៅរៀនសូត្រនៅភ្នំពេញ ។ ទូច រំឭកថា «គេថាយកទៅឲ្យរៀនសូត្រ ។ ខ្ញុំប្រាប់គាត់ថាឲ្យចេញពីហ្នឹងទៅ តែនៅហ្នឹងមុខជាគេហៅទៅបាត់ហើយ ព្រោះគេដឹងយើងធ្វើការ ។ គាត់ថាមិនអីទេ គេឲ្យទៅ

រៀនច្បាប់ មកវិញបានជួបកូនប្រពន្ធ ។ រួចគេយកទៅបាត់ទៅ ។ មុនចេញដំណើរ គាត់ផ្តាំថាបីខែទៀតគាត់នឹងត្រឡប់មកវិញ ។ គាត់ក៏បាត់ខ្លួនតាំងពីពេលនោះទៅ ។ ខ្ញុំសង្ស័យថា ទំនងជាគេយកគាត់ទៅសម្លាប់មិនផុតពីកោះនេះផង ។»

បន្ទាប់ពីខ្មែរក្រហមយកប្តីរបស់គាត់ទៅសម្លាប់ ទូច ត្រូវអង្គការចាត់តាំងឲ្យចូលកងវ័យចំណាស់ (កងស្ត្រីដែលគ្មានកូន ឬមានកូនធំ) ។ កងរបស់ ទូច ទៅច្រូតស្រូវនៅតំបន់ឆ្ងាយៗ ហើយមិនបានវិលមកសម្រាកនៅភូមិវិញឡើយ ។ បន្ទាប់ពីការងារច្រូតកាត់ ទូច ត្រូវធ្វើការងារផ្សេងទៀតដូចជា កិនស្រូវ ដាំអង្ករ រែងអង្ករ ។ កូនស្រីរបស់ ទូច ដែលមានអាយុ១៥ឆ្នាំ ត្រូវអង្គការបញ្ជូនចូលទៅក្នុងកងចល័តស្រួច ទៅវែកដីនៅទួលក្រសាំង ។ ទូច កម្របានជួបមុខកូនណាស់ ។ ទូច ប្រាប់ថា នៅពេលបាត់ដំណឹងកូនយូរពេក គាត់ចេះតែគិតផ្តេសផ្តាសថា កូនគាត់គ្មានជីវិតរស់ទេ ទោះបីជាអ្នកនៅក្នុងភូមិអះអាងថាបានឃើញកូនគាត់ក៏ដោយ ។ មានម្តងនោះ ទូច បានជួបកូនដែលមានរូបរាងស្គមស្គាំងមើលស្ទើរតែមិនស្គាល់ ។

នៅចុងឆ្នាំ១៩៧៧ ខ្មែរក្រហមបានជម្លៀសប្រជាជនទាំងអស់ចេញពីលើកោះ ទុកតែស្ត្រីប៉ុន្មាននាក់ប៉ុណ្ណោះរួមទាំង ទូច ផង ។ ខ្មែរក្រហមចាត់តាំងឲ្យ ទូច ធ្វើជាប្រធានរោងបាយ ។ នៅលើកោះនេះមានរោងបាយ៦ រោងបាយមួយមានចុងភៅ ១០នាក់ ។ ក្នុងចំណោមរោងបាយទាំង៦ រោងបាយរបស់ ទូច ល្បីថាដាំបាយឆ្ងាញ់ជាងគេ ។ គណៈស្រុកគណៈតំបន់តែងតែមកស្នើសុំបាយពីរោងរបស់គាត់ជាញឹកញាប់ ។

ទោះបីជាខ្មែរក្រហមចាត់តាំងឲ្យ ទូច ធ្វើជាប្រធានរោងបាយក៏ដោយ ក៏គាត់នៅតែពុំទាន់ត្រូវបានចាត់ទុកថាជាប្រជាជនពេញសិទ្ធិដែរ ពោលមានឋានៈត្រឹមតែជាប្រជាជនត្រៀមប៉ុណ្ណោះ ដោយហេតុថាគាត់ជាប់ពាក់ព័ន្ធជាមួយប្តីជាអ្នករដ្ឋការ ។ ម្ល៉ោះហើយ ទូច ស្ថិតនៅក្រោមការឃ្លាំមើលរបស់ប្រធានភូមិជាដរាប ។ ទូច បញ្ជាក់ថា «បើយើងធ្វើការល្អគេទុកទៀត បើធ្វើការមិនល្អគេដកចេញវិញចោល» ។ ក្រៅពីការងារដាំស្ល ទូច ត្រូវបររទេះទៅដឹកអង្ករ និងរកត្រកួនឬពោតបន្ថែមសម្រាប់ដាំលាយបាយឬបបរ ។

អង្គការបានស្នើឲ្យ ទូច រៀបការជាថ្មី ប៉ុន្តែគាត់បដិសេធ ។ ដោយសារតែការបដិសេធម្តងហើយម្តងទៀត ទូច ហៀបតែនឹងត្រូវខ្មែរក្រហមយកទៅសម្លាប់ចោល ប៉ុន្តែនៅពេលដែលកងទ័ពវៀតណាមចូលមកកម្ពុជានៅឆ្នាំ១៩៧៩ ទើប ទូច និងកូនបានរស់មកដល់បច្ចុប្បន្ននេះ ។ ទូច មិនបានចាកចេញពីកោះខ្សាច់ទន្លាទេ ។ គាត់បន្តរស់នៅជាមួយកូនស្រីនៅលើកោះនេះរហូត ហើយបានរៀបចំឲ្យកូនមានគូស្រករថែមទៀត ។ សព្វថ្ងៃកូនស្រី របស់ ទូច រស់នៅស្រុកកោះធំជាមួយក្រុមគ្រួសារ ។ ចំណែក ទូច មិនអាចធ្វើការធ្ងន់ឬធ្វើដំណើរទៅណាឆ្ងាយបានឡើយ ព្រោះឆ្អឹងខ្នងរបស់គាត់បាក់បណ្តាលមកពីធ្លាក់ពីលើដើមទឹកដោះគោកាលពីឆ្នាំ១៩៧៩ ។ គាត់រស់នៅជាមួយនឹងចៅប្រុសម្នាក់ក្នុងជីវភាពមធ្យម ។

**លី សុផល**

## ពន្យល់ពាក្យខ្មែរក្រហម

- **នាយទុនៈ** *អ្នកមានសម្បត្តិស៊ីចាយហូរហៀរមិនចេះខ្វះ ។*
  *(កំណត់ហេតុរបស់សមមិត្ត អ៊ីវ ពេជ្រ)*
- **នាយទុនកុំប្រាដរៈ** *គឺពួកនាយទុនធំៗដែលប្រមូលស្រូវ អង្ករ ពោត សណ្តែក ថ្នាំ និងផលិតផលឯទៀតៗនៅក្នុងស្រុក បញ្ជូនទៅលក់ក្រៅប្រទេសដែលវាមានខ្សែទាក់ទងជាមួយ ។*
- **នាយទុនជាតិៈ** *គឺជានាយទុនរកស៊ីក្នុងស្រុកខាងឧស្សាហកម្មក្តី ខាងពាណិជ្ជកម្មក្តី ខាងកសិកម្មក្តី ។ ប្រើប្រាស់វត្ថុធាតុដើម មធ្យោបាយពលកម្ម (កម្មករ) របស់ជាតិខ្លួន ហើយផលិតផលក្នុងប្រទេស ឬលក់ផលិតផលបន្តិចបន្តួចទៅក្រៅប្រទេស ។*
- **អនុធនបញ្ញាជនៈ** *សិស្ស និស្សិត អ្នករដ្ឋការ ដែលរស់នៅដោយប្រើប្រាជ្ញាជាសំខាន់ ។ ចំណុចសំខាន់របស់គេត្រង់ស្រលាញ់ជាតិ ស្រឡាញ់បដិវត្តន៍ ។*
  *(យុវជន-យុវនារីបដិវត្ត លេខពិសេសខែសីហា-កញ្ញា ១៩៧៤)*
- **អនុធនទីក្រុងៈ** *ជាកម្លាំងសម្ព័ន្ធមិត្តជិតស្និទ្ធរបស់កម្មករ-កសិករ ។ (កំណត់ហេតុលេខ ០៦៩)*

# គ្មានអ្វីអាចសងជីវិតបានទេ

នៅក្បែរជើងភ្នំ យាយ ស្រស់ ឌិន អង្គុយបាំងនឹងម្លប់ឫស្សីព្រៃមួយគុម្ពដំបំបែកថ្មឲ្យទៅជាដុំតូចៗ ។ នៅជិតគាត់គឺជាពំនូកថ្មដែលបានបំបែករួច ។ ក្រៅពីធ្វើស្រែចម្ការ ការដំថ្មលក់គឺជាមុខរបររបន្ថែមរបស់ យាយឌិន និងប្រជាជននៅក្នុងភូមិទ្រាជើងក្នុងឃុំទ្រា ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ។ ដើម្បីបានថ្មលក់ប្រជាជនត្រូវឡើងទៅដំបំបែកយកថ្មធំៗពីលើភ្នំ បន្ទាប់មករែកចុះមកក្រោម ហើយដំបំបែកឲ្យតូច ។ ភាគច្រើន បុរសៗជាអ្នកឡើងទៅបំបែកថ្មនៅលើភ្នំនិងរែកចុះមក ឯស្ត្រីនៅខាងក្រោមជាអ្នកដំ ។ ក្នុងរវាងពីរសប្តាហ៍ម្តង មានរថយន្តរបស់ក្រុមហ៊ុនសំណង់ទៅទិញបំណែកថ្មល្អិតៗទាំងនោះ ។ ថ្មដែលអ្នកស្រុកដំបានក្នុងរវាង១០ថ្ងៃឬកន្លះខែ លក់បានប្រហែល១ម៉ឺនរៀល ។ យាយឌិន មិនសូវបានធ្វើសស្រាក់សស្រាំដូចអ្នកដទៃទេ ។ គាត់អាចរកបានតែ៥ពាន់រៀលក្នុងរយៈពេលដូចគ្នា ។

យាយឌិន ចាប់កំណើតក្នុងគ្រួសារមួយដែលមានឪពុកជាតន្ត្រីករនៅក្នុងវង់ភ្លេងការ ។ ឪពុកម្តាយរបស់គាត់មានដើមកំណើតនៅឃុំព្រៃខ្មែរ ខេត្តកំពង់ឆ្នាំង ។ យាយមានបងប្អូនបីនាក់ ។ គាត់គឺជាកូនទីពីរ ។ ក្រៅពីការងារស្រែចម្ការ ឪពុករបស់យាយចេញទៅប្រគំភ្លេងនៅតាមរោងការ ។ នៅពេលដែលយាយទើបតែមានអាយុ៧ឬ៨ឆ្នាំ ឪពុករបស់គាត់បានស្លាប់ដោយជំងឺអាសន្នរោគ ។ អត់ពីឪពុកទៅ ម្តាយរបស់យាយលក់នំចំណីផ្លែឈើ ជួនកាលដេរស្លឹកលក់ ជួនកាលស៊ីឈ្នួលដកស្ទូងឲ្យអ្នកស្រុក ។ ប្រមាណ១០ឆ្នាំក្រោយមក ម្តាយរបស់យាយបានរៀបការប្តីថ្មី ហើយទៅរស់នៅជាមួយប្តីនៅស្រុកលើ ។ យាយមិនតាមម្តាយទៅរស់នៅស្រុកលើទេ ។ បងស្រីធំបង្អស់ដែលមានប្តីហើយក៏បែកផ្ទះនៅដោយឡែក ។ ចំណែកយាយនិងប្អូនប្រុសពៅ នៅជាមួយម្តាយមីងឈ្មោះ ណយ នៅស្រុកព្រៃខ្មែរដដែល ។ ក្រៅពីជួយធ្វើស្រែចម្ការរបស់ម្តាយមីង យាយស៊ីឈ្នួលដកស្ទូងឲ្យអ្នកភូមិផ្សេងទៀត ឬដេរស្លឹកលក់ ឬលក់នំចំណី ផ្លែឈើ ដើម្បីរកប្រាក់សន្សំទុកសម្រាប់ខ្លួនឯង ។ ក្នុងអំឡុងពេលនោះយាយនិងម្តាយទៅមកសួរសុខទុក្ខគ្នាមិនដែលដាច់ ។

នៅពេលដែល យាយឌិន មានអាយុ២៨ឆ្នាំ ម្តាយនិងមីងរបស់គាត់បានរៀបចំឲ្យគាត់មានប្តីជាអ្នកឡើងត្នោតនៅស្រុករលាប្អៀរ ។ អ្នកទាំងពីររស់នៅក្នុងជីវភាពជាអ្នកស្រែ រំពឹងលើដីស្រែដែលមានបន្តិចបន្តួចនិងរបរឡើងត្នោត ។ ប្តីរបស់យាយឡើងត្នោតដែលមានខ្លួនឯងប្រហែល៤-៥ដើម និងជួលគេបន្ថែមខ្លះទៀត ។ ចំណែកយាយនៅផ្ទះដាំដំណាំរួមផ្សំនិងចិញ្ចឹមសត្វ ។ យាយមានកូន៤នាក់ ។ នៅក្នុងរបបលន់ណុល ភូមិរបស់យាយមិនត្រូវបានខ្មែរក្រហមវាតត្បាតទេ ប៉ុន្តែប្រជាជនចេះតែភ្ញើលនៅពេលឮថាខ្មែរក្រហមមកជិតដល់ហើយ ក៏នាំគ្នារត់ចោលផ្ទះសម្បែងទៅរកកន្លែងសុវត្ថិភាព ។ ខ្មែរក្រហមមិនដែលចូលមកដល់ឃុំរបស់យាយទេ ប៉ុន្តែចូលឃុំផ្សេងៗដែលនៅជិតៗនោះ ។ យាយបញ្ជាក់ថា *«ខ្ញុំមិនដែលឃើញខ្មែរក្រហមផងឮតែគេថាឯណេះឯណោះចេះតែរត់នឹងគេទៅ»* ។

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានជម្លៀសប្រជាជននៅក្នុងឃុំរបស់យាយទៅនៅស្រុកលើ ដោយប្រាប់ថាទៅប្រជុំមិនចាំបាច់យកឥវ៉ាន់ទៅច្រើនទេ ។ ប្រជាជនធ្វើដំណើរកាន់តែឆ្ងាយទៅៗតាមបញ្ជារបស់ទាហានខ្មែរក្រហម ។ ម្នាក់ៗចេះតែឆ្ងល់ថា ទៅប្រជុំនៅឯណាអីក៏ឆ្ងាយម៉្លេះ ប៉ុន្តែគ្មាននរណាម្នាក់ហ៊ានសួរកងទ័ពខ្មែរក្រហមដែលនៅតាមផ្លូវឡើយ ចេះតែដើរតាមបញ្ជាទាំងភ័យខ្លាច ។ «គេប្រាប់ថាទៅប្រជុំតែត្រង់ណេះទេ ដល់ទៅឆ្ងាយបន្តិច ឆ្ងាយបន្តិចទៀត យើងមានហ៊ានជជែកអីនឹងគេ? យើងអត់មានសិទ្ធិជជែកទេ បើយើងរឹងទទឹងមិនទៅគេវ៉ៃចោលណា៎ កាលរាជហ្នឹងខ្លាំងណាស់ ។ ហើយទៅអត់មានបានយកអីទៅទេ ចុះបើគេប្រាប់ថាទៅប្រជុំ អាងតែត្រឡប់មកវិញណា៎ ម៉្លោះហើយបានតែបន្តិចៗម្នាក់ ដល់ហើយគេជំរុញឲ្យយើងទៅរហូត» ។ ខ្មែរក្រហមប្រាប់ឲ្យប្រជាជនតាំងទីលំនៅក្នុងតំបន់ព្រៃភ្នំ និងដាក់ទិសឲ្យប្រជាជនកាប់គាស់រានព្រៃដើម្បីយកដីធ្វើស្រែនិងដាំដំណាំ ។ យាយឌិន បានជួបម្តាយរបស់គាត់

ហើយក៏បានរស់នៅក្នុងសហករណ៍ជាមួយគ្នា ។

ពីដំបូងឡើយ ក្រុមគ្រួសាររបស់ យាយឌិន ត្រូវខ្មែរក្រហមដាក់បញ្ជាឲ្យគាស់គល់ឈើទាំងអស់គ្នា ។ មិនយូរប៉ុន្មាន សមាជិកគ្រួសារត្រូវបំបែកចេញពីគ្នា ។ យាយត្រូវចាត់តាំងឲ្យធ្វើស្រែ ចំណែកប្ដីរបស់យាយត្រូវចាត់តាំងឲ្យភ្ជួរស្រែនិងឃ្វាលគោដែលមានចំនួនរាប់រយក្បាល ។ កូនស្រីពីរនាក់របស់យាយត្រូវបញ្ជូនទៅកងចល័តកុមារ ចំណែកកូនប្រុសម្នាក់និងកូនស្រីម្នាក់ទៀតដែលនៅតូចៗនៅឡើយ រស់នៅក្នុងភូមិក្រោមការថែទាំរបស់ស្ត្រីចាស់ៗ ប៉ុន្តែក៏ត្រូវតែធ្វើការងារដែរ គឺកើបអាចម៍គោនិងកាប់ដើមទន្ទ្រានខែត្រសម្រាប់ធ្វើជីដាក់ស្រែ ។ សហករណ៍ដែលយាយរស់នៅឈ្មោះសហករណ៍កងបី ។ ប្រធានសហករណ៍ឈ្មោះ សែន ។ យាយឌិន និយាយថា សែន មិនសូវជាតឹងរ៉ឹងប៉ុន្មានទេ ប៉ុន្តែគាត់បានហាមប្រាមប្រជាជនថា កុំនិយាយអីច្រើន ទោះបីជាឃើញអ្វីក៏ដោយនៅឲ្យស្ងៀមទៅទើបបានសុខ ។ ប្រជាជនជាច្រើនបានបាត់ខ្លួននៅវេលាយប់ដោយគ្មាននរណាម្នាក់ដឹងថាត្រូវនាំយកទៅណាឡើយ ប៉ុន្តែអ្នកភូមិបានខ្សឹបខ្សៀវគ្នាថាអ្នកទាំងអស់នោះត្រូវយកទៅសម្លាប់ចោល ។ ក្រៅពីការសម្លាប់ប្រជាជនមួយចំនួនទៀតបានស្លាប់ដោយជំងឺគ្រុនចាញ់ ។ មិនសូវមានប្រជាជនស្លាប់ដោយកង្វះអាហារទេ ព្រោះនៅក្នុងសហករណ៍ដែលយាយរស់នៅ ខ្មែរក្រហមឲ្យប្រជាជនទទួលទានបាយមួយថ្ងៃពីរពេល ។ របបអង្ករគឺមួយកំប៉ុងសម្រាប់មនុស្សម្នាក់ក្នុងមួយថ្ងៃ ពេលខ្លះពីរកំប៉ុងសម្រាប់មនុស្សបីបួននាក់ ។ ចំណែកម្ហូបមានសម្លម្ជូរ ប្រហើរ ស្ងោរ ។ ជួនកាលក៏បានទទួលទាននំបញ្ចុក ហើយយូរៗម្ដងបានបង្អែម ។

ប្រហែលបួន-ប្រាំថ្ងៃឬមួយអាទិត្យម្ដង ប្រជាជនត្រូវប្រជុំជីវភាពតាមក្រុម ។ យាយនិយាយថា ក្នុងពេលប្រជុំ សមាជិកម្នាក់ៗត្រូវឡើងនិយាយអំពីគុណសម្បត្តិនិងគុណវិបត្តិរបស់ខ្លួន ហើយត្រូវប្ដេជ្ញាខិតខំធ្វើការងារ មិនលាក់កម្លាំង មិនខ្ជិលច្រអូស ។ បើអ្នកណាមានកំហុសអ្វីមួយនឹងត្រូវអ្នកដទៃទិតៀនកសាង ។ យាយបន្ថែមថា ប្រជាជនម្នាក់ៗនិយាយឲ្យតែមកងឃើញថានិយាយប៉ុណ្ណោះ មិនសូវហ៊ានទិតៀនគ្នាខ្លាំងៗទេ ។

ប្រហែលក្នុងឆ្នាំ១៩៧៦ កូនស្រីច្បងរបស់យាយអាយុ



យាយ ស្រស់ ឌិន និងកូនប្រុសឈ្មោះ សុក

១៧ឆ្នាំដែលធ្វើការនៅក្នុងកងចល័តយុវជន បានស្លាប់ដោយជំងឺគ្រុនក្តៅ ។ យាយនិយាយថា «ខ្ញុំដឹងក៏អត់មាត់ដែរ ។ ខ្ញុំអត់ហ៊ានទៅសួរប្រធានសហករណ៍ទេ កាលហ្នឹងគ្មានហ៊ានដេញដោលគេទេ» ។

ប្រហែលក្នុងឆ្នាំ១៩៧៦ យាយបានទៅប្រជុំនៅឃុំគោកម្តងដែលកាលណោះមានប្រជាជនរាប់ពាន់នាក់មកពីច្រើនឃុំមកចូលរួម ។ គណៈអធិបតីនៅក្នុងអង្គប្រជុំនោះគឺគណៈស្រុកឈ្មោះ តាកប ។ រំឭកអំពីមតិរបស់ តាកប នៅក្នុងអង្គប្រជុំ យាយនិយាយថា «ខ្ញុំឮតែគាត់ថាដាំបាយឲ្យសំចៃកុំឲ្យខ្ជះខ្ជាយ ហើយថាមើលឆ្អឹងប៉ុន្មានហើយព្រៃភ្នំ ។ មិនមែនសំចៃឲ្យស៊ីមិនឆ្អែតទេណា៎ សំចៃកុំឲ្យវាជ្រុះ សំចៃឲ្យស៊ីតែមួយឆ្អែត ស្អីៗទៀតខ្ញុំអត់ចាំទេភ្លេចអស់ហើយ ។»

ប្រហែលចុងឆ្នាំ១៩៧៦ឬដើមឆ្នាំ១៩៧៧ យាយឌិន មានផ្ទៃពោះកូនទី៥ ។ ពេលដែលផ្ទៃពោះរបស់យាយគម្រប់អាយុ៧ខែ ប្រធានសហករណ៍លែងឲ្យយាយទៅធ្វើការឆ្ងាយនៅកងទៀតហើយ គឺឲ្យសម្រាកនៅពេទ្យរង់ចាំថ្ងៃសម្រាលកូន ប៉ុន្តែត្រូវកាត់បន្ថយរបបអាហារពាក់កណ្តាល ។ នៅពេលដែលយាយសម្រាលកូន អង្គការមិនអនុញ្ញាតឲ្យប្តីរបស់គាត់ទៅសួរសុខទុក្ខគាត់ទេ ។ កម្មាភិបាលពេទ្យជាអ្នកដុតភ្លើងនិងដាំទឹកក្តៅឲ្យងូត ។ យាយនិយាយថា «ពេទ្យគេឲ្យរបបទន់ខ្សោយណាស់ មិនមែនដូចយើងនៅតាមសហករណ៍ទេ ។ គេដាក់បាយកន្ទះចាន បាយពីរវែកហ្នឹងអត់ពេញចានទេ ឲ្យតែអ៊ីចឹងទាំងព្រឹកទាំងល្ងាច ។ ហូបអ៊ីចឹងមានកម្លាំងឬអត់ក៏ដោយ យើងចេះតែទ្រាំទៅ យើងទៅទារអីគេ គេឲ្យប៉ុន្មានហូបប៉ុណ្ណឹងទៅ យើងអត់ហ៊ានទារទេ ។» កម្មាភិបាលពេទ្យមិនដែលចាក់ថ្នាំឲ្យគាត់ទាល់តែសោះ ចែកតែស្រាថ្នាំឲ្យផឹករាល់ថ្ងៃ ។ បន្ទាប់ពីសម្រាលកូនបាន២សប្តាហ៍ យាយត្រឡប់មកសហករណ៍វិញ ។ ប្រធានសហករណ៍ឲ្យយាយជួយធ្វើការនៅរោងចុងភៅរហូតដល់កូនរបស់យាយមានអាយុ២ខែទើបឲ្យទៅធ្វើការនៅក្នុងកងវិញ ។

ពេលដែលកងទ័ពវៀតណាមវាយសម្រុកចូលមកដល់ខេត្តកំពង់ឆ្នាំង ខ្មែរក្រហមបានប្រាប់ប្រជាជនថា បើនរណាមិនរត់យួននឹងចូលមកសម្លាប់ចោលទាំងអស់ ។ ប្រជាជនមានការភ័យខ្លាចក៏ចេះតែធ្វើដំណើរទៅតាមខ្មែរក្រហមឡើងភ្នំចូលព្រៃកាន់តែជ្រៅ ។ កូនៗរបស់យាយដែលធ្វើការនៅកងចល័ត បានត្រឡប់មកផ្ទះវិញ ហើយក្រុមគ្រួសាររបស់យាយក៏ធ្វើដំណើរទៅតាមគេឯងរហូតដល់តំបន់មួយមានឈ្មោះថាទឹកចែកបឹងសម្រាស់ ។ នៅក្នុងព្រៃទឹកចែកបឹងសម្រាស់ កូនស្រីពៅរបស់យាយដែលទើបតែមានអាយុ៥-៦ខែបានស្លាប់ដោយជំងឺ ។ យាយនៅសល់តែពីរនាក់ប្តីប្រពន្ធនិងកូនបីនាក់ ។ រត់ទៅរស់នៅលាក់ខ្លួនក្នុងព្រៃអស់រយៈពេលជាច្រើនខែ កងទ័ពវៀតណាមតាមទាន់ ហើយប្រាប់ប្រជាជនឲ្យវិលត្រឡប់មកស្រុកកំណើតវិញ ។

មកដល់ភូមិស្រុកវិញ ក្រុមគ្រួសាររបស់យាយមិនបានចូលទៅរស់នៅលើដីដែលជាកម្មសិទ្ធិពីមុនរបបខ្មែរក្រហមទេ ។ រដ្ឋអំណាចបានបែងចែកដីសាជាថ្មីឲ្យប្រជាជនសង់ផ្ទះសម្បែងនិងបែងចែកដីស្រែម្នាក់៨អារ ។ ប្តីរបស់យាយប្រកបរបរឡើងត្នោតដូចពីមុន ហើយយាយលក់នំចំណីបន្ថែមទៀតដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារ ។ កាលពីជាង១០ឆ្នាំមុនប្តីរបស់យាយបានស្លាប់ដោយជំងឺពិស ។ មួយឆ្នាំក្រោយពីប្តីរបស់យាយស្លាប់ កូនស្រីរបស់យាយក៏ស្លាប់នៅក្នុងយុទ្ធនាការ ក-៥ ។ បច្ចុប្បន្ននេះ យាយនៅសល់តែកូនប្រុសមួយនិងកូនស្រីមួយ ។ កូនស្រីមានប្តីហើយ ។ យាយរស់នៅជាមួយកូនប្រុសដែលមានអាយុជាង៣០ឆ្នាំនិងមានកាយសម្បទាមិនសូវមាំទាំ ។ យាយនិយាយថា «សព្វថ្ងៃបានតែប៉ុណ្ណឹងខ្ញុំអរហើយ ទោះបីខ្ញុំក្រខ្សត់អត់ឃ្លានយ៉ាងម៉េចក៏ខ្ញុំស្រួលដែរ ព្រោះខ្ញុំរកខ្លួនឯង គ្មាននរណាមកថាអីឲ្យខ្ញុំទេ ។...បើរបបប៉ុលពតយើងមានធ្វើចិត្តយើងឯណា គេប្រើយើងទេតើ គេមិនមែនឲ្យយើងជ្រើសរើសខ្លួនឯងទេ យើងដើរតាមតែគេ មិនមែនធ្វើដោយចិត្តឯងដូចសព្វថ្ងៃនេះទេ ។»

យាយឌិន មិនទាមទារសំណងមកវិញទេ ព្រោះកូនរបស់គាត់បានស្លាប់បាត់ទៅហើយ ទោះជាសំណងប៉ុន្មានក៏មិនអាចប្រៀបផ្ទឹមនឹងជីវិតកូនគាត់ដែរ ។ គាត់និយាយថា «បើតាមសំណងមិនស្មើនឹងកូនខ្ញុំទេទោះជាប៉ុន្មានក៏ដោយ ។ គ្មានអ្វីមកសងបានទេ ព្រោះជីវិត ។» គ្មានលទ្ធភាពទាមទារយុត្តិធម៌សម្រាប់ខ្លួនគាត់ទេ ។ គាត់មានតែផ្ញើក្តីសង្ឃឹមលើប្រមុខរាជរដ្ឋាភិបាលកម្ពុជាតែប៉ុណ្ណោះ ។

**សាន់ កល្យាណ**

# តើសកម្មជនជំរុញឱ្យមានតុលាការព្រហ្មទណ្ឌអន្តរជាតិតាមរបៀបណា?

នៅទសវត្សរ៍ចុងក្រោយនេះ ការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិគឺជាបញ្ហានាំមុខនៅក្នុងច្បាប់ ។ ទោះបីរដ្ឋនានារួមចំណែកផ្តល់សច្ចានុម័តិទៅលើលក្ខន្តិកៈច្បាប់តុលាការក៏ដោយ ក៏តុលាការព្រហ្មទណ្ឌអន្តរជាតិនឹងមិនលេចរូបរាងទេប្រសិនបើគ្មានការចូលរួមយ៉ាងសកម្មពីបុគ្គលទាំងឡាយមកពីមជ្ឈដ្ឋានសង្គមស៊ីវិលអន្តរជាតិ ។ ការបង្កើតបទបញ្ញត្តិថ្មីមួយនៃច្បាប់អន្តរជាតិដោយផ្អែកទៅលើការការពារបុគ្គល ដែលតុលាការព្រហ្មទណ្ឌអន្តរជាតិបានចែង និងការលេចឡើងនៃសង្គមស៊ីវិលអន្តរជាតិ គឺជាដំណើរការពីរដែលមានទំនាក់ទំនងយ៉ាងស្អិតល្មួត ។ ការពិនិត្យទៅលើតួនាទីរបស់សង្គមស៊ីវិលអន្តរជាតិនៅក្នុងការកកើតនៃតុលាការព្រហ្មទណ្ឌអន្តរជាតិអាចជះពន្លឺទៅលើទំនាក់ទំនងរវាងការបង្កើតច្បាប់ និងការចូលរួមផ្នែកនយោបាយនៅក្នុងពិភពលោកបច្ចុប្បន្ន ។

សញ្ញាណបង្កើតសង្គមស៊ីវិលមានប្រវត្តិដ៏យូរលង់ និងមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងទស្សនាទានច្បាប់ដើម្បីការពារពលរដ្ឋ ។ ពាក្យ "សង្គមស៊ីវិល" មានប្រភពតាំងពីសម័យចក្រភពរ៉ូម៉ាំង *societas civilis* ប៉ុន្តែត្រូវបានប្រើប្រាស់ជាពិសេសនៅក្នុងសម័យកាល "ត្រាស់ដឹង" (គឺជាសម័យកាលមួយនៅក្នុងសតវត្សរ៍ទី១៨ នៅពេលដែលស្មេរនិងអ្នកវិទ្យាសាស្ត្រជាច្រើនចាប់ផ្តើមអះអាងថាវិទ្យាសាស្ត្រនិងហេតុផលមានសារសំខាន់ជាងសាសនានិងទំនៀមទម្លាប់) ដើម្បីបញ្ជាក់ថាអ្នកដឹកនាំមិនមានសិទ្ធិអំណាចដូចអាទិទេពដែលអាចប្រព្រឹត្តចំពោះប្រជាជនសាមញ្ញតាមតែទំនើងចិត្តនោះទេ ។ ផ្ទុយទៅវិញ ប្រជាជនប្រមូលផ្តុំគ្នាដោយស្ម័គ្រចិត្ត ហើយពិភាក្សាទៅលើគំនិតដែលនាំទៅរកការបង្កើតសង្គមស៊ីវិលមួយ ក្នុងនោះសិទ្ធិនិងកាតព្វកិច្ចរបស់ប្រជាពលរដ្ឋនិងមេដឹកនាំត្រូវបានកំណត់យ៉ាងច្បាស់លាស់ ។ ទស្សនវិទូក្នុងសម័យ "ត្រាស់ដឹង" បានគិតតែក្នុងកម្រិតជាតិប៉ុណ្ណោះអំពីសង្គមដែលពឹងផ្អែកទៅលើច្បាប់ ។ ទោះជាយ៉ាងណា នៅក្រោយសង្គ្រាមលោកលើកទីពីរ ទំនោរទៅរកសិទ្ធិមនុស្សជាសកលនិងប្រព័ន្ធដ៏កាន់តែប្រទាក់ក្រឡាគ្នានៃនីតិអន្តរជាតិដែលជះឥទ្ធិពលដោយផ្ទាល់ទៅលើពលរដ្ឋ បានផ្តល់កំណើតឲ្យពិភពលោកមួយដែលគ្រប់គ្រងដោយច្បាប់ ។ ហេតុនេះ ទស្សនៈនៃសង្គមស៊ីវិលអន្តរជាតិមានទំនាក់ទំនងជាប្រវត្តិសាស្ត្រទៅនឹងទស្សនៈទាំងឡាយដែលនៅពីក្រោយច្បាប់មនុស្សជាតិនិងសិទ្ធិមនុស្ស ។

ទំនាក់ទំនងផ្ទុយពីនោះមានទម្រង់មិនសូវច្បាស់ ប៉ុន្តែប្រវត្តិនៃ "ច្បាប់មនុស្សធម៌អន្តរជាតិ" ឬ "ច្បាប់សង្គ្រាម" បង្ហាញអំពីរបៀបដែលនីតិអន្តរជាតិក្លាយជាផ្លែផ្កានៃសកម្មភាពរបស់ប្រជាជន លើសពីអ្វីដែលគេទទួលស្គាល់ ។ ស្ទើរតែរាល់សន្ធិសញ្ញានៅក្នុងច្បាប់មនុស្សធម៌អន្តរជាតិ មានប្រភពពី "គណៈកម្មាធិការអន្តរជាតិនៃកាកបាទក្រហម" ។ នៅក្នុងអត្ថបទថ្មីមួយ ខេណេត អាន់ដឺសុន បានសួរថា "តើនរណាជាម្ចាស់ច្បាប់សង្គ្រាម?" ចម្លើយរបស់ខ្ញុំគឺៈ សង្គមស៊ីវិលអន្តរជាតិគួរតែជាម្ចាស់ ឬយ៉ាងហោចណាស់ជាសហម្ចាស់នៃច្បាប់សង្គ្រាម ពីព្រោះថាប្រសិនបើគ្មានសកម្មជននៅក្នុងសង្គមស៊ីវិលអន្តរជាតិទេនោះ ពិតជាគ្មានច្បាប់ ហើយមានតែសង្គ្រាមប៉ុណ្ណោះ ។

### ឫសគល់នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ

សំណើបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិត្រូវបានលើកឡើងដំបូងដោយ ហ្គូស្តាវ ម៉ូយនៀរ ជាជនជាតិស្វីស ដែលជាអ្នករួមបង្កើតគណៈកម្មាធិការអន្តរជាតិនៃកាកបាទក្រហមនៅក្នុងឆ្នាំ១៨៧២ ។ សន្ធិសញ្ញាមនុស្សធម៌ទីមួយដឹកនាំដោយគណៈកម្មាធិការអន្តរជាតិនៃកាកបាទក្រហម គឺ "អនុសញ្ញាទីក្រុងហ្សឺណែវ" សម្រាប់ការធ្វើឲ្យប្រសើរឡើងដល់ល័ក្ខខ័ណ្ឌរស់នៅរបស់អ្នករបួសក្នុងសមរភូមិនៅឆ្នាំ១៨៦៤ ។ បច្ចុប្បន្ន អនុសញ្ញានេះត្រូវបានជំនួសដោយសន្ធិសញ្ញាបន្តបន្ទាប់ទៀត ។ នៅពេលដែលអនុសញ្ញាទីក្រុងហ្សឺណែវត្រូវបានចុះហត្ថលេខាដោយ

អារ្យប្រទេសជាច្រើន សមាជិកនៃចលនាកាកបាទក្រហមសង្កេតឃើញថា អនុសញ្ញានេះមិនត្រូវបានអើពើ ហើយអំពើឃោរឃៅត្រូវបានប្រព្រឹត្តដោយភាគីទាំងពីរនៅក្នុងសង្គ្រាមរវាងបារាំង និងអាល្លឺម៉ង់នាឆ្នាំ១៨៧០ ។

នៅពេលនោះមានអ្នកខ្លះទាញហេតុផលថា ប្រសិនបើការអនុវត្តន៍របស់រដ្ឋមិនបំពេញតាមច្បាប់ទេនោះ ច្បាប់អាចនឹងត្រូវរំលាយចោល ។ ម៉ូយនៀរ ប្រកាន់យកទស្សនៈផ្ទុយទៅវិញ ។ គាត់ទាញហេតុផលថា អនុសញ្ញាហ្សឺណែវមានសុពលភាពគ្រាន់តែអនុសញ្ញានេះត្រូវការជំនួយជ្រោមជ្រែង នោះគឺការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិដើម្បីទប់ស្កាត់មិនឲ្យមានការរំលោភទៅលើអនុសញ្ញា ហើយដើម្បីនាំជនទាំងឡាយណាដែលទទួលខុសត្រូវចំពោះការរំលោភបំពាន ទៅតុលាការ ។ មុនដំបូង រដ្ឋទាំងឡាយមិនបានចាប់អារម្មណ៍ទាល់តែសោះចំពោះសំណើថ្មីរបស់ ម៉ូយនៀរ ។ សូម្បីតែមេធាវីអន្តរជាតិក៏ឆ្លើយតបទាំងស្ទាក់ស្ទើរដែរ ។ ដូច្នេះ សំណើរបស់ ម៉ូយនៀរ ត្រូវទុកចោលមួយអន្លើ ។ ប្រាកដណាស់ សំណើនោះមានចំណុចមួយចំនួនមិនពេញលេញ ។ ទោះជាយ៉ាងណាក៏ដោយ ម៉ូយនៀរ អាចត្រូវចាត់ទុកថាជាបិតានៃគំនិតដ៏ពិសេសមួយ ។ គំនិតនោះគឺការប្រើប្រាស់អំណាចដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មមួយចំនួននៅក្រៅរដ្ឋដែលកំពុងធ្វើសង្គ្រាម ហើយទម្លាក់ភារកិច្ចនេះទៅឲ្យតុលាការអន្តរជាតិ ។

ការព្យាយាមរយៈពេលខ្លីដើម្បីបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិនៅក្រោយសម័យសង្គ្រាមលោកលើកទីពីរ មិនទទួលបានផ្លែផ្កាដោយសារគោលនយោបាយសង្គ្រាមត្រជាក់ ។ ការចង់បង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិនៅតែជាវត្ថុបំណងរបស់អង្គការជាច្រើន ដូចជា“សមាគមច្បាប់អន្តរជាតិ” “ចលនាអ្នកសហព័ន្ធពិភពលោក” និងបញ្ញាជនច្បាប់មួយចំនួនតូច ។ បញ្ញាជនអាមេរិកមួយរូបគឺ រ៉ូប៊ឺត វុតហ្វែល បាននិពន្ធសៀវភៅជាច្រើនទាក់ទងនឹងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ប៉ុន្តែវិភាគទានដ៏ធំបំផុតរបស់លោកចំពោះការចាប់បដិសន្ធិនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ គឺប្រហែលជាមិត្តភាពដ៏យូរអង្វែងរបស់លោកជាមួយអាហ្សឺរ រ៉ូប៊ឺនសុន និស្សិតសកលវិទ្យាល័យអក់ហ្វ៊ត ។ ក្រោយមក រ៉ូប៊ឺនសុន បានក្លាយទៅជាអគ្គនាយកនៃ “មូលនិធិសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ” ។ នៅឆ្នាំ១៩៨៩ រ៉ូប៊ឺនសុន បានក្លាយទៅជាប្រធានាធិបតីនៃប្រទេសទ្រីនីដែត-ថូបាហ្គូ ហើយលោកបានស្នើទៅមហាសន្និបាតអង្គការសហប្រជាជាតិឲ្យបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ ។ សំណើរបស់លោកបានទទួលការឆ្លើយតបចម្រុះ ហើយ “គណៈកម្មការច្បាប់អន្តរជាតិ” ក៏ត្រូវបានបង្កើតឡើង ។ ប្រសិនបើគ្មានការកាប់សម្លាប់ជាតិពន្ធនៅប្រទេសយូហ្គោស្លាវីនិងអំពើប្រល័យពូជសាសន៍នៅប្រទេសរ៉្វាន់ដា, ប្រសិនបើគ្មានកំហឹងក្រេវក្រោធរបស់សាធារណជន, និង ប្រសិនបើគ្មានការសម្រេចរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិដើម្បីបង្កើតតុលាការពិសេសមួយសម្រាប់ប្រទេសទាំងពីរនេះទេ គណៈកម្មការនេះអាចនឹងមិនមានដំណើរការជាច្រើនឆ្នាំ ។

## ការប្រឹងប្រែងរបស់សង្គមស៊ីវិលក្នុងការជំរុញឲ្យមានការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ

នៅឆ្នាំ១៩៩៥ “សហប្រតិបត្តិការសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ” ត្រូវបានបង្កើតឡើង ចូលរួមដោយអង្គការនិងបុគ្គលទាំងឡាយដែលបានគាំទ្រចំពោះការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិដ៏មានអំណាចនិងឯករាជភាពមួយ ។ នៅឆ្នាំបន្តបន្ទាប់មកទៀត នៅពេលដែលការចរចាដើម្បីបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិកាន់តែមានភាពស៊ុតស្មាញ សហប្រតិបត្តិការនិងសមាជិកបានប្រឹងប្រែងទាំងក្នុងកម្រិតជាតិនិងក្នុងតំបន់ ក្នុងការផ្សព្វផ្សាយតាមប្រព័ន្ធសារពត៌មានអំពីតុលាការព្រហ្មទណ្ឌអន្តរជាតិ ។ អង្គការធំៗជាសមាជិកដូចជា “អង្គការលើកលែងទោសអន្តរជាតិ” និង “ចលនាសហព័ន្ធពិភពលោក” និងព្រះវិហារមួយចំនួនរួមមាន ខ្មុកឃើរ និង មេនណូណៃ បានផ្សព្វផ្សាយឲ្យមនុស្សរាប់លាននាក់ដឹងអំពីមូលហេតុនៃការបង្កើតតុលាការ ។

នៅក្នុងការចរចាអំពីតុលាការព្រហ្មទណ្ឌអន្តរជាតិនៅទីក្រុងរ៉ូមនាខែមិថុនា-កក្កដា ឆ្នាំ១៩៩៨ យ៉ាងហោចណាស់មានសារពត៌មានប្រចាំថ្ងៃចំនួនបីបានទៅយកពត៌មានជាប្រចាំ ក្នុងនោះមានកាសែត “អនជីវ៉ើឧត” ដែលផ្ញើពត៌មានទៅសមាជិក៤ពាន់នាក់ ។ ការចូលរួមរបស់សង្គមស៊ីវិលអន្តជាតិបានធ្វើឲ្យប្រជាជន

ជាច្រើនរូបដឹងពត៌មានអំពីខ្លឹមសារនៃការចរចា មិនមែនដឹងត្រឹមតែរង្វង់អ្នកការទូតមួយក្តាប់តូចដែលចូលរួមចរចាដោយផ្ទាល់នោះទេ ។

ទោះជាយ៉ាងណាក៏សង្គមស៊ីវិលអន្តរជាតិបានខិតខំប្រឹងប្រែងផ្សព្វផ្សាយអំពីតុលាការព្រហ្មទណ្ឌទៅដល់ប្រជាជនដែលរង់ចាំស្តាប់ ។ ក្នុងពេលជាមួយគ្នានោះ ការចងក្រងឯកសារប្រកបដោយបច្ចេកទេសដ៏ទូលំទូលាយ ត្រូវបានធ្វើឡើងដោយបុគ្គលនិងអង្គការដែលបានចូលរួមនៅក្នុងដំណើរការតុលាការព្រហ្មទណ្ឌ ។ វាមានទម្រង់ពីរសំខាន់ៗគឺ កំណត់ត្រាប្រចាំថ្ងៃចេញផ្សាយនៅក្នុងព្រឹត្តិបត្រផ្នែកច្បាប់ និង របាយការណ៍របស់អង្គការក្រៅរដ្ឋាភិបាល ។ សំណេរទាំងពីរមានគោលដៅផ្តល់ពត៌មានទៅមជ្ឈដ្ឋានអង្គការក្រៅរដ្ឋាភិបាល អ្នកសិក្សា និងតំណាងរដ្ឋាភិបាល អំពីរបៀបវារៈបន្ទាប់បន្សំដែលបង្កឲ្យមានជម្រើសច្រើនផ្នែកទៅលើហេតុផលបទពិសោធន៍ ហេតុផលច្បាប់ ឬ ការពិតផ្នែកនយោបាយ ។ អ្នកសង្គមស៊ីវិលបានបើកសន្និសីទនិងអង្គប្រជុំជាច្រើននៅជុំវិញពិភពលោក ដែលរួមចំណែកដ៏ធំក្នុងការពិភាក្សាលើចំណុចបច្ចេកទេសអំពីតុលាការ









និងយុត្តិធម៌អន្តរជាតិ ។ សំណើរបស់សង្គមស៊ីវិលតែងតែមានឥទ្ធិពលខ្លាំងជាងសំណើចេញពីរដ្ឋាភិបាល ហើយបានបន្សល់នូវកេរដំណែលមិនសាបរលាបនៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិ ។

ចំណុចសំខាន់បំផុតដែលសង្គមស៊ីវិលអន្តរជាតិរួមវិភាគទានដល់ដំណើរការចរចានៃតុលាការព្រហ្មទណ្ឌគឺតម្លាភាព ។ តាមទម្លាប់ ការបង្កើតច្បាប់អន្តរជាតិគឺធ្វើឡើងជាសម្ងាត់ ។ អ្វីដែលសាធារណជនបានដឹងគឺជាលទ្ធផលចុងក្រោយ ។ ជួនកាលមានសន្ធិសញ្ញាសម្ងាត់ទៀតផង ។ កិច្ចចរចាអន្តរជាតិនឹងមិនមានលក្ខណៈចំហទាំងស្រុងនោះទេ ប៉ុន្តែសហប្រតិបត្តិការសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិបានព្យាយាមធ្វើឲ្យការចរចាអន្តរជាតិមានតម្លាភាពដល់កម្រិតកំពូល ។ សហប្រតិបត្តិការបានបង្កើតក្រុមសម្ងាត់ចំនួន១២ដើម្បីតាមដានការចរចាអំពីផ្នែកផ្សេងៗនៃលក្ខន្តិកៈទីក្រុងរ៉ូម សាកសួរប្រតិភូរដ្ឋក្រោយពីមានការប្រជុំសម្ងាត់ និងស្ទង់មតិសាធារណៈអំពីបញ្ហាសំខាន់ៗតាមរយៈការបោះឆ្នោតតាមប្រព័ន្ធអេឡិចត្រូនិក ។ បន្ទាប់មក ក្រុមដដែលផ្ញើពត៌មានដែលទទួលបានទៅកាន់សកម្មជនរាប់ពាន់នាក់តាមសារអេឡិកត្រូនិក និងចេញផ្សាយនៅតាមគេហទំព័រ ។ ដូច្នេះមនុស្សម្នាក់ដែលមានការចាប់អារម្មណ៍អាចតាមដានដឹងជារៀងរាល់ថ្ងៃ ថាតើប្រទេសណាប្រកាន់យកជំហរអ្វី ។ ម្យ៉ាងវិញទៀត ប្រទេសក្រីក្រក៏អាចតាមដានពត៌មានបានដែរ ។

ជំនួយថវិកាមួយភាគធំស្វែងរកដោយសហប្រតិបត្តិការសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ ត្រូវបានចំណាយទៅលើអ្នកជំនាញការអង្គការក្រៅរដ្ឋាភិបាលនិងអ្នកសិក្សា សម្រាប់ការចូលរួមកិច្ចចរចានៅក្នុងទីក្រុងញូវយ៉កនិងទីក្រុងរ៉ូម ។ ប្រទេសមួយចំនួន ដូចជា ប៊ូស្នៀ ទ្រីនីដែត-តូបាហ្គូ សេរ៉ាឡេអូន សេណេហ្គាល់ ប៊ូរុនឌី និង កុងហ្គោ បានរំពឹងលើកម្មវិធីជំនួយបច្ចេកទេសដោយអង្គការ “គ្មានសន្តិភាពបើគ្មានយុត្តិធម៌” ដើម្បីពង្រីកទំហំនិងកម្រិតចេះដឹងនៃគណៈប្រតិភូរបស់ខ្លួន ។ ហេតុនេះការចូលរួមរបស់សង្គមស៊ីវិលអន្តរជាតិជួយពង្រីងការចូលរួមរបស់ប្រជាជននៃប្រទេសតូចតាចនិងក្រីក្រ នៅក្នុងកិច្ចចរចាអំពីបញ្ហាផ្ទាល់ខ្លួន និងក្នុងកិច្ចចរចាផ្លូវការ ។

**ការរួមចំណែកនៅក្នុងលទ្ធផលចុងក្រោយ**

អង្គការនិងបុគ្គលនៅក្នុងសង្គមស៊ីវិលអន្តរជាតិដែលមានចំណាប់អារម្មណ៍ចំពោះតុលាការព្រហ្មទណ្ឌអន្តរជាតិមានដូចជា មេធាវី សកម្មជនសិទ្ធិមនុស្សនិងសិទ្ធិស្ត្រី ក្រុមទាមទារសន្តិភាព និងក្រុមសាសនានៅទូទាំងពិភពលោក ។ ទម្រង់មួយចំនួននៃលក្ខន្តិកៈសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិត្រូវទទួលកំណត់ដោយការចូលរួមនៃអង្គភាពទាំងឡាយនៅក្នុងសង្គមស៊ីវិលអន្តរជាតិ ។

សេចក្តីព្រាងដើមនៃគណៈកម្មការច្បាប់អន្តរជាតិដែលជាមូលដ្ឋានសម្រាប់ការចរចាររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ បានរៀបរាប់ត្រឹមតែវិធីពីរយ៉ាងដែលការស៊ើបអង្កេតមួយអាចចាប់ផ្តើមឡើង ។ ភាគីរដ្ឋអាចប្តឹងថាឧក្រិដ្ឋកម្មមួយត្រូវបានប្រព្រឹត្តឡើង ឬក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិអាចបញ្ជូនពាក្យបណ្តឹងនោះទៅកាន់តុលាការព្រហ្មទណ្ឌអន្តរជាតិ ។ ខុសពីប្រព័ន្ធច្បាប់ព្រហ្មទណ្ឌក្នុងស្រុក ព្រះរាជអាជ្ញាតុលាការមិនអាចបើកការស៊ើបអង្កេតដោយខ្លួនឯងបានទេ ។ នីតិវិធីប្តឹងផ្តល់របស់រដ្ឋធ្លាប់គាំងដំណើរជាច្រើនលើកនៅក្នុងសន្ធិសញ្ញាសិទ្ធិមនុស្ស ។ ការប្តឹងផ្តល់តាមរយៈក្រុមប្រឹក្សាសន្តិសុខគឺជាវិធីសាស្ត្រមួយកាន់តែលំបាកថែមទៀត ហើយអាចនាំឲ្យមានតុលាការមួយដែលមិនដំណើរការទៅមុខឬមានលក្ខណៈនយោបាយ ដែលអាចត្រឹមតែស៊ើបអង្កេតទៅតាមការណែនាំរបស់សមាជិកអចិន្ត្រៃយ៍ទាំង៥ប៉ុណ្ណោះ ។ អង្គការក្រៅរដ្ឋាភិបាលនិងបុគ្គលទាំងឡាយដែលជាសមាជិកនៃសហប្រតិបត្តិការសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ បានស្រុះស្រួលគ្នាទាមទារឲ្យមាន“ជម្រើស”ទីបីគឺ ព្រះរាជអាជ្ញាគួរតែមានសិទ្ធិបង្កើតនីតិវិធីច្បាប់ដោយខ្លួនឯង ។ តាមការពិត ឯករាជ្យភាពរបស់ព្រះរាជអាជ្ញាគឺជាបញ្ហាដ៏ចម្បងនៅក្នុងរបៀបវារៈនៃសហប្រតិបត្តិការសម្រាប់តុលាការនិងអង្គការជាច្រើនទៀតដែលជាសមាជិក ។

ខ្ញុំបានពិភាក្សាយ៉ាងទូលំទូលាយអំពីយុត្តិសាស្ត្រនិងវិធានការផ្សេងៗចាត់ដោយសហប្រតិបត្តិការសម្រាប់តុលាការដើម្បីទាមទារឯករាជ្យសម្រាប់ព្រះរាជអាជ្ញា ។ ទោះជាគ្មានហេតុផលបញ្ជាក់ឲ្យបានច្បាស់លាស់ថា ការប្រឹងប្រែងរបស់សង្គមស៊ីវិលបានធ្វើឲ្យមានការគាំទ្រចំពោះឯករាជ្យភាពព្រះរាជអាជ្ញាក៏ដោយ ក៏សកម្មជនភាគច្រើននិងប្រតិភូរដ្ឋមួយចំនួន ដូចជា អាហ្សង់ទីន និង ហុល្លង់ និយាយថា “នេះជាជោគជ័យដ៏ធំបំផុតមួយដែលអង្គការក្រៅរដ្ឋាភិបាលសម្រេចបាន” ។

ចំណាប់អារម្មណ៍មួយទៀតរបស់សមាជិកនៃសហប្រតិបត្តិការសម្រាប់តុលាការព្រហ្មទណ្ឌ គឺតួនាទីរបស់ជនរងគ្រោះនិងសាក្សីនៅក្នុងតុលាការ ។ អង្គការបីនៅក្នុងសហប្រតិបត្តិការសម្រាប់តុលាការ គឺសមាគមស្ត្រី សមាគមកុមារ និងក្រុមការងារសិទ្ធិជនរងគ្រោះ បានសហការគ្នាជាមួយអង្គការ “ស្តារការខូចខាត” អង្គការសង្កេតការណ៍សិទ្ធិមនុស្ស និងសមាគមនិស្សិតច្បាប់នៅអឺរ៉ុប ដើម្បីជួយបង្កើនតួនាទីរបស់សាក្សីនៅក្នុងនីតិវិធីច្បាប់របស់តុលាការ ។ ក្រុមនេះបានព្យាយាមធ្វើឲ្យមានការផ្តល់បន្ថែមដល់ជនរងគ្រោះនូវសិទ្ធិបញ្ចេញមតិយោបល់ (ពោលគឺលែងត្រូវបង្ខំឲ្យធ្វើជាឧបករណ៍របស់ព្រះរាជអាជ្ញា) និងសិទ្ធិទទួលសំណងការខូចខាត ។ ប្រតិភូរដ្ឋចំនួនពីររូបបាននិយាយថា សាក្សីមានតួនាទីយ៉ាងសំខាន់នៅក្នុងការបង្កើតមាត្រាពាក់ព័ន្ធ ។

អត្ថបទមួយរបស់ចលនាសហព័ន្ធពិភពលោក បានពន្យល់ដល់រដ្ឋនិងអង្គការក្រៅរដ្ឋាភិបាលអំពីវិធីដែលតុលាការព្រហ្មទណ្ឌអន្តរជាតិគួរទទួលថវិកា លើកឡើងអំពីបទពិសោធន៍មុនៗទាក់ទងនឹងតុលាការអន្តរជាតិផ្សេងទៀត ហើយបានដាក់សំណើដ៏រឹងមាំមួយថា តុលាការព្រហ្មទណ្ឌអន្តរជាតិមិនអាចដំណើរការបានដោយជោគជ័យទេប្រសិនបើគ្មានជំនួយថវិកាគ្រប់គ្រាន់ ។ អត្ថបទនេះបានលេចចេញមួយឆ្នាំមុនពេលរដ្ឋប្លេខាធិការដ្ឋានអង្គការសហប្រជាជាតិចេញលទ្ធផលជាដុំកំភួនទាក់ទងនឹងថវិកា ហើយសារប្រយោជន៍របស់វាត្រូវបានលើកឡើងដោយប្រតិភូរដ្ឋជាច្រើន ។ អត្ថបទបានប៉ាន់ស្មានថា វិភាគទានរបស់រដ្ឋអាចត្រូវបានបង្កើនដោយថវិកាស្ម័គ្រចិត្តដែលបរិច្ចាគដោយរដ្ឋ បុគ្គល អង្គការក្រៅរដ្ឋាភិបាល និងសាជីវកម្ម ។ ការប៉ាន់ស្មាននេះបានបង្កជាមូលដ្ឋានសម្រាប់បទបញ្ញត្តិអំពីការផ្តល់ថវិកានៃតុលាការ ។

### ផ្តោតការយកចិត្តទុកដាក់ទៅលើបទឧក្រិដ្ឋផ្លូវភេទ

វិភាគទានដ៏ចម្រូងចម្រាស់មួយនៃសង្គមស៊ីវិលអន្តរជាតិគឺ

បញ្ហាភេទ ។ ករណីនេះមិនដូចករណីជាច្រើនទៀតទេ សង្គមស៊ីវិលអាចមើលឃើញថាជាអ្នកផ្តល់យោបល់ទៅឲ្យភាគីប្រឆាំងគ្នាទៅវិញ ។

"សមាគមស្ត្រីសម្រាប់យុត្តិធម៌ផ្លូវភេទ" ត្រូវបានបង្កើតឡើងនៅខែកុម្ភៈ ឆ្នាំ១៩៩៧ ដោយសកម្មជនសិទ្ធិស្ត្រីមួយក្រុម ដើម្បីបន្ថែមទៅលើសេចក្តីព្រាងដើមនៃគណៈកម្មការច្បាប់អន្តរជាតិដែលមិនបានចាប់អារម្មណ៍ទៅលើបញ្ហាភេទ ។ អង្គការនេះបានក្លាយទៅជាសហប្រតិបត្តិការដ៏ធំមួយ ដែលមានអង្គការជាសមាជិកចំនួន៣០០មកទល់នឹងពេលចាប់ផ្តើមសន្និសីទនៅទីក្រុងរ៉ូម ។ ការចាប់អារម្មណ៍របស់អង្គការស្ត្រីគឺទៅលើនិយមន័យនៃភេទ ការរៀបរាប់អំពីភេទនៅក្នុងបទបញ្ញត្តិទូទៅនិយមន័យនៃទាសភាពផ្លូវភេទ ការបញ្ចូលការជិះជាន់ផ្លូវភេទជាផ្នែកមួយនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការការពារ និងប្រព្រឹត្តឲ្យបានត្រឹមត្រូវតាមភេទចំពោះជនរងគ្រោះនិងសាក្សី ។ ចំណុចខាងលើត្រូវបានបញ្ចូលទៅក្នុងលក្ខន្តិកៈចុងក្រោយ ក្នុងរបៀបមួយដែលបំពេញទាំងស្រុងឬដោយផ្នែកតាមការទាមទាររបស់សមាគមស្ត្រី ។

គោលបំណងដ៏មានវិវាទរបស់សមាគមស្ត្រីគឺការអនុម័តទទួលស្គាល់កថាខ័ណ្ឌបន្ទាប់បន្សំស្តីអំពី "បទឧក្រិដ្ឋផ្លូវភេទ" ត្រង់ចំណុចបកស្រាយអំពីនិយមន័យនៃបទឧក្រិដ្ឋនៅក្នុងលក្ខន្តិកៈច្បាប់ រួមទាំង "ការបង្ខំឲ្យមានផ្ទៃពោះ" ដូចដែលបានកើតឡើងនៅក្នុងកម្មវិធីបោសសំអាតជាតិពន្ធុនៅក្នុងសង្គ្រាមនៅប៊ូស្នៀ ដែលនៅពេលនោះ ស្ត្រីភេទត្រូវបានរំលោភរួចត្រូវបង្ខាំងរហូតដល់ពេលសម្រាលកូន ។

អង្គការ "ស្ត្រីពិតប្រាកដនៃកាណាដា" បានបញ្ចេញមតិប្រឆាំងចំពោះការបន្ថែមចំណុច "ការបង្ខំឲ្យមានផ្ទៃពោះ" ជាផ្នែកមួយនៃឧក្រិដ្ឋកម្មសង្គ្រាម ដោយទាញហេតុផលថា ពាក្យនេះត្រូវបានប្រើប្រាស់ដោយ "សហជីពនៃសេរីភាពសង្គមស៊ីវិលអាមេរិកាំង" នៅក្នុងបណ្តឹងស៊ីវិលមួយ ។ ការជំទាស់នេះបានលើកហេតុផលថា "ការបង្ខំឲ្យស្ត្រីពពោះគឺដើម្បីបម្រើគោលដៅរបស់រដ្ឋដែលចង់រក្សាជីវិតមនុស្សដែលមិនទាន់កើត" ក្នុងបំណងគាំទ្រច្បាប់ប្រឆាំងនឹងការពន្លូតកូន ។ សហជីពដដែលបានប្រឆាំងចំពោះការប្រើប្រាស់ពាក្យ "ភេទ" នៅក្នុងលក្ខន្តិកៈច្បាប់ ដោយលើកហេតុផលថា ធ្វើដូចនេះអាច "ផ្តល់ការការពារដល់ភេទផ្សេង" ដូចជាក្រុមមនុស្សស្រលាញ់ភេទដូចគ្នាជាដើម ។

ក្រុមទាំងពីរមានរដ្ឋជាសម្ព័ន្ធមិត្ត ។ ប្រតិភូវាទីកង់បានអនុម័តកថាខ័ណ្ឌបន្ទាប់បន្សំដោយឡែកមួយទាក់ទងនឹងបទឧក្រិដ្ឋផ្លូវភេទរួមមាន "ការរំលោភ ការបង្ខំឲ្យធ្វើទាសករភេទ ពេស្យាចារដោយបង្ខំ ការបង្ខំឲ្យពពោះ ការបង្ខំឲ្យចាក់ថ្នាំបង្ការកំណើតទារក និង ការរំលោភបំពានផ្លូវភេទផ្សេងទៀត" ដែលចម្លងចេញទាំងស្រុងពីសំណើរបស់សមាគមស្ត្រី ។ ការបង្ខំឲ្យពពោះជាចំណុចប្រទូសរ៉ាយបំផុតនៅក្នុងសន្និសីទទីក្រុងរ៉ូម ។ ទោះជាយ៉ាងណាក្រោយពីមានការជំទាស់ពីបុរីវ៉ាទីកង់និងរដ្ឋអារ៉ាប់ ការរក្សាទុកចំណុចនេះប្រហែលជាលទ្ធផលនៃការគាំទ្រយ៉ាងរឹងមាំពីប៊ូស្នៀ ដែលមានប្រៀបខាងសីលធម៌ចំពោះបញ្ហាភេទ និងការចរចាយ៉ាងអត់ធ្មត់របស់ប្រទេសអូស្ត្រាលី ជាជាងដោយសារសកម្មភាពរបស់សមាគមស្ត្រី ។ ការសម្រុះសម្រួលមួយត្រូវបានធ្វើឡើងគឺយល់ព្រមដាក់បន្ថែមការបង្ខំឲ្យមានផ្ទៃពោះ ប៉ុន្តែត្រូវពន្យល់ថា "គឺជាការឃុំឃាំងស្ត្រីដែលគេបង្កឲ្យមានផ្ទៃពោះមិនស្របច្បាប់ក្នុងចេតនាធ្វើឲ្យប៉ះពាល់ដល់សមាសភាពជាតិពន្ធុនៃសង្គមណាមួយ ដែលរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់អន្តរជាតិ ។ និយមន័យនេះនឹងមិនត្រូវបានយកទៅបកស្រាយឲ្យប៉ះពាល់ដល់ច្បាប់ជាតិទាក់ទងនឹងការមានផ្ទៃពោះឡើយ" ។

## ការពិភាក្សាវែកញែកអំពីសង្គមស៊ីវិល

ដូចខ្ញុំបានរៀបរាប់ខាងលើ ការបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិបានចាប់ផ្តើមដោយសង្គមស៊ីវិលជាមួយនឹងក្រុមអ្នកបង្កើតកាកបាទក្រហម ។ ក្នុងអំឡុងឆ្នាំ១៩៩៥-៩៨ ការចូលរួមរបស់សង្គមស៊ីវិលអន្តរជាតិបានធ្វើឲ្យគេដឹងឮជាសាធារណៈនូវការពិតដែលថា តុលាការព្រហ្មទណ្ឌអន្តរជាតិកំពុងតែឋិតនៅក្រោមការចរចា ។ ការណ៍នេះបានបង្កឲ្យមានការពិភាក្សាវែកញែកជុំវិញពិភពលោក សំណើជាជម្រើសផ្សេងៗ ពង្រីងការចូលរួមពីខាងត្បូង និង បានធ្វើឲ្យដំណើរការចរចាកាន់តែមានតម្លាភាព ។ វាបានជួយធ្វើឲ្យកកើតឡើងនូវតុលាការមួយដែលមានឯករាជ្យភាព យកចិត្តទុកដាក់ចំពោះបញ្ហាភេទ ខ្វាយខ្វល់

ចំពោះតម្រូវការរបស់ជនរងគ្រោះ និងទទួលបានជំនួយថវិកាគ្រប់គ្រាន់ ។ ផ្ទុយទៅវិញ មានមនុស្សមួយចំនួន ក្នុងនោះមានទិន អាន់ដឺសុន ខ្វាចរអានិងស្អប់ខ្ពើមការចូលរួមរបស់សង្គមស៊ីវិល ដោយលើកហេតុផលថាវា "គឺជាការឲ្យសិទ្ធិទូលំទូលាយពេក" ហើយធ្វើឲ្យបាត់បង់ "អធិបតេយ្យភាពជាតិ" ។ ការចូលរួមរបស់សង្គមស៊ីវិលមានលក្ខណៈមិនប្រជាធិបតេយ្យ ពីព្រោះអង្គការក្រៅរដ្ឋាភិបាល (និងបុគ្គលទាំងឡាយដែលបានជ្រៀតជ្រែកក្នុងដំណើរការដើម្បីខ្លួនឯង) មិនត្រូវបានបោះឆ្នោតជ្រើសរើសទេ ។ ក៏ប៉ុន្តែ ការបង្កើតច្បាប់អន្តរជាតិក៏មិនដែលមានលក្ខណៈប្រជាធិបតេយ្យដែរ ។ ទោះជាយ៉ាងណាក៏អាចតវ៉ាថា ឥឡូវនេះវាមានលក្ខណៈប្រជាធិបតេយ្យច្រើនជាងពេលមុនៗ ដោយសាររដ្ឋមួយចំនួនធំមានការបោះឆ្នោតពហុបក្ស ប៉ុន្តែមិនបោះឆ្នោតជ្រើសរើសអ្នកការទូត ហើយបញ្ហាអន្តរជាតិមួយចំនួនដូចជាតុលាការព្រហ្មទណ្ឌអន្តរជាតិជាដើម មិនមែនជារឿងដែលត្រូវបោះឆ្នោតដោយប្រទេសជាច្រើននោះទេ ។ មានទំនាក់ទំនងបន្តិចបន្តួចរវាងម្ចាស់ឆ្នោតនិងអ្នកការទូត ប៉ុន្តែគ្មានទំនាក់ទំនងទាល់តែសោះរវាងម្ចាស់ឆ្នោតនិងសកម្មជនសង្គមស៊ីវិល ។ នេះគឺជាអ្វីដែលអ្នកប្រឆាំងលើកមកបញ្ជាក់នៅពេលដែលខ្លួនតវ៉ាអំពីសារជាតិ "មិនប្រជាធិបតេយ្យ" របស់សង្គមស៊ីវិល ។

ទោះជាយ៉ាងនេះក្តី មានគំនិតមួយទៀតដែលមានលក្ខណៈចង្អៀតចង្អល់និងអភិរក្សជាង យល់ថា ប្រជាធិបតេយ្យនេះគ្រាន់តែជារូបភាពនិងជាការគោរពមតិភាគច្រើនប៉ុណ្ណោះ ។ តាមទ្រឹស្តី ម្ចាស់ឆ្នោតនៃប្រទេសមួយអាចជះឥទ្ធិពលដល់គោលជំហររបស់តំណាងប្រទេសនោះនៅក្នុងការចរចាអន្តរជាតិ ។ តាមការជាក់ស្តែងយើងដឹងថាវាមិនមែនដូច្នោះទេ ។ ប្រសិនបើខ្ញុំចាប់អារម្មណ៍ខ្លាំងចំពោះបញ្ហាអ្វីមួយដូចជាតុលាការព្រហ្មទណ្ឌអន្តរជាតិ ខ្ញុំមិនត្រឹមតែបញ្ចេញមតិរបស់ខ្ញុំតាមរយៈការបោះឆ្នោតប៉ុណ្ណោះទេ តែត្រូវបង្កើតឬចូលរួមអង្គភាពមួយដែលសមាជិកមានទស្សនៈដូចខ្ញុំ ហើយធ្វើឲ្យមានសកម្មភាពដោយខ្លួនឯង ។ អ្វីដែលសង្គមស៊ីវិលអន្តរជាតិបានធ្វើគឺថា មិនមែនតំណាងទេ គឺការចូលរួម ។ នៅក្នុងការអនុវត្តន៍ជាក់ស្តែងការចូលរួមនេះនៅតែជាកម្មសិទ្ធិដាច់មុខនៃសមាគមមួយដែលមានសមាជិកជាក្រុមមនុស្សដែលមានកេរ្តិ៍ឈ្មោះ និយាយភាសាអង់គ្លេស មានការអប់រំខ្ពស់ មានសេវាអ៊ិនធឺណែតប្រើប្រាស់ មានមធ្យោបាយគ្រប់យ៉ាងក្នុងការធ្វើដំណើរ និងមានភាពងាយស្រួលជាងអ្នកផ្សេងក្នុងការចូលរួម ។ សង្គមស៊ីវិលអន្តរជាតិមានគុណវិបត្តិធំៗមួយចំនួនដែលអ្នកគាំទ្រគួរប្រើប្រែងឲ្យបានខ្លាំងក្លាដើម្បីជម្នះ ។ អ្នកដែលលើកឡើងអំពីការបាត់បង់ប្រជាធិបតេយ្យក្នុងការបង្កើតច្បាប់អន្តរជាតិ កំពុងតែយល់ខុសទាំងស្រុងហើយ ។

បញ្ហាពិតប្រាកដដែលសង្គមស៊ីវិលមានគឺមិនមែនចំពោះការពិតដែលថាមានតួអង្គថ្មីៗនៅក្នុងការបង្កើតច្បាប់អន្តរជាតិនោះទេ ប៉ុន្តែចំពោះការពិតដែលថាមានច្បាប់អន្តរជាតិជាច្រើនទៀតកំពុងតែត្រូវបានបង្កើតឡើង ឧទាហរណ៍ដូចជាការយល់ថាមានការបាត់បង់អធិបតេយ្យភាពជាដើម ។ មនុស្សជាច្រើននៅក្នុងសង្គមស៊ីវិលអន្តរជាតិ ជាពិសេសគឺសកម្មជនសិទ្ធិមនុស្សចូលចិត្តរំកិលច្បាប់អន្តរជាតិទៅមុខតាមផ្លូវមួយដែលបំបិទស្វ័យភាពរដ្ឋក្នុងការដាក់គោលនយោបាយណាមួយទៅលើពលរដ្ឋរបស់ខ្លួន ។ អាន់ដឺសុន បានសរសេរថា ទស្សនៈបែបនេះ "ជំរុញឲ្យមានការបាត់បង់អធិបតេយ្យភាពជាតិ រួមទាំងអធិបតេយ្យភាពនៃប្រជាធិបតេយ្យ ដែលជាទង្វើមានគុណធម៌បំផុតដែលរដ្ឋមួយអាចធ្វើជូនសមុខឲ្យពលរដ្ឋរបស់ខ្លួន" ។ ខ្ញុំមានជំនឿយ៉ាងមុតមាំថា អធិបតេយ្យភាពដាច់ខាតរបស់រដ្ឋមួយគឺជារឿងដ៏គ្រោះថ្នាក់បំផុត ហេតុនេះ ការកាត់បន្ថយអធិបតេយ្យភាពខ្លះគឺជាអំណោយដ៏មានគុណធម៌បំផុតសម្រាប់ពលរដ្ឋនៃប្រទេសនោះ ។ នៅក្នុងសតវត្សរ៍ទី២០ ប្រជាជនរាប់សិបលាននាក់ត្រូវសម្លាប់ដោយតំណាងនៃរដ្ឋាភិបាលរបស់ខ្លួន ហើយប្រជាជនរាប់រយលាននាក់ទៀតត្រូវបានធ្វើទារុណកម្ម ឆក់ប្លន់ បណ្តេញចេញពីផ្ទះសម្បែង និងបង្អត់អាហារ ។ ក្នុងនោះមានរដ្ឋាភិបាលខ្លះប្រកាន់យកលទ្ធិប្រជាធិបតេយ្យមិនត្រឹមត្រូវ ។ គ្មានស្ថាប័នអន្តរជាតិណាមួយមានកំហុសឆ្គងធ្ងន់ធ្ងរដូចរដ្ឋធ្វើទៅលើប្រជាជនឯងនោះទេ ទោះជាស្ថាប័ននោះអាចមានកំហុសខ្លះក៏ដោយ ។

ខ្លឹមសារនៃ "គម្រោងការសីលធម៌" នៃសហប្រតិបត្តិការ

សម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិអាចត្រូវបានបកស្រាយតាមទ្រឹស្តីរបស់ ចច ស្តែល ថា «នៅក្នុងការបង្កើតច្បាប់អន្តរជាតិ រដ្ឋនីមួយៗមានតួនាទីពីរគឺ ការពារផលប្រយោជន៍ជាតិនិងសកលលោក ឬការពារផលប្រយោជន៍មនុស្សជាតិ ។ វាជាការពង្រឹងនិងជំរុញជាបន្តបន្ទាប់របស់រដ្ឋ និងទំនោរនៅក្នុងរដ្ឋចំពោះផលប្រយោជន៍មនុស្សជាតិ ដែលជាវិភាគទាននៃសង្គមស៊ីវិលអន្តរជាតិចំពោះដំណើរការតុលាការព្រហ្មទណ្ឌអន្តរជាតិ ។ សង្គមស៊ីវិលអន្តរជាតិមិនអាចបង្ខំឲ្យរដ្ឋធ្វើតាមខ្លួនបានទេ ប៉ុន្តែអាចជួយរដ្ឋឲ្យមើលឃើញនូវប្រយោជន៍សំខាន់មួយលើសពីអភ័យឯកសិទ្ធិនៅក្នុងច្បាប់អន្តរជាតិដែលនឹងទទួលផលប្រយោជន៍ភ្លាមៗ ។

រដ្ឋទាំងឡាយដែលធ្លាប់ទទួលរងការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរនាពេលថ្មីៗនេះដូចជា នីហ្សេរីយ៉ា ស៊ីប៊ី និង សេរ៉ាឡេអូន បានផ្តល់សច្ចាប័នដល់លក្ខន្តិកៈសម្រាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ ។ រដ្ឋទាំងនេះបានរៀបចំខ្លួនជាស្រេចដើម្បីចុះហត្ថលេខាប្រគល់អធិបតេយ្យភាពមួយផ្នែកតូចរបស់ខ្លួន ដើម្បីការពារពលរដ្ឋរបស់ខ្លួនមិនឲ្យជួបប្រទះនឹងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ជាថ្មីម្តងទៀត ដែលខ្លួនគ្មានឆន្ទៈឬគ្មានលទ្ធភាពកាត់ទោស ។ វាជារឿងអកុសលដែលរដ្ឋដ៏ធំនិងមានអំណាចមួយចំនួនតូចដូចជា ចិន ឥណ្ឌា និងសហរដ្ឋអាមេរិក មិនទាន់រៀបចំខ្លួនឲ្យបានស្រេចបាច់ដើម្បីទទួលរ៉ាប់រងនេះជាមួយនឹងសហគមន៍អន្តរជាតិ ។ ក៏ប៉ុន្តែដូចដែលកាកបាទក្រហមចាប់ផ្តើមបង្កើតច្បាប់សង្គ្រាមបន្ទាប់ពីសន្និសញ្ញាសង្គ្រាមទីមួយនៅហ្សឺណែវទទួលបរាជ័យ សង្គមស៊ីវិលអន្តរជាតិត្រូវតែបន្តព្យាយាមពន្យល់រដ្ឋទាំងឡាយដោយប្រើប្រាស់អាវុធតែមួយគត់ដែលមាន គឺហេតុផល ។

**ម៉ាលី ភ្លេះសៀស**



ចាប់ផ្តើមជីវិតថ្មីក្រោយពេលរួចផុតពីរបបខ្មែរក្រហម

# ការលំបាកក្នុងការកសាងសន្តិភាពនៅកម្ពុជា និងតួនាទីរបស់អង្គការមិនមែនរដ្ឋាភិបាល

## តើធ្វើយ៉ាងដូចម្ដេចដើម្បីឱ្យការអនុវត្តលទ្ធិប្រជាធិបតេយ្យ ក្លាយជាកម្មសិទ្ធិជាមូលដ្ឋានរបស់ប្រជាជនកម្ពុជា?

### *សេចក្ដីផ្ដើម*

### *ភារកិច្ចរយៈពេលយូរដែលរៀបរាប់មិនអស់ៈ ការកសាងវប្បធម៌ប្រជាធិបតេយ្យនៅកម្ពុជា*

«កាតព្វកិច្ចការពារ» ដែលជាគោលការណ៍គ្រឹះនៅក្នុងទ្រឹស្ដី និងការអនុវត្ត «អន្តរាគមន៍ជាលក្ខណៈមនុស្សធម៌» បង្កើតឡើងដោយគណៈកម្មាការអន្តរជាតិទទួលបន្ទុកអន្តរាគមន៍និងអធិប-តេយ្យភាពរដ្ឋ មានការទទួលខុសត្រូវសំខាន់ៗបីយ៉ាងគឺ ១) ទទួលខុសត្រូវក្នុងការទប់ស្កាត់ ២) ទទួលខុសត្រូវក្នុងការប្រតិកម្ម និង ៣) ទទួលខុសត្រូវក្នុងការស្ដាបនាឡើងវិញ ។ ចាប់តាំងពីដើមដំបូងនៃរបាយការណ៍របស់ខ្លួន គណៈកម្មការបង្ហាញយ៉ាងច្បាស់អំពីឋានានុក្រមនៃ «ធាតុផ្សំ» ទាំងនេះ ដោយលើកឡើងនៅក្នុង «គោលការណ៍គ្រឹះ» របស់ខ្លួនថា «ការការពារគឺជាចំណុចសំខាន់តែមួយគត់នៃការទទួលខុសត្រូវក្នុងកិច្ចគាំពារ ហើយការតាំងចិត្តព្រមទាំងធនធាននានាត្រូវតែផ្ដោតមកលើចំណុចនេះ» ។ ដូចនេះមិនមែនជាការគួរឲ្យភ្ញាក់ផ្អើលទេនៅពេលអានជំពូកទី៣ដែលនិយាយអំពីការទទួលខុសត្រូវចុងក្រោយបង្អស់ក្នុងការ «ស្ដាបនាឡើងវិញ» ឃើញថាមានលក្ខណៈកាន់តែស្រពេចស្រពិល និងណែនាំទៅរកផ្លូវខុសដូចដែលខ្ញុំនឹងលើកឡើង ។

ការផ្ដោតសំខាន់នៃនិក្ខេបបទនេះគឺនៅត្រង់សេចក្ដីសន្និដ្ឋាននៃជំពូកស្ដីអំពី «ការទទួលខុសត្រូវក្នុងការស្ដាបនាឡើងវិញដែលបញ្ជាក់អំពីការលំបាកក្នុងការសម្រេចបានកម្មសិទ្ធិជាមូលដ្ឋាន» ។ ដូចដែលខ្ញុំនឹងទាញហេតុផលនៅទីនេះ «កំណត់សម្គាល់ជាសេចក្ដីសន្និដ្ឋាន» ទាំងនោះគឺជាសេចក្ដីផ្ដើមឲ្យយល់អំពីការអនុវត្តដ៏មហិមាមួយ ដែលសារសំខាន់របស់វាក្នុងការធ្វើឲ្យសន្តិភាពស្ថិតស្ថេរនោះ នៅតែត្រូវលើកឡើងមិនអស់សេចក្ដី ។

តាមរយៈកថាខ័ណ្ឌទាំងពីរនេះ គេអាចយល់បានយ៉ាងច្បាស់នូវអារម្មណ៍«ប្រញាប់ប្រញាល់ពេក» ។ ដំបូងមានការសង្កត់ធ្ងន់ថា «អាជ្ញាធរអន្តរជាតិត្រូវតែប្រយ័ត្នកុំទទួលយកផ្ដាច់មុខនូវការទទួលខុសត្រូវខាងនយោបាយនៅក្នុងស្រុក» ។ បន្ទាប់មកមានការព្រមានថា «ការផ្ទេរការទទួលខុសត្រូវពីភ្នាក់ងារអន្តរជាតិមកភ្នាក់ងារមូលដ្ឋាន ត្រូវតែធ្វើឡើងឲ្យបានឆាប់តាមតែអាចធ្វើទៅបាន ដើម្បីចៀសវាងការសង្ស័យថាអន្តរាគមន៍ការពារមនុស្សជាតិគឺជាទម្រង់នៃចក្រពត្តិអាណានិគមបែបថ្មី» ។ ការបញ្ជាក់ទាំងនេះគឺជាការសន្និដ្ឋានមួយគួរឲ្យរំខានពោលគឺមិនគិតដល់ភាពលំបាកនៃ «ការផ្ទេរការទទួលខុសត្រូវ» ។

ជាការច្បាស់ណាស់ កថាខ័ណ្ឌទាំងពីរនេះហាក់ដូចជាគ្រឿងផ្សំល្អឥតខ្ចោះសម្រាប់អ៊ុនតាក់ទី២ ។ បេសកកម្មរក្សាសន្តិភាពនៅកម្ពុជា (១៩៩១-៩៣) ល្បីថាមិនបាន «សម្រេចនូវកម្មសិទ្ធិជាមូលដ្ឋាន» នៃការស្ដាបនាឡើងវិញ ។ តាមការពិត មានការសន្និដ្ឋានមួយជាប់រហូតមកថា កាតព្វកិច្ចការពារនៅទីនេះបានបណ្ដាលឲ្យអង្គការសហប្រជាជាតិបរាជ័យក្នុងការស្ដាបនាសន្តិភាពនៅក្នុងប្រទេសកម្ពុជា តួយ៉ាងដំណើរការរៀបចំនយោបាយដែលតម្រូវឲ្យតួអង្គថ្នាក់មូលដ្ឋានទទួលខុសត្រូវនោះ គឺជាការធានាឲ្យមានជោគជ័យ ។ កិច្ចការដ៏សម្បើមនៃការកសាងបទដ្ឋាននិងតម្លៃប្រជាធិបតេយ្យនៅក្នុងសង្គមមួយក្រោយពីឆ្លងផុតជម្លោះ ត្រូវបានប្រចបាច់ឲ្យចេញជាពីរកថាខ័ណ្ឌ ដោយគ្មាននិយាយដល់តួនាទីដ៏សំខាន់របស់តួអង្គក្រៅរដ្ឋាភិបាលឡើយ ។

សេចក្ដីអត្ថាធិប្បាយប្រៀបធៀបដែលមានលក្ខណៈគួរឲ្យកត់សម្គាល់គឺថា សារយ៉ាងខ្លីអំពី «កម្មសិទ្ធិជាមូលដ្ឋាន» នៃសន្តិភាព ដូចគ្នាទៅនឹង «ភាពស្ងប់ស្ងាត់» របស់អង្គការសហ

ប្រជាជាតិនៅក្នុងប្រទេសកម្ពុជាក្រោយការបោះឆ្នោត១៩៩៣ ។ បន្ទាប់ពីទទួលបានការអបអរចំពោះការរៀបចំការបោះឆ្នោតប្រកបដោយ“ជោគជ័យ” អង្គការសហប្រជាជាតិប្រញាប់ប្រញាល់ដកខ្លួនទៅបន្តបេសកកម្មរក្សាសន្តិភាពនៅប៊ូស្នៀនិងអាហ្វ្រិកកណ្តាល ។ ទោះបីវាជាការពិតថា អ៊ុនតាក់ទទួលបានការអបអរសាទរថាជា “បេសកម្មមានគោលបំណងខ្ពស់បំផុតរបស់អង្គការសហប្រជាជាតិដែលមិនធ្លាប់មានកន្លងមកក្តី” ក៏បេសកកម្មនេះគ្រាន់តែជាបេសកកម្ម “រក្សាសន្តិភាព” មួយ ហើយខកខានមិនបានធានាឲ្យមាន “សន្តិភាព” នៅកម្ពុជាបន្ទាប់ពីការដកកងទ័ពរបស់អង្គការសហប្រជាជាតិទេ ។

ប្រសិនបើការពិភាក្សាខ្លីរបស់ “កាតព្វកិច្ចការពារ” ស្តីអំពីភាពចាំបាច់ដើម្បី “សម្រេចនូវកម្មសិទ្ធិជាមូលដ្ឋាន” មានលក្ខណៈសមាមាត្រទៅនឹងការតាំងចិត្តរបស់សហគមន៍អន្តរជាតិក្នុងការសម្រេចឲ្យបាននូវការស្តាបនាឡើងវិញប្រកបដោយចីរភាព នោះវាគឺជាប្រផ្នូលអាក្រក់មួយ ។ ជាក់ស្តែង មេរៀនសំខាន់បំផុតបានមកពីបទពិសោធន៍នៃការកសាងសន្តិភាពនៅកម្ពុជាដែលនៅខ្វះចន្លោះ មិនទាន់ត្រូវបានធ្វើឲ្យជ្រួតជ្រាបនៅឡើយទេ ។ ផ្តើមចេញពីចំណុចនេះ គោលបំណងនៃនិក្ខេបបទនេះគឺចង់រំឭកឡើងវិញថា ការរក្សាសន្តិភាពនឹងមិននាំឲ្យមានសន្តិភាពចីរកាលដោយគ្មានការបណ្តុះបណ្តាលអំពីការកសាងសន្តិភាពនោះទេ ។

ខ្ញុំមានបំណងពិពណ៌នាអំពីការលំបាកជាក់ស្តែងនៃការ “សម្រេចបាននូវកម្មសិទ្ធិរបស់មូលដ្ឋាន” ដើម្បីឆ្លើយតបទៅនឹងការសន្មតដែលនាំដល់ការយល់ខុសទៅលើសង្គមនានាដែលទើបតែឆ្លងផុតពីជម្លោះ និងរៀបចំយ៉ាងត្រឹមត្រូវជូនស្តាប័នសន្តិភាពតាមរយៈមូលដ្ឋាននៃលទ្ធិប្រជាធិបតេយ្យ ។ កាន់តែពិសេសជាងនេះទៅទៀត បទពិសោធន៍កសាងសន្តិភាពប្រកបដោយបញ្ហានឹងត្រូវវាយតម្លៃថាជាការអនុវត្តជាក់ស្តែងសម្រាប់អង្គការមិនមែនរដ្ឋាភិបាលដែលមានជំហរជាយុទ្ធសាស្ត្រជាមួយប្រជាជនសាមញ្ញតាមមូលដ្ឋាន ។ ការពិភាក្សានេះនឹងធ្វើឡើងប្រឆាំងនឹងបទពិសោធន៍កសាងសន្តិភាពដែលមានបញ្ហាកន្លងមក ព្រមទាំងធ្វើឲ្យប្រសើរឡើងវិញនូវការពិភាក្សាចំៗទៅលើ “គោលដៅសម្រេចនូវកម្មសិទ្ធិជាមូលដ្ឋាន” ដែលរកឃើញនៅក្នុងធាតុផ្សំ “ការទទួលខុសត្រូវក្នុងការស្តាបនាឡើងវិញ” នៅក្នុងប្លង់គំនិតនៃ“កាតព្វកិច្ចការពារ” ។

ផ្ទៃរឿងសំខាន់ៗនៅក្នុងការសិក្សាស្រាវជ្រាវនេះគឺ តើបន្ទាប់ពីអន្តរាគមន៍ អង្គការមិនមែនរដ្ឋាភិបាលជួយសម្រេចឲ្យបាននូវកម្មសិទ្ធិជាមូលដ្ឋាននៃស្តាប័នប្រជាធិបតេយ្យបរទេសយ៉ាងដូចម្តេច ចេញពីទស្សនាទានបរទេសទៅលើពាក្យថាសន្តិភាព? ករណីប្រទេសកម្ពុជាប្រកបទៅដោយការលំបាកកាន់តែច្រើន ដោយសារតែប្រទេសកម្ពុជាពុំដែលមានសង្គមស៊ីវិល ហើយការប្រកាន់យកលទ្ធិប្រជាធិបតេយ្យមានលក្ខណៈប្រទាំងប្រទើសទៅនឹងកេរដំណែលវប្បធម៌និងប្រវត្តិសាស្ត្ររបស់កម្ពុជា ។

ពិនិត្យទៅលើការចូលរួមរបស់អន្តរជាតិក្នុងការស្តាបនាប្រទេសកម្ពុជាឡើងវិញបន្ទាប់ពីមានជម្លោះ ការសំខាន់គឺត្រូវស្វែងយល់ផលប៉ះពាល់នៃបរិបទមូលដ្ឋានទៅលើអន្តរកាលដែលមានលក្ខណៈប្រជាធិបតេយ្យ ។ ទោះជា“ការសម្រេចឲ្យបាននូវកម្មសិទ្ធិជាមូលដ្ឋាន”ជាលំហាត់បច្ចេកទេស ប៉ុក៏វាតម្រូវឲ្យមានការទទួលស្គាល់ការពិតទាក់ទងនឹងវប្បធម៌និងប្រវត្តិសាស្ត្រ ព្រមទាំងគម្រោងកម្មវិធីកែប្រែសង្គមក្តី គឺសុទ្ធតែជាបញ្ហាសារវន្តដែលត្រូវដោះស្រាយនៅពេលកំណត់និយមន័យនៃពាក្យ “ការទទួលខុសត្រូវក្នុងការស្តាបនាឡើងវិញ” ។ អត្ថបទនេះអះអាងថា គ្មាន “រូបមន្តជាសកល” សម្រាប់កសាងសន្តិភាពទេ ។ អត្ថបទនេះក៏នឹងទាញហេតុផលថា “ការសម្រេចឲ្យបាននូវកម្មសិទ្ធិជាមូលដ្ឋាន” តម្រូវឲ្យមានវិធីសាស្ត្រមួយច្បាស់លាស់ទាក់ទងនឹងបរិបទជាក់ស្តែង ចេញពីសារសំខាន់នៃការចូលរួមរបស់តួអង្គមិនមែនរដ្ឋាភិបាលដែលមកដល់សព្វថ្ងៃនេះនៅតែមិនទាន់ប្រើប្រាស់ឲ្យអស់លទ្ធភាពនៅឡើយក្នុងគម្រោងកម្មវិធីកសាងសន្តិភាពនៅកម្ពុជា ។

ពីរផ្នែកដំបូងនៃសំណេរនេះបង្ហាញជូននិងបដិសេធនូវការសន្និដ្ឋានអំពីកំហុសឆ្គងពីរយ៉ាងចេញពីផែនការសន្តិភាពរបស់អ៊ុនតាក់នៅក្នុងប្រទេសកម្ពុជា (និងភាពមិនច្បាស់លាស់នៃ “ការទទួលខុសត្រូវក្នុងការស្តាបនាឡើងវិញ”) ដែលជាមូលហេតុបណ្តាលឲ្យបរាជ័យក្នុងការនាំមកនូវសន្តិភាពសម្រាប់ប្រទេសកម្ពុជា ។ ការសន្និដ្ឋានទីមួយរកឃើញនៅក្នុងផ្នត់គំនិតបែបលោក

ខាងលិច គឺ «សន្តិភាពតាមលក្ខណៈប្រជាធិបតេយ្យ» ដែលយល់ខុសនិងមិនគោរពដល់ការពិតដែលថា សន្តិភាពគឺជាការស្ថាបនាសង្គមដែលមិនអាចបង្ខំពីខាងក្រៅបាន ។ ការសន្និដ្ឋានខុសមួយទៀតទាក់ទងនឹងការអះអាងនេះដែរ ដែលនិយាយថា «តួអង្គអន្តរជាតិត្រូវតែស្ថាបនាឡើងវិញនូវភាពខ្ទេចខ្ទាំ» ។ ស្តែងចេញពីករណីជាក់ស្តែងនៅកម្ពុជាដែលផ្នត់គំនិត «សន្តិភាពតាមរយៈប្រជាធិបតេយ្យ»មិនមែនជាលក្ខណៈដើមនោះ កិច្ចការចាំបាច់បំផុតដែលត្រូវធ្វើក្នុងការកសាងបទដ្ឋាននិងតម្លៃប្រជាធិបតេយ្យគួរតែជា«ការទទួលខុសត្រូវក្នុងការស្ថាបនា» ។ នៅផ្នែកបញ្ចប់មានការលើកឡើងនូវជំហានមួយចំនួនដែលអង្គការមិនមែនរដ្ឋាភិបាលនិងម្ចាស់ជំនួយត្រូវប្រកាន់យកដើម្បីរៀបចំ«ការផ្លាស់ប្តូរសង្គម» ដែលត្រូវការជាចាំបាច់សម្រាប់កសាងមូលដ្ឋានគ្រឹះ «សន្តិភាពតាមរយៈប្រជាធិបតេយ្យ» នៅក្នុងសង្គមដែលទើបតែងើបផុតពីជម្លោះ ដូចករណីប្រទេសកម្ពុជាជាដើម ។

## ផ្នែកទី១

## «សន្តិភាពតាមរយៈប្រជាធិបតេយ្យ» គឺជាការពិតជាសកល?

«តាមការពិត ប្រតិបត្តិការបង្កើតនិងរក្សាសន្តិភាពចង់បានសង្គមមួយដែលល្អឥតខ្ចោះ» ។ ត្រេវិន ហ៊ីនឡេ

ទោះបីជានៅក្រោយសម័យអ៊ុនតាក់មានចំនួនអង្គការក្រៅរដ្ឋាភិបាលកើនឡើងឥតឈប់ឈរយ៉ាងណាក៏ដោយ ក៏កិច្ចខិតខំប្រឹងប្រែងកសាងសន្តិភាពនៅតែទទួលបរាជ័យក្នុងការបង្កើតនូវស្ថាប័នរឹងមាំនៅក្នុងប្រទេសកម្ពុជា ។ បើគិតតាមចំនួនប្រជាជនប្រទេសកម្ពុជាបានទទួលជំនួយពីបរទេសច្រើនបំផុតនៅលើពិភពលោក ប៉ុន្តែប្រជាធិបតេយ្យរបស់កម្ពុជានៅតែអរូបដដែល ។ មានន័យថា រដ្ឋាភិបាលមិនទាន់បង្កើតធម្មាធិបតេយ្យ ហើយមិនសូវគោរពសិទ្ធិមនុស្សឡើយ ។ តាមការមើលឃើញជាក់ស្តែង កម្មវិធីរបស់អង្គការសហប្រជាជាតិក្នុងការបង្កើតសន្តិភាពតាមរយៈប្រជាធិបតេយ្យនៅកម្ពុជាបានបរាជ័យ ។ ហេតុអ្វីបានជាដូចនេះ? តើការអនុវត្តផែនការសន្តិភាពនោះមានលក្ខណៈត្រឹមត្រូវដែរឬទេ? តើវាជាការ«ខុសឆ្គង»ដែរឬទេក្នុងការសន្និដ្ឋានថាសន្តិភាពនៅកម្ពុជានឹងលេចចេញដោយឯកឯងទៅជាលទ្ធិប្រជាធិបតេយ្យ?

### ក) សន្តិភាពជាការស្ថាបនាសង្គម

ពៀរ ឡៃហ្វ៊ី គឺជាអ្នកនិពន្ធ បានរិះគន់ការបណ្តុះគំនិតបែបចាស់គំរិលរបស់អង្គការសហប្រជាជាតិចំពោះការបង្កើតនិងកសាងសន្តិភាព ។ តាមរយៈការបង្ហាញជូននូវរឿងរ៉ាវជាច្រើនទាក់ទងនឹងមូលហេតុដែលអង្គការសហប្រជាជាតិបរាជ័យក្នុងការបង្កើតរដ្ឋកម្ពុជាមួយប្រកបដោយអហិង្សា និងគោរពលទ្ធិប្រជា-ធិបតេយ្យ ឡៃហ្វ៊ី បានវិភាគទៅលើទស្សនៈជាមូលដ្ឋានដែលអង្គការសហប្រជាជាតិយកធ្វើជាគ្រឹះនៃអន្តរាគមន៍របស់ខ្លួនក្នុងប្រទេសកម្ពុជា ។ បើទោះជាការរិះគន់របស់ ឡៃហ្វ៊ី សំដៅជាពិសេសទៅលើអង្គការសហប្រជាជាតិក្តី ក៏ការឲ្យហេតុផលរបស់គាត់ដែលថា ផ្នត់គំនិតរបស់លោកខាងលិចស្តីអំពី«សន្តិភាពតាមរយៈប្រជាធិបតេយ្យ» មិនស៊ីគ្នាជាមួយតថភាពជាក់ស្តែងនៅកម្ពុជានោះ នឹងជួយកំណត់នូវតួនាទីពាក់ព័ន្ធរបស់អង្គការមិនមែនរដ្ឋាភិបាលនៅក្នុងការកសាងសន្តិភាពនៅកម្ពុជា ។

ផែនការសន្តិភាពឆ្នាំ១៩៩១មានគោលបំណងកែប្រែកម្ពុជាពីនយោបាយហិង្សាទៅនយោបាយអហិង្សាតាមរយៈការប្រែក្លាយរដ្ឋាភិបាលកម្ពុជាឲ្យទៅជាស្ថាប័នប្រជាធិបតេយ្យសេរីដែលបង្កើតនូវ«កិច្ចសន្យាសង្គម»ថ្មីមួយ ។ ខូក្លាស ភីក មានប្រសាសន៍ថា «នៅក្នុងប្រទេសកម្ពុជា ពាក្យផ្ទុយនឹងសង្គ្រាមមិនមែនជាសន្តិភាពទេ គឺអភិបាលកិច្ច» ។ លោកចង់បញ្ជាក់ថា «ប្រសិនបើមានរដ្ឋាភិបាល ពិតជាមានសន្តិភាព ផ្ទុយទៅវិញបើគ្មានរដ្ឋាភិបាលទេ សង្គ្រាមពិតជាបន្តកើតឡើង» ។ ការបង្កើតនូវអំណាចនយោបាយគឺជាស្នូលនៃដំណើរការសន្តិភាពនៅកម្ពុជាមានន័យថា សន្តិភាពនិងលទ្ធិប្រជាធិបតេយ្យមានតម្លៃស្មើគ្នា ។

ដោយផ្អែកទៅលើផ្នត់គំនិតសន្តិភាព «ដែលមានលក្ខណៈបច្ចេកទេស» បែបនេះ សំណេរអំពីបរាជ័យនៃដំណើរការសន្តិភាពនៅកម្ពុជាផ្តោតសំខាន់ទៅលើ «យន្តការ» នៃផែនការសន្តិភាពរបស់អង្គការសហប្រជាជាតិ «ដែលអនុវត្តមិនបានល្អ» ។ នៅក្នុងអ្វីដែលគេនិយាយស្ទើរតែមិនផុតពីមាត់ថាជាការសាដើមវិញនៃដំណើរការសន្តិភាពដូចដែលសហគមន៍អន្តរជាតិប្រមើលឃើញនៅក្នុងកម្មវិធីសន្តិភាពនោះ លោកអគ្គលេខាធិការអង្គការសហប្រជាជាតិបានពន្យល់អំពីបរាជ័យនៃប្រតិបត្តិការរក្សានិងកសាង

សន្តិភាពនៅប្រទេសសូម៉ាលី ប៊ូស្នៀ ឬកម្ពុជា ដោយសារ "ការលំបាកជាក់ស្តែង" ដែលអ្នករក្សាឬអ្នកកសាងសន្តិភាពបានជួបប្រទះ ក្នុងនោះរួមមានបញ្ហានៃ"ការបញ្ជានិងការគ្រប់គ្រងទំហំកងទ័ពនិងសម្ភារនិងសមត្ថភាពគ្រប់គ្រងពត៌មាន" ។

ផ្ទុយមកវិញ ឡៃហ្សី ផ្ទាកមកនិយាយអំពីសារជាតិនៃផែនការនោះថា "តើគេអាចបង្កើតសន្តិភាពត្រឹមតែតាមរយៈការបង្កើតដំណើរការប្រជាធិបតេយ្យបានដែរឬទេ?" សំណួរនេះនាំដល់ការចោទសួរកាន់តែស៊ីជម្រៅជាងនេះទៅទៀតថា "តើកម្ពុជាយល់ឃើញសន្តិភាពថាជាអ្វី?" ។ ឡៃហ្សី យល់ឃើញថា សំណួរនេះពិតជាមានសារសំខាន់ ពីព្រោះនយោបាយអហិង្សាពង្រីកខ្លួនដល់ការអភិវឌ្ឍន៍ផ្នែកសង្គមជាក់លាក់នានា ។ ផ្តើមចេញពីចំណុចនេះ មានលេចឡើងនូវសេចក្តីសន្និដ្ឋានប្រកបដោយការរិះគន់ថា "សន្តិភាពគឺជាការស្តាបនាសង្គមដែលមិនអាចឈោងចាប់បានដោយការយល់ឃើញជាសកលទៅលើដំណោះស្រាយជម្លោះនិងសន្តិភាព" ។ និយាយម្យ៉ាងទៀត គេនឹងមិនអាច "បង្កើត" សន្តិភាពដោយគ្រាន់តែ "ដាក់ចូល" នូវរចនាសម្ព័ន្ធប្រជាធិបតេយ្យទាំងដុលមកលើសង្គមមួយដូចជាកម្ពុជាដែលខ្វះរចនាសម្ព័ន្ធសង្គមសម្រាប់គាំទ្រដំណើរការប្រជាធិបតេយ្យនោះទេ ។

រចនាសម្ព័ន្ធសង្គមកម្ពុជាត្រូវបានបង្កើតដោយលទ្ធិផ្តាច់ការនិងការដឹកនាំបៀបលូនក្រាបជាយូរលង់មកហើយ ។ ហេតុដូចនេះ ឡៃហ្សី សន្និដ្ឋានថា "សន្តិភាពតាមរយៈប្រជាធិបតេយ្យ" គឺជាគំនិតវើរវាយដែលប្រទាំងប្រទើសជាមួយនឹងរចនាសម្ព័ន្ធសង្គមរបស់កម្ពុជា ។ ហ្វ្រេដរិក ប្រោន យល់ឃើញដូចគ្នាដែរថា "គ្មាននរណាម្នាក់យកឧត្តមគតិនិយមនយោបាយបែបលោកខាងលិចមកគតតាំងនឹងលទ្ធិផ្តាច់ការនិយមដែលមានចំណាស់រាប់ពាន់ឆ្នាំនោះទេ មានតែករណីកម្ពុជាមួយគត់" ។ ប្រវត្តិយូរលង់នៃលទ្ធិផ្តាច់ការនិយមបង្ហាញថា "ការយល់ឃើញរបស់កម្ពុជាទៅលើសញ្ញាណនៃសន្តិភាព" ត្រូវបានសន្និដ្ឋានថាកើតចេញពីតុល្យភាពអំណាចដែលសម្រេចបានតាមរយៈនយោបាយហិង្សាពហុភាគី ។

ឡៃហ្សី បង្ហាញជូននូវផ្នត់គំនិតទីពីរស្តីអំពីសន្តិភាពដែលកើតចេញពីជំនឿទៅលើ "អនត្តា" នៅក្នុងព្រះពុទ្ធសាសនា ។ ជំនឿបែបនេះមានទំនោរទៅរកការស្វែងរក "ភាពសុខដុមរមនា" តាមរយៈការស្វែងរកកិច្ចការពារពីចៅហ្វាយនាយ ។ គោលបំណងគឺចង់បញ្ចៀសអំពើហិង្សា ជាជាងព្យាយាមដោះស្រាយអំពើហិង្សាដោយផ្ទាល់ ។ ប្រការនេះពន្យល់ប្រាប់អំពីមូលហេតុដែលនាំឲ្យប្រជាជនកម្ពុជាភាគច្រើនដែលជាពុទ្ធសាសនិកទទួលយកហេតុផលរបស់មេដឹកនាំសាសនារបស់ខ្លួនដែលថា "សន្តិភាពធំជាងយុត្តិធម៌" ដែលបញ្ច្រាសគ្នានឹងគំនិតរបស់លោកខាងលិចដែលថា "យុត្តិធម៌គឺជាមូលដ្ឋាននៃសន្តិភាព" ។ ដូចដែលអ្នកវិភាគកម្ពុជាមួយរូបយល់ថា "គំនិតថាត្រូវតែមានយុត្តិធម៌សិនទើបសម្រេចបាននូវការអភិវឌ្ឍន៍មិនមែនជាផ្នែកនៃវប្បធម៌ខ្មែរទេ" ។

ផ្នត់គំនិតដែលថា "សន្តិភាពជាតុល្យភាពអំណាច" ឬ "ភាពសុខដុមរមនាឡើងវិញ" ត្រូវបានគាំទ្រដោយក្រុមមានអំណាចកម្ពុជា "ពីព្រោះអ្នកទាំងនោះគាំទ្រនិងផ្តល់ភាពស្របច្បាប់ដល់សណ្តាប់ធ្នាប់សង្គមដែលនាំឲ្យខ្លួនមានអំណាច" ។ នៅក្នុងការសង្កេតបែបរិះគន់របស់ខ្លួន ឡៃហ្សី ពន្យល់អំពីការបរាជ័យក្នុងការកសាង "សន្តិភាពតាមរយៈប្រជាធិបតេយ្យ" នៅក្នុងប្រទេសកម្ពុជា ។ ឡៃហ្សី និយាយថា វាជាការខុសឆ្គងក្នុងការសន្និដ្ឋានថា ក្រុមថ្មីដែលកើតចេញពីការបោះឆ្នោតដែលរៀបចំឡើងដោយអង្គការសហប្រជាជាតិ នឹងគាំទ្រដល់សណ្តាប់ធ្នាប់នយោបាយអហិង្សាដែលភ្ជាប់ជាមួយនឹងការកែប្រែសង្គម ។ រដ្ឋាភិបាលកណ្តាលរឹងមាំមួយអាចកើតឡើងលុះត្រាតែមានការរៀបចំសាឡើងវិញនូវរចនាសម្ព័ន្ធរបស់សង្គមខ្មែរ ។ នេះទើបជាការប្រែក្លាយសង្គមមួយដែលមិនធ្លាប់សាកល្បងពីមុន ហើយសូម្បីតែអង្គការសហប្រជាជាតិក៏មិនដែលគិតដល់ដែរនោះ ។ ឡៃហ្សី លើកឡើងទៀតថា "តាមការពិត ការរៀបចំបោះឆ្នោតត្រូវបានកំណត់ថាជាភស្តុតាងបញ្ជាក់អំពីជោគជ័យៈ អង្គការសហប្រជាជាតិប្រកាសសន្តិភាពហើយក៏ចាកចេញពីកម្ពុជាមួយរំពេច" ។ ហេតុផលរបស់អង្គការសហប្រជាជាតិគឺថា សន្តិភាពនៅក្នុងប្រទេសកម្ពុជាគឺជាបញ្ហា "បច្ចេកទេស" ដែលត្រូវការនូវដំណោះស្រាយបច្ចេកទេស ពោលគឺការរៀបចំការបោះឆ្នោតដោយលក្ខណៈប្រជាធិបតេយ្យ ។

និក្ខេបបទរបស់ ឡៃហ្វឺ ឆ្លុះបញ្ចាំងអំពីការឲ្យហេតុផលរបស់ "អ្នកវប្បធម៌និយម" ឬ "អ្នកពាក់ព័ន្ធនិយម" នៅត្រង់ថា អ្នកវប្បធម៌និយមអះអាងថា ប្រព័ន្ធនយោបាយនិងការវិវឌ្ឍន៍ផ្នែកនយោបាយគឺជាលក្ខណៈពិសេសបែបវប្បធម៌ ឬមានទំនាក់ទំនងជាមួយកាលៈទេសៈជាក់ស្តែង ។ និយាយម្យ៉ាងទៀត អ្នកវប្បធម៌និយមអាចនិយាយថា ដោយសារសង្គមមួយមិនទាន់បានឆ្លងកាត់ដំណាក់កាលនយោបាយតាមប្រព័ន្ធតំណាងនិយម ប្រព័ន្ធប្រជាធិបតេយ្យបែបនេះអាចត្រូវបានចាត់ទុកថាវាមិនអាចទៅរួច ឬមិនគួរជាទីប្រាថ្នាឡើយ ។ ក៏ប៉ុន្តែ តម្លៃនៃប្រជាធិបតេយ្យគឺជាសម្បត្តិផ្តាច់មុខរបស់លោកខាងលិចឬ?

វាអាចបង្ហាញបានថាមានភាពដូចគ្នាជាមូលដ្ឋានផ្នែកនយោបាយរវាងប្រជាជនដែលមានវប្បធម៌ផ្សេងគ្នា ។ ជាអាទិ៍ គ្មានអ្នកណាម្នាក់ (ទោះជាមកពីមជ្ឈដ្ឋានវប្បធម៌ណាក៏ដោយ) ចង់ទទួលទារុណកម្មទេ (នេះគឺសិទ្ធិជាមូលដ្ឋានរបស់មនុស្ស) ។ មិនតែប៉ុណ្ណោះសោត មនុស្សគ្រប់រូបប្រាថ្នាចង់បាននូវសិទ្ធិប្រឆាំងនឹងការរំលោភបំពានមកលើខ្លួន (សេរីភាពក្នុងការបញ្ចេញមតិ) និងចង់បានសេរីភាពក្នុងការធ្វើសេចក្តីសម្រេចចិត្តអំពីជោគវាសនារបស់ខ្លួន ។ "ភាពរួមគ្នា" ទាំងនេះហាក់ដូចជាអនុវត្តចំពោះប្រទេសកម្ពុជាដែរ ។ ចំពោះសង្គមមួយដែលមិនធ្លាប់ចូលរួមនៅក្នុងដំណើរការប្រជាធិបតេយ្យដ៏មានន័យ ការដែលប្រជាជនកម្ពុជាចំនួន៩០ភាគរយបានចូលរួមបោះឆ្នោតនាឆ្នាំ ១៩៩៣ បង្ហាញថាប្រជាជនកម្ពុជាភាគច្រើនទទួលយក ទោះបីជាមិនស្វាគមន៍កក់ក្តៅចំពោះគំនិតនៃការចូលរួមផ្នែកនយោបាយនិងមិនទទួលយកគំនិតតំណាងនិយមក៏ដោយ ។

ទាក់ទងនឹងបញ្ហានេះ ទោះបីជាផ្នត់គំនិត "សន្តិភាពតាមរយៈប្រជាធិបតេយ្យ" មិនស៊ីគ្នាជាមួយភូមិសាស្ត្រសង្គម-នយោបាយកម្ពុជាក៏ដោយ ក៏នៅតែជា "គោលដៅសន្តិភាព" មួយដែលគួរតែបន្តសម្រេចឲ្យបាន ។ តាមពិត ដោយសារតែការសន្មតបែបនេះហើយបានជា "ភាពរួមគ្នាផ្នែកនយោបាយមូលដ្ឋាន" ក្នុងទម្រង់ប្រជាធិបតេយ្យត្រូវបានគោរពជាសកល ដែលផ្នែកខាងក្រោយនៃនិក្ខេបបទនេះលាតត្រដាង ។ ការទាញហេតុផលប្រកបដោយទុទិដ្ឋិនិយមរបស់ ឡៃហ្វឺ ត្រូវបានពុះពារ ហើយហេតុផលនេះក៏នាំដល់ចំណោទបញ្ហាមួយទៀតថា ដោយការទទួលស្គាល់តម្រូវការចាំបាច់ក្នុងការសម្រេចឲ្យបាននូវ "កម្មសិទ្ធិជាមូលដ្ឋាន" នៃសន្តិភាពតាមរយៈប្រជាធិបតេយ្យ តើអង្គការមិនមែនរដ្ឋាភិបាលមានតួនាទីអ្វីខ្លះក្នុងការកសាងសន្តិភាព?

ការឆ្លើយតបទៅនឹងសំណួរនេះគួរតែធ្វើឡើងដោយឈរលើមូលដ្ឋាននៃការសង្កេតថា ការអនុវត្តក្នុងសង្គមបច្ចុប្បន្នមានភាពប្រទាំងប្រទើសជាមួយការស្ថាបនាគំនិតប្រជាធិបតេយ្យសេរីដែលរៀបចំឡើងដោយអង្គការសហប្រជាជាតិ ។ ហេតុដូចនេះការកសាងសន្តិភាពក្រោយពីមានជម្លោះអាចត្រូវបានចាត់ទុកថាធ្វើឡើងក្នុងគោលបំណង "បង្រួញគម្លាត" រវាងផ្នត់គំនិត "សន្តិភាពតាមរយៈប្រជាធិបតេយ្យ" ដែលស្ថាបនាឡើងដោយអ៊ុនតាក់ និងតថភាពជាក់ស្តែងនៃប្រទេសកម្ពុជា ។ នៅចំពោះមុខការលំបាកនេះ អង្គការមិនមែនរដ្ឋាភិបាលគួរតែត្រូវបានចាត់ទុកថាជាតួអង្គសំខាន់ក្នុងការកសាងសន្តិភាព ។ ទំនាក់ទំនងស្អិតល្មួតរវាងអង្គការក្រៅរដ្ឋាភិបាលជាមួយនឹងប្រជាជនតាមមូលដ្ឋានមិនត្រឹមតែអនុញ្ញាតឲ្យតួអង្គអន្តរជាតិដឹងអំពីផ្នត់គំនិតរបស់មូលដ្ឋានចំពោះពាក្យថាសន្តិភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដាក់ឲ្យតួអង្គទាំងនេះស្ថិតក្នុងជំហរមួយចូលរួមជាលក្ខណៈសង្គមជាមួយនឹង "សន្តិភាពតាមរយៈប្រជាធិបតេយ្យ" ផង ។

### ១) សន្តិភាពនយោបាយមិនមែនមានន័យថាជាសន្តិភាពសង្គមទេ: តួនាទីរបស់អង្គការមិនមែនរដ្ឋាភិបាលដែលបញ្ចេញមិនអស់

ដំណើរការសន្តិភាពនៅកម្ពុជាត្រូវបានបង្កើតនិងទ្រទ្រង់ដោយស្ថាប័នដឹកនាំដោយរដ្ឋ (ជាសមាជិកអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាសន្តិសុខ) ដែលដំណើរការភាគច្រើនស្របទៅនឹងរបៀបវារៈសន្តិភាព: "មូលដ្ឋានគ្រឹះនៃដំណោះស្រាយជម្លោះគឺជារដ្ឋនិងត្រូវតែជារដ្ឋ" ។ ឯកសារនេះមិនដែលវិភាគឲ្យល្អិតល្អន់ទៅលើសារជាតិនៃការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាលនៅក្នុងដំណើរការនេះឡើយ ។

សូមស្នើឡើងថា វិភាគទានដ៏សំខាន់បំផុតរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងការកសាងសន្តិភាពគឺការបង្កឲ្យមានបម្លាស់ប្តូរសង្គម ។ ចំណុចនេះបានលើកឡើងខាងដើមរួចហើយ

ថា បម្លាស់ប្តូរសង្គមដែលចាំបាច់ត្រូវតែកើតឡើងមុនគំនិត "សន្តិភាពតាមរយៈប្រជាធិបតេយ្យ" អាចជាប់ទាក់ទងគ្នាជាមួយបរិបទប្រទេសកម្ពុជា ។ តួអង្គមិនមែនរដ្ឋដែលយល់ដឹងច្បាស់បំផុតអំពីសង្គមកម្ពុជា គឺជាដៃគូដ៏សំខាន់ ។ អែនឌ្រូ ណាតស៊ីអូ និយាយថា "អង្គការមិនមែនរដ្ឋាភិបាលដែលយល់ដឹងជ្រៅអំពីសហគមន៍និងអង្គការសង្គមថ្នាក់មូលដ្ឋាន អាចចាត់ទុកថាជាស្ថាប័នដែលអាចសម្រេចទៅបានដោយគ្មានឥទ្ធិពលមកពីថ្នាក់ណាទៀតនៅអំឡុងពេលដែលស្មុគស្មាញ" ។

ប្រសិនបើអង្គការមិនមែនរដ្ឋាភិបាលពិតជា "ប្រភពដើមនៃអំណាច" មែននោះ ការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាលនៅក្នុងគម្រោងកម្មវិធីកាតព្វកិច្ចការពារដើម្បីឈានទៅ "សម្រេចកម្មសិទ្ធិជាមូលដ្ឋាន"ហាក់ដូចជាមានសារសំខាន់ខ្លាំងណាស់ ។ ឡៃហ្ស៊ី មានជំហរដូចគ្នានេះដែរ ។ គាត់បានអំពាវនាវឲ្យពិនិត្យមើល "គំរូថ្មី" ដែលទាញយកប្រយោជន៍ពីលក្ខណៈសម្បត្តិរបស់អង្គការមិនមែនរដ្ឋាភិបាលនៅតាមមូលដ្ឋាន ។ ក៏ប៉ុន្តែ យើងគួរតែប្រយ័ត្នកុំឆាប់សន្និដ្ឋានពេកថា សង្គមដែលបានឆ្លងកាត់ជម្លោះដូចជាកម្ពុជា គឺជាថ្នាលដ៏មានជីជាតិសម្រាប់ការចូលរួមយ៉ាងសកម្មរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងការកសាងសន្តិភាព ។ ដូចដែលយើងនឹងយកមកពិភាក្សានៅវគ្គបន្ទាប់នេះថា សង្គមស៊ីវិលនៅកម្ពុជាមានលក្ខណៈថ្មីសន្លាងដូចជាគំនិត "សន្តិភាពតាមរយៈប្រជាធិបតេយ្យ" ដែរ ។ ទោះជាយ៉ាងណាក៏ដោយ រយៈពេលជាង១០ឆ្នាំក្រោយពីសម័យអ៊ុនតាក់ "ការរីកដុះដាល" នៃសង្គមស៊ីវិលនៅក្នុងប្រទេសកម្ពុជាផ្តល់ក្តីសង្ឃឹមដល់ការកសាង "សន្តិភាពតាមរយៈប្រជាធិបតេយ្យ" ដែលមិនទាន់សម្រេចបាននៅឡើយ ។

## ផ្នែកទី២

## ការទទួលខុសត្រូវក្នុងការស្តាបនា ឬការយល់ខុសអំពី "ការស្តាបនាឡើងវិញ"

*"បើចង់ឲ្យប្រតិបត្តិការរក្សាសន្តិភាពបន្សល់ទុកនូវអំណាចស្របច្បាប់ និងអំណាចនយោបាយដែលមើលឃើញថាមានឯករាជ្យ ប្រតិបត្តិការនោះត្រូវតែជួយកែទម្រង់ឱ្យទិដ្ឋភាពនយោបាយតាមរយៈការកសាងនូវមូលដ្ឋានថ្មីសម្រាប់សន្តិភាពផ្ទៃក្នុង" ។ ម៉ៃឃើល ដូឡេ*

"កាតព្វកិច្ចការពារ" បានធ្វើឲ្យរាលដាលនូវការសន្មតខុសមួយអំពីតួអង្គអន្តរជាតិដែលត្រូវតែ "ស្តាបនាឡើងវិញនូវអ្វីដែលខូចខាំ" ។ ផ្ទុយមកវិញ ប្រវត្តិការណ៍នៃទស្សនៈ "អ្នកឈ្នះបានអ្វីៗទាំងអស់" និងនយោបាយលុនក្រាបនៅក្នុងប្រទេសកម្ពុជា បង្ហាញឲ្យឃើញថា គ្មានមូលដ្ឋានគ្រឹះសម្រាប់ "ការស្តាបនាឡើងវិញ" ឡើយ ។ ការហៅនានាដូចជាថា "អន្តរកាលពីសង្គ្រាមមកសន្តិភាព" ដែលជារឿយៗកើតមាននៅក្នុងទ្រឹស្តីកាតព្វកិច្ចការពារ និងនៅក្នុងផែនការសន្តិភាពនៅកម្ពុជា បង្ហាញអំពីជំហរចាក់បណ្តោយពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀត ហើយខកខានមិនបានទទួលស្គាល់ថា "សន្តិភាពដែលត្រូវបានប្រមើលឃើញថាមិនមែនជាការផ្តល់មកវិញងាយៗនូវស្ថានភាពមុនសង្គ្រាមនោះទេ" ។ ភាពចាំបាច់គឺតម្រូវឲ្យស្តាបនាឡើងវិញដើម្បីបង្កើតបានជា "កិច្ចសន្យាសង្គម" ថ្មីមួយ ហើយតម្រូវការនេះមិនត្រូវបានក្តោបឲ្យបានពេញលេញនៅក្នុងទ្រឹស្តី "ការទទួលខុសត្រូវក្នុងការស្តាបនាឡើងវិញ" នោះទេ ។

នៅក្នុងប្រទេសកម្ពុជា ជំនួយអន្តរជាតិធ្វើឡើងដោយគំនិត "ស្តាបនាឡើងវិញ" ដូចដែល ឪឡាន ហេនរីកសុន បានលើកឡើងថា "ក្រៅពីភ្នាក់ងារផ្តល់ជំនួយទាំង១០របស់អង្គការសហប្រជាជាតិដែលធ្វើការនៅកម្ពុជា មានអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិនិងរដ្ឋាភិបាលជាច្រើនទៀតដែលផ្តល់នូវជំនួយដ៏សន្ធឹកសន្ធាប់ ជាការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងដើម្បីស្តាបនាឡើងវិញនូវហេដ្ឋារចនាសម្ព័ន្ធរូបវន្តរបស់ប្រទេសកម្ពុជាដែលខូចខាំ និងដើម្បីកាត់បន្ថយភាពក្រីក្រ ។ សកម្មភាពទាំងនេះអាចត្រូវបានចាត់ទុកថាជាធាតុផ្សំសំខាន់នៃយុទ្ធសាស្ត្រកសាងសន្តិភាពរយៈពេលយូរអង្វែង ដែលនឹងជួយដោះស្រាយនូវបញ្ហាសេដ្ឋកិច្ចសង្គមកិច្ច និងបញ្ហាស្ថាប័ន ដែលរុញច្រានកម្ពុជាឲ្យធ្លាក់ចូលក្នុងស្ថានភាពជម្លោះ" ។ គេមិនអាចប្រកែកបានទេថា ទោះជាទ្រឹស្តីសម្ភារនិយមក្នុងការកសាងសន្តិភាពស្របជាមួយហេតុផលដែលគូសបញ្ជាក់អំពី "ការទទួលខុសត្រូវក្នុងការស្តាបនាឡើងវិញ" ក៏ដោយ វាគឺជាទ្រឹស្តីដែលសមហេតុផលក្នុងការអនុវត្ត ។

ដោយសារតែទ្រឹស្តី "សន្តិភាពតាមរយៈប្រជាធិបតេយ្យ"

មិនមែនជាគំនិតដើមនៅក្នុងសង្គមខ្មែរ អ៊ុនគាក់ ត្រូវតែ "ទទួលខុសត្រូវក្នុងការស្ដាបនា" មានន័យថា មិនមែនស្ដាបនាតែរចនាសម្ព័ន្ធប្រជាធិបតេយ្យដែលចម្លងលទ្ធិប្រជាធិបតេយ្យសេរីតាមបែបលោកខាងលិចនោះទេ ប៉ុន្តែត្រូវតែស្ដាបនានូវបទដ្ឋាននិងតម្លៃប្រជាធិបតេយ្យជាមុន ។ ការខកខានរបស់អង្គការសហប្រជាជាតិក្នុងការចូលរួមនៅក្នុងបម្លាស់ប្ដូរសង្គម បណ្ដាលឲ្យមានសភាព "ទទេស្អាត" ព្រមទាំងធ្វើឲ្យស្ថាប័នសង្គមស៊ីវិលស្ថិតនៅក្រោមសង្គម ។ ម៉ៃឃើល ដូឡេ លើកឡើងថា "ការកសាងសន្តិភាពប្រកបដោយជោគជ័យនាពេលបច្ចុប្បន្ននេះ មិនមែនត្រឹមតែជាការអនុវត្តប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងប្រែក្លាយអត្តសញ្ញាណនិងបរិបទនៃការបង្កើតមូលដ្ឋានគ្រឹះទៀតផង ។ នេះមិនមែនជាការលេងល្បែងដដែលៗនោះទេ វាគឺជាល្បែងថ្មី" ។

ការពិភាក្សាបន្ទាប់មកទៀតឆ្លុះបញ្ចាំងឲ្យឃើញចំណុចទាក់ទងគ្នាពីរដែលអ្នកផ្ដល់ជំនួយនិងអង្គការក្រៅរដ្ឋាភិបាលប៉ុនប៉ងកសាងសន្តិភាពនៅក្នុងប្រទេសកម្ពុជា ។ ទីមួយ ការយល់ឃើញរបស់លោកខាងលិចដែលថាមិនមានសង្គមស៊ីវិលនៅកម្ពុជាជាហេតុនាំឲ្យលំបាកដល់ការ "សម្រេចនូវកម្មសិទ្ធិជាមូលដ្ឋាន" ។ ទីពីរ ដើម្បីសម្រេចនូវកម្មសិទ្ធិជាមូលដ្ឋានទៅលើ "សន្តិភាពតាមរយៈប្រជាធិបតេយ្យ" ត្រូវតែដឹងថា កំណើនសេដ្ឋកិច្ចតែម្យ៉ាងមិន"គ្រប់គ្រាន់"សម្រាប់កសាងបទដ្ឋាននិងតម្លៃទេ ។

### ក) តើស្ដាបនាឡើងវិញយ៉ាងដូចម្ដេចនៅពេលដែលគ្មានសង្គមស៊ីវិល?

វគ្គស្ដីអំពី "ការសម្រេចនូវកម្មសិទ្ធិជាមូលដ្ឋាន" ក្នុងជំពូក "កាតព្វកិច្ចការពារ" ដែលជាផ្នែកធំនៃ "ការទទួលខុសត្រូវក្នុងការស្ដាបនាឡើងវិញ" ផ្ដោតការយកចិត្តទុកដាក់ជាសំខាន់ទៅលើតម្រូវការចាំបាច់ឲ្យមាន "តួអង្គមូលដ្ឋានដើម្បីទទួលខុសត្រូវក្នុងការស្ដាបនាឡើងវិញនូវសង្គមដែលខ្លួនរស់នៅ" នៅក្នុង "ដំណើរការប្រគល់ការទទួលខុសត្រូវដល់សហគមន៍មូលដ្ឋាន" ។

សេចក្ដីបន្ទាប់បែបនេះហូរចេញដោយផ្ទាល់អំពី "តក្កភាពនៃការស្ដាបនាឡើងវិញ" ដោយសន្មតថា សហគមន៍មូលដ្ឋានមានលក្ខណៈ "សមរម្យនិងរៀបចំខ្លួនជាស្រេច" ក្នុងការអនុវត្តផែនការសន្តិភាព ។ ជារឿយៗ សង្គមដែលយាយីដោយជម្លោះមិនត្រឹមតែទទួលរងនូវភាពខ្វះចន្លោះផ្នែកនយោបាយប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងទទួលរងនូវភាពខ្វះចន្លោះផ្នែកសង្គម ជាងនេះទៅទៀតគឺខ្វះសង្គមស៊ីវិលដើម្បីបំពេញមុខងារ ។ ករណីនេះមិនខុសពីករណីប្រទេសកម្ពុជាដែលជាប្រទេសមួយមិនកាន់ប្រពៃណីសង្គមស៊ីវិល ។ ចាប់តាំងពីរដ្ឋប្រហារដឹកនាំដោយសេនាប្រមុខលន់ណុលនៅឆ្នាំ១៩៧០ ប្រជាជនកម្ពុជាទទួលរងនូវអំណាចផ្ដាច់ការជាបន្តបន្ទាប់ ។ ជាលទ្ធផលគឺ គ្មានសង្គមស៊ីវិលឯណាដើម្បីអនុវត្តកម្មវិធីកសាងសន្តិភាពឡើយ ។

ចាប់តាំងពីអង្គការសហប្រជាជាតិចាកចេញពីកម្ពុជានៅឆ្នាំ១៩៩៣ បន្ទុកដ៏ធ្ងន់ធ្ងរនេះត្រូវធ្លាក់មកលើសង្គមស៊ីវិលកម្ពុជាដែលនៅក្មេងខ្ចី ក្នុងការការពារនូវលទ្ធិប្រជាធិបតេយ្យដែលងាយប្រេះស្រាំ ។ ដោយសារអង្គការមិនមែនរដ្ឋាភិបាលជំនាន់មុននៅកម្ពុជា (ដែលភាគច្រើនអង្គការអន្តរជាតិ) គឺជាអង្គការមនុស្សធម៌ ទើបអង្គការទាំងនេះមិនមានសម្ភារគ្រប់គ្រាន់ដើម្បីប្រឈមមុខដោះស្រាយការលំបាកនេះទេ ។ ការកសាងសន្តិភាពដែលបានពិភាក្សាខាងដើម គឺជាកិច្ចខិតខំប្រឹងប្រែងខាងផ្លូវនយោបាយដ៏សំខាន់ ពីព្រោះវាបង្ហាញអំពីប្រជាធិបតេយ្យនីយកម្មក៏ដូចជាតម្រូវការចាំបាច់ក្នុងការចូលរួមជាមួយតួអង្គនយោបាយ ។ ផ្ទុយមកវិញ ទស្សនៈមនុស្សធម៌និយមយល់ថា "មនុស្សធម៌គឺដើម្បីមនុស្សធម៌" ។

ទំនោរបច្ចេកទេសនិងនយោបាយរបស់អង្គការមិនមែនរដ្ឋាភិបាលជំនាន់មុន អាចនិយាយបានថាខ្វះសមត្ថភាពបែបមូលដ្ឋាននៅក្នុងសង្គមដែលងើបចេញពីសង្គ្រាម៣០ឆ្នាំ ពោលគឺខ្វះជំនាញចាត់ចែងអង្គការ ។ ជាលទ្ធផលគឺនាំឲ្យមានការផ្ដោតសំខាន់ហួសហេតុពេកទៅលើជំនួយសង្គ្រោះ (ដែលគេឲ្យឈ្មោះថា "ក្រុមខបត្ថម្ភ") ដែលផ្ដើមចេញពីគំនិតជួយសង្គ្រោះនិងភាពបន្ទាន់ច្រើនជាងធ្វើដើម្បីសម្រេចគោលដៅយូរអង្វែងនៃការផ្លាស់ប្ដូរសង្គមនិងការស្ដាបនាឡើងវិញ ។ ជំនួយមនុស្សធម៌បែបចាស់គំរិលដែលមុជមិនជ្រៅទៅមិនឆ្ងាយពីការកាត់បន្ថយការឈឺចាប់នោះ បដិសេធមិនចូលរួមក្នុង "តួអង្គរួមគ្នា" ដើម្បីដោះស្រាយនូវឫសគល់នៃអំពើឃោរឃៅដែលសំដៅផ្លាស់ប្ដូររចនាសម្ព័ន្ធសង្គម ។ ហេតុដូចនេះ សារជាតិមនុស្សធម៌នៃអង្គការ

មិនមែនរដ្ឋាភិបាលជំនាន់មុន បណ្តាលឲ្យមានកម្មវិធីជំនួយសង្គ្រោះ (មិនមែនជាអ្នកអន្តរាគមន៍) ដែលងាកចេញពីជំនួយកសាងសន្តិភាពដែលផ្អែកលើគោលនយោបាយ ។ ជំនួយក្នុងការកសាងសន្តិភាពដែលផ្អែកលើគោលនយោបាយពិតជាមានសារសំខាន់ បើចង់ឲ្យរចនាសម្ព័ន្ធប្រជាធិបតេយ្យប្រឌិតឡើងដោយអ៊ុនគាត់ នាំមកនូវការផ្លាស់ប្តូរសង្គម ។

ការពិភាក្សាលើមូលហេតុសីលធម៌នៃជំនួយមនុស្សធម៌ មានលក្ខណៈហួសពីដែនកំណត់នៃការពិភាក្សានៅក្នុងនិក្ខេបបទនេះ ប៉ុន្តែជាការចាំបាច់គឺត្រូវកត់សម្គាល់ថា ជំនួយបែបនេះជាការប្រថុយនឹងការពង្រឹងនូវសារជាតិលូនក្រាបដែលជាសំណាញ់គ្របសង្គមខ្មែរ ។ សំណាញ់នេះគឺជា “គំរូនៃការពឹងផ្អែក” ដែលតម្រូវឲ្យមានការផ្លាស់ប្តូរទៅរកបទដ្ឋានប្រជាធិបតេយ្យ ។ ចំណុចនេះមានលើកឡើងនៅក្នុងរបាយការណ៍របស់អង្គការអភិវឌ្ឍន៍និងការស្រាវជ្រាវកម្ពុជាឆ្នាំ១៩៩៨-៩៩ ដែលមានចំណងជើងថា “ការឆ្លុះបញ្ចាំងទៅលើការអនុវត្តន៍កម្មវិធីសន្តិភាព” ដែលចោទប្រកាន់អង្គការមិនមែនរដ្ឋាភិបាលថា “មានទំនោរតែទៅរកការធ្វើអំពើល្អ ប៉ុន្តែមិនបញ្ឈប់អំពើអាក្រក់” ជាបញ្ហាដែលបញ្ចេះអំពើឃោរឃៅ ។ អង្គការមិនមែនរដ្ឋាភិបាលក៏សន្មតងាយពេកដែរថា ឥទ្ធិពលមកលើបុគ្គលជាស្វ័យប្រវត្តិបន្ថែមមកលើឥទ្ធិពលសង្គម-នយោបាយទូទៅ» ។ ការទោរទន់ទៅរកនយោបាយរបស់អង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជាពិតជាមិនស័ក្តិសមចំពោះបម្លាស់ប្តូរសង្គមទេ ។

ជាចុងក្រោយ ភាពលម្អៀងទៅរកនយោបាយរបស់អង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជាអាចមានប្រភពចេញពីឧបសគ្គខាងវប្បធម៌បីយ៉ាងដែលបង្កើតឡើងដោយរបបខ្មែរក្រហម និងដែលប៉ះពាល់ដល់ការអភិវឌ្ឍន៍សង្គមស៊ីវិល ។ ឧបសគ្គទីមួយគឺស្ទាក់ស្ទើរមិនហ៊ានទុកចិត្តគ្នា ទីពីរ ស្ទាក់ស្ទើរមិនហ៊ានដាក់ផែនការ និង ទីបី ស្ទាក់ស្ទើរមិនហ៊ានធ្វើសេចក្តីសម្រេចចិត្ត ។ ដេវីត ឆេនដល័រ ពន្យល់ថា “នៅក្នុងអំឡុងសម័យខ្មែរក្រហម ប្រជាជនមិនអាចទុកចិត្តមិត្តភក្តិ អ្នកជិតខាង បងប្អូន ឬសូម្បីតែកូនបង្កើតរបស់ខ្លួនក៏មិនទុកចិត្តដែរ ។ កង្វះទំនុកចិត្តនៅតែមានមកទល់សព្វថ្ងៃ ហើយប្រការនេះរារាំងដល់ការអភិវឌ្ឍន៍សង្គមស៊ីវិល ។ គេអាចមើលឃើញប្រការនេះតាមរយៈកង្វះសហប្រតិបត្តិការនិងការសម្របសម្រួលរវាងសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ។ ឆេនដល័រ ក៏បានពន្យល់អំពីការរិះគន់ជាបន្តបន្ទាប់ពីសំណាក់ជនបរទេស អំពីជនជាតិខ្មែរដែលជាទូទៅខ្វះការយល់ឃើញឲ្យបានវែងឆ្ងាយទៅថ្ងៃមុខ និងខ្វះការរៀបចំផែនការ ។ ការនិយាយបែបនេះគឺយោងទៅលើការប្រយុទ្ធរវាងខ្មែរគ្នាឯង និងការផ្លាស់ប្តូរសង្គមជាបន្តបន្ទាប់នៅក្នុងបីទសវត្សរ៍កន្លងមក ជាពិសេសនៅក្នុងរបបខ្មែរក្រហម “ពេលដែលជួបស្ថានការណ៍មួយថ្ងៃរស់មួយថ្ងៃស្លាប់” ។ កេរដំណែលទីបីបន្សល់ទុកដោយខ្មែរក្រហម (នៅពេលដែលការសម្រេចចិត្តខុសអាចបណ្តាលឲ្យមានការផ្តន្ទាទោសធ្ងន់ធ្ងរឬដល់ស្លាប់) គឺការស្ទាក់ស្ទើរមិនហ៊ានសម្រេចចិត្ត ដែលនេះជាការបន្ទុចបន្ទាក់ដ៏ជាក់ច្បាស់មួយទៀតដល់ការរីកចម្រើននៃសង្គមស៊ីវិល ។

ការពិភាក្សាដោយសង្ខេបទៅលើរចនាសម្ព័ន្ធនៃសង្គមកម្ពុជាក្រោយពីមានជម្លោះ គឺចង់សំដៅគូសបញ្ជាក់អំពីការជឿខុសដែលមាននៅក្នុងទ្រឹស្តីនៃការទទួលខុសត្រូវក្នុងការស្តាបនាឡើងវិញថា “ការសម្រេចនូវកម្មសិទ្ធិមូលដ្ឋាន” គ្រាន់តែជាបញ្ហានៃ “ការអភិវឌ្ឍន៍សមត្ថភាពមូលដ្ឋាន” ប៉ុណ្ណោះ ដែលហាក់បីដូចជាទឹកដីនៃសង្គមក្រោយជម្លោះមានលក្ខណៈដូចជាលោកខាងលិច ឬយ៉ាងហោចណាស់ហាក់ដូចជាមានលក្ខណៈសមស្របបំផុតទៅនឹងការរីកចម្រើននៃសង្គមស៊ីវិលដែលងាយនឹងប្រេះស្រាំ ។ តថភាពវប្បធម៌នៅកម្ពុជាមានលក្ខណៈផ្ទុយពីនេះ ហើយជាថ្មីម្តងទៀតជួយឲ្យមានតម្រូវការស្តាបនាតាមវិធីផ្សេងពីនេះ ពោលគឺស្តាបនារចនាសម្ព័ន្ធសង្គមនិងរូបវន្ត ។

## ៦) កម្មវិធីរបស់ម្ចាស់ជំនួយសម្រាប់ការស្តាបនាសេដ្ឋកិច្ចឡើងវិញ

ទោះជាអង្គការមិនមែនរដ្ឋាភិបាលជាច្រើននៅកម្ពុជាបានចាប់ផ្តើមមានបុគ្គលិកក្នុងស្រុកក៏ដោយ ក៏ភាគច្រើននៃអង្គការទាំងនេះនៅតែធ្វើតាមគំនិតរបស់ម្ចាស់ជំនួយនៅឡើយ ដោយទទួលរងនូវអ្វីដែល ម៉ារី អាន់ឌឺសេន ហៅថា “ជាការគ្រប់គ្រងទិន្នផលនិងផ្តោតទៅលើជំនួយបែបមជ្ឈការ” ។

វគ្គនេះគ្មានបំណងវិនិច្ឆ័យទៅលើឧស្សាហកម្មជំនួយនោះទេ

ពីព្រោះថាមានសំណេរជាច្រើនមានលក្ខណៈស៊ីជម្រៅក្នុងការបង្ហាញអំពីរបៀបដែលអង្គការមិនមែនរដ្ឋាភិបាលត្រូវបានលើកទឹកចិត្តឲ្យដោះស្រាយនូវភាពចាំបាច់របស់ម្ចាស់ជំនួយ ជាជាងតម្រូវតាមភាពចាំបាច់របស់អ្នកដែលទទួលផលប្រយោជន៍ពិតប្រាកដ ។ ពិសេសជាងនេះទៅទៀត «ចរន្តទៅវិញទៅមក» នៃទំនាក់ទំនងរវាងម្ចាស់ជំនួយនិងអង្គការមិនមែនរដ្ឋាភិបាល នឹងត្រូវបានដោះស្រាយដើម្បីចៀសវាងកុំឲ្យប្រាសចាកពីផ្លូវនៃគំនិតដែលធ្វើឡើងតាំងពីដើមដំបូងនៃនិក្ខេបបទនេះ ។ មានការទាញហេតុផលថា ប្រភពនៃភាពបរាជ័យរបស់អ៊ុនតាក់មិនគួរត្រូវបានរកឃើញនៅក្នុងការសិក្សាលម្អិត «ផ្នែកបច្ចេកទេស» នៃការអនុវត្តន៍ផែនការនោះទេ ប៉ុន្តែគួរតែរកឃើញនៅក្នុងសារជាតិនៃផែនការនេះផ្ទាល់ ។ ហេតុផលដូចគ្នានេះដែរគឺការពិនិត្យដោយសង្ខេបទៅលើកម្លាំងជំរុញរវាងម្ចាស់ជំនួយនិងអង្គការមិនមែនរដ្ឋាភិបាល នឹងដោះស្រាយទៅលើសារជាតិនៃទំនាក់ទំនងជាដៃគូ ជាជាងកង្វះខាតទាក់ទងនឹងការចាត់ចែងដែលធ្វើឲ្យអន្តរាយដល់សម្ព័ន្ធភាពរបស់ខ្លួន (ដែលមានចំនួនច្រើនអនេក) ។

សារជាតិនៃភាពជាដៃគូរវាងម្ចាស់ជំនួយនិងអង្គការមិនមែនរដ្ឋាភិបាលនៅក្នុងប្រទេសកម្ពុជាកន្លងមកក៏ដូចជាបច្ចុប្បន្ន គឺថាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកជាអ្នក «ផ្តល់» នូវសេវាឬទំនិញដែលនឹងជំរុញដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ច ។ ដូចដែលបានរាយការណ៍ដោយ ប្រោន និង ធីមប៊ើមែន ដែរថា នៅពេលដែលអង្គការសហប្រជាជាតិចាកចេញក្រោយពីការបោះឆ្នោតរួចម្ចាស់ជំនួយអន្តរជាតិភាគច្រើនសន្និដ្ឋានថា ការសង្កត់ធ្ងន់ទៅលើការអភិវឌ្ឍន៍សេដ្ឋកិច្ចជាជាងផ្តោតសំខាន់ទៅលើការកែប្រែសង្គម អាចនឹងធានានូវសន្តិភាពនិងស្ថិរភាពនៅក្នុងប្រទេសកម្ពុជា ។ ការខុបត្ថម្ភគាំទ្រកម្រិតខ្ពស់របស់អន្តរជាតិចំពោះប្រជាធិបតេយ្យនីយកម្មរដ្ឋាភិបាលនិងសង្គមកម្ពុជា បានធ្លាក់ចុះយ៉ាងគំហុកក្រោយពីមានការបោះឆ្នោត ។ ម្ចាស់ជំនួយអន្តរជាតិជាច្រើនបានផ្តោតការយកចិត្តទុកដាក់មកលើការស្តាបនាកម្ពុជាឡើងវិញនិងការអភិវឌ្ឍន៍សេដ្ឋកិច្ច មិនមែនបន្តការយកចិត្តទុកដាក់មកលើការអភិវឌ្ឍន៍នយោបាយទៀតឡើយ ។

ការខកខានរបស់ម្ចាស់ជំនួយក្នុងការទទួលស្គាល់ថាមានភាពចាំបាច់ក្នុងការស្តាបនាជាថ្មីនូវរចនាសម្ព័ន្ធសង្គមកម្ពុជា បាននាំដល់បរាជ័យក្នុងការវិនិយោគវិស័យអភិវឌ្ឍន៍សមត្ថភាពរយៈពេលយូរអង្វែងទៅលើអង្គការដែលមានមូលដ្ឋាននៅសហគមន៍ផ្ទាល់ឬថ្នាក់ដឹកនាំមូលដ្ឋាន ។ អង្គការអភិវឌ្ឍន៍និងស្រាវជ្រាវកម្ពុជាបានបង្កើតគម្រោងសិក្សាមួយនៅឆ្នាំ១៩៩៨-៩៩ ក្នុងគោលបំណងវាស់ស្ទង់កម្រិតនៃជំនួយបច្ចេកទេសដែលអាចអភិវឌ្ឍន៍សមត្ថភាពរបស់ប្រទេសកម្ពុជា ហើយបានចេញរបាយការណ៍មកថា «បទពិសោធន៍កម្ពុជាចាប់តាំងពីឆ្នាំ១៩៩៣បង្ហាញថា គម្រោងកម្មវិធីភាគច្រើនគឺផ្តើមចេញពីម្ចាស់ជំនួយដែលជាអ្នកកំណត់ ជាអ្នកគូសវាស និងជាអ្នកអនុវត្ត រហូតទៅដល់ការធ្វើឲ្យអន្តរាយដល់ការអភិវឌ្ឍន៍សមត្ថភាពជាលក្ខណៈស្ថាប័នទៀតផង» ។ របាយការណ៍បន្តព្រមានដល់ការបង្ខំឲ្យអនុវត្តគម្រោងកម្មវិធីដោយប្រសិទ្ធភាព សង្កត់ធ្ងន់លើ «ផលិតផល» និង «ហេតុការណ៍» ជាជាងបង្កើតនូវយុទ្ធសាស្ត្រផែនការនយោបាយដែលផ្តល់លទ្ធភាពអប់រំ និងដែលអាចផ្តល់អំណាចដល់ប្រជាជននៅតាមមូលដ្ឋាន ។ ជាការច្បាស់ណាស់ថា ការផ្តោតសំខាន់ទៅលើ «លទ្ធផល» និង «ផលិតផល» គឺមិនស៊ីគ្នាជាមួយដំណើរការប្រែក្លាយសង្គមទេ ដែលនេះតម្រូវឲ្យ «សម្រេចបាននូវកម្មសិទ្ធិជាមូលដ្ឋាននៃសន្តិភាព» ។

គួរកត់សម្គាល់ទៅលើចំណុចចុងក្រោយនៃរបាយការណ៍នេះដែលថា «យុទ្ធសាស្ត្រដែលជំរុញដោយម្ចាស់ជំនួយ គឺពុំមានសមធម៌ឡើយ» ។ ការសង្កេតនេះគូសបញ្ជាក់អំពីផលវិបាកដែលមានផលប៉ះពាល់ខ្លាំងចេញពីការអនុវត្តរបស់អង្គការមិនមែនរដ្ឋាភិបាល ទៅលើ «ការផ្តល់សេវានិងទំនិញសេដ្ឋកិច្ច» មានដូចជាការឆ្លើយតបដោយស្ងៀមស្ងាត់ទៅតាមទម្លាប់លូនក្រាបដែលជាមូលដ្ឋាននៃរចនាសម្ព័ន្ធសង្គមកម្ពុជា ។ និយាយត្រឹមនេះ គេអាចទាញហេតុផលបានថា តាមពិត «ផែនការដែលជំរុញដោយសេដ្ឋកិច្ច» បែបនេះបានរារាំងដល់ការកសាងនូវ «សន្តិភាពតាមរយៈប្រជាធិបតេយ្យ» ។

## ផ្នែកទី៣ ការរៀបចំកែប្រែសង្គម

«សន្តិភាពតាមរយៈប្រជាធិបតេយ្យ» មិនមែនជាអ្វីដែលគេអាច «ស្តាបនាឡើងវិញ» ជាន់ពីលើនោះទេ ។ ដូចដែលបាន

លើកឡើងនៅក្នុងវគ្គមុន ការគិតអំពីសង្គមស៊ីវិលនៅក្នុងប្រទេសកម្ពុជាមិនទាន់មានទេកាលពីមុន ដែលជាការមិនជាក់ស្តែងចំពោះអ៊ុនតាក់ក្នុងការសន្និដ្ឋានថា កិច្ចព្រមព្រៀងសន្តិភាពដែលចុះហត្ថលេខាដោយមេដឹកនាំនយោបាយជាន់ខ្ពស់ អាចហូរពីលើចុះមកក្រោមដល់មូលដ្ឋាន ។ "សន្តិភាពតាមរយៈប្រជាធិបតេយ្យ" ត្រូវបាននិយាយថា គឺជាលទ្ធផលចុងក្រោយនៃដំណើរការផ្លាស់ប្តូរសង្គមរយៈពេលវែង ពោលគឺជាការកែប្រែសង្គមដែលអង្គការមនុស្សធម៌ពិបាកប៉ុនប៉ង ។ កម្មវិធីរបស់អង្គការទាំងនេះផ្តល់អាទិភាពទៅលើដំណោះស្រាយកំណើនសេដ្ឋកិច្ច ។ ស្តែងចេញពីហេតុផលនេះ សំណួរសំខាន់មួយដែលមិនទាន់បានដោះស្រាយគឺ *តើការផ្លាស់ប្តូរជាក់ស្តែងអ្វីខ្លះដែលតម្រូវជាចាំបាច់ក្នុងការ "សម្រេចបាននូវកម្មសិទ្ធិជាមូលដ្ឋាន" នៃសន្តិភាព?*

ខណៈដែល ឡៃហ្ស៊ី អះអាងថា ការផ្តោតសំខាន់លើគោលបំណងនៃការបោះឆ្នោតបានរួមចំណែកដល់ការបរាជ័យនោះ គាត់បានផ្តល់ដំបូន្មានមួយចំនួនទាក់ទងនឹងរបៀបកសាងសន្តិភាពនៅថ្នាក់មូលដ្ឋាន ។ វគ្គនេះមានបំណងបន្ថែមពីលើការពិពណ៌នារបស់ ឡៃហ្ស៊ី អំពី "ភាពទទេស្អាត" នៃសន្តិភាពតាមរយៈប្រជាធិបតេយ្យដែលត្រូវបានចុះកិច្ចព្រមព្រៀងដោយថ្នាក់លើ ដើម្បីកំណត់នូវតួនាទីពាក់ព័ន្ធរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងការកសាងសន្តិភាពនៅតាមមូលដ្ឋាន ។

ទីមួយ ខ្ញុំនឹងបង្ហាញជូនអំពីបុព្វលក្ខខណ្ឌដែលត្រូវបានមើលរំលង សម្រាប់ទទួលយកបទដ្ឋាននិងតម្លៃប្រជាធិបតេយ្យនៅក្នុងសង្គមខ្មែរ ដែលជាការផ្តល់នូវសន្តិសុខគ្រប់គ្រាន់ ។ បន្ទាប់មក ខ្ញុំនឹងពិភាក្សាអំពីគម្រោងកម្មវិធីដែលកំពុងតែអនុវត្តទៅលើវិមជ្ឈការគ្រប់គ្រងនៅក្នុងប្រទេសកម្ពុជា ជាការកែទម្រង់មួយដែលអង្គការមិនមែនរដ្ឋាភិបាលនិងម្ចាស់ជំនួយគួរតែចូលរួមឲ្យបានសកម្ម ដើម្បីឲ្យគម្រោងការនេះមានសក្តានុពលធំធេងប្រយោជន៍ដើម្បីកែប្រែសង្គមនៅតាមមូលដ្ឋាន ។

### ក) "សន្តិភាពតាមរយៈសន្តិសុខ"៖ បុព្វលក្ខខណ្ឌនាំដល់លទ្ធិប្រជាធិបតេយ្យ

អស់រយៈពេលពាទសវត្សរ៍មកនេះ ប្រទេសកម្ពុជាទទួលរងការគំរាមកំហែងដោយសោកនាដកម្ម អំពើឃោរឃៅ និងការបំផ្លិចបំផ្លាញ ។ ជីវិតរបស់ប្រជាជនត្រូវបានញាំញីដោយជម្លោះនិងការមិនគោរពសិទ្ធិមនុស្សអស់ជាច្រើនឆ្នាំ ។ ឆ្លងតាមការពិនិត្យទៅលើកាលៈទេសៈអសន្តិសុខខ្ពស់បែបនេះ មានហេតុផលមួយត្រូវបានលើកឡើងថា "ដោយសារប្រវត្តិកម្ពុជាពោរពេញទៅដោយនយោបាយហិង្សា ប្រជាធិបតេយ្យនីយកម្មនៃសន្តិសុខដែលគេសំដៅដល់សន្តិសុខមនុស្សជាតិ គឺជាជំហានសំខាន់ដំបូង ជាបុព្វលក្ខខណ្ឌជាសារវន្តមុនពេលចូលរួមនៅក្នុងប្រជាធិបតេយ្យនីយកម្មអំណាច ។ តាមការពិត មានតែតាមរយៈការ "ធ្វើប្រជាធិបតេយ្យនីយកម្ម" សន្តិសុខទេ ទើប "អភិបាលកិច្ចខាងនយោបាយ" ដែលជាលក្ខណៈពិសេសនៃនយោបាយកម្ពុជា លែងត្រូវការឲ្យមានការគាំពារជាលក្ខណៈបុគ្គល ដែលតាមរយៈនេះធ្វើឲ្យទស្សនៈ "សន្តិភាពកើតចេញពីប្រជាធិបតេយ្យ" នៅកម្ពុជាគួរឲ្យជឿទុកចិត្តបាន ។

ម្យ៉ាងវិញទៀត ទស្សនៈ "សន្តិភាពជាសន្តិសុខមនុស្សជាតិ" ទំនងជាល្បីខ្ទរខ្ទារនៅតាមមូលដ្ឋានក្នុងពេលដែលកម្ពុជាមានអសន្តិសុខខ្លាំង ជាងវិធីសាស្ត្រធម្មតាចំពោះការកសាងសន្តិភាពដែលលើកតម្កើងគំនិតដោយត្រង់ៗថា ប្រជាធិបតេយ្យគឺជាកូនសោរនៃសន្តិភាព ។ បើចង់ឲ្យមានការគាំទ្រចំពោះអង្គការសង្គមស៊ីវិលក្នុងប្រទេសកម្ពុជាក្នុងកម្មវិធីសន្តិសុខមនុស្សជាតិទូទៅ ជំហានដំបូងគឺត្រូវបែងចែកឲ្យដាច់រវាង "សន្តិសុខមនុស្សជាតិ" និង "ការអភិវឌ្ឍន៍មនុស្សជាតិ" ដើម្បីបញ្ជាក់ឲ្យបានច្បាស់អំពី "ភាពថ្មីប្លែក" របស់គោលដៅនយោបាយដែលស្នើឡើង ។ របាយការណ៍អភិវឌ្ឍន៍មនុស្សជាតិរបស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិបានឲ្យដឹងថា សកម្មភាពនានាដែលសំដៅជំរុញការអភិវឌ្ឍន៍មនុស្សជាតិ ត្រូវបានធ្វើឡើងដើម្បីពង្រីកជម្រើសផ្សេងៗរបស់ប្រជាជន ។ វាជាការបញ្ចប់ដោយខ្លួនឯង ហើយបង្ហាញអំពីគោលបំណងរបស់ភ្នាក់ងារជំនួយភាគច្រើនដែលបានចូលរួមនៅក្នុងការស្តាបនាកម្ពុជាឡើងវិញ ។ ម្យ៉ាងវិញទៀតគោលបំណងនៃសន្តិសុខមនុស្សជាតិគឺដើម្បីធានាថា "ប្រជាជននឹងមានលទ្ធភាពជ្រើសរើសដោយសុវត្ថិភាពនិងដោយសេរី" ។

**(នៅមានត)** **ម៉ារី ឡាប៊ីក**

ក្រោយពីរបបខ្មែរក្រហមដួលរលំ  ប្រជាជនវិលត្រឡប់ទៅស្រុកកំណើតវិញ ១៩៧៩



# មេដឹកនាំខ្មែរក្រហមវាយបកទៅអ្នករិះគន់

ថ្ងៃទី១៧ ខែមេសា ឆ្នាំ២០០៤ ជាខួបលើកទី២៩នៃការកាន់កាប់របស់ខ្មែរក្រហមមកលើប្រទេសកម្ពុជា ។ នៅក្នុងរយៈពេល៣ឆ្នាំ ៨ខែនិង២០ថ្ងៃនៃការកាន់កាប់ប្រទេស ប្រជាជនខ្មែរជិត២លាននាក់បានស្លាប់បាត់បង់ជីវិត ។ ប្រជាជនមួយចំនួនត្រូវបង្ខំឲ្យធ្វើការជាទម្ងន់រហូតដល់ស្លាប់ ខ្លះត្រូវសម្លាប់ដោយវាយនឹងត្បូងចបទៅលើកញ្ចឹងក ហើយអ្នកខ្លះទៀតត្រូវបញ្ជូនទៅគុកទួលស្លែង ដែលនៅទីនោះត្រូវចាប់បង្ខំថតរូប សួរចម្លើយធ្វើទារុណកម្ម និងសម្លាប់ចោល ។ ក្រោយពីបានចរចាអស់រយៈពេល៦ឆ្នាំ អង្គការសហប្រជាជាតិនិងរដ្ឋាភិបាលកម្ពុជាបានសម្រេចបង្កើត “តុលាការចម្រុះកាត់សេចក្តីបទឧក្រិដ្ឋសង្គ្រាម” ។ សូម្បីតែក្រោយពីបានបង្ខំឲ្យអង្គការសហប្រជាជាតិប្រគល់ដល់ប្រទេសកម្ពុជានូវចំនួនភាគច្រើននៅរាល់អង្គជំនុំជម្រះ សំណួរសំខាន់មួយនៅមិនទាន់ឆ្លើយចេញគឺ តើនាយករដ្ឋមន្ត្រី ហ៊ុន សែន មានឆន្ទៈនយោបាយក្នុងការគាំទ្រដល់ការកាត់សេចក្តីបទឧក្រិដ្ឋសង្គ្រាមដែលស្របច្បាប់ឬទេ?

ទោះបីជាសំណួរនេះជាការព្រួយបារម្ភរបស់បញ្ញាជនលោកខាងលិចនិងទីប្រឹក្សាសិទ្ធិមនុស្សក៏ដោយ វានៅតែមិនច្បាស់លាស់ចំពោះប្រជាជនកម្ពុជាជាច្រើននាក់ ដោយសារមូលហេតុត្រឹមត្រូវមួយចំនួន ។ នៅក្នុងអំឡុងពេល៣ទសវត្សរ៍មុន ប្រជាជនកម្ពុជាទទួលការឃោសនានយោបាយបាយមិនចុះសម្រុងគ្នាពីរបប លន់ ណុល គាំទ្រដោយសហរដ្ឋអាមេរិក (១៩៧០-៧៤) ពីរបបខ្មែរក្រហម (១៩៧៥-៧៩) ពីរបបសាធារណរដ្ឋប្រជាមានិតកម្ពុជាបង្កើតដោយវៀតណាម (១៩៧៩-៩១) និងពីអាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា (១៩៩២-៩៣) ។ ទោះបីជាមិនទាន់មានដីកាចោទប្រកាន់ ហើយកាលបរិច្ឆេទកាត់ទោសមិនទាន់កំណត់ក៏ដោយ ក៏អតីតមេដឹកនាំខ្មែរក្រហមកំពុងតែសាកល្បងរៀបចំការពារខ្លួននៅក្នុងតុលាការនៃមតិសាធារណៈ ។

ដោយប្រកាន់យកអាកប្បកិរិយាមុនការជម្រះក្តីដូចជាហ្គូអ៊ីរិងហ្គិស នួន ជា អាយុ៧៦ឆ្នាំ អះអាងថា ការកាត់ទោសគាត់គួរតែមិនចំណាយពេលវេលាយូរទេ ពីព្រោះគាត់គ្មានគម្រោងប្តឹងឧទ្ធរណ៍ ។ ថ្មីៗនេះ នួន ជា បានចោទសួរអំពីភាពបរិសុទ្ធនៃគុកទួលស្លែង ដែលជាកន្លែងមួយដែលមានមនុស្សប្រមាណ១ម៉ឺន៤ពាន់នាក់ត្រូវគេបញ្ជូនចូល ហើយមានតែប៉ុន្មាននាក់ប៉ុណ្ណោះដែលមានជីវិតរស់ចេញមកវិញ ។ នួន ជា ពោលថា “ពួកមនុស្សអាក្រក់ជាអ្នកក្លែងបន្លំ ។ គេត្រួតត្រាយើងអស់ជាច្រើនឆ្នាំ ហេតុនេះគេអាចបង្កើតគុកបែបនេះបាន” ។ ទោះជាត្រូវកាត់ទោសឬមិនត្រូវកាត់ទោស នួន ជា នៅតែមានជំនឿរហូតថ្ងៃស្លាប់ថាបដិវត្តន៍របស់គាត់បានជួយសង្គ្រោះកម្ពុជាពីការលេបត្របាក់របស់វៀតណាម ។ នួន ជា បានពោលថា “ពេលខ្ញុំស្លាប់ ឧត្តមគតិរបស់ខ្ញុំនឹងនៅរស់សម្រាប់ក្មេងជំនាន់ក្រោយ” ។

ខៀវ សំផន អាយុ៧២ឆ្នាំ មានតួនាទីជាប្រធានាធិបតីនិងជាអ្នកចេញមុខចេញមាត់នៃរបបកម្ពុជាប្រជាធិបតេយ្យរបស់ ប៉ុល ពត ពីទសវត្សរ៍ឆ្នាំ៧០រហូតដល់ទសវត្សរ៍ឆ្នាំ៩០ ។ ថ្មីៗនេះ ខៀវ សំផន បានបោះពុម្ពសៀវភៅមួយជាភាសាខ្មែរនិងភាសាបារាំង មានចំណងជើងថា “ប្រវត្តិសាស្ត្រកម្ពុជាថ្មីៗនេះ និងគោលជំហររបស់ខ្ញុំជាបន្តបន្ទាប់” ។ ក្នុងសៀវភៅនោះ មេធាវីបារាំង ហ្សាក់ វែរហែស ដែលល្បីឈ្មោះខាងការការពារក្តីឲ្យឧក្រិដ្ឋជនធំៗ ជាអ្នកសរសេរអត្ថបទមួយនៅលើទំព័រដំបូងនៃសៀវភៅ ថានឹងការពារក្តីឲ្យ ខៀវ សំផន ។ វែរហែស បកស្រាយថា ខៀវ សំផន ជាអ្នកបដិវត្តន៍ឧត្តមគតិនិយមមួយរូបដែលផុងខ្លួននៅក្រោមសម្ពាធនៃសង្គ្រាមត្រជាក់ ។ បេក្ខជននៃការកាត់ទោសពីបទឧក្រិដ្ឋសង្គ្រាមមួយរូបនេះបានរួមផ្សំភាពប៉ិនប្រសប់របស់ ស្តៀវ អាល់ប៊ឺត ជាមួយនឹងការបដិសេធមិនទទួលខុសត្រូវរបស់ ហិស រ៉ូដុហ្វ ។ (ស្តៀវគឺជារដ្ឋមន្ត្រីទទួលបន្ទុកផ្នែកសព្វាវុធរបស់អ៊ីត្លែរពីឆ្នាំ១៩៤២ដល់ឆ្នាំ១៩៤៥ ។ ក្រោយសង្គ្រាមលោកលើកទីពីរ ស្តៀវត្រូវបានកាត់ទោសនៅនូរឹមប៊ឺកពីបទឧក្រិដ្ឋកម្មសង្គ្រាមនិងឧក្រិដ្ឋ

កម្មប្រឆាំងមនុស្សជាតិ ហើយត្រូវសម្រេចឲ្យជាប់ពន្ធនាគាររយៈពេល២០ឆ្នាំ ។ ចំណែក ហិស ជាជនជិតរបស់ អ៊ីត្វែរ ។ ហិស ត្រូវតុលាការនូរីមប៊ឺកកាត់ទោសឲ្យជាប់ពន្ធនាគារអស់មួយជីវិត) ។

បច្ចុប្បន្ន ខៀវ សំផន អះអាងថា នៅក្នុងរបបខ្មែរក្រហម គាត់ «មិនមានអំណាច» អ្វីទាំងអស់ គឺគ្រាន់តែអាច «អង្គុយសោកស្តាយនិងអស់សង្ឃឹមដោយស្ងៀមស្ងាត់តែប៉ុណ្ណោះ» ។ ខៀវ សំផន បដិសេធដោយត្រង់ៗនូវការចោទប្រកាន់ថាគាត់បានបង្កឲ្យមានអំពើប្រល័យពូជសាសន៍នៅកម្ពុជា ឬបានជួយបិទបាំងការបង្កើតរបបបែបនោះ ។ ខៀវ សំផន ពោលថាតួនាទីរបស់គាត់ជាប្រធានាធិបតីរបស់បក្សកុម្មុយនិស្តកម្ពុជាគឺជាតំណែងដែលមានតែឈ្មោះប៉ុណ្ណោះ ។ ខៀវ សំផន បានបកស្រាយថា ពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៨ គាត់«នៅក្រៅថ្នាក់ដឹកនាំស្នូល» ហើយមិនសូវដឹងពុំអំពីអ្វីដែលបានកើតឡើងពិតប្រាកដនៅក្នុងប្រទេសទេ ។ ខៀវ សំផន អះអាងថា គាត់មិនបានដឹងពុំអំពីការរាលដាលនៃអំពើឃោរឃៅឡើយ ។

លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា បានលើកឡើងអំពីការពិតដ៏សោកសៅមួយដែលមនុស្សជាច្រើននៅឆ្ងាយពីប្រទេសកម្ពុជាតែងតែអើពើនោះគឺ «សាធារណជនគួរតែដឹងថា ច្បាប់និងភ័ស្តុតាងមិនខ្វះទេ ប៉ុន្តែឆន្ទៈនយោបាយជាបញ្ហាចោទនៅក្នុងការកាត់ទោសមេដឹកនាំខ្មែរក្រហម» ។ ច្បាប់អន្តរជាតិ សិទ្ធិមនុស្ស និងតុលាការព្រហ្មទណ្ឌអន្តរជាតិគ្រាន់តែជាសំឡេងមិនមានឥទ្ធិពលប៉ុណ្ណោះប្រសិនបើគ្មានឆន្ទៈនយោបាយ ។ ខាស្តេន ហេរែល ប្រធានក្រុមការងារតុលាការខ្មែរក្រហមខាងអង្គការសហប្រជាជាតិ បាននិយាយទៅអ្នកសារព័ត៌មានមួយរូបថា «យើងឋិតនៅក្រោមមេត្តាករុណានៃនយោបាយផ្ទៃក្នុងរបស់កម្ពុជា» ។ មិនដែលមានកង្វះខាតភ័ស្តុតាងនៅក្នុងការកាត់ក្តីខ្មែរក្រហមទេ មានតែកង្វះខាតឆន្ទៈនយោបាយប៉ុណ្ណោះ ។ ប្រសិនបើតុលាការខ្មែរក្រហមពិតជានឹងកើតឡើងដោគជ័យឬបរាជ័យរបស់តុលាការនេះមិនអាស្រ័យលើកិច្ចព្រម សេចក្តីព្រាង ឬចំណុចបច្ចេកទេសនៃច្បាប់នោះទេ គឺវាអាស្រ័យទៅលើឆន្ទៈនយោបាយរបស់នាយករដ្ឋមន្ត្រីកម្ពុជា ហ៊ុន សែន ។ មិនយូរមិនឆាប់ មេដឹកនាំកម្ពុជាត្រូវតែសម្រេចថាតើត្រូវប្រគល់ខ្លួនមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលអាចចោទប្រកាន់បាន ទៅកាន់តុលាការឬទេ ។

**ភីតធ័រ ម៉ាឃ្យៀរ**

# គ្រួសារខ្ញុំ

កុមារដែលមានរូបរាងស្គមស្គាំង ដៃជើងស៊ិតៗ ក្បាលធំ នៅនឹងកដើងមានចង្រ្កង់មួយ ជួនកាលទធាក់ជើងពុក្រើងៗ នោះគឺជារូបខ្ញុំក្នុងរបបប៉ុលពត ។ នេះគឺជាសម្តីរបស់ម្តាយខ្ញុំ ។ រូបខ្ញុំចាប់កំណើតនៅក្នុងរបបខ្មែរក្រហម គឺនៅឆ្នាំ១៩៧៦ ។ ស្រុកកំណើតរបស់ខ្ញុំគឺភូមិតារាម ឃុំត្បែង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ។ ខ្ញុំរៀនថ្នាក់បឋមសិក្សានៅក្នុងភូមិកំណើត និងបន្តការសិក្សាថ្នាក់អនុវិទ្យាល័យនិងវិទ្យាល័យនៅទីរួមខេត្តកំពង់ធំ ។ បន្ទាប់មក ខ្ញុំរៀននៅមហាវិទ្យាល័យពេទ្យនៅទីក្រុងភ្នំពេញ ។ សព្វថ្ងៃនេះ ខ្ញុំជាឱសថការីមួយរូប ។

កាលពីឱកាសចូលឆ្នាំខ្មែរកន្លងទៅនេះ ខ្ញុំបានត្រឡប់ទៅស្រុកកំណើតរបស់ខ្ញុំ ។ ក្នុងឱកាសជួបជុំគ្រួសារ ខ្ញុំបានសាកសួរបងៗនិងម៉ែអំពីរឿងរ៉ាវកាលពីរបបខ្មែរក្រហម ។ ម៉ែបានប្រាប់ខ្ញុំថា មុនឆ្នាំ១៩៧០ គ្រួសារយើងរស់នៅទីរួមខេត្តកំពង់ធំ ។ ប៉ាមានមុខរបរជាអ្នកលក់សំបុត្ររថយន្តនៅចំណតរថយន្តខេត្តកំពង់ធំ ។ ម៉ែលក់ដូរបន្តិចបន្តួច ។ ក្រុមគ្រួសាររបស់ខ្ញុំមានសមាជិក៧នាក់ គឺឪពុកម្តាយនិងបងៗ៥នាក់ ។

នៅដើមខែឧសភា ឆ្នាំ១៩៧០ ក្រុមគ្រួសារយើងបានសម្រេចចិត្តចាកចេញពីទីរួមខេត្តកំពង់ធំទៅស្វែងរកកន្លែងផ្សេងដើម្បីតាំងទីលំនៅ ។ អ្នកភូមិមួយចំនួនបានសុំរួមដំណើរជាមួយគ្រួសារយើងដែរ សរុបទាំងអស់ចំនួន២៥គ្រួសារ ។ ដោយសារ

ប៉ាមានមុខរបរជាអ្នកលក់សំបុត្ររថយន្ត ដូច្នេះគាត់ស្គាល់មនុស្សជាច្រើនដែលខស្សាហ៍ធ្វើដំណើរតាមរថយន្តឈ្នួល ។

ថ្ងៃចេញដំណើរបានមកដល់ ប្រជាជនដែលត្រូវចាកចេញបានរៀបចំកង់និងរ៉ឺម៉កហើយចេញដំណើរតាមបណ្តោយស្ពឹងសែនចុះមកក្រោម ។ ពេលនោះគឺជាខែឧសភា គឺដើមរដូវវស្សា មានភ្លៀងធ្លាក់ខ្លះៗបណ្តាលឲ្យផ្លូវរអិលនិងមានភក់ជ្រាំ ។ ទាំងអស់គ្នាមកដល់ភូមិអូរគន្ធរនៅម៉ោង៤រសៀល ហើយមានបំណងឈប់សំចតនៅទីនោះពេលយប់ ប៉ុន្តែគ្មានអ្នកភូមិណាម្នាក់អនុញ្ញាតឲ្យក្រុមរបស់យើងស្នាក់នៅទេ ព្រោះយើងមានសមាជិកច្រើនពេក គឺដល់ទៅជាង៧០នាក់ ។ រហូតដល់ម៉ោង៦ល្ងាចទើបមានអ៊ំប្រុសម្នាក់ឈ្មោះ ស៊ិន អនុញ្ញាតឲ្យក្រុមអ្នកភៀសខ្លួនចូលសម្រាកក្នុងផ្ទះរបស់គាត់ ។ យប់នោះ ប៉ា អ៊ំស៊ិន និងមេគ្រួសារផ្សេងទៀត បានពិភាក្សាគ្នាថា យើងគួរតែបំបែកគ្នាជាក្រុមតូចៗ ហើយធ្វើដំណើរទៅភូមិផ្សេងៗគ្នា ដើម្បីងាយស្រួលរកកន្លែងស្នាក់នៅ ។ ព្រឹកថ្ងៃបន្ទាប់ ក្រុមអ្នកភៀសខ្លួនក៏បំបែកគ្នា ។ ម្តាយនិងបងៗរបស់ខ្ញុំបន្តស្នាក់នៅផ្ទះរបស់ អ៊ំស៊ិន មួយរយៈសិន ព្រោះប៉ាវិលជូនដំណើរគ្រួសារផ្សេងៗម្តងមួយៗទៅដល់ភូមិស្រុកដែលគេចង់រស់នៅ ។ នៅតាមផ្លូវ យន្តហោះបានគាមទម្លាក់គ្រាប់បែកលើក្រុមអ្នកភៀសខ្លួន បណ្តាលឲ្យគាត់ភិតភ័យជាខ្លាំង ។ ការទម្លាក់គ្រាប់បែកនេះបានបន្សល់ទុកនូវរណ្តៅធំៗជាច្រើនរហូតមកដល់បច្ចុប្បន្ន ។

បន្ទាប់ពីចំណាយពេលជាងពីរសប្តាហ៍ជូនដំណើរក្រុមអ្នកជម្លៀសទៅដល់កន្លែងស្នាក់នៅរួចរាល់អស់ហើយ ប៉ាបានវិលត្រឡប់មកផ្ទះរបស់ អ៊ំស៊ិន វិញ ។ គាត់ទាំងពីរបានពិភាក្សាគ្នាថា ក្រុមគ្រួសាររបស់ខ្ញុំមិនគួររស់នៅតាមដងស្ទឹងសែននេះទៀតទេ ។ អ៊ំសិន មានបងប្អូននៅភូមិតារាម ដូច្នេះគាត់បានឲ្យយោបល់ថា គ្រួសារខ្ញុំគួរតែទៅរស់នៅភូមិតារាម ។ ប៉ាបាននាំក្រុមគ្រួសារចាកចេញពីភូមិអូរគន្ធរមកភូមិតារាមនៅចុងខែឧសភា ។

នៅភូមិតារាម ក្រុមគ្រួសារយើងរស់នៅដោយសុខសាន្ត ។ ប៉ាប្រកបរបរជាអ្នកកាប់ជ្រូក ។ មិនបានយូរប៉ុន្មានផង ភូមិតារាមបានធ្លាក់ក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ដែលហៅថា តំបន់រំដោះ ។ អង្គការបានបញ្ឈប់មុខរបរកាប់ជ្រូករបស់ប៉ា ។ ពេលនោះរដ្ឋាភិបាលលន់ណុលគ្រប់គ្រងនៅទីរួមខេត្តកំពង់ធំ ។ កងកម្លាំងទាំងពីរភាគីតែងតែប្រយុទ្ធគ្នាដើម្បីដណ្តើមប្រជាជនយកទៅតំបន់ដែលខ្លួនគ្រប់គ្រង ។ ដោយសារមូលហេតុនេះ ខ្មែរក្រហមជម្លៀសប្រជាជននៅភូមិតារាមឲ្យទៅរស់នៅក្នុងព្រៃជ្រៅចម្ងាយប្រហែល២០គីឡូម៉ែត្រខាងជើងផ្លូវជាតិលេខ៦ ។ ក្នុងរវាងពីឆ្នាំ១៩៧១ទៅឆ្នាំ១៩៧២ ប្រជាជនត្រូវជម្លៀសជាញឹកញាប់ពីព្រៃច្រងទៅព្រៃត្រពាំងត្រែង ព្រៃដងត្រយ៉ូង ហាន់កា ស្វាយផ្សា ព្រៃខាងជើងភូមិព្រហូត ។ ការជម្លៀសចុះឡើងៗធ្វើឲ្យប្រជាជនជួបការលំបាកជាខ្លាំង ។

នៅឆ្នាំ១៩៧៣ ក្រុមគ្រួសាររបស់ខ្ញុំនិងអ្នកភូមិមួយចំនួនបានរត់មករស់នៅភូមិដងស្វាយ ហើយនៅឆ្នាំ១៩៧៥ យើងក៏ត្រឡប់មករស់នៅភូមិតារាមវិញ ។ ពេលនោះ កងកម្លាំងខ្មែរក្រហមមានប្រៀបយ៉ាងខ្លាំងលើកងកម្លាំងលន់ណុល ហើយវាយកាន់កាប់បានតំបន់ជាច្រើននៅជាយៗទីរួមខេត្តកំពង់ធំ ។ បន្ទាប់ពីដាក់ការគ្រប់គ្រងទាំងស្រុងលើប្រទេសកម្ពុជានៅខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមចាប់ផ្តើមជម្លៀសប្រជាជននិងបង្កើតសហករណ៍ ។ ក្រុមគ្រួសាររបស់ខ្ញុំក្លាយជាប្រជាជនថ្មី ។

នៅឆ្នាំ១៩៧៦ ខ្មែរក្រហមបានបំបែកសមាជិកក្នុងគ្រួសាររបស់ខ្ញុំ ។ បងៗរបស់ខ្ញុំទាំង៥នាក់ ត្រូវអង្គការបញ្ជូនទៅកងចល័តជីកអាងបញ្ញាជី នៅជាប់នឹងភ្នំសន្ទុក ។ បងម្នាក់ដែលនៅតូចនៅផ្ទះជាមួយម្តាយខ្ញុំ ។ ចំណែកប៉ាត្រូវអង្គការចាត់តាំងឲ្យទៅនេសាទត្រីនៅផាត់សណ្តាយ បឹងទន្លេសាប ។

ហ៊ិន បងប្រុសរបស់ខ្ញុំ ដែលទើបតែមានអាយុ១០ឆ្នាំ ត្រូវអង្គការឲ្យលើកដីក្នុងមួយថ្ងៃបីម៉ែត្រគូប ។ បងហ៊ិន ពុំអាចលើកគ្រប់តាមផែនការឡើយ ។ គាត់ខិតខំធ្វើការទាំងថ្ងៃទាំងយប់ ។ រាល់យប់គាត់ពុំដែលបានដេកក្នុងរោងឡើយ គឺដេកនៅលើបង្គឺក្នុងរណ្តៅអាង ។ ពេលដែលនឹកម៉ែខ្លាំងពេក បងហ៊ិនលួចរត់ចេញពីកងចល័តមកផ្ទះ ។ មានម្តងនោះ គាត់ហែលឆ្លងស្ទឹងសែនលង់ទឹកស្ទើរស្លាប់ដើម្បីមកជួបម៉ែ ប៉ុន្តែនៅជាមួយម៉ែមិនបានប៉ុន្មានថ្ងៃផង គាត់ត្រូវមេកងចាប់បញ្ជូនទៅកងចល័តវិញ ។ ធ្វើការនៅអាងបញ្ញាជីបានប្រហែល៧ខែ អង្គការបញ្ជូនបងៗរបស់ខ្ញុំទៅជីកប្រឡាយមួយដែលបែកចេញពីស្ទឹងស្ទោង

មកវាលទំនាបខាងត្បូងឃុំសាន់គរ ។ ប្រឡាយនោះមានទំហំប៉ុនកូនស្ទឹងមួយ ។ ខ្មែរក្រហមបានដាក់ឈ្មោះថា ប្រឡាយ៣០កញ្ញា ។

នៅឆ្នាំ១៩៧៧ មេកងសន្តិសុខដែលមានទីតាំងនៅជិតវត្តស្រងែ បានចោទប្រកាន់ក្រុមគ្រួសារខ្ញុំថាមានជាប់ពាក់ព័ន្ធនឹងរបបចាស់ ប៉ុន្តែអ្នកភូមិជាច្រើននាក់បានចេញមុខធានាការពារក្រុមគ្រួសាររបស់ខ្ញុំ ទើបយើងរួចផុតពីការចោទប្រកាន់នេះ ។ នៅចុងឆ្នាំ១៩៧៧ បងប្រុសទីពីររបស់ខ្ញុំត្រូវអង្គការចាត់តាំងជានិរសាររបស់គណៈស្រុកឈ្មោះ ហឿន ។ បងស្រីទីបីឈ្មោះ មុំ ត្រូវអង្គការបញ្ជូនទៅធ្វើជាអ្នកដេរសម្លៀកបំពាក់នៅទីរួមខេត្តកំពង់ធំ ។ បងស្រីធំ បងហ៊ី និង បងហ៊ន ធ្វើការនៅកងចល័តដដែល ។ ចុងឆ្នាំនេះ បងស្រីធំរបស់ខ្ញុំរៀបការជាមួយបងថ្លៃរបស់ខ្ញុំដែលជាប្រជាជននៅក្នុងភូមិជាមួយគ្នា ។ ក្នុងថ្ងៃរៀបការរបស់គាត់មានគូផ្សេងទៀតជាង១០គូ បានឡើងចាប់ដៃប្តេជ្ញាចិត្តតាមការចាត់តាំងរបស់អង្គការ ។

នៅឆ្នាំ១៩៧៨ សមមិត្តហឿន ត្រូវអង្គការចាប់ខ្លួនពីបទក្បត់បដិវត្តន៍ ។ ពេលនោះបងប្រុសរបស់ខ្ញុំក៏ត្រូវហៅទៅសួរចម្លើយដែរ បន្ទាប់មកត្រូវបានដោះលែងមកវិញ ។ ចុងឆ្នាំ១៩៧៨ គណៈឃុំឈ្មោះ សមមិត្តឯម មានបំណងបញ្ជូនក្រុមគ្រួសារខ្ញុំទៅរៀនសូត្រនៅភូមិថ្មី ។ ប៉ាដឹងច្បាស់ថា ទៅភូមិថ្មីគឺមានន័យថាយកទៅសម្លាប់ចោល ។ អ្នកភូមិមួយចំនួនក៏បានដឹងអំពីការពិតនេះ ហើយបានអង្វរករគណៈឃុំឲ្យពន្យារពេលបញ្ជូនក្រុមគ្រួសារខ្ញុំទៅភូមិថ្មី ។ គណៈឃុំក៏យល់ព្រម ។ ប៉ុន្មានខែក្រោយមកមានការរំដើបរំជួលដោយសារវាយប្រហាររបស់កងទ័ពវៀតណាម ។ បងៗរបស់ខ្ញុំដែលនៅឯកងចល័តក៏បានរត់ត្រឡប់មកផ្ទះវិញ ។ ប្រជាជនបាននិយាយតៗគ្នាថា ទីក្រុងភ្នំពេញធ្លាក់ក្រោមការកាន់កាប់របស់វៀតណាមហើយ ។

ថ្ងៃមួយត្រូវនឹងថ្ងៃទី១០ ខែមករា ឆ្នាំ១៩៧៩ មានរថយន្តផលិតនៅប្រទេសចិនជាច្រើនគ្រឿងដែលដឹកពេញទៅដោយកម្មាភិបាលខ្មែរក្រហម បើកកាត់មុខផ្ទះរបស់ខ្ញុំឆ្ពោះទៅទិសខាងលិច ។ ប្រមាណមួយម៉ោងក្រោយមក រថក្រោះនិងរថយន្តដឹកកងទ័ពវៀតណាមបានបើកមកដល់ភូមិរបស់ខ្ញុំ ។ អ្នកភូមិមានការភិតភ័យជាខ្លាំងនៅពេលដែលឃើញកងទ័ពវៀតណាម ព្រោះខ្មែរក្រហមធ្លាប់បំភ័យប្រជាជនថា កងទ័ពយួននឹងចូលមកសម្លាប់ប្រជាជននៅទីនេះទាំងអស់ ។ ទាំងអស់គ្នារត់រកកន្លែងលាក់ខ្លួន ប៉ុន្តែកងទ័ពវៀតណាមបានឃាត់ហើយប្រាប់ថា កុំភ័យអីគេមិនសម្លាប់ទេ ។ ល្ងាចថ្ងៃដដែលនោះ ប្រជាជនបូព៌ាដែលត្រូវអង្គការជម្លៀសទៅនៅក្បែរស្រុកស្ទោង បានវិលត្រឡប់មកវិញ ។ អ្នកខ្លះអូសរទេះដែលមានកង់ធ្វើអំពីគល់ឈើមូលដឹកសណ្តោងកូនចៅយ៉ាងគគ្រឹកគគ្រេង ។ ប្រជាជនបូព៌ាទាំងនោះបានទម្លាយជង្រុកស្រូវសហករណ៍ដែលនៅក្បែរផ្ទះខ្ញុំ ហើយកើបយកស្រូវ និងចាប់ជ្រូកសម្លាប់យកសាច់តាមសេចក្តីស្រេកឃ្លាន ។ ប៉ាហាមបងៗរបស់ខ្ញុំមិនឲ្យទៅកើបស្រូវទាំងនោះទេ ព្រោះគាត់ខ្លាចអង្គការវិលមកវិញចាប់ទោសកំហុស ។ ពេលនោះខ្ញុំអាយុប្រហែល៣ឆ្នាំ ការចងចាំរបស់ខ្ញុំគឺស្រពេចស្រពិល ។

កងសន្តិសុខខ្មែរក្រហមនៅមន្ទីរសន្តិសុខវត្តស្រងែ ដែលរត់គេចខ្លួនមិនទាន់ ត្រូវកងទ័ពវៀតណាមចាប់យកមកឲ្យប្រជាជនវិនិច្ឆ័យទោសនៅវត្តពាមមេត្រី ។ ប្រជាជនបានកាត់ទោសកងសន្តិសុខទាំងនោះដោយបាញ់សម្លាប់ចោល ។

ខ្ញុំចាំថា នៅឆ្នាំ១៩៨០ នៅក្នុងភូមិខ្ញុំមានប្រារព្ធពិធីបុណ្យដ៏ធំរយៈពេល៣ថ្ងៃបីយប់ ។ ពេលនោះមានបញ្ចាំងកុន សម្តែងយីកេ និងចែកម្សៅទឹកដោះគោដល់កុមារ ។ គឺពេលនោះហើយដែលខ្ញុំបានស្គាល់រសជាតិរបស់អស់ទាំងនោះជាលើកដំបូង ។

**គី សុផល**

# ពាក្យស្លោកខ្មែរក្រហម

◆ **បើចង់ធ្វើបដិវត្តន៍ ត្រូវរកមនុស្សបដិវត្តន៍ ចង់បានមនុស្សបដិវត្តន៍ ត្រូវមានគោលជំហរសតិអារម្មណ៍លើបដិវត្តន៍។**

*(ដកស្រង់ពីសៀវភៅកំណត់ហេតុលេខ០៥៣)*

◆ **បដិវត្តន៍ជាសង្គ្រាមប្រជាជន មានតែការបំផុសបំផុលប្រជាជនទើបអាចធ្វើសង្គ្រាមបាន។**

◆ **មានតែប្រជាជនទេដែលអាចកសាងប្រវត្តិសាស្ត្រសកលលោក។** *(សៀវភៅកំណត់ហេតុរបស់សមមិត្ត ញ៉ុក សារុន)*

# ស្រមោលបង

(តពីលេខមុន)

## ស៊ុបស្បែកជើងកង់ឡាន

ខ្ញុំត្រូវទៅចម្ការវិញហើយ ។ ខ្ញុំបានស្រឡះចិត្តបន្តិចព្រោះបានជួបគ្នាឯងនិងបានដដែកគ្នាលេង ។ ខ្ញុំបានជួប អ៊ឹសយ ទៀតហើយ ។ យើងតែងលួចហៅគាត់ថា សេ.អ៊ី.អា ។ ព្រឹកនេះពេលកំពុងបោចស្មៅពោត គាត់លួចប្រាប់ខ្ញុំដោយរីករាយថា÷

-នែ៎ យប់មិញឪវាគាត់លួចបើកវ៉ាដ្យូស្តាប់ ឮព្រះរាជបន្ទូលសម្តេចឪថា... ។ រួចអ៊ឹសយគាត់ធ្វើភ្នែកស្ទីរកនឹក ។

មីង១ពីរ-បីនាក់ទៀតខំខិតមកជិតខ្ញុំដែរដើម្បីស្តាប់ ។ ចៃដន្យសមមិត្តនារីម្នាក់ដើរមកជិតខ្ញុំដើម្បីយកចបជីក ហើយក៏ស្តីឲ្យពួកយើងថា “មីង១ទាំងអស់គ្នាម៉េចមិនធ្វើការ ចង់អត់បាយល្ងាចឬ?” យើងថយចេញពីគ្នារៀងខ្លួន ហើយចាប់បោចស្មៅតទៅទៀត ។

ពេលល្ងាចឈប់ធ្វើការ យើងដណ្តើមគ្នាដើរជិត អ៊ឹសយ ដើម្បីសួរពត៌មានក្នុងវិទ្យុ ។ អ៊ឹសយ ឆ្លើយធ្វើព្រងើយថា÷

-បានអីឮបើអាវ៉ាដ្យូចង្រៃយក៍វាដាច់ គ្រាន់តែឮព្រះរាជបន្ទូលថា “កូនចៅជាទីស្នេហា...” ។

ពួកយើងហួសចិត្ត អត់បានការអីសោះ ។ ខ្ញុំចូលក្នុងខ្ទមឃើញនៅលើចង្ក្រានមានឆ្នាំងដាំទឹកពុះកំពុងហុយផ្សែងទ្រលោមហើយក្នុងទឹកឃើញមានដុំស្អីខ្មៅ១ខ្ញុំមើលមិនច្បាស់ ។ ក្នុងចិត្តខំអរ នឹកថាប្រហែលប្តីខ្ញុំបានឆ្អឹងគោឬក្របីយកមកស្ងោរស៊ុបហើយ ។ អរណាស់ក៏អង្គុយថែមខុសទៀតឲ្យវាឆាប់ពុះ ។ មួយស្របក់ ប្តីខ្ញុំមកពីរែកទឹកវិញ ។ ខ្ញុំពុំទាន់សួរគាត់ទេ រង់ចាំគាត់ត្រឡប់មកពីយកធុងទៅសងអ្នកជិតខាងវិញទើបសួរគាត់ថា÷

-ក្នុងឆ្នាំងស្ងោរអីហ្នឹងបង?

ប្តីខ្ញុំសើចហើយឆ្លើយថាៈ ឯងទាយមើលសាច់អី?

ខ្ញុំឆ្លើយថាៈ សាច់ក្របី ព្រោះវាខ្មៅ ។

ប្តីខ្ញុំសើចកាច់កកាច់ស្រង់ ហើយនិយាយថាៈ

-គឺស៊ុបកង់ឡានណ៎ា បងយកមកស្ងោរដើម្បីធ្វើស្បែកជើងឲ្យអូននិងកូនពាក់ ទម្រាំសុំគេបានពិបាកណាស់ណ៎ា ។

អូយ ខ្ញុំខំតែអរស្មានតែបានអីឆ្ងាញ់ ដឹងអីជាកង់ឡានសោះ ។ គាត់បត់វាចេញក្រៅហើយស្ងោរប្រហែលមួយអាទិត្យ ដើម្បីឲ្យវារលាបន្តិច ហើយកាត់ធ្វើស្បែកជើងឲ្យខ្ញុំនិងកូនពាក់ ។ ខ្ញុំក៏បានស្រួលជើងបន្តិច ព្រោះវាមិនឈឺជើង ។

## ភូមិបាក់ព្រា

ថ្ងៃមួយ ប្រធានភូមិបានហៅអ្នកភូមិទាំងថ្មីទាំងចាស់ទៅប្រជុំ ។ គេចង់រើសមួយភូមិពីរគ្រួសារឲ្យទៅធ្វើអាជីវកម្មត្រីនៅបាក់ព្រា ។ គេរើសយកអ្នកមានកូនតិចនិងមានមុងទើបគេឲ្យទៅព្រោះទីនោះមូសច្រើនណាស់ ។ ប្តីខ្ញុំលើកដៃខ្វាច់ស្ម័គ្រចិត្តទៅភ្លាម ។ ប្រធានភូមិសួរប្តីខ្ញុំថា÷

-មិត្តហួតឯងចេះបង់សំណាញ់រកត្រីទេ?

ប្តីខ្ញុំថាចេះ ។ ខ្ញុំកេះប្រាប់ប្តីខ្ញុំថាមិនទៅទេ ស្តាយកូនម្ទេសនិងស្លឹកគ្រៃទើបនឹងដាំលាស់ថ្មីល្អណាស់ ។ ប្តីខ្ញុំខ្សឹបថា កុំស្តាយអីរបស់ប៉ុណ្ណឹងនោះ ។

យប់នោះ ប្រធានភូមិបើកសិទ្ធិឲ្យគ្រួសារខ្ញុំនិងគ្រួសារបងប្រុសមួយទៀតដែលត្រូវទៅបាក់ព្រា អាចធ្វើមាន់ដែលជារបស់ខ្លួនឯងដើម្បីធ្វើម្ហូបទុកហូបតាមផ្លូវ ។ ខ្ញុំមានមាន់តែពីរប៉ុណ្ណោះតែយើងធ្វើមាន់ដល់ទៅជិតម្ភៃឯណោះ គឺរបស់បងប្អូនជិតខាងដែលគេយកមកផ្ញើធ្វើដែរ ។ យប់នោះចង់ទើសភ្លឺ យើងហាក់ដូចជាមានពិធីជប់លៀងយ៉ាងសប្បាយរីករាយ ។ ខ្ញុំស្រមៃថាព្រឹកស្អែកនេះគេឲ្យត្រឡប់ទៅផ្ទះវិញ ។ ស្អែកឡើង ក្រោយពីលាមិត្តភក្តិក្នុងភូមិទាំងអស់រួចមក ពីរគ្រួសារយើងក៏ចេញដំណើរទៅតាមរទេះគោដោយមានមិត្តឈ្លបម្នាក់ជាអ្នកជូនទៅ ។ ខ្ញុំពុំដឹងថាភូមិបាក់ព្រានៅចម្ងាយប៉ុន្មានគីឡូម៉ែត្រទេ ប៉ុន្តែយើងត្រូវឈប់ដាំបាយហូបនៅតាមផ្លូវពេលថ្ងៃត្រង់ ហើយក៏បន្តដំណើរទៅមុខទៀត ។ យើងបត់ចូលតាមផ្លូវដីដែលមានដងស៊ីងនៅឆ្វេងដៃ ។ ពេលល្ងាចទើបយើងទៅដល់ភូមិបាក់ព្រាដែលមានខ្ទមវែង១នៅលើទឹកទុកឲ្យអ្នករកត្រីសម្រាក ។ ខ្ទមអស់នោះអាច

រុះរើស្រេចនឹងចិត្តតាមទឹកឡើងឬទឹកស្រក ។ ភូមិបាក់ព្រាសប្បាយម្ល៉េះទេ ទេសភាពត្រជាក់ល្ហឹម ពេលគេងខ្ញុំនឹកឃើញបទចម្រៀងរបស់អ្នកស្រី រស់ សេរីសុទ្ធា៖ «ឱភូមិបាក់ព្រានាពេលសូរិយារៀបលិច...» ។

នៅទីនោះ ភារកិច្ចរបស់ប្រុសៗគឺចេញទៅបង់សំណាញ់រកត្រី ។ ទៅម្តង១០-២០ទូកក៏មាន ។ ប្តីខ្ញុំក៏ចេញទៅជាមួយនឹងគេដែរ ពុំដឹងគាត់ធ្វើបានឬពុំបានទេ តែនាងខ្ញុំដឹងថាគាត់ឆ្លាត គាត់ពិតជាអាចរៀនសូត្រពីគេបាន ។ ពេលទូកត្រីមកវិញមានមនុស្សវាយដួងជាសញ្ញា ហើយក្រុមស្រីៗក៏កាន់កាំបិតនិងចានគោមធំៗសម្រាប់ដាក់ពងត្រី ដើរសំដៅទៅរោងនៅមាត់ទឹកដើម្បីធ្វើត្រី ។ ទូកមកដល់ពេលណាគឺត្រូវឡើងធ្វើត្រីពេលនោះ ជួនកាលម៉ោងមួយឬម៉ោងពីរយប់ក៏មាន ។

ស្រុកនោះសម្បូណ៌មូសណាស់ ។ ប្រជាជនដុតភ្លក់ភ្លើងគ្រប់ទិសទីក៏នៅតែមានមូសដូចឃ្មុំ ។ ខ្ញុំធ្វើត្រីបណ្តើរ ដៃទះមូសបណ្តើរ ទម្រាំតែជិតភ្លឺទើបបានចូលសម្រាកនៅក្នុងខ្ទម មូសខាំក្រហាយពេញខ្លួន ។ ខ្ញុំពុំសូវប្រសប់ធ្វើត្រីទេ អ្នកផ្សេងបានពងត្រីពេញៗចាន ចំណែកខ្ញុំបានតែកន្លះចានប៉ុណ្ណោះ ។ យើងហូបពងត្រីទាល់តែរាកគ្រប់គ្នា ។

## ជំងឺគ្រុនចាញ់

គ្រួសារខ្ញុំនៅភូមិបាក់ព្រាបានប្រមាណកន្លះខែ ។ ថ្ងៃមួយខ្ញុំចាប់ផ្តើមឈឺគ្រុនក្តៅយ៉ាងខ្លាំង ។ មួយអាទិត្យកន្លងផុតហើយជំងឺរបស់នាងខ្ញុំមិនបានធូរស្រាលសោះ ។ ខ្ញុំដឹងថាប្រហែលជាគ្រុនចាញ់ហើយ ។ ខ្ញុំញុាំបាយមិនបាន ស្រេកតែទឹក ហើយនឹកឃ្លានម្ជូរជាខ្លាំង ។ ប្តីខ្ញុំដាច់ចិត្តទៅរោងបាយ សុំម្ជូរសណ្តាន់ពីចុងភៅបានពីរ-បីចំណិតនិងអំបិលគ្រួសបាន៤-៥គ្រាប់យកមកឲ្យខ្ញុំ ។ ខ្ញុំត្រេកអរណាស់ដូចបានផ្លែឈើទិព្វពីសួគ៌ាមកញុាំ ។

ស្ថានភាពជំងឺរបស់ខ្ញុំគ្មានស្រាកស្រាន្តសោះ ។ ខ្ញុំគ្មានថ្នាំអ្វីញុាំសោះ សូម្បីតែឫសឈើឫសព្រៃក៏គ្មាន ព្រោះទីនោះគ្មានគ្រូឱសថបុរាណឬពេទ្យអីទេ ។ ព្រឹកនោះ ប្តីខ្ញុំសម្រេចចិត្តដឹកដៃខ្ញុំទៅសុំប្រធានកងប្រធានក្រុមខាងអាជីវកម្មនេះ ដើម្បីត្រឡប់មកភូមិវិញ ។ ខ្ញុំស្លៀកសំពត់ផាឱបសជ្រលក់ភក់ស្មើរពុំចង់ជាប់ព្រោះគ្មានជាតិបាយក្នុងខ្លួនសោះ ។ ប្រធានកងប្រធានក្រុមពីរ-បីនាក់ស្តីឲ្យខ្ញុំនិងប្តីថាគ្មានការតស៊ូអត់ធ្មត់ដូចគេគ្រប់ៗគ្នាសោះ ។ គេអនុញ្ញាតឲ្យគ្រួសារខ្ញុំត្រឡប់មកភូមិវិញ ប៉ុន្តែគេដកយកមុងភួយសម្រាប់ទុកឲ្យអ្នកក្រោយ ។ បងហ្វូត គ្មានគិតអ្វីទាំងអស់ ឲ្យតែគេឲ្យទៅវិញ យកអីក៏យកចុះ ។ មេក្រុមចាត់មនុស្សជូនដំណើរយើងតាមទូកមកដល់ផ្លូវកៅស៊ូខាងក្រៅ ហើយទុកឲ្យយើងដោះស្រាយការធ្វើដំណើរបន្តទៀតព្រមទាំងបាយទឹកដោយខ្លួនឯង ទាំងយើងគ្មានអង្ករមួយគ្រាប់ជាប់ខ្លួនផង ។ គេប្រាប់ថា បើយើងទៅដល់ភូមិណា ចូលសុំគេភូមិនោះទៅ គេមិនចិត្តអាក្រក់ទេ ។ តាមពិត គ្មានភូមិណាគេអាណិតអាសូរយើងឡើយ សូម្បីតែបាយក្តាំងក៏មិនឲ្យដែរ ។ គេថាគ្រប់គ្រាន់សម្រាប់តែប្រជាជនភូមិគេប៉ុណ្ណោះ ។ មកដល់ផ្លូវធំ មេឃចាប់ផ្តើមងងឹតហើយភ្លៀងរលឹមតិចៗ ។ ប្តីប្រពន្ធនាងខ្ញុំនិងកូនប្រុសនាំគ្នាចូលជ្រកក្នុងផ្ទះឈើមួយដែលនៅដាច់តែឯង ។ ប្រុសក័ត្រ្តកូនប្រុសជាទីស្រលាញ់របស់នាងខ្ញុំ មុខស្លេកស្លាំងព្រោះតែការស្រេកឃ្លាន តែវាគ្មានថ្ងូរមួយម៉ាត់ ។ គួរអាសូរកូនណាស់ រយៈពេលប្រហែលពីរឆ្នាំធ្វើឲ្យកូនប្រុសខ្ញុំចេះមានការតស៊ូ ។ (នៅវេលាដែលខ្ញុំសរសេរដល់ត្រឹមនេះខ្ញុំទម្លាក់ស្លាបប៉ាកាចុះ ព្រោះទឹកភ្នែកបានហូរជន់ដោរក្នុងរង្វង់វ៉ែនតាកាត់ផែនថ្ពាល់រំយចំណាស់របស់នាងខ្ញុំ) ។

ផ្ទះដែលខ្ញុំចូលជ្រកគឺជាផ្ទះយោធាស្នាក់នៅ ។ មានមិត្តយោធាក្មេងម្នាក់អាយុប្រហែល២០ទៅ២៥ឆ្នាំ ដើរមកសួរដំណើរដើមទងអំពីពួកយើង ។ សមមិត្តប្អូននោះដូចជាមានចិត្តអាណិតអាសូរពួកយើង ក៏ដើរទៅក្រោយហើយដួសបាយមួយចានធំ ព្រមទាំងមានសម្លម្ជូរត្រកួនដាក់ពីលើផង មកហុចឲ្យប្តីខ្ញុំហើយប្រាប់ថា÷

-អស់ហើយមានតែប៉ុណ្ណេះទេ ហូបទៅ ។

ប្តីខ្ញុំគាត់លូកដៃទទួលដោយអំណរ ហើយបញ្ចុកខ្ញុំមុន តែខ្ញុំគ្រវីក្បាលហូបមិនកើតព្រោះល្វីងមាត់ខ្លាំងពេក ។ យុវយោធាឃើញដូច្នេះក៏សួរថា÷

-មិត្តនារីឯងកើតអី?

ខ្ញុំឆ្លើយថា ខ្ញុំគ្រុន៤-១០ថ្ងៃហើយមិត្ត ។ ឮដូច្នេះ មិត្តយោធាបានចូលទៅយកថ្នាំគ្រាប់តេត្រារបស់ចិនពណ៌លឿង

មួយគ្រាប់ហុចឲ្យខ្ញុំលេប ហើយប្រាប់ថា “យប់នេះនៅសម្រាកទីនេះហើយ ចាំស្អែកក្រែងមានឡានយោធាគេត្រូវទៅផ្លូវនោះ ចាំខ្ញុំសុំឲ្យដោយសារ” ។

ខ្ញុំលេបថ្នាំហើយក៏សម្រាកនៅលើក្តារជ្រើងជិតនោះទៅ ព្រោះអស់កម្លាំងពេក ។ កណ្តាលយប់ស្ងាត់ ខ្ញុំភ្ញាក់ឡើងព្រោះស្រេកទឹកពេក ។ ខ្ញុំដើរសរសៀរស្ទាបៗទៅរកពាងទឹក ហើយក៏យកទឹកញ៉ាំមួយចម្អែត ។ ខ្ញុំយល់ថា យប់នោះខ្ញុំញ៉ាំទឹកអស់ប្រហែលកន្លះពាងហើយមើលទៅ ។ ទឹកភ្លៀងត្រជាក់ផ្អែមឆ្ងាញ់ម៉្លេះទេ ។ ក្នុងអារម្មណ៍ខ្ញុំគិតថា ខ្ញុំកំពុងញ៉ាំទឹកក្រូចប៉ិបស៊ីទៅវិញ ។

ព្រឹកឡើង ប្តីប្រពន្ធខ្ញុំនិងកូនប្រុសភ័ក្រ្តបានសុំដោយសារឡានយោធាមួយ ។ អ្នកបើកឡានដាក់យើងនៅភូមិដើងវត្តស្រុកព្រះនេត្រព្រះ ទាល់តែដើរចូលទៅក្នុងជ្រៅ៤-៥គីឡូម៉ែត្រទៀតទើបដល់ភូមិស្រែះដែលខ្ញុំធ្លាប់រស់នៅ ។ យោធាទាំងអស់នោះប្រាប់ខ្ញុំថា នៅសម្រាកពេទ្យទីនោះហើយ ចាំធូរស្រួលបួលសឹមវិលទៅភូមិចាស់វិញ ។ ពេទ្យធ្វើការនៅក្នុងវត្តតែម្តង ហើយភូមិអ្នកស្រុកចាស់-ថ្មីក៏នៅជាប់ៗនឹងពេទ្យនេះដែរ ។ ខ្ញុំចូលសម្រាកពេទ្យបានពីរ-បីថ្ងៃ ។ រីឯថ្នាំសម្រាប់ព្យាបាលជំងឺខ្ញុំគឺគ្រាប់ធំៗខ្មៅៗដូចអាចម៍ទន្សាយ ដែលកម្មាភិបាលពេទ្យចែកឲ្យលេបរាល់ថ្ងៃ ។ ខ្ញុំសង្កេតឃើញថា ឈឺយ៉ាងម៉េចក៏ចែកតែថ្នាំមួយប្រភេទហ្នឹងដែរ ។ អ្នកត្រូវជាក៏ជា អ្នកមិនជាគឺស្លាប់ ។ វិលងបានបី-បួនថ្ងៃក្រោយមកខ្ញុំបានធូរស្រាលបន្តិច ហើយខ្ញុំនឹកឃ្លានចំណីតែផ្អេសតែផ្អាស ។ ព្រឹកនេះខ្ញុំប្រាប់ប្តីខ្ញុំថា ខ្ញុំឃ្លានដំឡូងមីជាខ្លាំង ។ បងហួត ក៏ធ្វើដំណើរទៅភូមិស្រែះដែលជាភូមិចាស់ធ្លាប់រស់នៅ ។ ល្ងាចឡើង ប្តីខ្ញុំត្រឡប់មកវិញជាមួយដំឡូងមីមួយកូនដុំដែលឆ្អិនស្រាប់ ។ ខ្ញុំបេះឲ្យកូនខ្ញុំខ្លះ និងឲ្យប្តីខ្ញុំខ្លះ តែគាត់ថាបានពិសានៅតាមផ្លូវខ្លះហើយ ។ ប្តីខ្ញុំបានខ្សឹបប្រាប់ខ្ញុំដោយញ័រមាត់ថាៈ អាបារាំងអើយ ពួកក្រុមយួនដែលនៅភូមិស្រែះ គេយកទៅណាបាត់អស់ហើយ ប្រហែល២០គ្រួសារឡើងស្ងាត់ភូមិ ។ ក្រោយយើងចេញទៅធ្វើអាជីវកម្មត្រីប្រហែលមួយអាទិត្យប៉ុណ្ណោះ ។ គេយកទៅគឺមានរបៀបរបស់គេ ។ ដំបូងគេហៅប្រុសៗដែលទើបមកពីចម្ការឲ្យទៅប្រជុំនៅចុងភូមិព្រោះមានការសំខាន់ ។ (ដល់ត្រង់នេះ ប្តីខ្ញុំដកដង្ហើមដូចជាហត់ណាស់ទើបគាត់បន្ត) ខ្លះនៅតែខោខ្លីប៉ុណ្ណោះ ។ រួចគេក៏ដើរហៅស្រីៗដែលនៅផ្ទះឲ្យរៀបចំអីវ៉ាន់និងកូនចៅចេញដំណើរទៅតាមរទេះគោ ព្រោះប្រុសៗនៅរង់ចាំឯចុងភូមិជាស្រេច ។ ប្តីខ្ញុំបន្តថាៈ អ៊ីគា ដែលគាត់មានផ្ទះនៅជាប់នឹងផ្ទះយើង (ពីសង្គមចាស់គាត់ជាថៅកែសាំង) ប្តីគាត់ជាអ្នកកប់មាសប្រាក់នៅក្នុងផ្ទះនោះ (ផ្ទះផ្ទាល់ដី) ។ អ៊ីគា គាត់ពុំដឹងនៅត្រង់ណាទេ ដល់គេបង្ខំឲ្យចេញភ្លាមៗដូច្នេះគាត់រកពុំឃើញ ក៏ដាច់ចិត្តប្រាប់ប្រធានភូមិឲ្យជួយរក ។ តែមួយប៉ព្រិចភ្នែកប៉ុណ្ណោះ ខ្ទមអ៊ីគាក៏រលាយអស់រលីង នៅតែរកមាសពុំឃើញ ។ ទោះជាគេនាំគ្នាកាប់គាស់ដីក្នុងផ្ទះយ៉ាងណាក៏ដោយ ក៏រកពុំឃើញដែរ ។

ខ្ញុំព្រឺក្បាលខ្លាក ។ នេះជាសំណាងមួយក្នុងមួយម៉ឺនមួយលានគ្រោះថ្នាក់ ។ ដូច្នេះវាសនាក្រុមយួនអស់នោះរួមទាំងក្មេងៗក្នុងអង្រឹងផង ពុំដឹងក្លាយទៅជាយ៉ាងណាទេ ។ ថ្ងៃក្រោយមកទៀត ខ្ញុំឮពាក្យចចាមអារ៉ាមថា ក្រុមយួនគេដាក់កាណូតទៅដល់កណ្តាលទន្លេ គេចាក់មេក្រូឮៗហើយពន្លិចកាណូតនោះចោលតែម្តង ។

តាំងពីថ្ងៃនោះមក ខ្ញុំក៏ក្លាយទៅជា នាងណាង វិញ ឬម៉ែអាភ័ក្រ្ត ចំណែកប្តីខ្ញុំក៏ជា មិត្តហួត វិញដដែល ។ បី-បួនថ្ងៃក្រោយមកទៀត យើងបានជួបនឹង អ៊ីរី ដែលត្រូវជាបងប្អូនប្តីខ្ញុំដែរ ។ គាត់រស់នៅភូមិដើងវត្តនេះ ។ គាត់ត្រេកអរណាស់ដែលបានជួបពួកយើង ។ គាត់បានឃាត់យើងឲ្យរស់នៅភូមិនេះជាមួយគាត់ ។ យើងក៏បានចូលនៅភូមិដើងវត្តនេះវិញក្រោយពី អ៊ីរី បានទៅសុំប្រធានភូមិនេះបានហើយ ។

## ពុកក្រូក ប្រធានសហករណ៍

ភូមិដែលខ្ញុំរស់នៅក្រោយនោះគេច្រើនហៅថា ភូមិបច្ចេកទេសមេម៉ាយ ព្រោះប្រុសៗដែលសុទ្ធតែជាអ្នកបច្ចេកទេសឬវេជ្ជបណ្ឌិត ត្រូវអង្គការយកទៅអស់ហើយ នៅសល់តែប្រពន្ធប៉ុណ្ណោះ ។ ក្នុងចំណោមនោះ ខ្ញុំជួបមិត្តចាស់ម្នាក់ឈ្មោះ សោភា ដែលធ្វើការនៅក្នុងមន្ទីរពេទ្យ ព្រះមុនីវង្ស ជាមួយគ្នា ។ សោភា ធ្វើការនៅផ្នែកត្រចៀក ច្រមុះ បំពង់ក ។ ប្តីរបស់ សោភា ក៏ជាវេជ្ជបណ្ឌិតដែរ គឺលោក ទក កាន ដែលអង្គការយកទៅរៀនសូត្របាត់ហើយ ។ សោភា រស់នៅជាមួយកូនប្រុសម្នាក់អាយុ

៥ឆ្នាំ ។ ក្នុងភូមិនោះ ប្រុសៗដែលមានវាសនាត្រឡប់មកជួបជុំប្រពន្ធកូនវិញមានតែបីនាក់ប៉ុណ្ណោះ ។ ទីមួយគឺលោក ឌីណា ដែលគាត់ជាអ្នកបច្ចេកទេសខាងអគ្គិសនី ។ ថ្ងៃនោះគាត់ឈឺងើបមិនរួច ហើយប្រពន្ធគាត់ឈ្មោះ ប្រណី ជាកូនកាត់លាវ ។ អ្នកទីពីរគឺលោកវេជ្ជបណ្ឌិត ជី ដែលមិនដឹងជាគាត់និយាយយ៉ាងម៉េចត្រូវចិត្តអង្គការទើបពីរថ្ងៃក្រោយមកគាត់បានត្រឡប់មកវិញទៅ ប្រពន្ធគាត់គឺបង សំឡី ដែលគាត់មានសម្ដីផ្អែមល្ហែមគួរឲ្យស្រលាញ់ ។ គាត់គឺជាអ្នកគ្រូពីសង្គមចាស់ ។ ម្នាក់ទៀតគឺ អ៊ឹសារ៉េត ពីសង្គមចាស់គាត់ធ្វើការនៅស្ថានីយរថភ្លើង ។ អ៊ឹសារ៉េត ត្រូវនាំយកទៅបានពីរថ្ងៃក៏ត្រឡប់មកវិញ ។ គាត់បានលួចប្រាប់កូនគាត់ទាំងបីនាក់ (ស្រីមួយប្រុសពីរ) ថាៈ «ពួកឯងត្រូវចាំណា បើគេហៅទៅសួរថាចង់មានសំណូមពរអ្វីទេ ពួកឯងត្រូវឆ្លើយដោយគោរពថា គ្មានទេសមមិត្តបង ។ គិតពួកឯងសំណូមពរឲ្យមានសាលារៀន មានទីផ្សារ មានវត្តអារាម គឺពួកឯងគ្មានវាសនាត្រឡប់មកវិញទេ ពុកហើយប៉ុនៅ?»

កូនគាត់ទាំងបីក៏ងក់ក្បាលទាំងពុំសូវយល់ពីមូលហេតុ ។ អង្គការតម្រូវឲ្យគ្រួសារខ្ញុំចូលរស់នៅក្នុងផ្ទះឈើធំមួយដែលមានបងស្រី ម៉ែអាទូ មេម៉ាយកូនពីរ និងប្អូនស្រី សូដា មេម៉ាយដែរមានកូនបីនាក់ (ប្រុសពីរស្រីមួយ) ។ បងស្រី ម៉ែអាទូ ចូលចិត្តប្ដីប្រពន្ធខ្ញុំណាស់ ហើយ អាទូ កូនច្បងរបស់គាត់ដែលមានអាយុ ៨ឆ្នាំ និង អាពៅ អាយុ៧ឆ្នាំ ក៏ស្រលាញ់ចូលចិត្ត កូនភ័ក្ត្រខ្ញុំដែរ ។

បងស្រី ម៉ែអាទូ មានសំឡេងពីរោះណាស់ ។ យប់ណាក៏គាត់និងខ្ញុំអង្គុយលេងនៅការំជណ្ដើរ ហើយគាត់តែងច្រៀងបទចម្រៀងពីសង្គមចាស់ដូចជា បទសំបុត្រក្រោមខ្នើយ បទបង្គួចរាត្រី ដែលច្រៀងដោយអ្នកស្រី ហ៊ួយ មាស ។ បងស្រីច្រៀងលន្ទងលន្ទោចពីរោះណាស់ ។ ខ្ញុំអង្គុយផ្អែកលើស្មាគាត់ហើយមានអារម្មណ៍ថាដូចជានៅក្នុងភោជនីយដ្ឋានណាមួយ ជួនក៏យំជួនក៏សើច ជាមួយគាត់ តែយើងដឹងថាមានទស្សនិកជនពីរ-បីនាក់ឈរស្ងៀមៗចាំស្ដាប់យើង ។ យប់ស្អែកឡើងក៏ចេះតែមានទស្សនិកជនកាន់តែច្រើនឡើងឈរលួចស្ដាប់ចម្រៀងគ្មានភ្លេងរបស់យើង ។

ល្ងាចនេះនៅពេលបាយ ស្ត្រីអ្នកមូលដ្ឋានម្នាក់មានអាយុប្រហែល៤០ឆ្នាំ ធ្មេញបាក់ជួរខាងមុខអស់ សម្ដីគំរោះគំរើយបានដើរប្រកាសថាៈ បងប្អូនទាំងអស់គ្នាហូបបាយហើយទៅប្រជុំនៅទីធ្លាវត្ត ។

ក្រោយពីជួបជុំគ្នាហើយ សមមិត្តដែលជាប្រធានក្នុងអង្គប្រជុំបានបើកអង្គប្រជុំ ។ ជាដំបូងគេគោរពពុក-ម៉ែ បងប្អូនមាមីង ហើយគេក៏និយាយដាស់សតិអារម្មណ៍យើងឲ្យខំធ្វើការមួយហិកតាឲ្យបានប្រាំតោន ថ្ងៃក្រោយយើងនឹងសំបូរសប្បាយមិនខ្វះហូប ទឹកភ្លើងអគ្គិសនីប្រើគ្រប់គ្រាន់ សូម្បីតែជណ្ដើរបង្គន់ក៏មានភ្លើងដែរ សម្លៀកបំពាក់ក៏មិនខ្វះស្លៀកពាក់ដោយមិនចាំបាច់ចាយលុយ ។ ពួកយើងក៏បង្ខំចិត្តត្រូវតែទះដៃឲ្យបានខ្លាំងៗ ។ អស់ពីនិយាយរឿងសម្បូរសប្បាយ ចូលដល់រឿងអប់រំ រឿងកសាង រឿងសីលធម៌ ។ គេនិយាយរបៀបគំរាមបន្តិច សម្លុតបន្តិច ។ សមមិត្តនិយាយបន្តឹងសំឡេងរាងកាចមិនផ្អែមដូចវគ្គមុនសោះថាៈ មានមិត្តនារីខ្លះមួយចំនួនប៉ុណ្ណោះ មិនភ្លេចវប្បធម៌សក្តិភូមិ មូលធននិយម ពេលយប់ឡើងនៅលួចច្រៀងលួចនិយាយរឿងកុនល្ខោនដែលជាប្រពៃណីមិនល្អ (ដល់ត្រង់នេះ បងស្រីម៉ែអាទូ លួចកេះខ្ញុំខ្លាច) ។ សមមិត្តបន្តទៀតថា មានមិត្តនារីខ្លះទៅហូបបាយនៅពេលបាយស្លៀកពាក់មិនសមរម្យឡើយ ។ ខ្លះពាក់អាវកវាលធំៗ ដើម្បីចង់ពង្រីកអារម្មណ៍អ្នកដួសបាយឲ្យភ្លេចខ្លួន ច្រឡំហើយមិត្តនារីអើយ សមមិត្តប្រុសៗយើងមិនលង់នឹងសម្រស់មិត្តឯងទេ ត្រូវកសាងខ្លួនឲ្យល្អឡើងវិញស្លៀកពាក់ឲ្យជិតៗ ។

នៅតាមផ្លូវត្រឡប់មកផ្ទះវិញ បងស្រី ម៉ែអាទូ និយាយលេងសើចនឹងខ្ញុំថា÷

-ពួកវាពូកែតែមាត់ទេ តែពួកប្រុសៗមូលដ្ឋានវាតែងលួចមើលយើងគ្រប់ៗគ្នា... ។

ខ្ញុំសួរបងស្រីថា អ្នកណាដែលច្រើនពាក់អាវកធំៗទៅញ៉ាំបាយល្ងាច ។ បងស្រីថា គ្មានអ្នកណាក្រៅពី កល្យាណ ទេ វាមេម៉ាយកូនមួយ អ៊ីរី នៅជាមួយវាមើលកូនឲ្យវា ។ កល្យាណជាអតីតសិស្សវិទ្យាល័យដេកាត ហើយវាក្រឡុកពួកមូលដ្ឋានឲ្យជ្រួលដោយសារវាច្រើនដងហើយ ។

ព្រឹកនេះពីព្រលឹមស្រាងៗ យើងរៀបបាយកញ្ចប់គ្រប់ៗគ្នាដើម្បីទៅចម្ការគាស់ដំឡូង ។ ចម្ការនៅលើភ្នំមានចម្ងាយប្រហែលពីរគីឡូម៉ែត្រពីភូមិដែលយើងរស់នៅ ។ ចំណែកប្ដីខ្ញុំទៅលើកទំនប់នៅភូមិខាងជើងជាមួយក្រុមប្រុសៗ ។ នៅតាមផ្លូវទៅចម្ការដែលនៅលើភ្នំ ខ្ញុំបានស្គាល់មិត្តថ្មីជាច្រើនទៀត ហើយនិង កល្យាណ ។ យើងដូចមាននិស្ស័យនឹងគ្នាណាស់ ស្គាល់គ្នាភ្លាមចូលចិត្តគ្នា និយាយរកគ្នាលេងសើច ហើយចូលចិត្តនិយាយរឿងតែពីសង្គមចាស់ល្អមតែគេកសាងមិនខុសមែន ។ នៅលើភ្នំ ខ្ញុំគាស់ដំឡូងមិនសូវបានល្អនឹងគេទេ តែទោះគេស្ដីថាឲ្យយ៉ាងណាក៏ខ្ញុំមិនត គិតតែធ្វើការ ហើយទន្ទេញពាក្យដែលប្ដីខ្ញុំប្រាប់ថា "តស៊ូទើបរស់" ។ ល្ងាចឡើង យើងត្រឡប់មកផ្ទះដោយមានទូលដំឡូងដែលយើងលួចបន្ទំបានដាក់ក្នុងកញ្ជើគ្របដោយស្លឹកដំឡូងជ្វា ។ យើងដើរបណ្ដើរជជែកគ្នាបណ្ដើរ ។

មកដល់ផ្ទះឈើស្អាតមួយ ខ្ញុំសួរអ្នកដើរជាមួយថា ផ្ទះអ្នកណាស្អាតម្ល៉េះ? បងស្រីម្នាក់ថា គឺផ្ទះពុកក្រុក មេប្រធានសហករណ៍យើង ។ មួយខែកន្លងផុត ព្រឹកនេះនៅក្នុងចម្ការដំឡូងក្រោមកម្ដៅព្រះអាទិត្យក្ដៅហែង មានជនម្នាក់ដើរចូលមកក្នុងចម្ការដោយដំណើរយ៉ាងស្វាហាប់ មានទឹកមុខញញឹមស្រស់ស្រាយ អាយុប្រហែលចន្លោះពី៤៨ទៅ៥០ឆ្នាំ ។ បងស្រីម៉ែអាទូ ប្រាប់ខ្ញុំថា នោះគឺ ពុកក្រុក ហើយប្អូនណាង ។ ខ្ញុំមើលមុខគាត់ដូចជាស្លូតទេ ។ បងស្រីម្នាក់ដែលនៅក្បែរខ្ញុំពេបមាត់ថាៈ ចាស ស្លូតល្អណាស់ សម្លាប់មនុស្សដូចសម្លាប់សត្វអីចឹងនាងអើយ ។ ខ្ញុំបះសក់ព្រូង ។

## សោកនាដកម្មស្នេហាមួយ

យប់នេះក្រោយពេលបាយរួច បងស្រី ម៉ែអាទូ និងប្អូនស្រីសូថា បានអង្គុយលេងជាមួយខ្ញុំ ។ បងស្រីងាកមើលឆ្វេងស្ដាំឱនមើលក្រោមផ្ទះព្រោះខ្លាចជញ្ជាំងមានត្រចៀក ហើយគាត់និយាយរឿង ពុកក្រុក ឲ្យខ្ញុំស្ដាប់ ។ បងស្រីនិយាយថា÷

-ឯងកុំឃើញមុខញញឹមៗថាគាត់ស្លូតនោះ សាហាវជាងខ្លាទៅទៀត ។ កាលពីបី-បួនខែមុនមានរឿងស្នេហាមួយយ៉ាងអាណោចអាធ័មបំផុត ។ ប្រុសជាអ្នកមូលដ្ឋាន ហើយស្រីជាអ្នក១៧មេសា តែទាំងពីរនាក់សុទ្ធតែមានប្ដី-ប្រពន្ធរៀងៗខ្លួន ។ ប្រុស-ស្រីពីរនាក់នោះបានលួចស្រលាញ់គ្នា ហើយលួចយកគ្នាដោយលួចលាក់រហូតមានផ្ទៃពោះបី-បួនខែ ។ នៅពេលគេឲ្យទៅដេកលើកទំនប់នៅក្រៅភូមិ យប់មួយនោះអ្នកទាំង២បានលួចជួបគ្នា ហើយត្រូវប្ដី-ប្រពន្ធទាំងសងខាងចាប់បាននាំទៅប្ដឹងប្រធានភូមិ ។ ស្អែកឡើង គេបានយកអ្នកទាំងពីរមកកាត់ទោសនៅក្នុងទីធ្លាជើងវត្តនេះ ។ (បងស្រីចង្អុលដើមអម្ពិលបារាំងពីរដើមដែលគេចងអ្នកទាំងពីរ) គេចងពីរនាក់នោះទល់មុខគ្នា ហើយគេហៅប្រជុំអ្នកភូមិអ្នកស្រុក ទោះទៅធ្វើការនៅទីឆ្ងាយឯណាក៏ដោយ ក៏គេហៅមកដែរ ។

ប្អូនស្រី សូថា និយាយកាត់ថា÷ កាលណោះពួកយើងខំតែអរ ស្មានតែគេហៅមកដើម្បីឲ្យរៀបចំខោអាវត្រឡប់ទៅភ្នំពេញវិញ ។ (ពុទ្ធោ ពីរឆ្នាំថ្ងាយហើយយើងនៅតែរស់ក្នុងក្ដីស្រម័យជានិច្ច) ។ តែតាមពិតគេហៅមកជួយកាត់ទោសជនផិតក្បត់សោះ ។ ពុកក្រុក ឡើងលើវេទិកាមួយខ្ពស់ ហើយស្រែកសួរពួកយើងទាំងអស់គ្នាតើត្រូវកាត់ទោសជនក្បត់ពីរនាក់នេះយ៉ាងម៉េច? ស្ងាត់ច្រៀបគ្មានអ្នកណាឆ្លើយ មានតែប្រុសៗអ្នកមូលដ្ឋានពីរ-បីនាក់ស្រែកថា កម្ទេចចោលៗ ។ ពុកក្រុកស្រែកបន្ទរតាមក្រោយ ទឹកមុខកាចសាហាវ ហើយឲ្យពួកយើងលើកដៃ បើអ្នកណាមិនលើកគឺចូលដៃនឹងខ្មាំងដែរ ។ ទាំងអស់គ្នាក៏បង្ខំលើកដៃទាំងទើសទាល់ ។ ក្រោយពីអង្គប្រជុំសម្រេចហើយ ពុកក្រុក ក៏ចុះពីលើវេទិកា ដៃកាន់ចបជីកមួយ ដើរសំដៅអ្នកទោសប្រុសហើយសួរថាៈ "មិត្តឯងមានយោបល់អីទេ?"

បុរសមានទោសស្នេហាមុខខ្មៅអែ ដឹងថាថ្ងៃអវសានដល់ហើយ គាត់ងើបមើលមុខប្រពន្ធដើម មើលមុខសង្សារក្រោយ មើលមុខប្រជាជនគ្រប់ៗគ្នា ដូចជាអង្វរឲ្យគេជួយជង តែគ្មានអ្នកណាម្នាក់ហ៊ានងើបមុខបញ្ចេញយោបល់អ្វីទេ ។ ពុកក្រុកបញ្ជាឲ្យឈ្លបស្រាយបុរសនោះពីដើមអម្ពិលមកលុតជង្គង់ឱនក្បាលចុះហើយឲ្យស្រែកថា ខ្ញុំរាងហើយ ៗ ។ ពុកក្រុក យារចបជីកសំពងអស់មួយទំហឹងផ្នែកក្បាលខាងក្រោយឮសូរប៉ូកពុំសមនឹងស្លាប់សោះ ។ បុរសអភ័ព្វដួលផ្កាប់មុខទៅដី ហើយថែមមួយចបទៀតស្ងាត់មាត់គ្មានកម្រើកខ្លួន ។ ប្រពន្ធដើមបុរសនោះក៏ដួលនៅក្នុងចំណោមមនុស្សគ្រប់គ្នា ។ ឥឡូវដល់វេនស្រីសហាយ

វិញម្តង ។ នៅពេលឈប់ស្រាយចំណងនាងក៏ដួលរលំទៅហើយ ។ នាងទឹកភ្នែកហូររហាម ព្រលឹងធំរបស់នាងប្រហែលជារត់ចេញមុនទៅហើយក៏មិនដឹង ។ នាងត្រូវឈ្លបបញ្ជាឲ្យលុតជង្គង់ដែរ ហើយឲ្យស្រែកថា «ខ្ញុំឈប់ធ្វើដូច្នេះហើយ» ។ ពុកក្រុក សំពងក្បាលស្រីនោះពីក្រោយប្រហែលប្រាំពីរ-ប្រាំបីចបទើបនាងលែងកម្រើកខ្លួន ។ ប្រហែលមកពីនាងមានមនុស្សម្នាក់ទៀតនៅក្នុងពោះទើបក្រស្វាប់ដូច្នេះ ។ ពួកយើងទាំងអ្នកចាស់ទាំងអ្នក១៧មេសា សែនតក់ស្លុតរន្ធត់ញាប់ញ័រគ្រប់គ្នា ព្រោះទោសស្នេហាប៉ុណ្ណេះពុំសមទទួលទណ្ឌកម្មដល់ថ្នាក់នេះសោះ ។

ខ្ញុំស្រក់ទឹកភ្នែកដោយមិនដឹងខ្លួន ។ បងស្រីបន្តថា គេដឹកសពអ្នកទាំងពីរតាមរទេះគោយកទៅកប់ជាមួយគ្នា ហើយគេនិយាយថា ក្រោយមកកន្លែងនោះលងសម្បើមណាស់ ទោះដើរពេលថ្ងៃក៏ដោយក៏គេឮសំឡេងមនុស្សស្រី-ប្រុសសើចប្រឡែងគ្នាលេង ហើយដើមឫស្សីពីរ-បីដើមនោះតែងយោលយោកជានិច្ច ទោះជាគ្មានខ្យល់ក៏ដោយ ។ ពុកក្រុក បញ្ជាឲ្យពីរនាក់ប្តី-ប្រពន្ធដែលនៅរស់យកគ្នាទៅ កុំឲ្យចាញ់ចិត្ត គេយកប្តីយើងបាន យើងក៏យកប្តីគេបានវិញដែរ តែពុំដឹងថាអ្នកទាំងពីរយកឬអត់ ។

នេះជាសោកនាដកម្មស្នេហាមួយដែលអ្នកស្រុកជើងវត្តនិងអ្នកភូមិជិតខាងពុំអាចបំភ្លេចបាន ។ បងប្អូនខ្លះដែលធ្លាប់រស់នៅភូមិនោះពិតជាចងចាំរឿងនេះពុំខានឡើយ ។ តាំងពីថ្ងៃនោះមកឲ្យតែមានអ្នកណាលួចស្រលាញ់គ្នា គេតែងហៅថា «អាដើមអម្ពិលបារាំង» ដើម្បីជាការក្រើនរំឭកអ្នកទាំងពីរ ។

## ទឹកត្នោតពូបារាំង! Kiss ប្រែថាដែកកេះមួយ

ព្រឹកនេះខ្ញុំដើរទៅចម្ការពីព្រឹកជាមួយ កល្យាណ ។ នៅពេលដើរដល់ដើមត្នោតពីរ-បីដើម កល្យាណ ប្រាប់ខ្ញុំថា «បង! យើងសុំទឹកត្នោតពូបារាំងញ៉ាំ» ។ ពូបារាំង ថ្វីត្បិតតែគាត់ជាអ្នកមូលដ្ឋាន តែគាត់មានសម្បុរសមាឌធំល្អណាស់ ។ គាត់ចូលចិត្តលេងសើចនឹងក្រុមស្រីៗបច្ចេកទេសមេម៉ាយណាស់ ។ ប្រពន្ធចាស់របស់គាត់តែងឃ្លាំមើលគ្រប់ពេលវេលា ។ នៅពេលដើរដល់ដើមត្នោត មានបំពង់ទឹកត្នោតដែលមានទឹកហើយស្រេចព្យួរតែកតោកនៅគល់ត្នោត ចំណែកពូបារាំងកំពុងតែតោងឡើងដល់ពាក់កណ្តាលដើម ។ កល្យាណ ស្រែកថា÷

-ពូបារាំងអើយ ខ្ញុំសុំទឹកត្នោតហូបបន្តិច ។

ពូបារាំងឆ្លើយទាំងមិនមើលមកក្រោមថា÷

-អឺ ហូបទៅ ហើយឲ្យអីខ្ញុំវិញ?

កល្យាណ ឆ្លើយថា÷

-ចាំខ្ញុំឲ្យ Kiss មួយ (ប្រែថាថើប)

តែពូបារាំងមិនចេះស្តាប់ គាត់ក៏ថា÷

-អឺ ដែកកេះក៏យកដែរ ។

ពួកយើងហូបឆ្អែតហើយនាំគ្នារត់យ៉ាងលឿនទៅចម្ការ ។ ថ្ងៃក្រោយឲ្យតែជួបមុខ ពូបារាំង តែងទាររកដែកកេះជានិច្ច ។ កល្យាណ ចូលចិត្តនិយាយលេងសើចច្រើន ហើយហ៊ាននិយាយមិនសូវខ្លាចអ្នកណាទេ ។ ពេលល្ងាចនៅពេលត្រឡប់ពីចម្ការវិញ កល្យាណ ងូតទឹកយ៉ាងស្អាតហើយពាក់អាវយឺតវាលកវាលក្លៀកយ៉ាងព្រហើនដើរទៅហូបបាយនៅរោងចុងភៅ ។ នៅរោងបាយគេធ្វើតុវែងមានកៅអីពីរជួរសម្រាប់អង្គុយហូបបាយ ។ សម្លមួយចានមានគ្នាបួននាក់អង្គុយហូបព័ទ្ធជុំវិញចានសម្លដែលគ្មានឃើញសាច់ត្រីឬសាច់ជ្រូកបន្តិចសោះ មានតែបន្លែស្ពៃឬត្រកួននិងខ្ទាញ់អណ្តែតត្រាប៉ុណ្ណោះ ។

នៅពេលបាយ ពួកយើងមិនអាចចាំប្តីឬប្រពន្ធបណ្តើរគ្នាទៅហូបបាយបានទេ ។ អ្នកណាមកដល់មុនទៅហូបមុនទៅ ទោះកូនប្រុសភ័ក្ត្រខ្ញុំក៏ដោយ វាទៅជាមួយក្មេងៗគ្នាវាទៅ ។ នៅទីនោះមានចុងភៅប្រុសម្នាក់នៅចាំដួសបបរឲ្យ (មិនទាន់ដល់ខែប្រូតយើងហូបបបរជួនរាវជួនខាប់) ។ ចុងភៅនោះតែងតែសម្លក់សម្លឹងយើងនៅពេលដែលយើងទៅដួសបបរដែលសុទ្ធតែទឹកញយពេក ។ សម្លវិញក៏ដូច្នេះដែរ បើមានស្នេហ៍មុខ ប៉ុនសម្តីបញ្ជោរដូច កល្យាណ ទើបអាចមានវាសនាប្រទះសាច់ត្រីមួយៗ ។

ខ្ញុំអង្គុយហូបជុំគ្នាជាមួយ ចែមុំ ពីរថ្ងៃហើយ ។ គាត់តែងយកវែកបាយទៅហូបបបរ ដួសសម្លតែមួយវែកគាត់គឺអស់សម្លកន្លះចានស្រេច ។ ពួកយើងបីនាក់សម្លឹងមើលគាត់ គាត់ធ្វើអឹមអៀនហើយនិយាយថា÷

-ខ្ញុំបាក់ស្លាបព្រាអស់ហើយទើបយកវែកមកហូបដូច្នេះ ។

ស្អែកឡើងខ្ញុំយកវែកបាយទៅហូបបបរដែរ ដួសសម្តែមួយវែកចង់អស់សម្ពីចាន (សម័យនោះទាល់តែឆ្លាតទើបរស់បាន) ។ ពុកក្រក តែងលើកសុភាសិតមួយឃ្លាថា "សុខចិត្តឲ្យស្គួរ តែមិនឲ្យដាច់" ។

ព្រឹកនេះអង្គការដូរកម្មវិធីឲ្យក្រុមស្រីៗយើងទៅជួយលើកទំនប់នៅជិតភូមិម្តង ។ ល្ងាចឡើង នៅពេលជិតឈប់សម្រាកទៅហើយ បងស្រី ម៉ែអាទូ មុតជើងនឹងចបជីកចេញឈាមយ៉ាងច្រើន ។ យើងបោចស្មៅយកមកឃាត់ឈាមយ៉ាងណាក៏មិនបាត់ ។

ខ្ញុំមានភារៈត្រូវជូនបងស្រីមកផ្ទះ ។ នៅតាមផ្លូវ យើងប្រទះឃើញចម្ការស្លឹកខ្ទឹមបី-បួនរង ។ បងស្រី ម៉ែអាទូ ឲ្យខ្ញុំគ្រាហ៍គាត់ទៅសុំគេពីរ-បីសន្លឹកយកមករុំជើងឃាត់ឈាម ។ លោកអ្នកអានទាយទៅមើល តើម្ចាស់ស្លឹកខ្ទឹមឆ្លើយយ៉ាងម៉េច ។ គេថា តាំងពីកើតពោះម៉ែមកមិនដែលមានអ្នកណាយកស្លឹកខ្ទឹមទៅឃាត់ឈាមទេ បើចង់បានយកទៅស៊ីប្រាប់តាមត្រង់ទៅ ។ បងស្រី ម៉ែអាទូ ដើរបណ្តើរ យំបណ្តើរ ជេរបណ្តើរថា "អាចោរថ្លើមខ្មៅ ចាំមើលពីរបីថ្ងៃទៀតអញលួចដកបោចឲ្យអស់" ។

បានប្រហែល១០ថ្ងៃ ជើងបងស្រីក៏បានគ្រាន់បើបន្តិច ។ យប់នេះរាងស្វាត់បន្តិចទៅហើយ បងស្រី ម៉ែអាទូ បបួលខ្ញុំទៅលួចដកស្លឹកខ្ទឹម ។ ខ្ញុំរួញរាមិនហ៊ានទៅ តែទីបំផុតក៏ព្រមទៅតាមការអង្វរកររបស់គាត់ ។ យើងទាំងពីរនាក់ដកស្លឹកខ្ទឹមអស់មួយរង ហើយច្រកក្នុងស្បោងក្រណាត់យកមកផ្ទះ ។ មកដល់ផ្ទះ យើងកាត់មើមៗវាលាងឲ្យស្អាតហើយច្រកចូលក្នុងឪទិនទឹកត្រីធ្វើជ្រក់ភ្លាមៗ ស្លឹកវាច្រើនពេកយើងកប់នៅក្នុងដេះមុខចង្ក្រាន ។ យប់នេះ យើងនៅក្នុងផ្ទះបីគ្រួសារ រួមទាំងប្អូនស្រី សូដា ផងគេងពុំលក់ទេ ។

ស្អែកឡើងយើងទៅលើកទំនប់ធ្វើដូចមិនដឹងខ្លួន ។ ថ្ងៃត្រង់ពេលឈប់សម្រាកហូបបាយ អាទូ កូនប្រុសរបស់បងស្រីរត់ត្រហេបត្រហបទៅខ្សឹបប្រាប់ម៉ែវាថា មានឈ្លបពីរ-បីនាក់ដើរឆែកតាមផ្ទះដើម្បីរកស្លឹកខ្ទឹមដែលបាត់មួយរងពីយប់មិញឥឡូវជិតដល់ផ្ទះយើងហើយ ។ បងស្រី ម៉ែអាទូ និងខ្ញុំ រត់យ៉ាងលឿនទៅផ្ទះ ហើយកាយស្លឹកខ្ទឹមដែលនៅក្នុងដេះមុខចង្ក្រានច្រកចូលក្នុងថង់ក្រណាត់ ហើយដាក់ព្យួរនឹងជញ្ជាំងក្រោយផ្ទះដោយលូកតាមបង្អួច ។ ខ្ទឹមមិនបានចោលក្លិនទេ ព្រោះកប់ដេះមួយយប់ហើយ តែយើងភ័យបុកពោះមិនស្មើរទេ ។ រួចរាល់ហើយ បងស្រីធ្វើជាដេកឲ្យខ្ញុំកោសខ្យល់ឲ្យមិនទាន់ត្រឡប់ទៅធ្វើការវិញទេ ។ ឈ្លបបានឡើងមកពិនិត្យមើលចង្ក្រានបាយយើង គឺកន្លែងដែលសម្រាប់ឲ្យយើងដាំទឹកហូបតែប៉ុណ្ណោះ ។ សំណាងល្អ ឈ្លបរបស់អង្គការអាវខ្មៅមិនបានអើតមើលជញ្ជាំងខាងក្រោយផ្ទះ ។ ប្រហែលបារមីជើងវត្តជួយក៏មិនដឹង ។ យើងក៏រួចគ្រោះម្តងទៀត ដោយចៃដន្យបំផុត ។

## ប្អូនអឿន អ្នកវែកជីមនុស្ស

ក្នុងភូមិនេះ អ្នកវែកជីមនុស្សគឺជាមនុស្សដែលគេខ្ពើមបំផុត ។ បើចូលផ្ទះអ្នកណា សុំទឹកគេហូបក៏គេមិនចង់ឲ្យដែរ ហើយបើទៅហូបបាយនៅរោងបាយក៏គេមិនចង់ឲ្យអង្គុយជិតដែរ ។ តែអ្នកវែកជីមានសុវត្ថិភាពល្អណាស់ ព្រោះគេពុំរវល់ហៅទៅកងចល័តឆ្ងាយពីផ្ទះ ឬធ្វើការអីផ្សេងទៀតទេ ។ ប្អូនអឿន អាយុ១៨ឆ្នាំហើយ មានមុខវែង ច្រមុះស្រួច សក់ស្កូត គឺជាអតីតនិស្សិតពេទ្យឆ្នាំទី១ ហើយត្រូវជាកូនទី១របស់ អ៊ំសារ៉េត ។ ប្អូនពុំដែលរវល់ធ្វើចេះដឹងអ្វីទេ ហើយក៏មិនចង់និយាយរកអ្នកមូលដ្ឋានដែរ ។ ប្អូនធ្វើសឹៗ ឡឹកឹៗ ជួនធ្វើថ្លង់ក៏មាន ។ នៅពេលស្វាត់កំបាំងពីមុខអ្នកមូលដ្ឋាន ប្អូននិយាយព្រោកប្រាជ្ញមិនចេះខ្ជិល ។ ប្អូនអឿន និយាយថា៖ "ខ្ញុំមិនឆោតទៅកើបអាចម៍គេទេ គឺខ្ញុំយកដីទៅចាក់ក្នុងបង្គន់ហើយកាយយកដីនោះវែកដាក់បង្គីជាការស្រេច" ។ ជួនកាល ប្អូនដើរត្រឡប់ចុះត្រឡប់ឡើងពេញភូមិ ដើម្បីឲ្យអង្គការមើលឃើញថាប្អូនជាមនុស្សសកម្ម ។ សម័យនោះមានតែអ្នកធ្វើល្ងង់ទេទើបអាចសល់ជីវិតបាន ។ មកដល់សម័យនេះ ប្អូនអឿន ក្លាយជាវេជ្ជបណ្ឌិត ។

## នារីកំពូលល្បិចទាំង១៨នាក់

យប់នេះ ប្រហែលពាក់កណ្តាលអធ្រាត្រ បងស្រី ម៉ែអាទូ ងើបមកកេះជើងខ្ញុំហើយខ្សឹបថា៖

-ប្អូនណាងឯងចង់ស្តាប់ចម្រៀងទេ?

គំនិតព្រើលរបស់ខ្ញុំនៅមិនចេះរាងចាលសោះ ។ ខ្ញុំផ្ទៀងត្រចៀកស្តាប់ពុល្មើយៗពីសាលាឆាន់ដែលឥឡូវនេះទុកសម្រាប់

ឲ្យពួកក្រុមឈ្លបយុវជន-យុវតីស្ទាក់នៅ ។ ខ្ញុំនិងបងស្រីលួចចុះដណ្តើរថ្នមៗ ដើរសំដៅទៅប្រភពសំឡេងដោយចិត្តពុះកញ្ជ្រោល ។ គឺពិតជាពុំមែនបទបដិវត្តន៍ដែលខ្ញុំធ្លាប់ឮរាល់ព្រឹកនោះទេ ។ គឺជាសំឡេងតួញត្អែររបស់អ្នកស្រី ម៉ៅ សារ៉េត "មេឃខ្មៅងងឹត សម្លឹងមើលចិត្ត..."

ឱ! ពីរោះអ្វីម្ល៉េះទេ! ថ្មើរណោះអ្នកស្រីរសាត់អណ្តែតទៅដល់ណាហើយ ។ ខ្ញុំឈរឱបដៃបងស្រី ម៉ែអាទូ ដាក់នៅទ្រូងទឹកភ្នែកហូររហាម មិនស្មានថាមានវាសនាបានឮបទចម្រៀងអស់នេះឡើងវិញសោះ រីឯបងស្រីក៏ដូច្នេះដែរ ។ យប់ក្រោយៗមក យើងតែងនាំគ្នាទៅលួចស្តាប់ចម្រៀងរាល់យប់នៅក្រោមសាលាលោកឆាន់នោះ ។ យប់ខ្លះក៏ឮពួកយុវជនស្រី-ប្រុសនោះប្រឡែងគ្នាឲ្យកក្អឹក ។ យប់នោះ ពេលខ្ញុំនិងបងស្រីកំពុងស្ងួងអារម្មណ៍នឹងបទ "ម្ភៃឆ្នាំក្នុងគុកដោយដៃស្រីល្អ" របស់លោកស៊ិន ស៊ីសាមុត ។ ខ្ញុំឈរផ្អែកលើបាវជាច្រើនដែលដាក់គរជាច្រើនជួរ ។ ខ្ញុំលូកដៃចុចស្ទាបមើលជាបាវអ្វី ។ បងស្រីខ្សឹបប្រាប់ខ្ញុំថាជាបាវស្រូវ ។ ដល់ពេលនោះទើបខ្ញុំនឹកឃើញថាមែនហើយ កន្លែងនេះពេលថ្ងៃគេកិនស្រូវទេតើ ។ ពេលត្រឡប់មកផ្ទះវិញ ពួកយើងពីរនាក់គិតគ្នាដើម្បីលួចស្រូវក្នុងបាវនោះឲ្យបាន ។

គិតអស់ពីរ-បីយប់ទើបខ្ញុំនឹកឃើញរឿងកុនចិនហុងកុងមួយដែលលេងនៅរោងគិរីរម្យ គឺរឿងកំពូលនារី១៨នាក់ ។ កាលនោះ ស្ត្រីៗទាំងអស់នោះមានប្តីជាមេទ័ព ក្រោយមកទៅធ្វើសង្គ្រាមក៏ត្រូវសត្រូវសម្លាប់អស់ទៅ ។ ស្ត្រី១៨នាក់ដែលត្រូវជាប្រពន្ធនោះក៏ស្ម័គ្រចិត្តសុំព្រះរាជាទៅធ្វើសឹកម្តងដើម្បីសងសឹកជូនប្តីខ្លួន ។ ស្តេចក៏យល់ព្រម ហើយស្ត្រីទាំងនោះក៏នាំទ័ពធ្វើដំណើរទៅ ។ ពេលឈប់សម្រាកនៅពេលយប់នៅតាមផ្លូវសត្រូវម្ខាងទៀតបានមកលួចដុតស្បៀងអង្ករបស់ទ័ពខាងនារី១៨នាក់ហិនហោចអស់រលីង ។ "ធ្វើស្រែនឹងទឹក ធ្វើសឹកនឹងបាយ" សេនាទាហានខាងនារី១៨នាក់គ្មានកម្លាំងកំហែងនឹងច្បាំងព្រោះគ្មានអ្វីហូប ។ ពេលនោះមានទាហានស្ម័គ្រចិត្តស៊ូស្លាប់ពីរ-បីនាក់សុខចិត្តទៅលួចអង្ករនៅឃ្លាំងរបស់សត្រូវម្ខាងវិញ ។ ទាហានបីនាក់នោះមានកូនបាវតូចល្មមមួយម្នាក់ និងបំពង់ឫស្សីដែលគេសម្រួចចុងហើយស្រេច លូនចូលក្នុងឃ្លាំងអង្ករ ។ ទៅដល់គេយកឫស្សីចុងស្រួចចាក់ចូលក្នុងបាវអង្ករ បង្ហូរចូលបាវតូចដែលយកទៅចងនៅចង្កេះរបស់គេ ។ ទាហានដ៏ក្លាហាននោះត្រឡប់មកវិញតែពីរនាក់ប៉ុណ្ណោះ ម្នាក់ទៀតបានពលីជីវិតនៅតាមផ្លូវទៅហើយដោយសត្រូវតាមទាន់ ។ ទោះយ៉ាងណា អង្ករបន្តិចបន្តួចយកមកលាយនឹងស្លឹកឈើព្រៃអាចជួយទ័ពទាំងអស់ឲ្យមានកម្លាំងធ្វើសឹកតទៅទៀតបានដែរ ។

នឹកឃើញដល់ត្រង់នេះខ្ញុំក៏និយាយប្រាប់បងស្រី ម៉ែអាទូ គាត់ក៏យល់ស្របតាមខ្ញុំ ។ យប់នេះយើងក៏បើកប្រតិបត្តិការនៅពេលពាក់កណ្តាលអធ្រាត្រ ។ ពេលចេញដំណើរទៅ ខ្ញុំមានអារម្មណ៍ថាដូចជាចេញទៅធ្វើសង្គ្រាមដ៏ធំមួយ ។ បេះដូងគក់ក្តាក់ចង់ខុសចង្វាក់ ។ យើងទាំងពីរនាក់ប្រុងប្រយ័ត្នណាស់ ត្រចៀកស្តាប់ភ្លេងបណ្តើរ យកបំពង់ឫស្សីតូចមួយប្រវែងមួយម៉ែត្រដែលសម្រួចចុងហើយស្រេច ចាក់ចូលក្នុងបាវស្រូវ ហើយបង្ហូរស្រូវចូលក្នុងស្បោងក្រណាត់ដែលយើងយកអាវមកកាត់ ។ យើងមិនហ៊ានយកច្រើនទេ បានតែមួយកូនស្បោងតូចប្រហែលបី-បួនគីឡូក្រាមប៉ុណ្ណោះ ។ ម្យ៉ាងខ្លាចរហែកស្បោង ព្រោះក្រណាត់វាផុយណាស់ទៅហើយ ។ មកដល់ផ្ទះ យើងស្រាយមើលទាំងរញីរញ៉័រ ។ គឺស្រូវដែលកិនហើយ ប៉ុន្តែមិនទាន់ស្រិត ។ ចំជារកខុសប្រទះឃើញវាប់មែន ។ បងស្រី ម៉ែអាទូ មានកូនល្អីតូចមួយ ។ គាត់អុំយកអង្ករស្អាតហើយក៏ដាំបាយទាំងយប់នោះហូបតែម្តងទៅកុំឲ្យឃើញដាន ។ គ្មានអ្វីសប្បាយជាងមានបាយហូបទេ ។ ខ្ញុំនៅអង្គុយកាំជណ្តើរមើលផ្លូវ ។ សំណាងល្អគ្មានឃើញស្រមោលឈ្លបណាមកក្បែរសោះយប់នេះ ។ យើងហូបបាយជាមួយខ្ទឹមជ្រក់ដែលលួចបានពីថ្ងៃមុន ។

ព្រឹកនេះ យើងត្រូវទៅចម្ការដកដំឡូងមីម្តង ។ យើងសប្បាយរីករាយពេលទិសដៅត្រូវទៅចម្ការ ព្រោះទោះយ៉ាងណាក៏យើងបានដំឡូងមកផ្ទះសោរហូបដែរ ជួនកាលក៏យកមកឈូសចំហុយ ។ នៅតាមផ្លូវទៅចម្ការ បានជួបនឹងអ៊ំស្រីម្នាក់ដែលខ្ញុំមើលគាត់មិនចង់ស្គាល់ ព្រោះគាត់ស្គមពេក ។ គាត់កំពុងតែរែកទឹកនៅតាមផ្លូវ ។ អ៊ំស្រីឱបខ្ញុំដោយសេចក្តីនឹករឭក ។ គាត់ចង្អុលផ្ទះរបស់គាត់ឲ្យខ្ញុំស្គាល់ដើម្បីថ្ងៃក្រោយចូលលេង ។ អ៊ំស្រី

ឱ្យបសួរខ្ញុំថា មានថ្នាំជក់ទេ ដូរត្រីដូរស្ករក៏បាន ។ ខ្ញុំថាគ្មានទេ តែនៅចម្ការក្រោយផ្ទះខ្ញុំមានគេដាំថ្នាំជក់ ចាំថ្ងៃណាខ្ញុំចូលយកស្លឹកថ្នាំមកឲ្យ ។ អ៊ំស្រីថាយកមកគាត់ហាលឲ្យ ព្រោះផ្ទះអ៊ំនៅឆ្ងាយពីគេ គ្មានអ្នកណាគេចាប់អារម្មណ៍ទេ ។ រវល់តែជជែកគ្នា ទឹកក្នុងធុងអ៊ំស្រីក៏អស់រលីងព្រោះធុងវាធ្លាយ ។

ល្ងាចឡើងពេលមកពីចម្ការវិញ ពួកអ្នកមូលដ្ឋានទូលកញ្ជើដើរដោយក្រុមៗ ។ គេទូលកញ្ជើដើរដោយមិនយកដៃទប់កញ្ជើដូចពួកយើងទេ ។ ក្រុមយើងបួន-ប្រាំនាក់ដើរខាងក្រោយគេឆ្ងាយបន្តិចស្រួលជជែកគ្នា ។ កល្យាណ និយាយថា "ពួកយើងរៀនទូលកញ្ជើដូចពួកខាងមុខ ហាមមិនឲ្យយកដៃកាន់ទេណា៎ ចាំមើលខ្ញុំធ្វើមុនគេហើយ" ។ កល្យាណ ក៏ដើរកាច់រាងដោយយកដៃច្រត់ចង្កេះ ។ ទើបនឹងបានបួន-ប្រាំជំហានក៏កំពប់កញ្ជើចំមុខផ្ទះ ពុកក្រុក តែម្តង ចៃដន្យ ពុកក្រុក ជិះកង់មកដល់ល្មម ។ កល្យាណ ស្ទាំងមុខ ឱនរើសដំឡូងដែលធ្លាក់រាយប៉ាយយ៉ាងប្រញាប់ប្រញាល់ ។ យើងទាំងអស់គ្នាក៏ស្ទុះទៅជួយរើសដែរ ។ ពុកក្រុក មុខមាំស្តីឲ្យថា "ពួកឯងប៉ិនលួចណាស់ គ្រាន់តែម្នាក់ប៉ុណ្ណឹងទៅហើយ បានតែយកទៅរៃចោលមួយ-ពីរឲ្យដឹងម្តង" ។

តាមពិត ពុកក្រុក គ្មានបំណងធ្វើបាបយើងទេ បើពុំដូច្នេះ ថ្ងៃនោះប្រហែលគ្មាននរណាម្នាក់រួចខ្លួនឡើយ ។

ពីរ-បីថ្ងៃក្រោយមក ខ្ញុំបបួលបងស្រី ម៉ែអាទូ ទៅលួចបេះស្លឹកថ្នាំជក់ ។ យប់សែនមហាងងឹតរកចាក់ភ្នែកពុំយល់ ផ្ទៃមេឃគ្មានផ្កាយមួយដួងសោះ ។ ខ្ញុំដើរជាមួយបងស្រីស្ទាបៗតាមការចំណាំប៉ុណ្ណោះ ប្រសិនបើមានឈ្លបដើរមកពីមុខបុកគ្នាក៏មើលពុំឃើញដែរ (មកដល់ត្រង់នេះ មិត្តអ្នកអានពិតជាសើចនឹងចោរីខ្ញុំពុំខាន) ។ អស់លោកទាយទៅមើល ខ្ញុំទៅលួចស្លឹកថ្នាំតើខ្ញុំបេះអ្វី? ខ្ញុំគិតថា បើញាំអន្ទក់គឺគេបេះត្រួយឲ្យវាខ្ចីឆ្ងាញ់ ហើយខ្ញុំក៏កាច់ស្លឹកថ្នាំតែត្រួយខាងលើខ្ចីៗដែរ ។

ព្រឹកនោះខ្ញុំងើបពីព្រលឹមងងឹតតិចៗនៅឡើយ ។ ខ្ញុំដើរទៅចម្ការមុនគេ ហើយក៏ដើរសំដៅទៅផ្ទះអ៊ំស្រីយកស្លឹកថ្នាំទៅឲ្យគាត់ហាល ។ អ៊ំស្រីនិយាយថា ស្អែកយកមកត្រីប្រឡាក់ទៅហូប ។ ល្ងាចនេះ ពេលខ្ញុំទៅហូបបាយល្ងាចនៅរោងបាយ ខ្ញុំឮប្រជាជនជជែកគ្នាអំពីរឿងចោរលួចបេះត្រួយថ្នាំជក់ ។ គេសើចគ្រប់ៗគ្នាថា "ចោរអីក៏ភ្លើម្ល៉េះ" ។ ខ្ញុំហួសចិត្តខ្លួនឯងពុំសមល្ងង់ដល់ថ្នាក់នេះសោះ ។

## មរណភាព ពេទ្យធី

ឥឡូវស្រូវទុំហើយ ។ អង្គការតម្រូវឲ្យយើងទៅច្រូតកាត់ម្តង ។ មុនដំបូងច្រូតនៅក្បែរភូមិ បន្ទាប់មកច្រូតនៅក្រោយភូមិ ។ ថ្ងៃត្រង់ជាក់ ក្រុមអ្នកច្រូតប្រុស-ស្រីដើរចូលភូមិវិញដើម្បីហូបបាយ ។ ក្រោយពីហូបបាយរួចភ្លាម យើងត្រូវទៅសម្រាកនៅកន្លែងធ្វើការវិញប្រហែលកន្លះម៉ោងប៉ុណ្ណោះ ។ ក្រោមកម្តៅថ្ងៃក្តៅហែង យើងយកកណ្តាប់ស្រូវរៀបគរលើគ្នាដើម្បីបាំងថ្ងៃ ហើយយើងអង្គុយប្រជៀតគ្នាជជែកលេងតែអំពីរឿងសង្គមចាស់ប៉ុណ្ណោះ ។ កល្យាណ ដែលពូកែវោហារនិយាយថា កាលនៅរៀន មានអ្នកនេះអ្នកនោះតាមគេមិនឈប់ នៅក្នុងថ្នាក់ខស្សរាហ៍មានសំបុត្របុប្ផាកុលាបនៅក្នុងថតតុ ។ ប្អូនស្រី សម្ផស្ស មិនសូវចេះនិយាយស្តីដូចគេឯងទេ ។ ប្អូនស្រីជាអតីតនិស្សិតពេទ្យឆ្នាំទីមួយ ហើយពេលមកនៅភូមិនេះបានមួយឆ្នាំ ប្អូនស្រីក៏ត្រូវអង្គការបង្ខំឲ្យរៀបការមិនដឹងជាប៉ុន្មានសិបគូជាមួយយុវជនជាអ្នកស្រុកអរិយក្សត្រ ទាំងប្អូនមិនពេញចិត្ត ។ ប្តីរបស់ប្អូនស្រី សម្ផស្ស ឈ្មោះ ដែត ជាអ្នកទន្លេពូកែរកត្រីណាស់ ។ អង្គការក៏ចាត់តាំងឲ្យយុវជន ដែត រកត្រីផ្គត់ផ្គង់ជីវភាពនៅរោងបាយ ។ រាល់ល្ងាច មិត្តដែត មកពីរកត្រីវិញនៅពេលយប់ងងឹត ហើយច្រើនចូលផ្ទះរបស់ប្អូនស្រីបង្កើតដើម្បីស្ងោរត្រីហូប ឬជួនកាលរើសត្រីធំៗអាំងហូបឆ្អែតទើបយកត្រីតូចៗមកប្រគល់ឲ្យចុងភៅនៅរោងបាយ ។ មិត្តដែត មិនដែលយកត្រីមកផ្ញើប្រពន្ធទេ ព្រោះគេធុញក្នុងផ្ទះមានម្តាយឪពុកក្មេក និងបងប្អូនសាច់ថ្លៃច្រើនពេក ។ ប្អូនស្រី សម្ផស្ស ក៏ដឹងដែរ ប៉ុន្តែប្អូនស្រីខ្ជិលរវល់ច្រើន ។ ប្អូនស្រីនិយាយទាំងទឹកភ្នែករលីងរលោងថា នៅយប់ខ្លះដែលប្អូនមិនព្រមរួមដំណេកជាមួយប្តី មិត្តដែត ទៅប្តឹងប្រធានភូមិ ហើយប្អូនស្រីក៏ត្រូវប្រធានភូមិហៅទៅកសាងទាំងយប់ ជួនកាលត្រូវអង្គុយហាលមូសទល់ភ្លឺក៏មាន ។ ប្អូនស្រីនិយាយថា បើស្រុកយ៉ាងម៉េចៗទៅ កិច្ចការដំបូងរបស់ប្អូនស្រីគឺលែងប្តីដែលប្អូនគ្មានចិត្តស្រលាញ់អ្វីបន្តិចសោះ ហើយកិច្ចការទីពីរគឺចូលរៀនពេទ្យបន្តទៀត ។

ចំណែកបងស្រី សំឡី និយាយអំពីអនុស្សាវរីយ៍របស់គាត់ជាមួយនឹងប្ដី គឺគ្រូពេទ្យ ធី ដែលកាលនោះពេលការហើយ ប្ដីគាត់នៅរៀនពេទ្យមិនទាន់ចប់ ។ គាត់និយាយថា គាត់ទាំងពីរនាក់តស៊ូនឹងគ្នាណាស់ ទោះអត់ឃ្លានយ៉ាងណាក៏ដោយ ។ កាលនៅរៀន ទោះយប់ជ្រៅយ៉ាងណាក៏គាត់អង្គុយចាំប្ដីគាត់រៀនទាល់ចប់ទើបចូលគេងទាំងអស់គ្នា ។ យប់ខ្លះពេលរៀនចប់ ពួកគាត់ឃ្លានបាយក៏នាំគ្នាយកអាល់កុលដុតសាច់ក្រកញ៉ាំបាយកក ។ និយាយដល់ត្រង់នេះ បងស្រីម៉ែអាទូ ស្រែកថា «អូយ! ឃ្លានសាច់ក្រកណាស់ កុំនិយាយ!» ។

ក្រុមយើងខស្សាហ៍ត្រូវប្រធានកងកសាងណាស់ ព្រោះបេះតែនាំគ្នានិយាយពីរឿងម្ហូបឆ្ងាញ់ រឿងនំឆ្ងាញ់ពីសង្គមចាស់ ។

ស្រូវនៅជិតៗភូមិប្រូតអស់ហើយ ។ អង្គការក៏តម្រូវឲ្យយើងចេញទៅឆ្ងាយម្ដងបន្តិចៗរហូតប្រហែលពីរគីឡូម៉ែត្រពីភូមិ តែគេមិនទៅទាំងប្ដី-ប្រពន្ធទេ ជូនឲ្យប្ដីទៅ ជូនឲ្យប្រពន្ធទៅ ។ អង្គការតម្រូវឲ្យយើងនៅដេកពេលយប់នៅកន្លែងប្រូតតែម្ដង មិនឲ្យមកផ្ទះវិញទេ ដោយមានចុងភៅទៅដាំស្លឲ្យយើងហូបនៅទីនោះ ។

ពេទ្យធី ដែលមានមាឌធំមាំ ខ្ពស់ស្រឡះ កាត់សក់ផ្កាថ្កូវ មានចរិតរួសរាយ ត្រូវអង្គការតម្រូវឲ្យគាត់ទៅប្រូតស្រូវដែរ ។ យប់នោះ នៅក្នុងខ្ទមរួមគ្នាកណ្ដាលវាលស្រែល្ហឹងល្ហើយ ខ្ញុំអង្គុយអណ្ដែតអណ្ដូងនឹកកូននិងប្ដីដែលនៅឯផ្ទះពុំដឹងបានអ៊ីហូប ។

រដូវប្រូតកាត់ យើងបានហូបបាយស្រួយ មានសម្លយើញត្រីខ្លះៗ ។ ព្រឹកនេះ ថ្ងៃទើបតែរះនៅបាំងចុងព្រៃចោលរស្មីបាចសាចមកលើរោងសហករណ៍របស់យើងទាំងអស់គ្នា ខ្ញុំនៅគេងក្នុងជំរំនៅឡើយ ខ្ញុំបានឮសម្រែកដ៏តក់ស្លុតរបស់អ៊ីម្នាក់ថា÷

- ជួយផង ពេទ្យធីស្លាប់ហើយ!

ម្នាក់ៗស្ទុះសឹងបាក់កទៅអើតមើលជំរំដែលគេសើយក្រណាត់ឡើងដើម្បីមើលមុខគាត់ ។ ពេទ្យធី មានទឹកមុខស្លេកស្លាំង ខ្លួនត្រជាក់ស្រឹបគ្មានកម្រើក ប្រៀបដូចគល់ខសងាប់ ។ អ៊ំប្រុស ដួង ដែលនៅសម្រាន្តជិតគាត់ ក៏មិនបានដឹងថាគាត់ស្លាប់ពីអង្កាល់ដែរ ។ អ៊ំប្រុស ដួង ប្រាប់ថា ពីក្បាលព្រលប់ឮសូរពេទ្យធីថ្ងូរថាឈឺក្បាល ។ ឈ្លបក្មេងម្នាក់ដែលមើលការខុសត្រូវកងខ្ញុំ បានរត់ទៅភូមិភ្លាមដើម្បីប្រាប់ប្រពន្ធរបស់ពេទ្យធី ហើយផ្ដែផ្ដាំឈ្លបពីរ-បីនាក់ដែលនៅចាំកន្លែងថា កុំអាលយកសពពេទ្យធី ទៅកប់អី ចាំប្រពន្ធគាត់មកដល់សិន ។ តាមមើលប្រហែលជា ពេទ្យធី ស្លាប់ដោយសារតែត្រជាក់ពេកក៏មិនដឹង ព្រោះយើងទាំងអស់គ្នាសុទ្ធតែគេងផ្ទាល់លើដី ដោយក្រាលតែកូនកន្ទេលកក់តូចមួយប៉ុណ្ណោះ ។ ម្យ៉ាងទៀត ពេលយប់មានសន្សើមច្រើនផង ។ ដោយរង់ចាំយូរពេក ណាមួយក្រុមអ្នកប្រូតមិនព្រមចុះធ្វើការសោះ ព្រោះម្នាក់ៗមិនអស់ចិត្តនឹងការស្លាប់របស់ ពេទ្យធី ឈ្លបក៏សម្រេចថាយកសព ពេទ្យធី ទៅកប់នៅទីទួលមួយក្បែរនោះ ។ គ្រាន់តែកប់ហើយភ្លាម បងស្រី សំឡី ប្រពន្ធ ពេទ្យធី រត់មកដល់ភ្លាម ។ គាត់រត់ទៅទម្លាក់ខ្លួននៅលើផ្នូរប្ដីសម្លាញ់ដែលទើបកប់ថ្មីៗ ស្រែកទ្រហោយំគ្មានខ្មាសនរណាទាំងអស់ ហើយដៃគាត់ទាំងពីរកាយផ្នូរប្ដីគាត់ ។ យើងទៅចាប់ដៃគាត់កុំឲ្យកាយដី ។ គាត់រៀបរាប់អស់ហើយរឿងប្ដីគាត់ ។ គាត់និយាយខ្មែរផង បារាំងផង អង់គ្លេសផង ស្រេចតែចិត្តនឹកឃើញ គ្មានខ្លាចឈ្លបដែលកំពុងតែឈរមើលគាត់ព្រោងព្រាតឡើយ ។ យើងរលីងរលោងទឹកភ្នែកគ្រប់គ្នា «លាហើយពេទ្យធី ជាទីស្រលាញ់ សូមលោកទៅឲ្យបានសុខចុះ» ។

កងឈ្លបក៏អាណិតអាសូរ ពេទ្យធី ដែរ ធ្វើមុខស្រងូតស្រងាត់គ្រប់ៗគ្នា ព្រោះកាលនៅរស់ ពេទ្យធី ធ្លាប់ជួយមើលជំងឺទាំងអ្នកមូលដ្ឋាន ទាំងអ្នក១៧មេសា ច្រើនណាស់ ។ (សព្វថ្ងៃ បងសំឡី បើកឱសថស្ថាន មុងពេជ្រ នៅផ្លូវកម្ពុជាក្រោម) ។

**(នៅមានត)** **ហេង សុខផាន់ណា**

## ស្ដាប់ប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតកម្មវិធីអានអត្ថបទទស្សនាវដ្ដីស្វែងរកការពិតដែលចាក់ផ្សាយរៀងរាល់ថ្ងៃពុធនិងព្រហស្បតិ៍ វេលាម៉ោង៣:៣០-៣:៤៥នាទី តាមរយៈវិទ្យុ ១០២ MHz របស់មណ្ឌលពត៌មានស្ត្រីកម្ពុជា ។

ផាត រចនា និង លី សុផល

# ការពិតរបស់សមមិត្ត នួន ជា

បន្ទាប់ពីបានអានទស្សនាវដ្ដី «ស្វែងរកការពិត» របស់មជ្ឈមណ្ឌលឯកសារកម្ពុជា លេខ៥១ ខែមីនា ឆ្នាំ២០០៤ ខ្ញុំសូមយល់ស្របទាំងស្រុងជាមួយលោក ឆាំង យុ ដែលបានយល់ស្របជាមួយ នួន ជា ដែលនិយាយថា «មានតែប្រជាជនដែលបានឈឺចាប់ ឬទទួលរងការជិះជាន់ប៉ុណ្ណោះដែលបានយល់អំពីការពិត» ។

តាមការសន្និដ្ឋានរបស់ខ្ញុំ នួន ជា ហាក់បីដូចជានៅមិនទាន់យល់ការពិតនៅឡើយ ថាតើប្រជាជននៅក្នុងរបបណាមួយបានឈឺចាប់ឬទទួលរងការជិះជាន់ធ្ងន់ធ្ងរជាងគេនោះ ។ ទោះបីជាលោក ឆាំង យុ បានពន្យល់ត្រួសៗដល់ នួន ជា អំពីវាសនាដង្ហើមចង្រិតរបស់ប្រជាពលរដ្ឋខ្មែរក្នុងរបបមហាលោតផ្លោះមហាអស្ចារ្យរបស់ខ្មែរក្រហមយ៉ាងណាក៏ដោយ ខ្ញុំជឿជាក់ថា នួន ជា នៅតែមិនអាចយល់ច្បាស់ទាំងស្រុងទេ ។

អាស្រ័យហេតុនេះហើយ ខ្ញុំសង្ឃឹមថា នួន ជា ប្រាកដជាព្យាយាមថែរក្សាខ្លួនឲ្យមានសុខភាពល្អ រស់រានមានជីវិតរហូតដល់ពេលមានតុលាការកាត់ទោសខ្មែរក្រហមនាពេលឆាប់ៗនេះ ហើយនឹងហ៊ានស្រាយបំភ្លឺនៅចំពោះមុខតុលាការថាតើរបបកម្ពុជាប្រជាធិបតេយ្យរបស់លោកបានលោតផ្លោះដល់ណាដែរ ។ **ចំរើនស័ក្តិ ម៉ារឌី**

សមមិត្ត នួន ជា ឬ បងទី២











ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំនៅទូទាំងព្រះរាជាណាចក្រកម្ពុជា
ទស្សនាវដ្តីចំនួន១០០០ច្បាប់ជារៀងរាល់លេខនឹងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ មួយច្បាប់តម្លៃ ៧០០០រៀល

*មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្តីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន ។ ព័ត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្តីស្វែងរកការពិត សូមមេត្តាទាក់ទងមកនាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!*

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth!. For contribution, please contact (855) 23 211 875 or By Email: dccam@online.com.kh. Thank you.

**A magazine of the Documentation Center of Cambodia: *Searching for the truth*. Number 53, May 2004.**
**Funded by Germany, Norway, Sweden, the Netherlands, and USA.**